# លក្ខណៈសម្បត្តិរបស់មនុស្ស ល្អគ្រប់លក្ខណ៍

សូមអរគុណប្អូនប្រុសនីវៀល។ សូមព្រះអម្ចាស់ប្រទានពរអ្នក។

រីករាយណាស់ ដែលបានត្រឡប់មករោងឧបោសថម្តងទៀតព្រឹកនេះ។ សូមនិយាយថា "អរុណសួស្តី" ដល់អ្នកទាំងអស់គ្នា។ ហើយខ្ញុំជឿថានេះនឹងជា ជាថ្ងៃដ៏អស្ចារ្យមួយសម្រាប់យើងទាំងអស់គ្នានៅ—នៅក្នុងវត្តមាននៃព្រះ អម្ចាស់ របស់យើង។ ហើយឥឡូវនេះខ្ញុំ ទទួលបានមេរៀនមួយព្រឹកនេះ។ ខ្ញុំចង់តម្រង់ទៅកាន់មេរៀននេះតែម្តង ដោយសារតែវាជា…ខ្ញុំគិតថាវាជាការសំខាន់។ ហើយវាជា…ហើយដើម្បីរក្សាហ្វូងមនុស្សពីការមិនសប្បាយចិត្តព្រោះអ្នកដឹងហើយថាយើង ត្រូវឈរនៅជាមួយគ្នាជាយូរទៀត។ ខ្ញុំនឹងទៅកាន់មេរៀនរបស់យើងតែម្តង។

2 ហើយឥឡូវ នៅក្នុងយប់នេះ ខ្ញុំចង់និយាយអំពីមេរៀនមួយគឺ *អ្នកនាំផ្លូវនៃជីវិតខ្ញុំ។* ហើយខ្ញុំសង្ឃឹមថាមានមនុស្សជាច្រើន តាមតែអាចបាន នឹងមានវត្តមាននៅទីនោះ សំរាប់យប់នេះ។ យ៉ាងណាមិញ បើអ្នកមានព្រះវិហារផ្ទាល់ខ្លួន យើងនឹង…ពិតណាស់ យើងចង់ឲ្យអ្នកនៅក្នុងព្រះវិហារ—របស់អ្នក។ នេះជាតួនាទីរបស់អ្នកក្នុងការនៅទីនោះ ជាកន្លែងដែលអ្នកបំពេញតួនាទី ដើម្បីឲ្យពន្លឺរបស់អ្នកបានចែងចាំងឡើង។

3 ឥឡូវយើងនៅតែសង្ឃឹមថា គ្រប់ពេលដែលអ្នកមកវិញ យើងនឹងមានបន្ទប់បន្ថែមទៀតនៅទីនេះ។ ប៉ុន្តែយើងកំពុងតែមានបញ្ហាជាមួយវា អូ គឺគ្រប់ទីកន្លែង។ ក្រុមប្រឹក្សាបានគាស់កកាយគ្រប់ទីកន្លែង។ ហើយគេបានបញ្ជូនទៅកន្លែងមួយ ពួកគេនឹងព្រមជាមួយវារួច ហើយបញ្ជូនវាទៅកន្លែងផ្សេងទៀត ហើយគេនឹងបដិសេធ។ ហើយគេនឹងបញ្ជូនវាមកវិញ ហើយនឹងដាក់វានៅ*ទីនេះ* និងត្រលប់ទៅវិញ។ អូ តើយើងកំពុងមានពេលវេលាអ្វី! តើអ្នកដឹងទេ សាតាំងវាតែងតែប្រឆាំងនឹងការត្រឹមត្រូវជានិច្ច។ គ្រាន់តែចងចាំថា អ្នកតែងតែត្រូវចំពោះ…

4 ខ្ញុំបានឆ្ងល់ថា តើអ្នកនៅឯណា នៅឯអានតូនី។ ខ្ញុំឃើញអ្នកបានជួបឪពុករបស់អ្នក។ ហើយខ្ញុំបានមើលទៅឯក្រុមជនុំ។ គាត់និយាយថាអ្នកកំពុងតែអង្គុយ

នៅទីនោះ។ យើងរីករាយក្នុងការមានអ្នក និង ឪពុករបស់អ្នកនៅទីនេះ ប្អូនប្រុស មីលានូ មកពី ទីក្រុងញូយ៉ក។ សង្ឃឹមថានឹងបានចេញទៅបរទេសនៅក្នុងពេលនេះ ខ្ញុំទទួលបានការឈប់សំរាកនៅរដូវស្លឹកឈើជ្រុះ នៅខាងក្រៅ ញូយ៉កនៅកន្លែងណាមួយនៅខាងក្រៅ បើព្រះអង្គសព្វព្រះទ័យ។

5 ហើយដូច្នេះយើងរីករាយណាស់សំរាប់អ្នកគ្រប់គ្នា។ គឺថា—គឺថាវាល្អណាស់ដែលអ្នកនៅទីនេះ។

6 ហើយយើងមានពេលវេលាដ៏ល្អនៅយប់មិញនេះ ឬក៏យ៉ាងហោចណាស់ខ្ញុំបានសប្បាយ។ ខ្ញុំបាន...[ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] "ហើយអេសាយនៅក្នុងព្រះវិហារ។" ហើយអ្នកដែរ...

7 ហើយនៅពេលព្រឹកនេះ យើងចង់និយាយពីមេរៀនមួយ ឬបង្រៀនបើសិនជាយើងអាច "សង់រោងឧបោសថដ៏រស់ សង់—សង់រោងឧបោសថដ៏រស់ដែលជាកន្លែងដែលព្រះដ៏មានព្រះជន្មរស់គង់នៅ មនុស្សល្អគ្រប់លក្ខណ៍ រោងឧបោសថដ៏រស់នៃព្រះដ៏រស់ ទ្រង់គង់នៅ។" ហើយបើ...

8 ខ្ញុំយល់ថាពួកគេមានចម្រៀងល្អៗដែលកំពុងតែច្រៀងនៅទីនេះ។ ខ្ញុំមិនបានឮវាទេ។ ហើយនៅយប់នេះខ្ញុំនឹងព្យាយាមមកឲ្យដល់ទីនេះ។ ប្រពន្ធរបស់ខ្ញុំបានប្រាប់ខ្ញុំពីជីវិតរបស់ប្អូនប្រុស អាន់ហ្គេន ខ្ញុំជឿថា ឈ្មោះរបស់គាត់គឺមក—ពី តេនីស៊ី។ ឥឡូវគាត់បាននៅទីនេះកាលពីយប់មិញ។ ខ្ញុំមិនបានឃើញគាត់ទេនៅពេលព្រឹកនេះ តែខ្ញុំគិតថាគាត់ពិតជានៅកន្លែងណាមួយនៅទីនេះ។ ហើយខ្ញុំចង់ស្តាប់គាត់ច្រៀងនៅពេលយប់នេះ បើសិនជាអាចសូមច្រៀងបទ *ចុះពីសិរីល្អទ្រង់* ឬ *ទ្រង់ធំអស្ចារ្យ*។ ខ្ញុំចង់ស្តាប់បទនឹង។ តើមានប៉ុន្មាននាក់ចង់ស្តាប់ប្អូនប្រុសអាន់ហ្គេន? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] អូ ខ្ញុំ—ខ្ញុំចូលចិត្តចម្រៀងណាស់។ ហើយមីដា និយាយថាគាត់មានសំលេងរបស់បុរស។ ហើយវាបានរំលឹកខ្ញុំពីប្អូនប្រុសប៉េកស្មើ គាត់ក៏ជាអ្នកចំរៀងដែល យើងធ្លាប់បានស្គាល់គាត់ដែរ។ ហើយ *ចុះពីសិរីល្អទ្រង់* និង *ទ្រង់ធំអស្ចារ្យ*។ ខ្ញុំជឿថា ខ្ញុំនៅក្បែរគាត់ឥឡូវនេះ ពីលើ...វានឹងបានល្អឡើងវិញ ប្អូនប្រុស អាន់ហ្គេន នៅយប់នេះ តើអ្នកនឹង នៅបន្តឬទេ? តើអ្នកនឹងនៅបន្ត ឬក៏ព្យាយាមនៅបន្តសំរាប់ការថ្វាយបង្គំយប់នេះ? បាទខ្ញុំ—ខ្ញុំ... ល្អកុំអី...ខ្ញុំប្រាប់អ្នកពីរឿងទាំងនេះ បើយើង...ខ្ញុំមិនចង់ឲ្យអ្នកណាម្នាក់រង្កៀសចិត្តនោះទេ។ ហេតុអ្វីមិនអាច បើយើងអាច នៅក្នុងពេលរបស់ *គ្រាទីប្រាំពីរ* នៅពេល

ដែលយើងអធិប្បាយពីការនេះ សូមឲ្យអ្នកមកចូលរួម។ ខ្ញុំថតសំលេងទុក ហើយអ្នកនឹងទទួលបានវា *ទ្រង់ធំអស្ចារ្យ* ហើយនិង *ចុះពីសិរីល្អទ្រង់* នៅក្នុងពេលនោះ។

9 អូ តើវាមិនមែនជារឿងដ៏អស្ចារ្យទេ ឬអ្វីដែលបានបំរើព្រះ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] ខ្ញុំមិនដឹងថាខ្ញុំនឹងធ្វើអ្វីទេ បើខ្ញុំមិនមែនជាគ្រីស្ទាន!...?...គឺវាពិតជាល្អណាស់ដែលយើងជាគ្រីស្ទាន ខ្ញុំដូចជាមានអារម្មណ៍ ចង់ លោតចុះឡើង ហើយស្រែក ឲ្យអស់ពីសំលេងរបស់ខ្ញុំ។ ក្នុងភាពជាគ្រីស្ទាន សូមគិតពីការនេះ គឺដូចមានយុថ្កាដែលបានដាក់ជាមួយនឹងព្រះគ្រីស្ទ!

10 ខ្ញុំដឹងថាខ្ញុំបានហៅឈ្មោះបុរសនេះខុសរាល់ដង។ បើមិន S.T. ឬ T.S. ឬអ្វីស្រដៀង។ សុមនើរ ប្អូនប្រុសសុមនើ។ គាត់...ខ្ញុំចង់អរគុណគាត់ និងប្រពន្ធជាទីស្រឡាញ់របស់គាត់។ ខ្ញុំគិតថា គាត់បានចំណាយពេលប្រហែលប្រាំមួយខែ ដើម្បីសរសេរ *សម័យកាលនៃក្រុមជំនុំទាំងប្រាំពីរ*។ ហើយឥឡូវយើងមានវានៅទីនេះដោយបានសរសេររួចជាស្រេច សំរាប់រៀបចំធ្វើជាសៀវភៅ*សម័យកាលនៃក្រុមជំនុំទាំងប្រាំពីរ*។ ប្អូនស្រីសុមនើ ទោះជាអ្នកនៅទីណា សូមឲ្យយើងបានបង់ថ្លៃសំរាប់ការធ្វើវា។ វាមានការងារច្រើនណាស់ក្នុងការធ្វើ។ ហេតុអ្វី*បានជា*វាក្រាស់យ៉ាង*នេះ*។ ក្នុងការអានសៀវភៅនោះខ្ញុំត្រូវការពេលប្រាំមួយខែ នេះគ្រាន់ជាការដែលយកវាចេញពីកាសែតប៉ុណ្ណោះ ហើយបន្ទាប់មកធ្វើវាម្តងទៀត ដោយធ្វើជាសៀវភៅ។ យើងនឹងរៀបចំវាឲ្យរួច ហើយជញ្ជូនវាទៅបោះពុម្ពភ្លាម ព្រោះយើងគិតថាវាជាអ្វីដែលមនុស្សគ្រប់គ្នាគួរតែមានឥឡូវនេះ ហើយអ្នកអាចសិក្សាវា។ ហើយប៊ីលីទើបតែបានបង្ហាញខ្ញុំ ពេលដែលខ្ញុំបានចូលមកវិញ ប៉ុន្មាននាទីមុនថា—វា—រួចជាស្រេច—ហើយសំរាប់ការបោះពុម្ព។ ដូច្នេះប្អូនស្រីអើយ រោងឧបោសថបង់ថ្លៃសំរាប់រឿងនោះ។ ខ្ញុំមិនចង់ឲ្យអ្នកធ្វើវាដោយមិនបានអ្វីនោះទេ។ ហើយ—ហើយ ឬក៏យើង...បើយើងទទួលបានសៀវភៅហើយយើងលក់វាឲ្យបានកំរៃខ្លះ ឬអ្វីខ្លះ យើងនឹងដាក់តម្លៃដើម្បីឲ្យអ្នកបានទទួលអ្វីខ្លះនៅពេលដែលគេបានលក់វានៅតម្លៃណាមួយ។ អ្នកគ្រាន់តែនិយាយជាមួយនឹងក្រុមប្រឹក្សា គឺជាក្រុមប្រឹក្សាទទួលបន្ទុកហិរញ្ញវត្ថុ ឬអ្នកណាម្នាក់ក្នុងចំនោមពួកគេដែលនៅទីនោះ នោះពួកគេនឹងដោះស្រាយឲ្យអ្នក។ សូមឲ្យព្រះប្រទានពរឲ្យអ្នកយ៉ាងបរិបូរណ៍។

11 បងប្រុស និងបងស្រី ឃីដ កំពុងតែអង្គុយនៅទីនេះ នៅម៉្តុំលេខរៀងទីមួយ រយ គឺនៅក្បែរនឹង។ ហើយខ្ញុំបានជួបគាត់មុននេះ ហើយគាត់បាននិយាយថា

"នេះប្រហែលជា ពេលចុងក្រោយហើយ ដែលខ្ញុំនឹងបានជួបអ្នកប្អូនប្រុសប៊ីលី។" និយាយថា "ខ្ញុំកាន់តែចាស់ហើយ។"

12 ខ្ញុំនិយាយថា "ឱ ខ្ញុំអើយ! ខ្ញុំមិនចង់លឺបងនិយាយយ៉ាងនេះទេ។ អ្នកទាំងពីរហាក់ដូចជាលោកឪពុក និងអ្នកម្ដាយដែលមានចំណាស់បន្តិចប៉ុណ្ណោះ។" យើងស្រឡាញ់បងប្រុស និង បងស្រីឃីដ។ គឺយើងគ្រប់គ្នាស្រឡាញ់។ ហើយវា…

13 វាមានអ្វីកើតឡើងសំរាប់ខ្ញុំនៅពេល ដែលខ្ញុំបានឃើញពួកគាត់ដើរនៅក្នុងព្រះវិហារ ហើយដែលពួកគាត់ជាប្ដីប្រពន្ធវ័យចំណាស់យ៉ាងនេះ។ ហើយចូរគិតមើលពួកគាត់បានផ្សាយដំណឹងល្អតាំងពីខ្ញុំមិនទាន់កើតមកម្ល៉េះ។ ហើយនេះគឺជាខ្ញុំឥឡូវខ្ញុំគិតថាខ្ញុំដូចជាចាស់ដែរហើយ។ ខ្ញុំរៀបនឹងគិតថា ខ្ញុំគួរតែបញ្ឈប់ហើយ។ ខ្ញុំបានឃើញបងប្រុស និង បងស្រីឃីដចូលមក "សូមថ្វាយសិរីរុងរឿងដល់ព្រះ! ហាលេលូយ៉ា!" ខ្ញុំនិយាយថា "អត់ទេ ខ្ញុំនៅសុខសប្បាយណាស់។" បាទលោក។ បានឃើញពួកគាត់ ពួកគាត់ពិតជាបានលើកទឹកចិត្តយើងខ្លាំងណាស់!

14 រួចអ្នកនឹងដឹងថា ជិតដល់អាយុប៉ុនខ្ញុំហើយ ហើយនៅតែចុះទៅទីវាល។ ចូរមកនៅពេលព្រឹកនេះ ហើយសុំសៀវភៅ បើសិនជាគេអាចយកសៀវភៅ ទាំងនោះទៅលក់។ ចង់បានកាសែតសំលេង ដើម្បីឲ្យគេអាចទៅខាងក្រៅ នាំព្រលឹងមកឲ្យដល់ព្រះដោយអធិស្ឋានតាមកាសែតសំលេងនោះ ដែលពួកគាត់មានអាយុជិតមួយរយឆ្នាំទៅហើយ។ ឥឡូវឯណា "ស្លាបទាំងពីរ" របស់ឯង ដែលយើងបាននិយាយកាលពីយប់មិញ? បាទ។ ខ្ញុំចាប់ផ្ដើមគិតថា "តើរបស់ខ្ញុំនៅឯណា?" នៅពេលដែលគាត់និយាយ—ថាម្សិលមិញ។ តើអ្នកអាយុប៉ុន្មាន បងស្រីឃីដ? [បងស្រីឃីដនិយាយថា "ខ្ញុំអាយុប៉ែតសិបមួយ។"—Ed។] ប៉ែតសិបមួយ។ តើអ្នកអាយុប៉ុន្មាន បងប្រុសថម? [បងប្រុសឃីដនិយាយថា "ប៉ែតសិបពីរ។"] ប៉ែតសិបមួយហើយនិងប៉ែតសិបពីរ ហើយនៅតែប្រើស្លាបរបស់គាត់បន្តធ្វើការទៀត។

15 មានអ្វីមិនទំនងកើតឡើងនៅ អូហៃយ៉ូ ដែលបងស្រីឃីដបានដឹងពីការដែលទូរស័ព្ទរោទ៍នៅឯផ្ទះ។ ពីថ្ងៃមុនគាត់បានតែទៅ ហើយកូនង៉ែតតូច គឺជាក្មេងស្រី ខ្ញុំជឿថាវាបានកើត ហើយពោះវៀននៅខាងផ្នែកម្ខាងរបស់វា។ [បងស្រីឃីដនិយាយថា "ប្លោកនោម។"—Ed។] ប្លោកនោម នៅក្រៅខ្លួន កូននោះ។ ហើយគ្រូពេទ្យមិនដឹងត្រូវធ្វើអ្វីជាមួយវា ហើយគាត់មានការភ័យខ្លាចក្នុងការវះកាត់។ យើងបានអធិស្ឋាន។ [ "វះកាត់រួចហើយ ប្អូនប្រុស ប្រានហាំ ហើយដាក់វាចូលវិញ

ពីព្រោះគេនិយាយថា 'វាមិនអាចរស់ទៀតបានទេ។' ហើយគេបានដាក់ពោះវៀននោះចូលវិញ។"] ដាក់ពោះវៀនចូលវិញ ជាមួយនឹងការវះកាត់ ហើយ បើទោះវាមិនអាចរស់។ ["គ្មានច្រក។"] គ្មានច្រក ហើយសំរាប់—សំរាប់...ពីរន្ធគូថ សំរាប់អាហារឲ្យបានកន្លងបាត់ទៅ។ ហើយបងស្រីឃីដតែទៅម្តងទៀត។ យើងបានអធិស្ឋានម្តងទៀត ហើយឥឡូវវាមានច្រកធម្មតាមួយ។ ហើយគាត់នៅទីនេះ ជាទីបន្ទាល់រួមទាំងគ្រូពេទ្យផងដែរ។ ឃើញទេ? នេះជាទីបន្ទាល់ដែលព្រះយេស៊ូវគ្រីស្ទ ជាព្រះអាទិករ! ឃើញទេតើអ្វីខ្លះដែលសាតាំងព្យាយាមធ្វើ? ចង់ផ្តាច់ជីវិតរបស់កូននោះ។ រួចហើយមើល រួចខ្ញុំជឿថាស្ត្រីម្នាក់នោះនឹងមកឯព្រះជាម្ចាស់។ ["នាងបានត្រលប់មកឯព្រះវិញនៅនឹងផ្ទះរបស់ខ្ញុំតែម្តង។"] ចូរមកឯព្រះជាម្ចាស់។ បងស្រីឃីដបាននាំគាត់មកឯព្រះគ្រីស្ទវិញ គឺបន្ទាប់ ពីការអស្ចារ្យកើតឡើងលើកូនរបស់គាត់។

16 ខ្ញុំបានទទួលការហៅពី កាលីហ្វូញ៉ាកាលពីម្សិលមិញ មានប្អូនប្រុសជាអ្នកដឹកនាំនៅទីនោះ ខ្ញុំធ្លាប់បាននៅជាមួយនៅពេលដែលខ្ញុំទៅ កាលីហ្វូញ៉ាប៉ុន្មានឆ្នាំមុន។ ចៅរបស់គាត់កើតមកជាមួយ—ជាមួយបួន...សន្ទះបីបិតជិតនៅក្នុងបេះដូងរបស់វា។ ហើយខ្ញុំបានប្រាប់ពីរឿងនោះដល់គាត់។ ខ្ញុំនិយាយថា "ព្រះដែលអាចបង្កើតអ្នកដទៃ ហើយអាចធ្វើវាបាន ក៏អាចនឹងព្យាបាលចៅរបស់អ្នកបានដែរ។" គ្រាន់តែប្រាប់ក្មេងតូចនោះថាកុំបាក់ទឹកចិត្ត។

17 ហើយកូនក្មេងនោះក៏នៅក្នុងការជួបជុំនោះដែលនៅពេលដែលខ្ញុំនៅ កាលីហ្វូញ៉ាកាលពីដប់ប្រាំបីឆ្នាំមុន ឥឡូវវាបានកន្លងទៅអស់រយៈពេលដប់ប្រាំមួយឆ្នាំហើយ។ ហើយខ្ញុំបាននៅកាលីហ្វូញ៉ា។ ហើយគេ...ការជួបជុំនោះបានប៉ះពាល់ចិត្តក្មេងប្រុសនោះរហូត...នៅពេលដែលគេមានកូន ហើយកូននោះបានកើតហើយ ហើយគេបានឃើញថាមានអ្វីមិនស្រួល វាមានពណ៌ខៀវ ហើយគេព្យាយាមសប់បញ្ចូលអុកស៊ីសែន ហើយនឹងអ្វីផ្សេងទៀត។ ហើយវាមើលទៅហាក់ដូចជាមិនអាចទ្រាំទ្របាន រួចគ្រូពេទ្យក៏បានពិនិត្យមើល ហើយបានរកឃើញថាមានសន្ទះបី ដែលបានបិទបេះដូងរបស់វាជិត។ មិនមានអ្វីបើកបានទេ មើល គឺ—មានតែសន្ទះមួយទេដែលកំពុងលោត។ ហើយគាត់បានហៅ ឪពុករបស់គាត់និយាយថា "លោកប៉ាតេទៅបងប្រុសប្រានហាំភ្លាម។ ប្រាប់គាត់ថា...'គ្រាន់តែសូមព្រះ គ្រីស្ទ។

ទ្រង់នឹងធ្វើវា។៉ ត្រូវហើយ។ ឱ ខ្ញុំអើយ! នោះជាឥទ្ធិពល អ្វីដែលពួកគេឃើញមើល យើងបាននិយាយកាលពីយប់មិញ។ ការត្រឹមត្រូវនៅក្នុងពេលដ៏ត្រឹមត្រូវ។

18 ល្អ យើងបន្តនិយាយទៀតនោះនឹងមិនទទួលបានមេរៀនទេ យើងមិនបានទេ? វាដូចជាស្រទាប់ស្រអាប់នៅពេលព្រឹកព្រលឹម វានឹងកាន់តែក្រាស់តាមដែលអាចទៅបាន អ្នកដឹងទេ ហើយគ្រប់ទាំងអស់រួមបញ្ចូលគ្នា។ យើងមានភាពរីករាយណាស់ដែលបានជួបប្រជុំបែបនេះ។ បាទលោក។

19 ដូច្នេះ ឥឡូវសូមយើងសួរខ្លួនឯង ហើយចាប់ផ្តើមទៅលើមេរៀនរបស់យើងឥឡូវ។ ទៅប្រហែល...ខ្ញុំមិនដឹងថាតើអ្នកអាចឃើញវាឬក៏អត់នៅលើក្តាខៀនខ្មៅ។ ប្រហែលបើខ្ញុំត្រលប់វាដូច*នោះ* មួយភ្លែត ហេតុអ្វី អាចមើលឃើញហើយឥឡូវនេះ អ្នកខ្លះ...[ប្អូនប្រុសអេដហ្កា "Doc" ប្រានហាំនិយាយ "ចង់មានស្នាមនៅលើវា?"—Ed។] និយាយថាម៉ិច? ["អ្នកចង់បានស្នាមនៅលើវា?"] បាទ អត់ទេ ខ្ញុំមិនគិតថាឥឡូវទេ Doc។ ប្រហែលជាពេលបន្តិចទៀត។ ["នៅលើឥដ្ឋនោះ ខ្ញុំអាចដាក់ស្នាមនៅលើវា។"] បាទ យើងនឹង—យើងនឹង ធ្វើវានៅពេលដែលខ្ញុំបាន... មានស្នាមមួយនៅទីនេះ? ត្រូវហើយ។ គ្រាន់តែត្រលប់ពីលើវា។ អ្នកដែលនៅខាងនោះមើលឃើញទេ? មើលឃើញទេ? បើសិនជាអ្នកមើលឃើញសូមលើកដៃឡើង បើអ្នកមើលឃើញក្តារខៀននេះសូមអានវានៅទីនោះ។ ទេ។ ត្រូវហើយ។សូមដាក់ស្នាម។ ឥឡូវនៅពេលដែលពួកគេកំពុងតែត្រៀមខ្លួនឲ្យហើយសំរាប់...

20 ខ្ញុំបានចាប់ផ្តើមយឺតនៅព្រឹកនេះ ឬ ទេ ទេ ប៉ុន្មានដប់ប្រាំនាទីមុននេះ។ ហើយដូច្នេះ យើងនឹងយកពេលវេលារបស់យើងឥឡូវ ព្រោះអ្នកមិនចង់ប្រញាប់ពេកទេ។ នៅពេលដែលអ្នកប្រញាប់ពេក នោះអ្នកនឹងភ្លេចនូវអ្វីដែលអ្នកចង់និយាយ។ ឥឡូវខ្ញុំបានស្តាប់កាសែតសំលេងនៅថ្ងៃមួយ ដូចដែរខ្ញុំបានប្រាប់អ្នករាល់គ្នាហើយថា ខ្ញុំខ្មាស់ខ្លួនឯងខ្លាំងណាស់ មិនមែននឹងអ្វីដែលខ្ញុំនិយាយនោះទេ ប៉ុន្តែ កាលដែលខ្ញុំនិយាយនោះ វាលឿនពេកហើយ វាគឺជាភាពធុញទ្រាន់ជាទីបំផុត។ ខ្ញុំមានអារម្មណ៍ថាកំពុងរង់ចាំ។ វា...

21 ខ្ញុំ—ខ្ញុំបានឃើញកាលពីថ្ងៃមុន នៅកន្លែងដែលគេរៀបនឹងធ្វើជាសួនសត្វ គឺនៅចំ ចំនុចកណ្តាល ល្វីសវីល នេះ។ ហើយលោកប្រោន ខ្ញុំជឿថាវាពិតជានៅទីនោះ បានជូនលុយមួយលានដុល្លាដល់សួនសត្វ។ ល្អបើសិនជាខ្ញុំមានលុយនោះ ខ្ញុំធ្វើវាឲ្យទៅជាកន្លែងសត្វខ្វាត់ខ្វាយ។ ខ្ញុំ—ខ្ញុំមិនជឿលើការបង្កើតទ្រុងសត្វ

ដូច្នេះទេ។ ខ្ញុំគ្រាន់តែ...ខ្ញុំដើរទៅក្នុងសួនសត្វ ហើយមើលសត្វដ៏កំសត់ ដូចជាខ្លាឃ្មុំ តោ និងសត្វផ្សេងទៀត ដើរចុះដើរឡើង នៅក្នុងទ្រុងអស់មួយជីវិត អ្នកឃើញទេ។ វាធ្វើឲ្យអ្នកមានអារម្មណ៍មិនល្អ។ ចុងបញ្ចប់ពួកគេត្រូវបានចាប់ដោយក្រុមមនុស្សដែលមានប្រាជ្ញាជាងពួកគេ។ ឃើញទេ? ហើយពួកគេបានចាប់វា ហើយបានឃុំឃាំងវា។

22 ហើយខ្ញុំគិតអំពី: វិញ្ញាណអាក្រក់វាធ្វើរឿងនោះ។ វាយកមនុស្សដ៏មានតម្លៃ ដែលនឹងត្រាច់ចរទីកន្លែងអស្ចារ្យនិង ទីវាលរបស់ព្រះ និង—និងរឿងអ្វីស្រដៀងនឹង ហើយដាក់គេនៅក្នុងគុកនៃ និកាយ ឬគោលលទ្ធិ ឬអ្វីមួយ ហើយចងគាត់នៅក្នុងនោះ។ ហើយមានកន្លែងណាអាក្រក់ជាងកន្លែងនោះទៅទៀត។

23 ហើយខ្ញុំមិនចូលចិត្តសួនសត្វទេ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ដូចជាសត្វទាំងនោះដែរ គឺនៅពេល ដែលយើងត្រូវបានគេចាប់ ហើយកំពុងតែរើបំរាស់ អ្នកដឹង—ដឹងពីវិធីក្នុងការចេញ ហើយធ្វើអ្វីម្យ៉ាង។

24 ឥឡូវមុនពេលដែលយើងចូលដល់ព្រះបន្ទូលរបស់ព្រះ សូមយើងជួបអ្នកនិពន្ធនៃព្រះបន្ទូលជាមុនដោយអោនក្បាលចុះហើយអធិស្ឋាន។

25 ឱ ព្រះបិតាដែលគង់នៅនគរឋានសួគ៌ យើងបានជួបជុំគ្នានៅវេលាព្រឹកនេះជាថ្មីម្តងទៀតក្នុងព្រះនាមព្រះព្រះអម្ចាស់យេស៊ូវ ជាបុត្រាដ៏ខ្ពង់ខ្ពស់របស់ទ្រង់។ ព្រះបានយកនិស្ស័យជាមនុស្ស ហើយយាងមកលើផែនដីនេះ ដើម្បីជាដង្វាយធួននៃអំពើបាបរបស់យើងហើយបានសុគតដើម្បីយើង ដោយភាពសុចរិតរបស់ទ្រង់ក្នុងការដែលយើងមានបាបនៅឡើយបានរាប់ជាគ្រប់លក្ខណ៍នៅក្នុងទ្រង់។ យើងមកដោយសារភាពថា យើងមិនស្អាតស្អំទេព្រះអង្គអើយ។ គ្មានអ្វីដែលហៅថាល្អនៅក្នុងយើងទេ។ ហើយយើងគ្រប់គ្នានៅក្នុងគុកដ៏ធំមួយ។ មិនថាយើងឈរនៅទីកន្លែងណា គឺយើងនៅក្នុងគុក។ គ្មាននណាម្នាក់អាចជួយគ្នាបាន។ តែព្រះដោយសេចក្តីមេត្តាករុណាគ្មានទីបញ្ចប់របស់ទ្រង់ បានយាងមកហើយបើកទ្វានៃគុកនោះ ឲ្យយើងមានសេរីភាព។ ឥឡូវយើងមិនមែននៅក្នុងទ្រុងទៀតទេ។ យើងមិនមែននៅក្នុងសួនសត្វរបស់លោកីយ៍នេះទៀតទេ ប៉ុន្តែឥឡូវយើងមានសេរីភាព។ យើងនៅខាងក្រៅ។

26 អូ តើយើងស្រឡាញ់ទ្រង់ ហើយសសើរទ្រង់យ៉ាងណា! តើយើងអាចដើរនៅក្នុងទីវាលដ៏អស្ចារ្យនៃសេចក្តីសន្យារបស់ទ្រង់បានយ៉ាងណា ហើយបានឃើញ

វាបើកបង្ហាញនៅពីមុខយើង! ហើយដោយភ្នែករបស់យើងផ្ទាល់ បានឃើញព្រះដ៏គង់នៅអស់កល្ប បង្ហាញរូបអង្គទ្រង់នៅចំពោះ មុខយើងពិតៗ ដូចទ្រង់ធ្វើនៅសម័យពួកហោរាចាស់ៗដែរ។ ត្រូវដឹងថាពួកគេបានសំរាកជាមួយការធានាថានៅថ្ងៃមួយយើងនឹងបានត្រលប់មកវិញ បន្ទាប់ពីបានបញ្ចប់ជីវិតនេះទៅ នៅថ្ងៃនៃការរស់ឡើងវិញ រហូតដល់ជីវិតអស់កល្បដែលមិនចេះពុករលួយ។ រូបកាយយើងនឹងមិនចេះចាស់។ ហើយយើងមិនចេះស្លាប់ឡើយ។ ហើយយើងនឹងមិនចេះឃ្លានឡើយ។ ហើយយើងនឹងមិនចង់បានអ្វីឡើយ។ ប៉ុន្តែយើងនឹងដើរជាមួយទ្រង់។ យើងចង់ឮទ្រង់មានបន្ទូលថា "ចូរឯងចូលមកក្នុងសេចក្តីអំណររបស់ព្រះអម្ចាស់របស់ឯងមក ដែលបានរៀបចំទុកឲ្យឯងតាំងតែពីដើមកំណើតផែនដីមកម្ល៉េះ។" មុនពេលដែលអំពើបាបមាននៅក្នុងលោកីយ៍នេះ តើទ្រង់បានរៀបចំពិធីនេះយ៉ាងណា ដូចជាសំរាប់អាដាំ និង នាង អេវ៉ា ដើម្បីកុំឲ្យយើងមានជម្ងឺ ឬមានបញ្ហា។ ហើយឥឡូវទ្រង់បានរៀបចំសំរាប់យើង ហើយទ្រង់បានជ្រាបថាយើងមក។ អំពើបាបធ្វើជារនាំងដ៏ធំ តែឥឡូវអំពើបាបបានតំរូវយកចេញ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូវ។ ឥឡូវយើងកំពុងតែតំរង់ទៅទឹកដីសន្យា ដោយព្រះបន្ទូលសន្យារបស់ទ្រង់ ដែលជាអស់កល្បជានិច្ច។

27 សូមទ្រង់ប្រទានព្រះពរយើងឥឡូវព្រះបិតាអើយ ដែលយើងនឹងសិក្សាព្រះបន្ទូលទ្រង់។ យើងចង់ដឹងថាតើយើងគួរក្លាយជាមនុស្សប្រភេទណា ដើម្បីឲ្យបានឡើងទៅទីនោះ។ ជួយយើងនៅថ្ងៃនេះ នៅសាលានេះ ដែលយើងមានគ្រូបង្រៀនដ៏អស្ចារ្យជាជំនួយយើង ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់នឹងយាងមកបង្ហាញរូបអង្គទ្រង់ដល់យើងដោយព្រះបន្ទូលទ្រង់។ ដ្បិតយើងសូមដោយនៅព្រះនាមទ្រង់ និង សិរីល្អទ្រង់។ អាម៉ែន។

28 ឥឡូវជាដំបូងខ្ញុំចង់ឲ្យអ្នកទាំងអស់គ្នាបើកទៅ ក្នុងព្រះគម្ពីរពេត្រុសខ្សែទីពីនៅជំពូកទីមួយ។ ខ្ញុំចង់អានចំណែកនៃអត្ថបទព្រះគម្ពីរនេះ ពេត្រុសខ្សែទីពីរ នៅជំពូកទីមួយ។ ហើយឥឡូវសំរាប់អ្នកដែលមានខ្មៅដៃ និង ក្រដាស់...

29 ហើយខ្ញុំជឿថាខ្ញុំត្រូវបានប្រាប់នៅពេលព្រឹកនេះថា—ថាពេលខ្លះងាកក្បាលខ្ញុំចេញពីទីនោះ វាធ្វើឲ្យកាសែតថតសំលេងរអាក់រអួល។ ខ្ញុំពិតជាមិនចង់ធ្វើវាទេ។ ហើយខ្ញុំជឿថា ពេលខ្លះបើយើងដោះស្រាយក្នុងការយក មេក្រូ—សំណាញ់

ហើយចងវានៅលើពីដាននោះ។ មិនថាអ្នកនៅទីណានោះទេ នោះវាមិនមានបញ្ហាអ្វីឡើយ។ វានឹងល្អគ្រប់គ្រាន់ សំរាប់ជុំវិញ ដោយមានមេក្រូនៅលើពិដាន។

30 ហើយឥឡូវនៅពេលដែលខ្ញុំកំពុងនិយាយ ហើយបើអ្នកបន្ទាប់ពីការថ្វាយបង្គំ ឬចង់ អាចគូររូបនៃគ្រោងនៅទីនេះ។ រួចហើយខ្ញុំក៏ត្រូវវាយអត្ថបទនៅទីនេះដែរ។ ខ្ញុំនឹងយកដែកគោល ហើយដាក់វានៅខាងមុខនេះ បើអ្នកចង់ធ្វើវានៅពេលណាមួយ។ សូមឲ្យឆាប់បន្តិចនៅរសៀលនេះ ដើម្បីឲ្យយើងបានងាយយល់។

31 ឥឡូវយើងបានមកដល់ *ត្រាទីប្រាំពីរ។* យើងទើបតែបានចប់ *សម័យកាលនៃព្រះវិហារទាំងប្រាំពីរ។* ហើយព្រះរាជសារនេះគឺការបង្រៀនអំពី ការចងមនុស្សនៅខាងក្នុង ដែលនឹងត្រូវលោះមកវិញដោយសារព្រះលោហិតរបស់ព្រះអម្ចាស់យេស៊ូវ ហើយនឹងត្រូវនៅក្នុងយុគសម័យនៃព្រះវិហារនោះ គឺជាព្រះវិហារដ៏នៅអស់កល្បបន្ទាប់ពីការបញ្ចប់នៃត្រានោះ។ ឥឡូវយើងដឹងថាយើងមានត្រែប្រាំពីរ គ្រោះកាចប្រាំពីរ និងដបតូច ព្រមទាំងអ្វីៗផ្សេងទៀត ដែលយើងបានយកចូល នៅពេលដែលយើងទៅជាមួយ។ តែយើងរង់ចាំឲ្យមានបន្ទប់ថែមទៀត ដើម្បីឲ្យមនុស្សបានអង្គុយ។

32 ឥឡូវ ហើយខ្ញុំគិតថាវានឹងចងចំកន្លែង ដែលខ្ញុំរំពឹងទុក។ ខ្ញុំមិនគិតថាគូគម្រោងឆ្អឹងនោះទេ ប៉ុន្តែនៅថ្ងៃមួយ ខ្ញុំបាននៅជាមិត្តជិតស្និតរបស់ខ្ញុំឈ្មោះ ខូកនៅកេនតាគី។ ខ្ញុំបានចុះទៅ គឺដូចជាមួយថ្ងៃទៀត ដើម្បីប្រមាញ់កំប្រុក មុនពេលបញ្ចប់រដូវកាល។ ហើយខ្ញុំបាននៅលើកំណាត់ឈើមួយជាមួយមិត្តខ្ញុំ ឆាលីឈរនៅទីនោះហើយរ៉ូដនីប្អូនគាត់ដែរ។ ខ្ញុំមិនបានឃើញកំប្រុកទេសូម្បីតែមួយ។ ខ្ញុំគិតថាខ្ញុំបានធ្វើឲ្យវាភ័យហើយរត់អស់ទៅហើយ នៅពេលដែលខ្ញុំបានស្រែកនៅលើកំណាត់ឈើនោះ។ នេះជាអ្វីដែលកើតឡើងមកលើខ្ញុំ ក្មេងប្រុស និង—និងប្អូនស្រី នីលី និង ម៉ាហ្គី ហើយនៅពេលដែលខ្ញុំបានប្រាប់អ្នកនៅថ្ងៃអាទិត្យ ពេលដែលខ្ញុំទៅដល់បានវា។ នោះគឺជាអ្វីដែលបានមកឯខ្ញុំនៅក្នុងព្រះរាជសារដែលខ្ញុំនឹងអធិប្បាយ។ ហើយតើអ្នកដែលនៅសេសសល់ នឹងចងនៅក្នុងវាយ៉ាងណា! ហើយ អូ ខ្ញុំចូលចិត្តវា។ មាន—ពិត — វិញ្ញាណដ៏ពិតនៃការស្រែកខាងលើនោះពីលើកំណាត់ឈើ។

33 ដូច្នេះឥឡូវ សូមយើងអានឥឡូវ ពេត្រុសខ្សែរទីមួយ ឬ...ពេត្រុសខ្សែរទីពីរ ឬក៏ចំនែកមួយនៃជំពូកទីមួយ។

*សំបុត្ររបស់ពេត្រុស ជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ មកដល់អស់អ្នកដែលបានទទួលសេចក្ដីជំនឿដ៏ប្រសើរជាមួយយើង ដោយសេចក្ដី សុចរិតនៃព្រះ និង ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង:*

34 ខ្ញុំចូលចិត្តនូវអ្វីដែលបានសរសេរនៅទីនេះ ពីព្រោះមេរៀនរបស់ខ្ញុំនៅព្រឹកនេះគឺជាសេចក្ដីជំនឿ។ ឃើញទេ? សូមឲ្យខ្ញុំបានអានម្ដងទៀត។ សូមចូលជិតនិងស្ដាប់។

*លោកពេត្រុស ជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ មកដល់អស់អ្នកដែលបានទទួល—បានទទួល សេចក្ដីជំនឿដ៏ប្រសើរ...ដោយសេចក្ដីសុចរិតនៃព្រះ... ព្រះអង្គសង្គ្រោះនិង ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើង:*

35 សំគាល់ គាត់បាននិយាយថា "ខ្ញុំបានទទួលសេចក្ដីជំនឿនេះ ហើយខ្ញុំបង្ហាញវាទៅដល់ពួកគេ ដែលបានទទួលដូចសេចក្ដីជំនឿដ៏ប្រសើរ។" ខ្ញុំចង់...វាមិនមែនសំរាប់ពិភពលោកខាងក្រៅទេ។ គឺសំរាប់ក្រុមជំនុំវិញ ឃើញទេ ជាអ្នកដែលនៅក្នុងព្រះគ្រីស្ទ។

*ព្រះគុណ និង សេចក្ដីសុខសាន្ត បានចំរើនឡើងដល់អ្នកតាមរយៈចំណេះដឹងរបស់ព្រះ និង (តាមរយៈ) ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើង។*

*ស្របតាមឫទ្ធិអំណាចរបស់ទ្រង់ដែលបានប្រទានដល់យើងនូវអ្វីៗទាំងអស់...ឫទ្ធិអំណាចរបស់ទ្រង់បានប្រទានមកយើងគ្រប់ការទាំងអស់ឥឡូវនេះ នូវអ្វីដែល ជាជីវិត...ភាពជាព្រះ តាមចំណេះដឹងរបស់ទ្រង់ ដែលបានយើងមកសិរីរុងរឿង និង គុណធម៌:*

*ជាកន្លែងដែលយើងត្រូវបានឲ្យទៅ...បានប្រទានមកយើងនូវព្រះគុណយ៉ាងអស្ចារ្យ ហើយ និង សេចក្ដីសន្យាដ៏ប្រសើរ: ដែលដោយសារវា(សេចក្ដីសន្យា)យើងនឹងបានជាផ្នែកនៃនិស្ស័យជាព្រះ...*

36 ឥឡូវសូមយើងចូលកាន់តែស៊ីជំរៅថែមទៀត។ មិនមែនអធិប្បាយទេនៅព្រឹកនេះ គឺជាការបង្រៀនវិញ។ "និស្ស័យនៃភាពជាព្រះ។" សូមឲ្យខ្ញុំបានអាននៅក្នុងខទីបួនម្ដងទៀតឥឡូវ ដើម្បីកុំឲ្យអ្នករំលងវា។ "ដែលយើងបានត្រូវប្រទានឲ្យ..."

*ដែលដោយសេចក្ដីទាំងនោះ ទ្រង់បានប្រទានទាំងសេចក្ដីសន្យាដ៏ធំបំផុត: ហើយវិសេសផង មកយើងរាល់គ្នា (សេចក្ដីសន្យាទាំងនេះ) ដើម្បីឲ្យអ្នករាល់គ្នាបានចំណែកនៃនិស្ស័យព្រះ ដោយសារសេចក្ដីជំនឿនោះឯង ដោយបានរួចពីសេចក្ដីពុករលួយនៅក្នុងលោកិយ៍នេះដែលជាសេចក្ដីប៉ងប្រាថ្នា។*

37 មើល "ពិភពលោក" យើងបានរួចផុតវាហើយឥឡូវ។ គាត់បាននិយាយការនេះដល់ក្រុមជំនុំ។ ហេតុនេះហើយបានយើងនៅទីនេះព្រឹកនេះ គឺដើម្បីស្វែងរកផ្លូវ ហើយតើអ្វីដែលព្រះចង់បាន។ គ្មាននណាម្នាក់នៅទីនេះ ដែលស្រឡាញ់ព្រះតែចង់ឲ្យ—ចង់ឲ្យបានដូចជាព្រះគ្រីស្ទនោះទេ។ ហើយឥឡូវវាបានបង្ហាញនៅទីនេះ។ គ្រប់គ្រីស្ទានទាំងអស់! ខ្ញុំគឺជាទាហានចាស់ម្នាក់ប៉ុណ្ណោះ។ ចូរក្រឡេកមើលបងប្រុស និង បងស្រីយើង ទីនេះ ពួកគាត់ប្រហែលជាអ្នកដែលចាស់ជាងគេនៅក្នុងបន្ទប់នេះ។ ប៉ុន្តែបើខ្ញុំសួរគាត់ថា "តើអ្វីជាបំណងចិត្តរបស់អ្នក?" វាប្រាកដជា "ឲ្យបាននៅជិតព្រះ។" ពេលដែលអ្នករៀនអំពីព្រះគ្រីស្ទ គឺមានអ្វីនៅក្នុងទ្រង់ដែលមានក្ដីស្រឡាញ់ខ្លាំង អ្នកនឹងព្យាយាមឲ្យបានចូលទៅក្នុងទ្រង់។

38 សូមអធ្យាស្រ័យការនិយាយបែបនេះ។ ខ្ញុំបានប្រាប់ភរិយាខ្ញុំនៅទីនេះមិនយូរប៉ុន្មាន នាង...ទាំងពីរនាក់កាន់តែចាស់ហើយ ហើយខ្ញុំនិយាយទៅកាន់នាងថា "តើអូនស្រឡាញ់បងដូចដែលអូនស្រឡាញ់ពីមុនទេ?"

នាងនិយាយថា "ខ្ញុំពិតជាស្រឡាញ់។"

39 ហើយខ្ញុំនិយាយថា "អូនដឹងទេថាបងស្រឡាញ់អូនខ្លាំងពេក រហូតដល់ចង់លេបអូនទុក ដើម្បីឲ្យយើងបានជាថ្មីម្ដងទៀត។"

40 ឥឡូវដែលស្វ័យគុណនឹងមួយរយលាន យើងអ្នករកឃើញថាអស់អ្នកជឿដែលបានស្រឡាញ់ព្រះគ្រីស្ទ ចង់ចូលទៅក្នុងទ្រង់ ពីព្រោះវាជាសេចក្ដីស្រឡាញ់។ ហើយនៅទីនេះទ្រង់នឹងបង្ហាញយើង ដោយសេចក្ដីសន្យារបស់ទ្រង់ យើងនឹងជាអ្នករួមចំណែកនៅក្នុង និស្ស័យនៃភាពជាព្រះរបស់ព្រះគ្រីស្ទ។ រូបកាយមិនអមតៈមួយនេះតើយើងអាចជាអ្នករួមចំណែកបានយ៉ាងម៉េច។

41 ខ្ញុំអាចនឹងនិយាយអ្វីខ្លះនៅទីនេះ។ ហេតុផលដែរខ្ញុំជឿ...ឥឡូវមានអ្នកខ្លះបានធ្វើឲ្យខ្ញុំខុសទាំងស្រុង នៅទីនេះមិនយូរប៉ុន្មាន។ ខ្ញុំបានទទួលសំបុត្រពី

សមាគមអ្នកបម្រើព័ន្ធកិច្ចមួយដែលបាននិយាយថា ខ្ញុំជឿថាមាន..."យើងជាដៃគូខាងព្រលឹងវិញ្ញាណ។ ហើយយើងត្រូវតែចាកចេញពីទីនោះ ទោះបីយើងមិនមែនជាដៃគូរខាងវិញ្ញាណជាមួយគ្នា ដើម្បីរៀបការជាមួយអ្នកផ្សេងទៀតដែលត្រូវជាគូររបស់យើង។" ឱ ខ្ញុំអើយ!

42 ខ្ញុំនិយាយថា "ខ្ញុំមិនមានកំហុសទៅលើរឿងបែបនេះទេ។" ខ្ញុំតែងតែប្រឆាំងនឹងវា។ ខ្ញុំ—ខ្ញុំមិនជឿការហ្នឹងទេ។ មិនជឿមែន។ ខ្ញុំជឿថាព្រះប្រទានគូរឲ្យខ្ញុំ។ នេះជាការពិត។ ហើយយើងក្លាយជាផ្នែកមួយនៃគ្នានឹងគ្នា។ ត្រូវណាស់។ ហើយសំរាប់បុរសក្នុងការរៀបការគេគួរតែគិតពីវា សិក្សាវា។

43 មានយុវជនម្នាក់បានសួរខ្ញុំនៅថ្ងៃមួយថា "បងប្រុសប្រានហាំ តើអ្នកគិតថាខ្ញុំគួរតែរៀបការជាមួយនឹងស្រ្តី *មួយនេះ-ឬ-មួយនោះ?*"

ខ្ញុំនិយាយថា "តើអ្នកបានគិតពីនាងប៉ុន្មានហើយ?"

គាត់និយាយថា "ឱ ខ្ញុំអើយ ខ្ញុំ គ្រាន់តែស្រឡាញ់នាង។"

ខ្ញុំនិយាយថា "ណាស់ហើយបើអ្នកមិនអាចរស់បានបើគ្មាននាងទេរៀបការជាមួយនាងទៅអញ្ចឹង តែបើអ្នកអាចរស់បានបើគ្មាននាង អ្នកមិនគួរទេ។ ដូច្នេះ បើវានឹងសម្លាប់អ្នក អ្នកគួរតែ—គួរតែរៀបការជាមួយនាងទៅ" ខ្ញុំនិយាយ។ ហើយអ្វីដែលខ្ញុំចង់ប្រាប់គាត់ គឺថាបើអ្នកស្រឡាញ់នាងខ្លាំង!

44 ឥឡូវ គឺឥឡូវនេះមុនពេលដែលអ្នករៀបការ គ្រប់យ៉ាងវានឹងល្អ ហើយនឹងល្អប្រសើរ។ ប៉ុន្តែនៅពេលដែលអ្នករៀបការហើយនោះគ្រប់ទាំងអន្ទាក់ និងការសាកល្បង នៃជីវិតនឹងចូលមកដល់។ នេះគឺជាពេល ដែលអ្នកគួរតែបិតក្នុងក្តីស្រឡាញ់ ដែលអ្នកអាចយល់ពីគ្នាទៅវិញទៅមក។ នៅពេលដែលអ្នកខកចិត្តជាមួយនាង ឬ នាងខកចិត្តជាមួយអ្នក នោះអ្នកទាំងពីរនឹងអាចយល់ចិត្តគ្នា។

45 នេះគឺជាវិធីមួយជាមួយនឹងព្រះគ្រីស្ទដែរ។ ឃើញទេ? យើងត្រូវតែស្រឡាញ់ទ្រង់ជាខ្លាំង រហូតដល់ពេលដែលយើងសូមអ្វីមួយ ហើយបើទ្រង់មិនប្រទានវាមកយើងទេ វានឹងមិនធ្វើឲ្យរង្គើរនោះទេ។ ឃើញទេ? ឃើញទេ? ហេតុអ្វី? ហើយមានផ្លូវតែមួយដែលយើងអាចធ្វើវា គឺត្រូវក្លាយជាចំណែកនៃនិស្ស័យជាព្រះរបស់ទ្រង់ នោះអ្នកនឹងបានយល់ពីហេតុដែលទ្រង់មិនប្រទានវាដល់អ្នក។ "ជាចំណែកនៃនិស្ស័យជាព្រះរបស់ទ្រង់។"

46 ហើយសូមមើលមកទីនេះ "ហើយដែលបានរួចផុតពីសេចក្ដីពុករលួយរបស់លោកិយនេះ ដែលកើតឡើងពីសេចក្ដីបំណងប្រាថ្នា។" ចូរគេចចេញពីវា! មើលតើសំរាប់អ្នកណា? វាសំរាប់ក្រុមជំនុំ ជាអ្នកនៅក្នុងព្រះគ្រីស្ទ បានត្រូវដំកើងលើសពីសេចក្ដីទាំងនេះ។ មិនមែនគាត់បានលើកខ្លួនឡើងនោះទេ តែគឺជាព្រះគ្រីស្ទទេដែលបានលើកគាត់ឡើងវិញ។

47 សំរាប់បងប្អូនប្រុសស្រីមកពីគ្រប់ព័ណសម្បុរ ដែលមានវត្តមាននៅទីនេះព្រឹកនេះខ្ញុំមិនចង់ធ្វើឲ្យអ្នកណាម្នាក់មានគ្រោះថ្នាក់នោះទេ។ ប៉ុន្តែនៅក្នុងការប្រជុំកាលពីមុននេះ ខ្ញុំមិនបានដឹងថាខ្ញុំបាននិយាយវានៅលើរោងឧបោសថទេឬទេ។ ខ្ញុំបានប្រាប់វាជាច្រើនកន្លែង។ មានប្អូនស្រីស្បែកខ្មៅម្នាក់និយាយថា "តើខ្ញុំអាចមានទីបន្ទាល់ ឬ ការបញ្ជាក់បន្តិចបានទេ?"

"មិនថ្វីទេប្អូនស្រី សូមអញ្ជើញ។"

48 នាងនិយាយថា "ខ្ញុំចង់ធ្វើទីបន្ទាល់នេះដើម្បីថ្វាយសិរីល្អដល់ព្រះ។" នាងនិយាយថា "អ្នកដឹងទេខ្ញុំ—ខ្ញុំមិនជាអ្វីដែលខ្ញុំគួរតែ" ហើយនាងនិយាយថា "ខ្ញុំ—ខ្ញុំមិនបានក្លាយជាអ្វីដែលខ្ញុំចង់ក្លាយ ប៉ុន្តែ" នាងនិយាយថា "មានរឿងមួយប្រាកដថាខ្ញុំមិនមែនអ្វីដែលខ្ញុំធ្លាប់ពីមុន។" ឃើញទេ? នាងបានមកពីកន្លែងណាមួយ។ នាងត្រូវបានលើកឡើងលើ។

49 នេះហើយជាវិធីដែលយើងបានដឹងថាយើងបានរួចពីសេចក្ដីស្លាប់ហើយមានជីវិត។ យើងមើលទៅក្នុងរណ្ដៅដែលយើងត្រូវបានយកចេញមក។ ឃើញទេ? យើងមិនជាអ្វីដែលយើងចង់ក្លាយទេ យើងក៏មិនមែនជាអ្វីដែលយើងគួរតែក្លាយដែរ ប៉ុន្តែរឿងមួយដែលយើងដឹងគុណនោះគឺ យើងមិនមែនជាអ្វីដែលយើងធ្លាប់ជា។ ត្រូវណាស់។ យើងកំពុងតែនៅលើផ្លូវ។

50 "ហើយដែលបានរួចផុត ពីភាពពុករលួយរបស់លោកិយ។" បានរួចផុតគឺសេចក្ដីបងប្រាថ្នា និង ភាពពុករលួយរបស់លោកិយ៍ អ្នកនៅលើរបស់ទាំងអស់នោះ។ ឥឡូវដែរ—ឥឡូវដែលប្រភេទនៃមនុស្សដែលគាត់និយាយទៅកាន់ គឺមនុស្សដែលបានរួចផុតពីការទាំងនេះ មើលភាពពុករលួយនៃលោកិយ។

*ហើយក្រៅពីនេះចូរឲ្យមានសេចក្ដីឧស្សាហ៍ ដើម្បីឲ្យសេចក្ដីជំនឿបានទៀងត្រង់ ហើយសេចក្ដីទៀងត្រង់បានដំរិះ*

*ឲ្យដំរិះបានចេះសង្កត់ចិត្ត...សង្កត់ចិត្តបានខ្ជាប់ខ្ជួន...ឲ្យសេចក្តីខ្ជាប់ខ្ជួនបានគោរពប្រតិបត្តិដល់ព្រះ ឲ្យសេចក្តីគោរពប្រតិបត្តិដល់ព្រះ*

*បានចេះរាប់អានគ្នាជាបងប្អូន យើងឲ្យសេចក្តីរាប់អានគ្នាជាបងប្អូនបានសេចក្តីស្រឡាញ់ថែមទៀត។*

51 ឥឡូវគាត់បានឲ្យគំរូ ពីអ្វីដែលយើងត្រូវធ្វើ និង ចេះធ្វើវា។ ឥឡូវដូចដែលខ្ញុំបាននិយាយ យើងទាំងអស់គ្នាចង់ជិតព្រះ។ នេះហើយជាហេតុដែលខ្ញុំជ្រើសរើសព្រះរាជសារនេះនៅព្រឹកនេះ ដើម្បីឲ្យក្រុមជំនុំបាន ដឹងថាមានមនុស្សកំពុងធ្វើដំណើរ។ ដ្បិតយប់មិញខ្ញុំបាននិយាយថា "តើមានប៉ុន្មាននាក់នៅទីនេះរស់នៅក្រៅក្រុង?" ប៉ុន្មានជាកៅសិបភាគរយមកពីខាងក្រៅក្រុង។ "តើមានប៉ុន្មាននាក់មកពីចំងាយមួយរយម៉ាល?" ហេតុអ្វីបានជាវាលើសខ្ញុំគិតថាមានតែប៉ែតសិបភាគរយប៉ុណ្ណោះ។ "តើមានប៉ុន្មាននាក់នៅទីនេះមក ពីចំងាយប្រាំរយម៉ាល?" ហើយវាស្ទើរតែ—តែមួយភាគបីនៃមនុស្សទាំងអស់គ្នា បានមកពីមួយរយ និង ប្រាំរយម៉ាល។ សូមគិតពីរឿងនេះ គឺពីមនុស្សធ្វើដំណើរ។ មនុស្សទាំងអស់នោះមិនមែនមកព្រះវិហារដើម្បីឲ្យបានឃើញនោះទេ។ គ្មាន...អ្វីដែលពិភពលោកខាងក្រៅអាចមើលឃើញថាជាកន្លែងល្អនោះទេ។ ពួកគេគឺជាមនុស្សធម្មតា ក្រហើយស្លៀកពាក់ធម្មតា។ វាមិនមានភ្លេងជាតិ របស់អ្នកតែងខ្លួនដូចទេវតា គ្មានខ្លុយ គ្មានព្យាណូ គ្មានបង្អួចក្បាច់កញ្ចក់ទេ។ អ្នកនឹងមានការលំបាកក្នុងការរកកៅអី ឬក៏កន្លែងឈរក្បែរជញ្ជាំងផង។ ពួកគេមិនបានមកដើម្បីការទាំងនោះទេ។ ប៉ុន្តែដែលគេមក ពីព្រោះនៅក្នុងចិត្តពួកគេបានឃើញនូវភាពស្រស់ស្អាតដែរភ្នែកមិនអាចមើលឃើញ។ គឺភ្នែកខាងវិញ្ញាណដែលបានភាពស្រស់ស្អាតរបស់ព្រះយេស៊ូវគ្រីស្ទ។ ហេតុនេះហើយទើបពួកគេមក។

52 ដូច្នេះនៅមុនថ្ងៃដែលយើងមានការថ្វាយបង្គំ ខ្ញុំអធិស្ឋានជាប់ជានិច្ច។ ទោះឯមាត់បង្អួច ខ្ញុំលូកចូលក្នុងហោប៉ៅខ្ញុំ...ប្រាប់ប្រពន្ធថា "នៅព្រឹកនេះខ្ញុំទៅបរបាញ់កំប្រុក។" ហើយខ្ញុំបានដាក់ខ្មៅដៃ និង ក្រដាស់ក្នុងហោប៉ៅខ្ញុំ។ កាលណាមានពន្លឺគ្រប់គ្រាន់សំរាប់មើល ខ្ញុំនឹងអង្គុយទល់នឹងដើមឈើនៅកន្លែងណាមួយ លើកដៃឡើងទៅលើមេឃហើយនិយាយថា "ព្រះអង្គអើយតើទូលបង្គំអាចធ្វើអ្វីបាននៅថ្ងៃនេះ? តើទ្រង់នឹងប្រទានអ្វីដល់ទូលបង្គំសំរាប់រាស្ត្រទ្រង់?"

53 រួចហើយនៅពេលខ្ញុំបានប៉ះអ្វីមួយដែលបានឆេះ ក៏ចេញជាយ៉ាងដូចនេះ។ នៅពេលដែលព្រះវត្តមានកាន់តែជិត ខ្ញុំចាប់ផ្តើមដូចជាលឺអ្វីមួយដែលនៅឆ្ងាយ មានអ្វីដូចរបៀបនេះ។ "ពីរគុណ និង ពីរ ស្មើរបួន។" កាន់តែជិត "ពីរគុណ និងពីរស្មើរបួន។ ពីរគុណនិងពីរស្មើរបួន។ ពីរគុណ និងពីរស្មើរបួន។" [ប្អូនប្រុសប្រានហាំនិយាយកាន់តែញាប់ទៅៗ—Ed។] ម្តងហើយម្តងទៀតៗៗ ដូច្នេះ។ នេះគឺជាព្រះវត្តមានទ្រង់កំពុងតែយាងចូលមក។

54 ផ្ទង់គំនិតយើង ហើយបន្ទាប់មកយើងនឹងចេញពីខ្លួនយើង។ នោះនិមិត្តនឹងមក "*ចូរទៅកន្លែងនេះ- ឬ-កន្លែងនោះ ហើយការនេះ-ឬ-ការនោះ។*" ឃើញទេ? គឺវាចាប់ផ្តើមនៅពេលដែលយើងពិចារណាអំពីព្រះ ក្រៅពីផែនដី ឆ្ងាយពីផែនដី គឺនៅទីរហោស្ថាន សំរាប់ខ្លួនអ្នក។

55 ហើយវាចាប់ផ្តើមយក "ម្តងមួយៗ..."ខ្ញុំនិយាយថាលេខណាក៏ដោយឬអ្វីផ្សេងទៀតដែលយកជាបន្តបន្ទាប់ ចេះតែចូលមក។ រួចហើយវាមកកាន់តែញាប់ទៅៗ។ អ្នកអង្គុយនៅទីនោះហើយលើកដៃអ្នកឡើង កុំនិយាយអ្វីទាំងអស់គ្រាន់តែលើកដៃទៅឯលើ។ ការដំបូងដែលយើងបានដឹងគឺថា ខ្លួនរបស់យើងទាំងមូលត្រូវបានឆក់យកទៅបាត់។ រួចហើយអ្នកនឹងឃើញនូវអ្វីដែលទ្រង់ចង់ឲ្យអ្នកដឹង គឺបង្ហាញអ្នកពីអ្វីដែល និងត្រូវកើតឡើង។

56 ពេលខ្លះឡើងមកជាស្នាម រហូតដល់ស្នាមមួយ រួចហើយស្នាមជាច្រើន។ វាមិនក្លាយទៅជានិមិត្តទេ។ ហើយព្រះបន្ទូលបានចាក់បញ្ចូលគ្នា។ [ប្អូនប្រុសប្រានហាំបានគោះបីដង—Ed។] ខ្ញុំបានចាប់កាន់ខ្មៅដៃខ្ញុំវិញ ដើម្បីកុំឲ្យខ្ញុំភ្លេច ហើយកត់វាទុក។

57 ហើយខ្ញុំបានមកដល់ផ្ទះហើយបានមើលវាម្តងទៀត ហើយបានសិក្សាវា។ ហើយពេលខ្លះវាដូចជា មិនមានន័យអ្វីសោះសំរាប់ខ្ញុំ ពេលដែលខ្ញុំមើលវាម្តងទៀត។ ហើយបន្ទាប់មកវាគឺយ៉ាងនេះ! គឺវាបានប៉ះហើយវាទៅវិញម្តងទៀត។ រួចខ្ញុំមានសៀវភៅ តូចមួយដូច*នេះ* ហើយចាប់ផ្តើមធ្វើគំនូរព្រាងឡើង ឲ្យកាន់តែខ្លាំងតាមដែលខ្ញុំអាចធ្វើទៅបាន នូវអ្វីដែលទ្រង់បានប្រាប់ខ្ញុំ។ ខ្ញុំគិតថា "ព្រះអម្ចាស់អើយ ទូលបង្គំ ទៅឯអាសនាដើម្បីប្រាប់ពួកគេ។ ខ្ញុំ...'ចុះមក'។ ខ្ញុំមានអ្វីមួយចំនួនឲ្យពួកគេ។" នេះហើយគឺវិធីដែលវាបានមក។ គឺវាយ៉ាងនឹងឯង។ រហូតដល់ទីមួយដែលទ្រង់បានប្រទានឲ្យខ្ញុំ ខ្ញុំមិនអាចឲ្យវាទៅអ្នកណាបានទេ។

58 ដូច្នេះនៅលើគំនូរព្រៀងតូចមួយដែលខ្ញុំកំពុងតែមើលនេះ។ ហើយនៅមុនដំបូង ដែរខ្ញុំបានចាប់ផ្ដើម ខ្ញុំមិនយល់នៅត្រង់ចំនុចនេះទេ រហូតមកដល់ប៉ុន្មានថ្ងៃមុននេះដែលខ្ញុំបាននៅលើកំណាត់ឈើនោះប៉ុណ្ណោះ។

59 ឥឡូវពួកមនុស្សទាំងនេះគឺ—គឺ...ពេត្រុសបាន និយាយនៅទីនេះតើយើងធ្វើយ៉ាងណាឲ្យបានក្លាយជាចំណែកនៃនិស្ស័យជាព្រះរបស់ទ្រង់។ ឥឡូវពួកយើងគ្រប់គ្នាកំពុងតែព្យាយាមក្នុងការឲ្យបានដូចជារូបអង្គទ្រង់។

60 ឥឡូវដែលយើងបានរៀនរួចហើយនូវត្រាទាំងប្រាំពីរ។ ហើយនៅពេលដែលមានសូរសំលេងនៃត្រាទីប្រាំពីរនោះ ឬ ការដោះលែង...បង្ករឡើង យើងបានថាត្រានោះគឺជាអ្វី គឺដើម្បីដោះលែងព័ន្ធកិច្ច ដើម្បីដោះលែងត្រាទាំងប្រាំពីរ។ ហើយយើងនឹងបានឃើញវានៅលើក្រដាស់។ គឺជាការដោះលែងព្រះរាជសារ គឺអ្វីដែលបោះត្រាដល់យើង។

61 កាលពីថ្ងៃអាទិត្យមុនខ្ញុំអធិប្បាយអំពី "កូនសោរ។" ហើយកូនសោរនោះគឺសេចក្ដីជំនឿ។ សេចក្ដីជំនឿកាន់កូនសោរ ហើយកូនសោរនោះគឺជាព្រះបន្ទូលរបស់ព្រះ។ ហើយព្រះគ្រីស្ទគឺជាទ្វា។ ឃើញទេ? ដូច្នេះសេចក្ដីជំនឿគឺជាបង្គួចនៃព្រះបន្ទូល ហើយនឹងបើកបង្ហាញនូវសិរីរុងរឿង និង ភាពល្អ របស់ព្រះ ទៅដល់ប្រជារាស្ត្ររបស់ទ្រង់។ ឃើញទេ? ដូច្នេះគឺជាសេចក្ដីជំនឿដែលមានកូនសោរសំរាប់បើកវា ហើយបង្ហាញវា។

62 ដូច្នេះនៅថ្ងៃនេះយើងព្យាយាមក្នុងការយកកូនសោរដដែលនោះ ដើម្បីបើកសោរទៅកាន់ផ្លូវដែលនឹងនាំឲ្យយើងបានក្លាយទៅជាគ្រីស្ទានដ៏ឧស្សាហ៍ នៅក្នុងភាពដូចជាព្រះ ហើយឲ្យបានក្លាយជារោងឧបោសថដ៏រស់សំរាប់ឲ្យព្រះដ៏មានព្រះជន្មរស់គង់នៅ។

63 ចងចាំ ព្រះសំដែងអង្គទ្រង់ដោយវិធីបី។ លើកទីមួយទ្រង់សំដែងអង្គទ្រង់នៅក្នុងសរសរភ្លើង ដែលត្រូវបានហៅថាជាព្រះបិតា។ ហើយព្រះដដែលនោះបានបង្ហាញរូបអង្គនៅក្នុងភាពជាព្រះយេស៊ូវគ្រីស្ទ បានកើតមកជារូបសាច់ដែលទ្រង់បានបង្កើត។ ទីបីតាមរយៈការសុគតរបស់ទ្រង់ ទ្រង់បានលាងសម្អាតព្រះវិហារដែលទ្រង់អាចគង់នៅបាន។ គឺជាព្រះនៅពីលើយើង ព្រះគង់នៅជាមួយយើង ព្រះនៅក្នុងយើង គឺជាព្រះតែមួយ។

64 នោះជាមូលហេតុដែលទ្រង់ត្រូវបានហៅថា ព្រះវបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ មិនមែនជាព្រះបីនោះទេ តែគឺជាចំណែកបីនៃព្រះតែមួយ។ គឺគេគ្រាន់តែដឹងថាវាមាននៅក្នុងក្រុមប្រឹក្សានីសៀប៉ុណ្ណោះ យើងមិនមានការច្រលំទេមែនទេ? ត្រូវហើយ។ មិនមែនព្រះបីអង្គទេ។ មនុស្សមិនអាចយល់បានថាតើព្រះយេស៊ូវមានបន្ទូលទៅកាន់ព្រះវរបិតាបានយ៉ាងណា ព្រោះតែទ្រង់ និង ព្រះវរបិតាគឺតែមួយ។ គឺថាគ្រប់យ៉ាងវាអញ្ចឹង។ គឺគ្រាន់តែបើកវាប៉ុណ្ណោះ! មែន។ ឃើញទេ? គឺមិនមែនព្រះបីអង្គនោះទេ។ បីមុខងារ! បីអង្គ-...

65 តើវាជាអ្វី? ព្រះបានយកនិស្ស័យជាមនុស្ស។ ព្រះទ្រង់ចង់ឲ្យយើងថ្វាយបង្គំទ្រង់។ ពាក្យ*ព្រះ*មានន័យថា "ជាអ្វីមួយសំរាប់ថ្វាយបង្គំ។" ហើយគឺជាព្រះដែរព្យាយាមកំណត់ឲ្យប្រជារាស្ត្រទ្រង់ ដើម្បីឲ្យទ្រង់បានទទួលនូវអ្វី ដែលទ្រង់បង្កើតមនុស្សមក។ ទ្រង់មិនបានបង្កើតអ្នកមកក្រៅពីឲ្យក្លាយជាកូនប្រុសស្រីរបស់ទ្រង់ទេ។ បើយើងមិនបានវា គឺមានន័យថាអ្នកបានខុសគោលដៅហើយ។

66 ហើយ "ខុស" ពាក្យថា *អំពើ-បា-ប* មានន័យថា "ខុសគោលដៅ" ខុសគោលដៅ។ រួចបើខ្ញុំកំពុងបាញ់ទៅលើគោលដៅមួយ តំរង់គ្រាប់ចំរយៈចំងាយហាសិបយ៉ាត ហើយខ្ញុំបាញ់ យកកាំភ្លើងខ្ញុំមកហើយបាញ់ ហើយខ្ញុំបាញ់ខុស បួន ឬ ប្រាំអិញ តើនឹងមានអ្វីកើតឡើង? កាំភ្លើងរបស់ត្រូវការបែរ។ មានអ្វីខុសហើយ។ ហើយបើខ្ញុំមិនបានមានជំនឿទៅលើព្រះទេ ហើយបើខ្ញុំមិនបានក្លាយជាគ្រីស្ទានទេ...ព្រះបានដាក់អ្នកនៅទីនេះដើម្បីឲ្យអ្នកបានក្លាយជាគ្រីស្ទាន។ បើយើងនៅខាងក្រៅនៃកន្លែងមួយ ត្រលប់មកវិញនៅកន្លែងនោះទៀត។ ហើយមានការតែមួយប៉ុណ្ណោះ ដែលអាចនាំអ្នកត្រឡប់មកវិញ គឺជាព្រះបន្ទូលរបស់ព្រះ។ ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងព្រះបន្ទូលនាំអ្នកឲ្យត្រលប់មកវិញ ហើយនាំអ្នកឲ្យចូលមកក្នុងគោលដៅម្តងទៀត។ ត្រូវហើយ។

67 ឥឡូវយើងនឹងសិក្សាពីព្រះបន្ទូលរបស់ព្រះ។ លោក ស្ទេផានបាននិយាយថា នៅក្នុងកិច្ចការជំពូកទី៧ និង នៅក្នុង...សូមឲ្យយើងបានអានវា។ (និយាយអំពីឥឡូវ គឺយើងនិយាយអំពីរោងឧបោសថរបស់ព្រះ។) ឥឡូវលោក ស្ទេផាននិយាយថា...(ដែលរស់ វានឹងក្លាយជារោងឧបោសថរស់សំរាប់ព្រះដ៏មានព្រះជន្មគង់នៅ។) លោកស្ទេផានបាននិយាយ នៅក្នុងកិច្ចការជំពូកទី៧ ហើយខ្ញុំជឿថាយើង...នៅក្នុងកិច្ចការជំពូកទី៧ ចាប់ផ្តើមពី ខទី៤៤:

*រីឯពោងឧបោសថនៃសេចក្តីបន្ទាល់ នោះបាននៅជាមួយពួកព្វយុកោរបស់យើងរាល់គ្នា នៅទីរហោស្ថាន ដូចជាព្រះបានបង្គាប់មក ឲ្យលោកម៉ូសេធ្វើតាមគំរូដែលលោកបានឃើញ។*

*ពួកព្វយុកោយើងក៏បានទទួលមកតៗគ្នា ហើយបាននាំចូលមកក្នុងស្រុក ជាមួយនឹង...ព្រះយេស៊ូវ ក្នុងកាលដែលគេចាប់យកអស់ទាំងនគររបស់ពួកសាសន៍ដទៃ ដែលបានបណ្តេញ ពីមុខពួកព្វយុកោយើងចេញ ដរាបដល់រាជហ្លួងដាវីឌ*

*រីឯហ្លួងដាវីឌនេះ ព្រះទ្រង់សព្វព្រះហឫទ័យនឹងទ្រង់ ហើយស្តេចទ្រង់មានព្រះទ័យប្រាថ្នាចង់រកទីលំនៅសំរាប់ព្រះនៃយ៉ាកុប។*

*តែហ្លួងសាឡូម៉ូនវិញ ដែរស្អាងសំណាក់មួយថ្វាយព្រះ។*

*ប៉ុន្តែ ឯព្រះដ៏ខ្ពស់បំផុតទ្រង់មិនគង់នៅក្នុងព្រះវិហារ ដែលដៃមនុស្សធ្វើនោះឡើយ ដូចដែលហោរ៉ាបានទាយថា*

*ស្ថានសួគ៌ជាបល្ល័ង្កអញ ហើយផែនដីជាកំណល់កល់ជើងអញ ព្រះជាម្ចាស់មានបន្ទូលថា តើឯងរាល់គ្នានឹងស្អាងសំណាក់ណាឲ្យអញ ឬ កន្លែងឲ្យអញឈប់សំរាកបាន?*

68 ឥឡូវនៅក្នុង...ឥឡូវ "ពោងឧបោសថ" គឺពិតណាស់ជាកន្លែងដែលយើងនឹងទៅសំរាក ឥឡូវទទួលបានភាពស្រស់ថ្លា និងអ្វីផ្សេងទៀត ដូចជាសំរាកពីគេង ឬ អ្វីផ្សេងទៀត។ ឥឡូវក្នុងហេព្រើជំពូកទី១០ ហើយនៅក្នុងខទី៥ សាវ័កប៉ុលបានលើកវាមក។

*ហេតុនោះបានជាកាលទ្រង់យាងមកក្នុងលោកិយ៍ ទ្រង់មានបន្ទូលថា "យញ្ញ បូជា...*(ជាព្រះគ្រីស្ទ)*...ទ្រង់មិនចង់បានយញ្ញបូជា និង ដង្វាយទេ តែទ្រង់បានរៀបចំឲ្យរូបកាយទូលបង្គំវិញ:*

69 តើអ្វីជាពោងឧបោសថឥឡូវនេះ? ជារូបកាយ ព្រះស្នាក់នៅក្នុងរូបកាយ។

70 ព្រះទ្រង់ធ្លាប់គង់នៅខ្ពស់ នៅពេលដែលទ្រង់យាងមកនៅលើភ្នំ ទោះបីជា—ជាគោ ឬជាគោគ្រាវក៏ដោយបើប៉ះជើងភ្នំហើយនោះនឹងត្រូវស្លាប់។ ដ្បិតព្រះទ្រង់បរិសុទ្ធ។

71 កាលពីរសៀលថ្ងៃមុន ពេលដែលទេវតាបានបាំងមុខរបស់ទ្រង់។ សេរ៉ាភីម ដែលមានមុខដ៏បរិសុទ្ធ ដែលមិនដែលស្គាល់ថាតើអំពើបាបជាអ្វី ហើយពួកគេត្រូវ បាំងមុខ នៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ បាំងជើងក្នុងហ្វូងមនុស្ស។

72 ឥឡូវព្រះដ៏បរិសុទ្ធមិនលើកទោសឲ្យអំពើបាប ដូច្នេះគ្មានអ្វីអាចប៉ះភ្នំដែលព្រះ ទ្រង់គង់នៅបានទេ។

73 រួចព្រះក្លាយជាសាច់ឈាម ហើយរស់នៅក្នុងចំណោមយើង នៅក្នុងរូបអង្គនៃ ព្រះយេស៊ូវគ្រីស្ទ ជាបុត្រាទ្រង់ និង ជាស្នាព្រះហស្តទ្រង់។ រួចហើយបុត្រនោះបាន ប្រទានរូបអង្គទ្រង់ ហើយព្រះលោហិតទ្រង់បានខ្ចាយចេញ ដើម្បីឲ្យតាមរយៈព្រះ លោហិតនោះ យើងបានជីវិតវិញ។

74 តាមរយៈព្រះលោហិតនោះយើងបានស្អាត។ ហើយឥឡូវ ឈាមរបស់យើង ជីវិតរបស់យើងដែលបានមកដោយចំណង់ខាងផ្លូវភេទ ហើយនាំឲ្យយើងមានជីវិត នៅលើផែនដីនេះ។ ព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទបានសំអាតយើង ផ្លាស់ប្តូរ និស្ស័យរបស់យើង ដែលបានប្រទានមកយើង នូវព្រះវិញ្ញាណបរិសុទ្ធ ហើយ យើងបានរួមចំណែកនៅក្នុងនិស្ស័យជាព្រះរបស់ព្រះ រួចហើយយើងបានក្លាយជា កន្លែងដែលព្រះទ្រង់គង់នៅ។ ព្រះយេស៊ូវមានបន្ទូលថា "នៅថ្ងៃនោះអ្នកនឹង បានដឹងថា ខ្ញុំនៅក្នុងព្រះបិតា ហើយព្រះបិតានៅក្នុងខ្ញុំ ខ្ញុំនៅក្នុងអ្នក ហើយអ្នក នៅក្នុងខ្ញុំ។" ឃើញទេ?

75 ដឹងថាតើព្រះ នៅក្នុងពួកជំនុំរបស់ទ្រង់។ ក្រុមជំនុំឥឡូវគឺគួរតែទទួលតំណែង របស់ព្រះយេស៊ូវគ្រីស្ទបន្តបេសកម្មរបស់ទ្រង់។ "អស់អ្នកណាដែលជឿដល់ខ្ញុំ ការអ្វីដែលខ្ញុំធ្វើគេក៏អាចធ្វើបានដែរ ហើយនៅពេលបន្តិចទៀតលោកិយ៍នឹង មិនបានឃើញខ្ញុំទៀតទេ តែអ្នកនឹងឃើញខ្ញុំវិញដ្បិតខ្ញុំនៅជាមួយអ្នក គឺនៅក្នុង អ្នក រហូតដល់ចុងបំផុតកល្ប។" ឃើញទេ? នេះគឺជាអ្វីដែលត្រូវបន្តការងាររបស់ ទ្រង់។

76 ឥឡូវព្រះឬក៏ព្រះគម្ពីរបានចែងថា។ លោកស្ទេផាននិយាយអំពីសាឡូម៉ូន សាងសង់ព្រះវិហារឡើង "ហើយព្រះដ៏ខ្ពស់បំផុតមិនគង់នៅក្នុងព្រះ វិហារដែលធ្វើ ដោយដៃរបស់មនុស្សទេ។ 'ស្ថានសួគ៌ជាបល្ល័ង្គអញ ហើយផែនដីជាកំណល់កល់ បាទជើងអញ។ ហើយកន្លែងណាឲ្យអញឈប់សំរាកបាន?' 'តែទ្រង់បានរៀបចំ រូបកាយទូលបង្គំវិញ។'" អាម៉ែន។ អ្នកនៅទីនោះ។

77 "តែទ្រង់បានរៀបចំរូបកាយទូលបង្គំវិញ។" ព្រះទ្រង់គង់នៅក្នុងមនុស្ស ឆ្លុះបញ្ចាំងរូបអង្គទ្រង់នៅក្នុងមនុស្សនោះ។ ការថ្វាយបង្គំយ៉ាងល្អ! ព្រះគង់ក្នុងយើងដែលជាពេងខុបោសថរបស់ទ្រង់ ព្រះបើកសំដែង។ អូ តើយើងអាចនៅបានយ៉ាងណារហូតដល់យើងពិបាកដកដង្ហើមនៅទីនេះពីកំដៅ។ សំគាល់ព្រះក្នុងគ្រប់ពេលវេលា ឆ្លុះបញ្ចាំងរូបអង្គទ្រង់នៅក្នុងមនុស្ស។

78 គឺជាព្រះនៅក្នុងលោកម៉ូសេ។ ចូរមើលទៅគាត់កើតជាអ្នកដឹកនាំ ព្រះគ្រីស្ទ។ នៅក្នុងពេលដែលគាត់កើត មានការសម្លាប់កូនក្មេង ព្យាយាមស្វែងរកគាត់ដូចគ្នានឹងព្រះគ្រីស្ទដែរ។ ហើយគាត់ត្រូវ—បានបញ្ចូន គាត់ត្រូវបានបញ្ជូននៅពេលនោះ ដូចអង្គព្រះគ្រីស្ទដែរ។ គាត់ជាអ្នកឲ្យច្បាប់ដូចព្រះគ្រីស្ទដែរ។ លោកម៉ូសេបានឡើងទៅឯភ្នំអស់រយៈពេលសែសិបថ្ងៃ ហើយបានទទួលបទបញ្ញត្តិ រួចបានចុះមក។ ព្រះគ្រីស្ទបានយាងទៅទីរហោស្ថានអស់រយៈពេលសែសិបថ្ងៃ ហើយបានត្រលប់មកវិញដោយមានបន្ទូលថា "អ្នកបានឮកាលពីដើមហើយថា 'ឯងមិនត្រូវកំផិតឡើយ។' ប៉ុន្តែខ្ញុំនិយាយទៅអ្នកថា អស់អ្នកដែលមើលទៅស្ត្រីហើយមានសំរើបដំរេកចង់បាន នោះបានប្រព្រឹត្តិអំពើផិតនឹងនាងហើយ។" ឃើញទេ? គ្រប់ទាំងរឿងខុសគ្នាទាំងអស់គ្នានេះគឺព្រះឆ្លុះបញ្ចាំងពីរូបអង្គទ្រង់។

79 មើលទៅយ៉ូសែប បានកើតជាកូនខាងព្រះវិញ្ញាណនៅក្នុងចំណោមបងប្អូនគាត់។ ពួកគេទាំងអស់គ្នាជាមនុស្សល្អ ហើយជាមេគ្រួសារ។ ប៉ុន្តែនៅពេលដែលយ៉ូសែបមក គឺគាត់ខុសគេ។ គាត់អាចមើលឃើញនិមិត្ត ហើយអាចបកស្រាយសុបិន ហើយគាត់ត្រូវបានដំកើងឲ្យខ្ពស់ជាងបងៗ ដោយព្រោះការនោះ។ ដោយព្រោះកាលដែលទ្រង់បានដាក់ឲ្យគាត់ធ្វើនៅលើផែនដីនេះ បងប្រុសគាត់បានស្អប់គាត់។ ឃើញទេ? ហើយគ្រប់ការទាំងអស់គឺបានចង្អុលទៅលើឈើឆ្កាង។ ហើយសូមមើលគាត់ត្រូវលក់ដោយប្រាក់សាមសិបកាក់ ដោយបងៗរបស់គាត់។ ត្រូវបានទំលាក់ទៅក្នុងរណ្តៅឲ្យស្លាប់ដោយសារបងៗគាត់។ ត្រូវបានលើកពីរណ្តៅ ហើយបានទៅអង្គុយនៅខាងស្តាំនៃផារ៉ោន។ ហើយគ្មានអ្នកណាដែលអាចមកឯផារ៉ោន ជាអ្នកដែលគ្រប់គ្រងពិភពលោកនៅសម័យនោះបានទេ ក្រៅពីតាមរយៈយ៉ូសែប។ គ្មានអ្នកណាអាចមកព្រះបានទេក្រៅពីតាមរយៈព្រះយេស៊ូវគ្រីស្ទ។ ហើយនៅពេលដែលយ៉ូសែបចាកចេញពីព្រះរាជវាំង គឺមុនពេលដែលគាត់ចាកចេញ មានសូរត្រែ ហើយមានអ្នករត់ រត់តាមគាត់ "លុតជង្គង់ចុះ! លោក

យ៉ូសែបមកហើយ!” មិនថាអ្នកនៅកន្លែងណា ធ្វើការងារអ្វី ការងាររបស់អ្នកសំខាន់ប៉ុណ្ណា អ្នកត្រូវតែលត់ជង្គង់ចុះរហូតដល់យ៉ូសែបទៅដល់ទីនោះ។

80 ហើយនៅពេលដែលត្រែបានបន្លឺឡើង គ្រប់ទាំងជង្គង់ត្រូវលុតចុះ គ្រប់ទាំងអណ្តាតថ្លែងប្រាប់។ ពេលដែលព្រះគ្រីស្ទ ជាយ៉ូសែបរបស់យើង បានលះចោលសិរីល្អទ្រង់ហើយបានយាងមក គ្រប់ទាំងការងាររបស់ អ្នកលែងសំខាន់ទៀតហើយ។ គ្រប់ទាំងជង្គង់ត្រូវលុតចុះ ហើយអណ្តាតថ្លែងប្រាប់ថាទ្រង់គឺជាបុត្រានៃព្រះ។ ត្រូវហើយ។

81 អូ តើយើងឃើញទ្រង់នៅក្នុងដាវីឌយ៉ាងម៉េច! តើស្តេចដាវីឌ ជាស្តេចដែលគេមិនទទួលស្គាល់ ហើយត្រូវបានគេទំលាក់ពីបល្ល័ង្កយ៉ាងដូចម្តេច ដោយបងប្អូនទ្រង់ បុត្រទ្រង់បានអង្គុយនៅលើភ្នំអូលីវនៅពេលដែលទ្រង់យាងឡើងទៅកំពូលនៃភ្នំអូលីវ បានក្រឡេកមើលមកទីក្រុងយេរូសាឡឹម ហើយព្រះកន្សែង ដ្បិតពួកគេជារាស្ត្រទ្រង់ ដែលទ្រង់បានបំរើគេ ហើយបានបង្រៀនគេពីព្រះ ហើយគឺជារាស្ត្ររបស់ទ្រង់ដែលបានទំលាក់ទ្រង់ ហើយគ្រវែងរបស់លើទ្រង់ និយាយកំប្លែងពីទ្រង់ ពេលដែលទ្រង់ចាប់ឡើងលើភ្នំក៏ត្រូវបានគេបដិសេធ។ អូ តើបុត្ររបស់ព្រះគ្រប់លក្ខណ៍យ៉ាងណា នៅពេលប្រាំបីរយឆ្នាំក្រោយមក មានស្តេចដែលត្រូវបានបដិសេធដោយសាររាស្ត្ររបស់ទ្រង់បានអង្គុយនៅលើភ្នំ ហើយព្រះកន្សែងនឹងក្រុងយេរូសាឡឹម ក្នុងភាពជាស្តេចដែលត្រូវគេបដិសេធ។

82 តើវាគឺជាអ្វី? ព្រះបានឆ្លុះបញ្ចាំងរូបអង្គទ្រង់នៅក្នុងហោរា គឺឆ្លុះបញ្ចាំងរូបអង្គព្រះគ្រីស្ទ។

83 រួចហើយមានម្នាក់បានមក គឺជាភាពល្អឥតខ្ចោះរបស់ព្រះ។ គឺជាព្រះនៅក្នុងចំណោមយើង។

84 ហើយតាំងពីពេលនោះ ទ្រង់បានឆ្លុះបញ្ចាំងរូបអង្គទ្រង់នៅក្នុងក្រុមជំនុំរបស់ទ្រង់ នៅផ្នែកខាងនេះនៃកាល់វារី។ ដូច្នេះអ្នកបានឃើញហើយថាយើងព្យាយាមដើម្បីឲ្យបានចូលមកក្នុងសំណាក់នេះ គឺរោងឧបោសថនៃព្រះដ៏មានព្រះជន្មរស់។ ឥឡូវមានមនុស្សមួយចំនួន…

85 យើងសំគាល់នៅត្រង់នេះ ទ្រង់មានបន្ទូលថា “មុនដំបូងយើងមានសេចក្តីជំនឿ សេចក្តីទៀងត្រង់ ដំរិះ បានចេះអត់ធ្មត់ បានខ្ជាប់ខ្ជួន សេចក្តីល្អ ឬ បានចេះ

គោរពប្រតិបត្តិដល់ព្រះ បានចេះរាប់អានគ្នាជាបងប្អូន។″ ត្រូវហើយ។ ចេះរាប់អានគ្នាជាបងប្អូន ហើយបន្ថែមសេចក្តីស្រឡាញ់។ សូមឲ្យខ្ញុំបានអានវាម្តងទៀតដើម្បីឲ្យអ្នកយល់វាទាំងស្រុងឥឡូវនេះ។ ឥឡូវយើងនឹងចាប់ផ្តើមនៅខទី៥។

*ហើយដោយហេតុនោះបានត្រូវឲ្យអ្នករាល់គ្នា បន្ថែមឲ្យមានសេចក្តីឧស្សាហ៍ដែរ ដើម្បីឲ្យសេចក្តីជំនឿបានទៀងត្រង់ ឲ្យសេចក្តីទៀងត្រង់បានដំរិះ*

*ឲ្យដំរិះបានចេះអត់សង្កត់ ឲ្យសេចក្តីអត់សង្កត់បានខ្ជាប់ខ្ជួន ឲ្យ សេចក្តីខ្ជាប់ខ្ជួនបានចេះគោរពប្រតិបត្តិដល់ព្រះ*

*ឲ្យសេចក្តីគោរពប្រតិបត្តិ បានចេះរាប់អានគ្នាជាបងប្អូន ហើយឲ្យសេចក្តីរាប់អានគ្នា បានសេចក្តីស្រឡាញ់ថែមទៀត។*

*....ដ្បិតបើមានសេចក្តីទាំងនោះចំរើនឡើង ក្នុងចិត្តអ្នករាល់គ្នាហើយ នោះអ្នករាល់គ្នាមិននៅទំនេរ ឬឥតផលខាងឯដំណើរស្គាល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះព្រះអម្ចាស់នៃយើងរាល់គ្នាឡើយ។*

86 ឥឡូវពេត្រុសបានបង្ហើបអ្វីខ្លះដល់យើងនៅទីនេះ គឺជាវិធីដើម្បីឲ្យបានទៅដល់ទីនោះ។

87 ឥឡូវខ្ញុំចង់និយាយយ៉ាងដូច្នេះថា មានមនុស្សមួយចំនួនមានសេចក្តីទៀងត្រង់ ដំរិះ ប្រាជ្ញាការអត់ធន់និងអ្វីផ្សេងទៀតដែលមិនចាំបាច់សម្រាប់គ្រីស្ទានទេ។ ឥឡូវយើងគ្រាន់តែ...យើងបង្រៀនសាលាថ្ងៃអាទិត្យ។ ហើយនេះជាការពិត។ គឺមានមនុស្សដែលមានចំនែកនៃវា ហើយដែលមិនបានបង្ហាញថាជាគ្រីស្ទាន។ តែនេះមិនមែន...វានឹងមិនធ្វើនោះទេ។ វាដូចជាបក្សីពណ៌ខ្មៅហើយព្យាយាមដាក់រោមក្ងោកនៅលើស្លាបរបស់វា ដើម្បីឲ្យបានក្លាយជាក្ងោក។ គឺវាមានតែទំលាក់ខ្លួនឯងប៉ុននោះ។ វាគួរតែនៅជាបក្សីខ្មៅប្រសើរជាង។ ឃើញទេ? ពេលដែលគាត់ព្យាយាមធ្វើវា ដោយមិនបានក្លាយជាគ្រីស្ទាន គឺថាដូចជាគ្មានប្រយោជន៍សោះ។

88 វាដូចជាដើមសែគូម៉ ចង់ធ្វើឲ្យដូចដើមផ្លែប៉ោមដែរ។ វាមិនអាចទៅរួចទេ ឃើញទេ ទោះបីវាជាដើមឈើក៏ដោយ។ វាមិនអាចធ្វើឲ្យដូចជាដើមប៉ោមបានទេ។

89 វាដូចជាលាព្យាយាមពាក់រោមចៀម ព្យាយាមធ្វើជាចៀមដូច្នេះដែរ នៅពេលដែលវាពាក់រោមចៀមឬក៏លា។ អ្នកឃើញទេ វាមិនអាចបង្កើតរោមចៀមបានទេ។

វាមិនអាចធ្វើបានទេ។ រោមចៀមគឺជាអំណោយទានសំរាប់ចៀម មិនមែនសំរាប់លាទេ។ វាអាចនឹងព្យាយាមធ្វើកាយវិការឲ្យដូចជាចៀមប៉ុន្តែនៅតែជាលាដដែល។ ឃើញទេ?ដូច្នេះវានិយាយថា "ខ្ញុំអាចស៊ីដូចជាចៀម។ ខ្ញុំអាចធ្វើ*នេះ*ដូចជាចៀម។" មិនថាអ្នកចេះធ្វើអ្វីក៏ដោយអ្នកត្រូវតែជាចៀមដើម្បីឲ្យទទួលបានរោមចៀម។

90 ហើយសូមឲ្យខ្ញុំឈប់នៅទីនេះបន្តិច។ ចៀមមិនបានបង្កើតឲ្យមានរោមចៀមនោះទេ។ វាមានរោមពីព្រោះវាគឺជាចៀម។ មានមនុស្សជាច្រើនព្យាយាមនិយាយថា "បាទ ខ្ញុំនឹងព្យាយាមឲ្យបានល្អ។ ខ្ញុំនឹងព្យាយាមធ្វើរឿង*នេះ*។" កុំធ្វើឲ្យមានអ្វីឲ្យសោះ។ ទេអ្នកមិនអាចធ្វើវាបានទេ។ ចៀមមិនបានសុំ មិនបានគិតថានឹងមានរោមនោះទេ។ វាមានរោមពីព្រោះវាគឺជាចៀម។

91 ហើយនៅពេលដែលអ្នកជាគ្រីស្ទាន អ្នកនឹងមានផលផ្លែនៃព្រះវិញ្ញាណ។ អ្នកមិន—អ្នកមិនបង្កើតវានោះទេ។ អ្នកមិនមែនព្យាយាមបង្កើតវាឡើងនោះទេ។ អ្នកព្យាយាម...កុំធ្វើឲ្យអ្នកក្លាយជាអ្វីដែលមិនមែនជាអ្នក។ អ្នកគ្រាន់តែក្លាយជាអ្វីដែលអ្នកជា ហើយវានឹងចេះរក្សាខ្លួនវាហើយ។ តើអ្នកមានធ្លាប់ឮគេនិយាយថា "បាទ ខ្ញុំប្រាប់អ្នក។ ខ្ញុំ...ខ្ញុំបានចូលក្នុងព្រះវិហារ។ ខ្ញុំ—ខ្ញុំគួរតែឈប់កុហក់"? អ្នកកំពុងតែព្យាយាមបង្កើតអ្វីមួយហើយនៅពេលនេះ។ អ្នកមិនអាចធ្វើវាបានទេ ដូច្នេះមិនចាំបាច់ព្យាយាមនោះទេ វា—មិន—ខុសអ្វីនឹងលាធ្វើខ្លួនឯងឲ្យមានរោមចៀមនោះទេ។ វាមិនអាចធ្វើបានទេ។

92 ឬក៏ត្មាតព្យាយាមស៊ីជាមួយនឹងសត្វព្រាប ត្មាតព្យាយាម—ត្មាតព្យាយាមឲ្យក្លាយទៅជាព្រាប។ សូមអ្នកពិចារណាជាមួយគ្នា ថាមានក្អែកមួយនិយាយថា "អ្នកដឹងទេខ្ញុំជាព្រាប" ហើយបានដាក់រោមមួយចំនួននិយាយថា "ឃើញទេ ខ្ញុំមើលទៅដូច..." ឃើញទេ? គឺថាវាមិនមានរាងដូចទាល់តែសោះ។ នោះគឺ—គឺជាអ្នកណាម្នាក់ដែលអួតខ្លួនជាអ្នកជំនាញលើអ្វីមួយ តែតាមការពិតមិនចេះសោះ។ មើលអ្នកមិនអាចធ្វើដូច្នេះបានទេ។

93 អ្នកមិនអាចនិយាយថា "ឥឡូវសូមមើល ខ្ញុំគួរតែមានសេចក្ដីទៀងត្រង់ ដូច្នេះខ្ញុំនឹងមានសេចក្ដីទៀងត្រង់។ ខ្ញុំគួរតែចេះគោរពប្រតិបត្តិដល់ព្រះ ដូច្នេះនឹងមានវា។" ហេតុអ្វីបានជាអ្នកព្យាយាមក្នុងការពាក់ស្លាប។ បើទោះជាអ្នកអាចដាក់ដៃដល់ក៏ដោយ ក៏អ្នកមិនអាចដាក់រោមឲ្យខុសសត្វបានឡើយ។ ឃើញទេ? វាមិនអាចទៅរួចបានទេ។ ហើយវាគ្រាន់តែបញ្ជាក់ថា វាគឺជាបក្សីដែលពេញដោយ

ភាពពុតត្បុតតែប៉ុណ្ណោះ។ តើអ្នកអាចស្រមៃបានទេអំពីការដែលក្អែកចាស់មួយក្បាលចង់បានស្លាបរបស់សត្វព្រាប ដោយនិយាយថា "មើលខ្ញុំនេះគឺជាសត្វព្រាប"។? ឃើញទេ? ហេតុអ្វីបានជាយើងដឹងថាវាគឺជាក្អែក។ ឃើញទេ? ឃើញទេ? ត្រូវហើយ។ យើងអាចដឹងថាវាគឺជាក្អែកបាន។

94 ឥឡូវនេះដែរមធ្យោបាយក្នុងការព្យាយាមធ្វើ—គឺធ្វើឲ្យក្លាយជាគ្រីស្ទាន។ អ្នកមិនអាចធ្វើវាបានទេ។ រឿងដំបូងដែលអ្នកត្រូវធ្វើ គឺត្រូវតែបានកើតជាថ្មី។ អ្នកត្រូវតែផ្លាស់ប្រែ។ ឃើញទេ? ហើយនៅពេលដែលអ្នកផ្លាស់ប្រែ នោះអ្នកនឹងបានក្លាយទៅជាមនុស្សថ្មី។ ឥឡូវអ្នកអាចទទួលបានឥឡូវ។ ឃើញទេ? ឥឡូវ អ្នកមិនចាំបាច់ខ្វល់អំពីស្លាបនោះទេ វានឹងចេះថែរក្សាខ្លួនវាហើយនៅពេល—នៅពេលដែលអ្នកបានកើតជាថ្មី។ ពិតមែនហើយ។

95 ដូចអ្វីដែលខ្ញុំបាននិយាយ។ បើអ្នកយក—ជ្រូកហើយចងវាដាក់ឯកសណ្ឋានអ្នកបើកទូកពីលើវា ឬក៏ពាក់អាវថូដូដាក់នៅលើវា រួចប្រលែងវាទៅខាងក្រៅ នោះនឹងទៅចូលក្នុងរណ្ដៅភក់ហើយននៀលនៅទីនោះ។ ព្រោះវាមានអ្វីល្អសំរាប់វានោះទេ។ ព្រោះវាគឺជាជ្រូក។ នេះគឺជានិស្ស័យរបស់វា។ ការននៀលគឺជានិស្ស័យរបស់វា។ អ្នកគឺគ្រាន់តែត្រូវផ្លាស់ប្ដូរធម្មជាតិរបស់វាប៉ុណ្ណោះ ហើយ(វា)ការផ្សេងទៀតវានឹងមកដោយខ្លួនវា។

96 ឥឡូវសំគាល់។ អ្នកត្រូវកើតជាថ្មី នេះគឺជាការផ្លាស់ប្ដូរ។ វាត្រូវតែមានការផ្លាស់ប្ដូរ។

97 អ្នកនិយាយថា "បងប្រុសប្រានហាំ ខ្ញុំស្គាល់ស្ត្រីម្នាក់នៅទីនេះ ហេតុអ្វីបានជាគាត់មិនដែលធ្វើអ្វីខុសសោះ។ នាងគឺជាស្ត្រីដ៏ល្អ។ ឬ*បុរសនេះ-និង-បុរសនោះ* គាត់គឺជាមនុស្សល្អណាស់។ គាត់មិនដែលធ្វើអ្វីសោះ។ អ្នកដឹងទេគាត់មិនដែលឬធ្វើឲ្យអ្នកណាភ័យខ្លាចនោះទេ។" នេះវាមិនមែនរឿងមួយនោះទេ។ គាត់ប្រហែលជាអ្នកជិតខាងដ៏ល្អ ប៉ុន្តែគាត់មិនមែនជាគ្រីស្ទានទេ លុះត្រាតែគាត់បានកើតជាថ្មី។

98 ព្រះយេស៊ូវមានបន្ទូលថា "ទាល់តែអ្នកនោះបានកើតជាថ្មី" សាវ័កយ៉ូហានជំពូកទី៣ថា "គាត់ក៏មិនអាចមើលឃើញឋានសួគ៌ឡើយ។" ឥឡូវមានន័យថា *ឃើញ* វាមានន័យថា "យល់។"

99 អ្នកមើលទៅគ្រប់របស់ទាំងអស់ហើយនិយាយថា "ខ្ញុំមើលមិនឃើញវាទេ។" មានន័យថាអ្នកមិនយល់វាទេ។

100 មនុស្សម្នាក់មិនអាចយល់បានថាតើហេតុអ្វីបានជាមនុស្សស្រែក។ មនុស្សម្នាក់មិនអាចយល់បានថាតើហេតុអ្វីបានជាភាសារបស់មនុស្សផ្លាស់ប្តូរ ហើយគាត់អាចនិយាយភាសាដទៃ។ មនុស្សខាងឯសាច់ឈាមមិនអាចមើលឃើញថាតើសិរីល្អព្រះអាចនឹងមកឲ្យភ្នែកមនុស្សឃើញបានជាយ៉ាងណា ហើយដែលគេអាចមើលឃើញនិម្មិត រួចអាចប្រាប់ ពីដំណើររឿងផ្សេងៗ នឹងអ្វីដែលគួរធ្វើ ប្រាប់គេពីកាលដែលនឹងត្រូវកើតឡើង និងហេតុការដែលអាចនឹងកន្លងផុត ដូចជាអ្វីដែលព្រះអម្ចាស់បានធ្វើសំរាប់យើងនៅយប់មិុញ។ ឃើញទេ? ឃើញទេ? គំនិត—ខាងសាច់ឈាមព្យាយាមដោះស្រាយ។ "ពិតមែនហើយ តើគាត់បានធ្វើអ្វី? ឬតើគាត់កំពុងតែប្រើល្បិចអ្វី? តើគាត់មានគ្រឿងបំភាន់ភ្នែកអ្វី?" ដែលឃើញមនុស្សនិយាយភាសាដទៃ គេនឹងនិយាយថា...ហើយមានអ្នកខ្លះមកបកប្រែ ហើយប្រាប់ដោយចំៗចំពោះសមាជិកណាម្នាក់នូវអ្វីដែលគេបានធ្វើ ហើយ និងអ្វីដែឬគេមិនគួរធ្វើ។ ឃើញទេ? ឃើញទេ? គេគិតថាវាគឺជាការប្រើល្បិច។ "គឺថាមានអ្វីនៅ ចំកណ្តាលគេ។"

101 គេមិនអាចយល់បានឡើយលុះត្រាតែគេបានកើតជាថ្មី។ រួចហើយនៅពេលដែលគាត់បានកើតជាថ្មី រួចគាត់បាននៅក្នុងបន្ទាប់នៃភាពជាបងប្អូន ពីព្រោះគាត់ជាមនុស្សដែលបានកើតជាថ្មី។ អបិយជំនឿចាស់ៗ កន្លងមក គំនិតសង្ស័យដែលគាត់មានត្រូវបានស្លាប់។ ឥឡូវគាត់គឺជាមនុស្សថ្មី។ ដូច្នេះអ្នកបានឃើញហើយថាគាត់មិនចាំបាច់ដាក់បន្ថែមអ្វីនោះទេឥឡូវនេះ ពីព្រោះវាត្រូវបានបន្ថែមដោយស្វ័យប្រវត្តិ។

102 សំគាល់គាត់ត្រូវតែកើតជាថ្មី។ ហើយនៅពេលដែលអ្នកកើតជាថ្មី អ្នកមិនអាចកើតជាថ្មីដោយគ្មានសេចក្តីជំនឿនោះទេ។ ត្រូវហើយ។ ដូច្នេះអ្នកបានឃើញនៅគំនូសតាងរបស់ខ្ញុំនេះ ខ្ញុំមានគ្រឹះដំបូង ហើយសេចក្តីជំនឿគឺជាគ្រឹះនៃអ្វីៗទាំងអស់។ "ដ្បិតបើគ្មានសេចក្តីជំនឿទេ នោះមិនអាចធ្វើឲ្យព្រះសព្វព្រះទ័យបានឡើយ។ អ្នកណាមកឯព្រះត្រូវតែជឿថាទ្រង់គឺជាព្រះ ហើយទ្រង់នឹងប្រទានរង្វាន់ដល់អស់អ្នកណាដែរស្វែងរកទ្រង់អស់អំពីចិត្ត។" ឃើញទេ? គាត់ត្រូវតែ។ ហើយ

នៅពេលដែលអ្នកសង្ស័យព្រះគម្ពីរ ពេលអ្នកសង្ស័យព្រះបន្ទូល ដ៏ត្រឹមត្រូវ គឺអ្នកត្រូវនៅចាំដល់ពេលដែលអ្នកបានជឿវាសិន។

103 តើអំពើបាបគឺជាអ្វី? ការមិនជឿ។ គឺវាមានធាតុពីរដែលគ្រប់គ្រងលើមនុស្ស។ គឺមានទាំងចំងល់ ឬជំនឿ គឺមានមួយឬផ្សេងទៀត។ អ្នកជាកម្មសិទ្ធមួយដែលមានអំណាចនៅលើជីវិតរបស់អ្នកហើយ។ គឺវាគ្រាន់តែផ្អែកទៅលើថាអ្នកមានសេចក្តីជំនឿប៉ុន្មាន ហើយតើអ្នកអាចឡើងបានខ្ពស់ប៉ុនណា។

104 ប៉ុន្តែដំបូងវាគឺត្រូវតែជាសេចក្តីជំនឿ។សូមឲ្យខ្ញុំឈរជាគ្រឹះឲ្យបានបន្តិចទៀត។ ឥឡូវសេចក្តីជំនឿ គឺជាអ្វីដែលអ្នកត្រូវតែជឿ។ ជំនឿគឺជាអ្វី..."សេចក្តីជំនឿគឺជាសារធាតុមួយដែលសង្ឃឹមបាន។" គឺថាអ្នកមានវារួចទៅហើយនៅពេលដែលអ្នកមានជំនឿ ពីព្រោះវាបង្ហាញក្នុងសេចក្តីជំនឿ។ "សេចក្តីជំនឿគឺជាសារធាតុដែលសង្ឃឹមបាន" ហេព្រើរ ជំពូកទី១១ មើល "ជាភស្តុតាង" តើវាជាអ្វី? តើជាភស្តុតាងប្រភេទណា? ជាភស្តុតាងដ៏បរិសុទ្ធ។

105 ដូច្នេះនៅពេលដែលអ្នកនិយាយថា "បងប្រុសប្រានហាំ ខ្ញុំជឿថាព្រះអង្គគឺជាព្រះដែលព្យាបាល។" ល្អ បើអ្នកជឿលើការនោះ ហើយទទួលទ្រង់ជាអ្នកព្យាបាលរបស់អ្នក ហើយដែលមិនបានកុហក ហើយជឿពិតនៅក្នុងចិត្តថា ដោយសារស្នាមរបស់ទ្រង់អ្នកបានជា វានឹងគ្មានអ្វីដែលអាចនាំអ្នកចេញពីការនោះបានឡើយ។ វាគឺអ្វីដែលបានដោះស្រាយរួចហើយ។ ឥឡូវអ្នកអាចនឹងសង្ឃឹមថា គេចពីការ*នេះ* គេចពីការ*នោះ*។ ប៉ុន្តែពេលដែលអ្នកមានជំនឿវិញ អ្នកនឹងបានស្គាល់វា ពីព្រោះវាគឺជាទីសំគាល់។ អ្នកបានមានវារួចទៅហើយ។ ខ្ញុំធ្លាប់...

106 តើប៉ុន្មាននាក់ មានអ្នកណាខ្លះធ្លាប់បានស្តាប់ អូរាល់ រ៉ូបឺត នៅព្រឹកនេះ គឺនៅពេលដែលគាត់អធិប្បាយនៅព្រឹកនេះ? ខ្ញុំ—ខ្ញុំបានឮគាត់និយាយពីអ្វី ឬអ្នកណាម្នាក់ថា គឺមានសេចក្តីជំនឿ នៅពេលមានការអធិស្ថានសុំឲ្យមានការដោះលែង ហើយនោះគឺជាការអធិស្ឋានដោយសេចក្តីជំនឿនៃការដោះលែង។ គាត់និយាយថា "សូមភ្ជាប់ការទំនាក់ទំនងដោយការប៉ះវិទ្យុ សូមភ្ជាប់ទំនាក់ទំនងដោយការប៉ះលើអ្វីមួយ ដើម្បី..." បុរសនោះបានធ្វើវា គឺថា គាត់បានឲ្យរបស់មួយចំនួនដើម្បីឲ្យពួកគេអាចដាក់ដៃលើ។ អ្វីខ្លះ អ្នកនិយាយថា "ខ្ញុំបានវាហើយឥឡូវនេះ ពីព្រោះគាត់ប្រាប់ខ្ញុំឲ្យប៉ះវិទ្យុ។ ខ្ញុំមានហើយ។" ឃើញទេ? ឥឡូវវាត្រូវហើយ។ ប៉ុន្តែសេចក្តីជំនឿដ៏ពិតមិនចាំបាច់ត្រូវការប៉ះរបស់ទាំងនោះទេ។ ឥឡូវ

ខ្ញុំមិនបានកាត់ក្ដីប្អូនប្រុសអូ៉ាល់ទេ គឺមិនទេ។ គាត់បានធ្វើការងារដ៏អស្ចារ្យ ហើយគាត់គឺជាមនុស្សរបស់ព្រះ ហើយខ្ញុំ—ខ្ញុំពិតជាបានយកចិត្តទុកដាក់ជាខ្លាំងដល់ប្អូនប្រុសអូ៉ាល រ៉ូបឺត។ អាក្រក់ពេកហើយយើងមិនបានឲ្យកាន់តែច្រើនពីវា។

107 ប៉ុន្តែអ្វីដែលខ្ញុំព្យាយាមនិយាយនោះគឺ គឺថាសេចក្ដីជំនឿមិនត្រូវការអ្វីទេ។ ឃើញទេ? ជំនឿគឺជឿលើព្រះបន្ទូលរបស់ព្រះ។ ដ្បិតសេចក្ដីជំនឿកើតពី "ការប៉ះ"?ទេ។ "សេចក្ដីជំនឿបានមកពីការឮ ហើយគឺឮព្រះបន្ទូលរបស់ព្រះ។" នោះជា យុត្ដា។ វានៅទីនោះ។ ឃើញទេ? ហើយសេចក្ដីជំនឿ ដូចជាអ្វីដែលវាបាននិយាយហើយ វាគ្មានប្រវែងនោះទេ។ សេចក្ដីជំនឿគឺជាឥឡូវ។ សេចក្ដីជំនឿគឺនៅទីនេះ។ ឥឡូវបើមាននណាម្នាក់...

108 មានទារកតូចមួយនៅថ្ងៃមួយ។ គឺជាម្ដាយម្នាក់ដែលបងស្រីយើងនិងពួកគេបាននិយាយ ដែលមានពោះវៀននៅខាងក្រៅនោះនឹងមិនមានរន្ធនៅចុងពោះវៀនដើម្បីឲ្យអាហារឆ្លង់កាត់។ ឥឡូវស្ត្រីនោះបានឮពួកគាត់ធ្វើទីបន្ទាល់ បានជឿថាបើគាត់មានទំនាក់ទំនង ហើយខ្ញុំបានអធិស្ឋានឲ្យទារកនោះ។ ឥឡូវមើល ព្រះបានប្រទានឲ្យមានមនុស្ស...

109 ពួកយើងមួយចំនួនមានបទពិសោធន៍ជាមួយព្រះ យ៉ាងពិប្រាកដមែន—ទែនដែលធ្វើឲ្យទ្រង់សព្វព្រះទ័យនឹងគង់នៅទីនេះ ដូចហើយមានបន្ទូលនឹងប្អូនប្រុសនីវិល ឬអ្នកណាម្នាក់ដែលអ្នកជិតស្និទ្ធជាមួយ។ ហើយយើងនៅពេលខ្លះសូមឲ្យអ្នកទាំងអស់នោះអធិស្ថានឲ្យ។ នេះជាអ្វីដែលយើងគ្រប់គ្នាត្រូវធ្វើ។ រួចហើយបើយើងមានសេចក្ដីជំនឿជឿថាមានប្រុសឬក៏ស្រី ជាអ្នកក៏បានដែរ អធិស្ឋានឲ្យយើង កំពុងតែនិយាយទៅកាន់ព្រះ នោះមានន័យថាសេចក្ដីជំនឿ យើងត្រូវបានកាន់ជាប់។ វាត្រូវបានក្ដាប់ជាប់។ វាត្រូវបានរួចរាល់។

110 នេះ ពួករ៉ូមបានចេញទៅជួបព្រះយេស៊ូវ។ ហើយគាត់បាននិយាយថា "ខ្ញុំ— ខ្ញុំមិនសក្តិសម នឹងឲ្យទ្រង់មកដល់ផ្ទះរបស់ខ្ញុំទេ។ ខ្ញុំមិន។ ខ្ញុំ—ខ្ញុំមិនសក្តិសមទេ។ ហើយខ្ញុំ—ខ្ញុំមិន...ខ្ញុំ—ខ្ញុំមិនបានរាប់ខ្លួនឯងដូច្នេះទេ។ ប៉ុន្តែ" និយាយថា "កូនខ្ញុំវាឈឺខ្លាំងណាស់។ សូមទ្រង់គ្រាន់តែមានបន្ទូល មើល នោះវានឹងមានជីវិតវិញ។"

111 តើនេះគឺជាអ្វី? ប្រវែងវាមិនអាចផ្លាស់ប្ដូរអ្វីបានទេ។ ឃើញទេ? ពីព្រោះព្រះទ្រង់មានវត្តមានគង់នៅគ្រប់ទីកន្លែង។ ហើយដែលទ្រង់មាន ព្រះវត្តមានគ្រប់ទីកន្លែង ដែលធ្វើឲ្យទ្រង់គង់នៅគ្រប់ទីកន្លែងទាំងអស់។ ឃើញទេ? ព្រះអង្គទ្រង់

អស្ចារ្យនៅ អាឡឺម៉ង់ ហ្វាំងឡង់ ហើយនៅអាហ្វ្រិច នៅនាទីនេះ ដែលទ្រង់គង់នៅទីនេះ។ អូ! អ្នកក៏នៅដែរ។

112 ដូច្នេះឥឡូវគាត់និយាយថា "ខ្ញុំមិនសក្តិសមឲ្យទ្រង់ មកក្រោមដំបូលខ្ញុំទេគឺគ្រាន់តែមានព្រះបន្ទូល។" តើវាគឺជាអ្វី? នេះគឺជាសេចក្តីជំនឿរបស់ជនជាតិរ៉ូមម្នាក់នោះ។ គាត់បានជឿវា។

ហើយព្រះយេស៊ូវមានបន្ទូលថា "ចូរត្រលប់ទៅវិញចុះ។ កូនអ្នកជាហើយ។"

113 ហើយគាត់បានធ្វើដំណើរពីរថ្ងៃ។ ហើយនៅថ្ងៃបន្ទាប់ ដ្បិតដែលគាត់បានទៅផ្ទះគាត់បានជួបនឹងអ្នកបំរើរបស់គាត់កំពុងមក។ ហើយពួកគេ និយាយថា "កូនរបស់លោកនៅរស់ទេ។"

114 ហើយជនជាតិរ៉ូមនោះរំភើបចិត្តរហូតដល់គាត់និយាយថា "តើនៅម៉ោងប៉ុន្មានដែលវាបានប្រសើរឡើង? នៅពេលណា?"

គាត់និយាយថា "នៅប្រហែលម៉ោង១១ វាមានការផ្លាស់ប្តូរ។"

115 ហើយជនជាតិរ៉ូមនោះបានដឹងថាគឺជាពេល ដែលព្រះយេស៊ូវមានបន្ទូលថា "កូនរបស់អ្នករស់ហើយ" ហើយគាត់បានជឿ។ អាម៉ែន។

116 មានអំណាចគ្រប់ទាំងអស់ មានវត្តមាននៅគ្រប់ទាំងអស់ ហើយដឹងគ្រប់ទាំងអស់ពិតជាព្រះ។ ដូច្នេះ នៅពេលដែលគេបានតេទូរស័ព្ទ ហើយនិយាយថា "អធិស្ឋាន!" នេះជាទំនាក់ទំនង! ហើយសេចក្តីជំនឿរបស់អ្នកនឹងនាំព្រះមក។ នេះគឺជាអ្វីដែលនាំព្រះនិងសេចក្តីអធិស្ឋានជាមួយគ្នា នៅក្នុងវិញ្ញាណ។ ការអធិស្ឋាន! សេចក្តីជំនឿប្តូរពី*កន្លែងនេះ*ទៅ*កន្លែងនេះ*។ វានាំមកជាមួយគ្នា។

117 "ចូរនិយាយព្រះបន្ទូល។ អ្វីខ្ញុំចង់ឲ្យអ្នកធ្វើគឺនិយាយព្រះបន្ទូលមក ហើយគ្រប់ទាំងអស់នឹងបានប្រសើរឡើង។" ឃើញទេទ្រង់មិនចាំបាច់នៅទីនោះទេ "គ្រាន់តែមានបន្ទូលប៉ុណ្ណោះ"។ ហេតុអ្វី? ព្រះទ្រង់មានវត្តមានគ្រប់ទាំងអស់។ ទ្រង់មានអំណាចគ្រប់ទាំងអស់។ គឺទ្រង់មានអំណាចពីក្រោយព្រះបន្ទូល ដូចដែលទ្រង់គង់នៅពីលើផែនដី ឬនៅទាំងសងខាង។ ទ្រង់គឺជាព្រះ។ "ហើយអ្វីដែលអ្នកត្រូវធ្វើនោះគឺគ្រាន់តែនិយាយព្រះបន្ទូល" គាត់និយាយ។

118 ហើយឥឡូវសេចក្តីជំនឿធ្វើកសរដែលនៅសល់។ សេចក្តីជំនឿធ្វើការដែឬនៅសល់។ ដូច្នេះសំរាប់ជាគ្រឹះ អ្នកត្រូវមានសេចក្តីជំនឿ។ គ្រប់គ្រឹស្ទានទាំងអស់

គ្រប់អ្វីដែលជាអ្នក គ្រប់ទាំងអ្វីដែលអ្នកនឹងក្លាយជា គឺស្ថិតនៅលើជំនឿទៅលើព្រះបន្ទូលរបស់ព្រះ។ នេះហើយគឺជាមូលហេតុដែលខ្ញុំជឿលើព្រះបន្ទូលរបស់ព្រះ។ ឃើញទេ?

119 ខ្ញុំមិនអាចដាក់សេចក្ដីជំនឿរបស់ខ្ញុំទៅលើអ្វីទៀតបាន។ បើសិនជាខ្ញុំនឹងដាក់វាទៅលើព្រះវិហារ តើព្រះវិហារណាមួយដែលខ្ញុំគួរតែជឿ: កាតូលិក លូធើរៀន ម៉េតូឌីស បាប់ទីស្ទ ឬក៏ពេនទីកុស្ដ? តើខ្ញុំគួរជឿមួយណា? ខ្ញុំមិនដឹងទេ។ ពួកគេទាំងអស់គ្នាបាននៅស្ទាក់ស្ទើរ ហើយនិងអ្វីផ្សេងទៀត គឺជាខ្សែរ រមូល ហើយនិងអ្វីផ្សេងទៀត។

120 ប៉ុន្តែនៅពេលដែលខ្ញុំដាក់សេចក្ដីជំនឿខ្ញុំនៅលើព្រះបន្ទូលទ្រង់វាជាយុថ្កា។ គ្មាននរណាអាចបកស្រាយវាបានទេ។ វាគឺជា ព្រះអម្ចាស់**មានព្រះបន្ទូលថា។** រួចហើយខ្ញុំជឿលើការនោះ។ នេះគឺជារឿងធម្មតា។

121 គ្រូពេទ្យតូចមានសុខុភាពល្អម្នាក់ដែលនៅក្នុងទីក្រុងនេះជាមិត្តភក្តិរបស់ខ្ញុំឈ្មោះ លោកគ្រូពេទ្យស៊ែម អាឌ៊ែរ។ យើងធំឡើងមកជាមួយគ្នា។ អ្នកទាំងអស់គ្នាស្គាល់ ស៊ែម។ ហើយគាត់បាននិយាយមកខ្ញុំ គាត់និយាយថា "ប៊ីល..." បន្ទាប់ពីនិមិ្មតនោះបានមក បានប្រាប់គាត់ពីកន្លែងដែលគាត់ត្រូវបង្កើតកន្លែងរបស់គាត់ ហើយតើវាមានរូបរាងដូចម្ដេច។ ឥឡូវចូរចូលទៅខាងក្នុង ហើយសួរគាត់ចុះ តើមានអ្វីដែលមិនមែនជាការពិតឬទេ។ ពីរ ឬបីឆ្នាំមុន គឺមុនដែលវាបានកើតឡើងបានប្រាប់គាត់ឲ្យដឹងពីកន្លែងដែលវានឹងកើត។ ខ្ញុំបាននិយាយថា "អ្នកស្ទើរតែបានបិទទីក្រុងនេះទៅហើយ។" ហើយវាមិនមែនទេ ប៉ុន្តែអ្វីមួយរវាងគាត់នឹងវា ហើយនោះជាកន្លែងស្ដារឡើងវិញ។ គ្រូពេទ្យអាឌ៊ែរបានទទួល ចំណែកសេសសល់ ហើយជាអ្នកលក់ថ្នាំ។ ទាំងអស់ហើយ។ គ្រូពេទ្យ អាឌ៊ែ គិតថានេះគឺជានិមិ្មតនោះហើយ។ តើកន្លែងណាដែលគាត់និយាយថា "វាមិនទាំងបានប៉ះទេអស់រយៈពេលម្ភៃប្រាំឆ្នាំហើយ។ ពីព្រោះវានៅក្នុងតុលាការ"។

122 ខ្ញុំនិយាយថា "គ្រូពេទ្យព្រះបានប្រទានវាឲ្យអ្នកហើយ ពីព្រោះដោយការបន្ទាបខ្លួនរបស់អ្នក។"

គាត់និយាយថា "ខ្ញុំមិនល្អទេ។"

123 ខ្ញុំនិយាយថា "អ្នកជាអណ្តើក។ អ្នកមានសំបកនៅពីខាងក្រៅ អ្នកផ្សេងអាចនឹងហៅអ្នកថាជាសំបកគ្រៀមៗ ប៉ុន្តែធាតុពិត អ្នកគឺជាបុរសពិត។ ចូរចេញពីស្នូកនោះមក។" ខ្ញុំនិយាយថា "ព្រះបានប្រទានវាមកឲ្យអ្នក។"

124 គាត់និយាយថា "ខ្ញុំមិនដែលសង្ស័យអ្នកទេ ប៊ីលី ប៉ុន្តែខ្ញុំនឹងសង្ស័យចំពោះការនោះវិញ។"

ខ្ញុំនិយាយថា "ចូរទៅឯការិយាល័យរបស់អ្នក។" ហើយគាត់ក៏បានចេញទៅ។

125 នៅព្រឹកបន្ទាប់គាត់បានតេមកខ្ញុំនិយាយថា "ខ្ញុំកក ជិតនឹងស្លាប់ហើយ។"

126 ខ្ញុំនិយាយថា "តើមានរឿងអ្វី?" គឺវានៅក្នុងខែកក្កដា។ ខ្ញុំនិយាយថា "តើវាមានរឿងអ្វី គ្រូពេទ្យ?"

127 និយាយថា "ខ្ញុំបានទិញដីនោះហើយប៊ីលី។ ពួកគេបានប្រជុំគ្នាយប់មិញនៅទីក្រុងប៉ុសស្ទុន ហើយខ្ញុំបានទិញដីនោះនៅព្រឹកនេះ ។"

និយាយថា "ខ្ញុំបានប្រាប់អ្នកហើយ។"

128 ខ្ញុំបាននៅខាងក្រោមនោះ នៅថ្ងៃមួយបាននិយាយជាមួយគាត់ នៅពេលដែលគ្រាប់កាំភ្លើងបានតំរង់មកមុខរបស់ខ្ញុំ។ គាត់និយាយថា "ខ្ញុំស្រមៃថា ខ្ញុំបានប្រាប់ការនេះដល់មនុស្សរាប់ពាន់នាក់ដែលមកទីនេះ ថាយ៉ាងនោះ។" តើវាគឺជាអ្វី? ឥឡូវនៅពេល ដែលព្រះមានព្រះបន្ទូលថាយ៉ាងណា នោះការនោះត្រូវតែកើតឡើង។

129 កាលពីរសៀលម្សិលមិញមិត្តភក្តិបានចូរមក។ ពួកគេបានឮពីនិម្មិតមួយអំពីសត្វរមាំង ដែលមានស្នែងប្រវែង៤២អិញ ហើយ និងសត្វខ្លាឃ្មុំ ដែលមានកន្ទុយពណ៌ប្រាក់។ ខ្ញុំមិនដឹងថាមានមនុស្សប៉ុន្មាននាក់មកក្នុងបន្ទប់នោះទេ គឺគេមកចង់មើលវា។ ខ្ញុំនិយាយថា "នេះគឺជាម៉ែត សូមវាស់ស្នែងរបស់វា។" គាត់បានឮគេប្រាប់មុនដែរវាកើតឡើង។ ឃើញទេ? ហេតុអ្វី? ពេលដែលព្រះមានបន្ទូលពីរឿងអ្វីមួយវានឹងកើតឡើង។ នេះហើយជាហេតុផលរបស់វា។

130 ឥឡូវ *នេះ*គឺជាគំរោងការនៃការសង្គ្រោះរបស់ព្រះ។ ហើយបើនិម្មិតរបស់គាត់បានកើតឡើងយ៉ាងពិតប្រាកដតាមអ្វីដែលបាននិយាយ ហើយក្រុមជំនុំនៅទីនេះដឹងថានេះគឺជារឿងត្រឹមត្រូវ រួចចុះព្រះបន្ទូលវិញយ៉ាងម៉េចដែល។ ឃើញទេ? នោះវាច្បាស់ជាងនិម្មិតទៅទៀត។ បើសិនជានិម្មិតមិនបាននិយាយដោយព្រះបន្ទូលទេ

នោះនិម្មិតនោះគឺជាការខុសឆ្គង។ ប៉ុន្តែវាគឺជាព្រះបន្ទូល ទីមួយគឺព្រះបន្ទូលគឺជាព្រះ។ ឃើញទេ? ដូច្នេះទ្រង់គឺជាព្រះដែលមានវត្តមាននៅគ្រប់ទីកន្លែង។ ទ្រង់បានមានបន្ទូលនៅទីនេះ ហើយទ្រង់បានធ្វើវា ឲ្យកើតឡើងនៅប្រទេសកាណាដា។ អាម៉ែន។ ឃើញទេ ទ្រង់គឺព្រះដែលមានវត្តមាននៅគ្រប់ទីកន្លែង។ ត្រូវហើយ។

131 ទីមួយ អ្នកត្រូវតែបានកើតជាថ្មី។ ហើយនៅពេលដែលអ្នកបានកើតជាថ្មីហើយ អ្នកនឹងមានសេចក្ដីជំនឿ អ្នកជឿទៅលើព្រះបន្ទូល។ ក្នុងកាលដែលអ្នកមិនទាន់បានកើតជាថ្មីនៅឡើយ អ្នកនឹងប្រកែកនឹងវា។ បើអ្នកជាមនុស្សដែលបំរុងនឹងជឿទៅលើសាសនា—ហើយ អ្នកមាន—មាន—ចំណេះរបស់មនុស្សថាអ្នកគួរតែធ្វើការត្រឹមត្រូវ អ្នកនឹងមិនអាច យល់ព្រមតាមព្រះបន្ទូលរបស់ព្រះបាននោះទេ។ អ្នកនឹងមិនធ្វើតាមវាទេ។ អ្នកត្រូវតែឲ្យបានកើតជាថ្មី។ ហើយការដែលបានឲ្យកើតជាថ្មីវានឹងបង្កើតឲ្យបាននូវសេចក្ដីជំនឿ។ ត្រូវហើយ។ ហើយនៅពេលដែលអ្នកមានសេចក្ដីជំនឿ គឺមួយ*នេះ* ជំ-នឿ ជំនឿ រួចហើយអ្នកគឺឋិតនៅក្នុងដំណាក់កាលនៃការលូតលាស់។

132 ឥឡូវមានមនុស្សច្រើនបានទៅឯអាសនា ហើយអធិស្ឋានដោយនិយាយថា "ព្រះអង្គអើយ សូមទ្រង់អត់ទោសឲ្យកូន។" ហើយការលាងសម្អាតដ៏អស្ចារ្យជាច្រើនកើតឡើងដល់ពួកគេ ហើយនិងរឿងអ្វីផ្សេងទៀត។ រួចហើយអ្នកអាចនឹងមានពេលវេលាដ៏ល្អនឹងឡើងទៅឯអាសនាហើយស្រែក។ អ្នកត្រលប់ទៅវិញហើយនិយាយ "សូមឲ្យប្រកបដោយព្រះពរ ខ្ញុំទទួលបានវាហើយ។" ទេ អ្នកទើបតែចាប់ផ្ដើមពីកន្លែងដែលអ្នកអាចនឹងលូតលាស់ឡើង។ អ្នកមិនទាន់បានធ្វើអ្វីនៅឡើយទេ។ ឃើញទេ? ការតែមួយដែលអ្នកបានធ្វើនោះគឺបានចាប់ផ្ដើមគ្រឹះរបស់អ្នក។

133 ឥឡូវអ្នកនឹងត្រូវធ្វើផ្ទះ ហើយអ្នកចាក់គ្រឹះដោយបាននិយាយថា "ក្មេងប្រុសអើយ ខ្ញុំបាននាងហើយ។" ឃើញទេ? អ្នកមានគ្រឹះរបស់អ្នកដើម្បីធ្វើផ្ទះនៅពីលើ។ ឥឡូវអ្នកត្រូវធ្វើផ្ទះ។

134 ឥឡូវនេះជាកន្លែងដែលអ្វីៗបានមក នៅពេលព្រឹកនេះ ហើយយើងនឹងនិយាយពីវានៅពេលឥឡូវនេះ។ ត្រូវហើយ។ ធ្វើផ្ទះ គ្រឹះគឺជាទីមួយ។ តើអ្វីគឺជាគ្រឹះរបស់គ្រីស្ទាន? គឺជាសេចក្ដីជំនឿទៅលើព្រះបន្ទូលរបស់ព្រះ។ នេះហើយគឺជាគ្រឹះ

របស់អ្នក។ ហើយអ្នកនឹងបានលូតលាស់ឡើង។ រួចហើយអ្នកនឹងបានចាប់ផ្ដើម ហើយក៏បានបន្ថែមទៅលើគ្រឹះមួយនេះ។

135 ឥឡូវធ្វើផ្ទះ អ្នកត្រូវដាក់អ្វីៗផ្សេងទាំងអស់ចូល។ បងប្រុស រ៉ូត ហើយនឹងជាងឈើ និងជាងសំណង់មួយចំនួននៅទីនេះអាចប្រាប់ យើងអំពីការសាងសង់ផ្ទះបាន។ ឃើញទេ? ប៉ុន្តែខ្ញុំនឹងប្រាប់អ្នកពីរបៀបសាងសង់ផ្ទះខាងព្រលឹងវិញ្ញាណជាកន្លែងដែលព្រះអាចគង់នៅបាន។ ទ្រង់ចង់គង់នៅក្នុងអ្នក។ ទ្រង់ចង់ឲ្យអ្នកបានដូចជាទ្រង់។ ទ្រង់ចង់ឲ្យអ្នកអាចឆ្លុះបញ្ចាំង គឺឆ្លុះបញ្ចាំងអំពីរូបអង្គទ្រង់។

136 អ្នកដឹងទេកាលពីសម័យដើម នៅពេលដែលគេធ្វើមាស គឺមិនទាន់មានប្រដាប់រំលាយនៅឡើយគេបានយកមាសទៅដំ គេដំមាសចេញ ដំដែក ស្ពាន់ និងរបស់អ្វីៗផ្សេងទៀត។ គឺថាដំហើយដំទៀត ត្រលប់វាទៅម្ខាងហើយដំវាទៀត។ ជនជាតិឥណ្ឌានៅតែធ្វើវារហូតដល់ឥឡូវនេះ គឺគេនៅតែដំ។ តើអ្នកដឹងទេថាគេប្រាប់ថាមួយណាជាដែកបាននៅក្នុងលោហៈធាតុទាំងនោះ ហើយនិងភក់លោហៈ និងរបស់ផ្សេងៗ កម្ទេចធ្លាក់ចេញពីវា? នៅពេលដែលម្នាក់ដែលអ្នកដំអាចមើលឃើញរូបរបស់គាត់ គឺដូចជាមើលនៅក្នុងកញ្ចក់។ គឺវាស្អាត ហើយថ្លាដល់អ្នកដំអាចមើលរូបខ្លួនឯងឃើញ។

137 នេះគឺជាអ្វីដែលព្រះទ្រង់បានធ្វើ។ ទ្រង់បានយកមាសដែលទ្រង់បានរកឃើញនៅលើផែនដី ហើយទ្រង់បានដំវាដោយព្រះវិញ្ញាណបរិសុទ្ធ ប្រែវាចុះឡើង ចុះឡើង និងដំរហូតទាល់តែ (ទ្រង់ទទួលបាន) ទ្រង់អាចទតឃើញរូបអង្គទ្រង់។ [បងប្រុសប្រានហាំបានទះដៃរបស់គាត់ជាច្រើនដងពេលនិយាយល្បះនេះ—Ed។]

138 ហើយនេះគឺអ្វីដែលយើងគួរតែធ្វើ គឺត្រូវឆ្លុះបញ្ចាំងពីព្រះរាជបុត្រារបស់ព្រះ។ ហើយឥឡូវគឺយើងត្រូវតែធ្វើការងាររបស់ទ្រង់។ ទ្រង់មានបន្ទូលថា "អ្នកដែលជឿដល់ខ្ញុំ..." យ៉ូហានជំពូកទី១៤:៧ "អស់អ្នកណាដែរជឿដល់ខ្ញុំ ការអ្វីដែលខ្ញុំធ្វើនោះគាត់នឹងធ្វើដែរ។" គឺអ្នកកំពុងតែចាប់ផ្តើមឆ្លុះបញ្ចាំងពីការងាររបស់ព្រះគ្រីស្ទ។

139 ប៉ុន្តែមានពួកយើងជាច្រើនដែលបានព្យាយាម ធ្វើការងាររបស់ព្រះគ្រីស្ទមុនពេលដែលមានការឆ្លុះបញ្ចាំងរបស់ព្រះគ្រីស្ទនៅក្នុងរូបយើង។ ឥឡូវនេះហើយគឺជាបញ្ហា។ យើងបានរកឃើញថាមានរឿងដូច្នេះកើតឡើង។ អ្នកដឹងរឿងនេះ។ ខ្ញុំដឹងរឿងនេះ។ យើងឃើញការជំពប់ដើងនៅតាមផ្លូវ។ យើងរកឃើញកំទេចកំទី

ដែលគរជាដុំរបស់អ្នកដឹកនាំ របស់គ្រីស្ទាន គរពីលើគ្នានៅតាមផ្លូវ នេះគឺពីព្រោះគេមិនធ្វើវាឲ្យបានត្រឹមត្រូវ។

140 នេះហើយគឺជាហេតុដែលខ្ញុំនៅទីនេះព្រឹកនេះ គឺដើម្បីបង្រៀនដល់ក្រុមជំនុំដ៏តូចមួយនេះ ហើយនឹងរូបខ្ញុំផ្ទាល់ ថាតើយើងអាចនឹងក្លាយជាទីសំណាក់របស់ព្រះដ៏មានព្រះជន្មរស់បានជាយ៉ាងណា។ តើមានប៉ុន្មានអ្នកចង់បានដូចជាយ៉ាងនោះ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] ជាសំណាក់របស់ព្រះដ៏មានព្រះជន្មរស់!

141 ឥឡូវនេះគឺជាអ្វីដែលយើងធ្វើ។ តើទីមួយគឺជាអ្វី? មានសេចក្ដីជំនឿ ហើយត្រូវកើតជាថ្មី។ នេះគឺជាការចាក់គ្រឹះ។

142 រួចបន្ទាប់ពីយើងចាក់គ្រឹះហើយ ទីពីរគឺអ្នកបន្ថែមពីលើគ្រឹះរបស់អ្នក។ "បន្ថែមពីលើជំនឿរបស់អ្នក។" ពេត្រុសនិយាយនៅទីនេះ។ បន្ថែមពីលើ...ទីមួយគឺអ្នកមានសេចក្ដីជំនឿ ហើយអ្នកត្រូវបន្ថែមសេចក្ដីទៀងត្រង់ទៅលើសេចក្ដីជំនឿរបស់អ្នក។ នេះគឺជាក្រឡានមួយទៀត។ ទីមួយគឺត្រូវចាក់គ្រឹះរបស់អ្នក គឺសេចក្ដីជំនឿ។ រួចសំរាប់សេចក្ដីជំនឿរបស់អ្នកបន្ថែមសេចក្ដីទៀងត្រង់។

143 ឥឡូវ នៅទីនោះមានពួកយើងជាច្រើនត្រូវបានចាញ់។ បាទ អ្នកទាំងអស់គ្នា បាទ "បន្ថែមសេចក្ដីទៀងត្រង់ដល់សេចក្ដីជំនឿរបស់អ្នក។" វាមិនត្រឹមតែមានន័យថារស់នៅក្នុងជីវិតដ៏បរិសុទ្ធប៉ុណ្ណឹងទេ អ្នកដឹងដូចជាបុរស ឬក៏ស្ត្រី និងអ្វីផ្សេងទៀត។ វាគឺមិនមានអ្វីដែលត្រូវធ្វើជាមួយវានោះទេ។

144 ព្រះគម្ពីរបានសំដែង ហើយយើងបានអាននៅក្នុងកាន់គម្ពីរលូកា ដែលបានសំដែងថា "សេចក្ដីទៀងត្រង់បានចេញពីទ្រង់។" ត្រូវទេ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] បើសិនជាយើងនឹងត្រូវដូចជាទ្រង់ គឺយើងត្រូវមានសេចក្ដីទៀងត្រង់។ យើងត្រូវមានសេចក្ដីទៀងត្រង់ឲ្យដូចទ្រង់។ គឺជាចំរៀងទីមួយដែលខ្ញុំបានស្រឡាញ់ ដែលជាបទទំនុកដំកើង ជាបទមួយដ៏អស្ចារ្យគឺ *ឲ្យបានដូចព្រះយេស៊ូវ។* ពិតណាស់បើខ្ញុំនឹងបានដូចជាព្រះយេស៊ូវ ខ្ញុំត្រូវមានសេចក្ដីទៀងត្រង់ ហើយនឹងការបន្ដ ដែលអាចបន្ដពីខ្ញុំទៅដល់មនុស្សដទៃ។ ពីព្រោះ "សេចក្ដីទៀងត្រង់បានចេញពីទ្រង់ទៅដល់មនុស្សទាំងឡាយ។" សេចក្ដីទៀងត្រង់! ហើយមុនពេលដែលអ្នកអាចឲ្យវាចេញបាន ទាល់តែអ្នកមានវាជាមុនសិន។ បើអ្នកមិនទានមានវា នោះវាមិនអាចចេញមកបានទេ។ វាគ្មានអ្វីសំរាប់ចេញមកនោះទេ។

145 តើនឹងមានអ្វីកើតឡើងបើមានអ្នកខ្លះចង់ទាញសេចក្តីទៀងត្រង់ចេញពីយើង ហើយលទ្ធផលគឺ "រកឃើញភាពមិនគ្រប់គ្រាន់"? ឃើញទេ? ទេ ទេ គ្មានអ្វីសំរាប់ដកនោះទេ។ មានអ្នកណាម្នាក់មើលមកយើងក្នុងភាពជាគ្រីស្ទាន ហើយនៅថ្ងៃស្អែកបានឃើញនៅទីនោះដូចជាអ្នកមានបាប គឺថាគ្មានសេចក្តីទៀងត្រង់គ្រប់គ្រាន់សំរាប់ដកបានទេ។ ឃើញទេ? ត្រឹមត្រូវ។

146 សេចក្តីទៀងត្រង់ត្រូវតែនៅក្នុងយើង។ រហូតដល់ពេលដែលយើងមានភាពទៀងត្រង់...រួចនៅពេលដែលយើងមានសេចក្តីទៀងត្រង់ពិត យើងអាចបន្ថែមវានៅក្នុងសេចក្តីជំនឿរបស់យើង។ នេះគឺជាជញ្ជាំងមួយទៀតនៃគ្រឹះ។ ឥឡូវទីមួយអ្នកត្រូវមានសេចក្តីជំនឿ។ សេចក្តីជំនឿតែមួយនឹងមិនអាចធ្វើវាបានទេ។ អ្នកមាន...ពេត្រុសនិយាយថា "រួចហើយត្រូវបន្ថែមសេចក្តីទៀងត្រង់ទៅលើសេចក្តីជំនឿរបសអ្នក។" អ្នកត្រូវតែមានសេចក្តីទៀងត្រង់ ដើម្បីបន្ថែមវាទៅលើសេចក្តីជំនឿរបស់អ្នក។

147 ឥឡូវ រួចវាប្រហែលជាហេតុដែលអ្នកមិនមានវាពីព្រោះមានក្រុមជំនុំជាច្រើនបានបង្រៀនអ្នកថាមិនចាំបាច់មានវាក៏បាន ឬក៏ថាថ្ងៃរបស់វាបានកន្លងផុតទៅហើយ។ "ពួកគេមិនចាំបាច់មានវានោះទេ។ ការអ្វីដែលអ្នកគួរធ្វើនោះគឺត្រូវចូលព្រះវិហារ។ មែនហើយថ្ងៃទាំងនោះបានកន្លងផុតហើយ។"

148 សេចក្តីទៀងត្រង់ តើមានអ្នកយល់ទេថាតើពាក្យថាសេចក្តីទៀងត្រង់មានន័យថាម៉េចមើលហើយយើងត្រូវតែមានវា។ បើសេចក្តីទៀងត្រង់បានចេញពីទ្រង់ហើយបានព្យាបាលស្ត្រីដែលមានជម្ងឺនោះ គឺទ្រង់ត្រូវការឲ្យមានសេចក្តីទៀងត្រង់ដូចគ្នានោះដែរសំរាប់ក្រុមជំនុំរបស់ទ្រង់ ពីព្រោះទ្រង់គឺជាគំរូរបស់យើង។ ហើយដែលទ្រង់មានសេចក្តីទៀងត្រង់ ឲ្យទៅមនុស្សទាំងឡាយ ទ្រង់ក៏រំពឹងថាយើងនឹងមានសេចក្តីទៀងត្រង់ ឲ្យទៅមនុស្សទាំងឡាយផងដែរ។ ហើយតើអ្វីទៅដែលហៅសេចក្តីទៀងត្រង់? សេចក្តីទៀងត្រង់គឺជា កំលាំង ឬអំណាច។

149 មានពួកគេមួយចំនួនមិនជឿលើព្រះចេស្តារបស់ព្រះ។ ពួកគេនិយាយថា "វា—វា—វា កន្លងផុតទៅហើយ។ រឿងដែលអ្នកត្រូវធ្វើ នោះគឺធ្វើយ៉ាងណាឲ្យតែអ្នកមានឈ្មោះនៅក្នុងសៀវភៅជីវិតទៅបានហើយ រួចមកត្រូវផ្លាស់ប្តូរ ចាក់ប្រេងតាំង ឬជ្រមុជទឹក ឬរឿងអ្វីផ្សេងទៀត។ ហើយនេះគឺជាអ្វីដែលអ្នកត្រូវធ្វើ។"

150 ប៉ុន្តែនៅទីនេះ ពេត្រុសបាននិយាយថា "បន្ថែមសេចក្តីទៀងត្រង់" ឥឡូវពេត្រុសកំពុងតែនិយាយពីការសាងសង់សំណាក់របស់ព្រះឃើញទេ គឺជាព្រះវិហាររបស់ព្រះ ហើយបានធ្វើវាឲ្យក្លាយទៅជាកន្លែងមួយ។ ហើយបន្ទាប់ពីអ្នកមានសេចក្តីទៀងត្រង់អ្នកត្រូវមាន...បន្ទាប់ពីអ្នកមានសេចក្តីជំនឿ អ្នកត្រូវមានសេចក្តី ទៀងត្រង់ជាមួយវា។ ត្រូវហើយ។ ត្រូវមានសេចក្តីទៀងត្រង់សំរាប់ពិភពលោកទាំងមូល។

151 ខ្ញុំបានអធិប្បាយព្រះបន្ទូលកាលពីម្ភៃឆ្នាំមុន ខ្ញុំគិតថានៅក្នុងវិវរណៈ។ លោកគ្រូលីលី។ លីលីគឺជាគ្រូគង្វាល។ បានដកស្រង់ពីអត្ថបទដែលព្រះយេស៊ូវបានមានបន្ទូលកថា "ចូរពិចារណាអំពីផ្កាឈូក គឺពីការដែលវារីក និងស្រពោន។ ប៉ុន្តែខ្ញុំសូមប្រាប់អ្នករាល់គ្នាថា ឯហ្លួងសាឡូម៉ូនក៏មិនបានតែងអង្គឲ្យដូចផ្កានោះដែរ។"

152 ចូរក្រលេកមើលទៅឯផ្កាព្រលឹត។ គឺវាបានដុះមកពីក្នុងលាមកសត្វ។ ហើយនៅគ្រប់នាទីទាំងអស់គឺវាបានដុះនៅលើផែនដី។ ឃើញទេ? ហើយតើវាបានធ្វើអ្វីជាមួយនឹងសេចក្តីទៀងត្រង់ដែលវាបានដុះមក? វាបានបញ្ចេញការនោះមកវិញ។ វាបានបង្កើតឲ្យមានការគយគន់ដ៏ល្អ និងការកោតសសើរ។ វាបានបើកសំបករបស់វាឡើងដើម្បីឲ្យទឹកឃ្មុំ សំរាប់ឃ្មុំឲ្យមកទទួលចំណែករបស់វា។ កុំរអ៊ូឡើយ។ គឺថាវាមានការទាំងនោះដើម្បីឲ្យត្រលប់ទៅវិញ។ តើនឹងមានរឿងអ្វីកើតឡើងបើឃ្មុំបានមកហើយគ្មានទឹកឃ្មុំសម្រាប់ក្រេប? ឃ្មុំតូចនោះនឹងគ្រវីក្បាលរបស់វាហើយនិយាយថា "តើនេះគឺជាផ្កាព្រលឹតយ៉ាងម៉េចនឹង?"

153 បើមានមនុស្សណាម្នាក់បានមក ដើម្បីឲ្យទទួលបានសេចក្តីសង្គ្រោះ ហើយបានមកឯព្រះវិហារមួយដែរជឿថាថ្ងៃការអស្ចារ្យបានកន្លងផុតទៅហើយ?

154 ដូចដែលជេកខូបាននិយាយថា។ បានចូលទីក្នុងហាងអាហារមួយដែលមានមីនុយយ៉ាងធំ ហើយដ៏ចាប់ផ្តើមអានវា ឆ្អឹងជំនីប្រលាក់ ហើយមុខម្ហូបផ្សេងទៀត។ និយាយថា "ខ្ញុំនឹងយក ឆ្អឹងជំនីប្រលាក់។"

"បាទ មុខម្ហូបគឺសំរាប់ថ្ងៃកន្លងទៅទេ។ ហើយយើងមិនមានវានេះទៀតទេ។"

155 ហើយក៏បានដាក់មីនុយចុះ រួចក៏ដើរចេញទៅ ឃើញទេ វាត្រូវណាស់ ពីព្រោះនៅទីនោះមិនមានអ្វីសំរាប់ហូបទេ។ ដូច្នេះអ្នកគួរតែទៅហាង អាហារណាដែលមានអាហារសំរាប់ហូប។

156 ហើយមនុស្សខាងឯព្រះវិញ្ញាណក៏ត្រូវការអ្វីសំរាប់ហូបដែរ។ នោះគឺជាព្រះបន្ទូលរបស់ព្រះ។ ខ្ញុំជឿថាគ្រប់ទាំងព្រះបន្ទូលទាំងអស់។

ព្រះទ្រង់មានតុអាហារជាកន្លែងដែលពួកបរិសុទ្ធរបស់ទ្រង់
ត្រូវបានចំអែត
ទ្រង់បានអញ្ជើញអស់អ្នកដែលទ្រង់បានជ្រើសរើស "ចូរមក
បរិភោគ។"
ជាមួយនឹងនំម៉ាណារបស់ទ្រង់ គឺទ្រង់បានចំអែត ទ្រង់បាន
ផ្គត់ផ្គង់ គ្រប់ទាំងដំរូវការរបស់យើង
អូ ពិតជាល្អណាស់ ដែលបានបរិភោគជាមួយព្រះយេស៊ូវ
គ្រប់ពេល។

157 ត្រូវហើយ។ បាទលោក។ គាត់ទទួលបានវាហើយ។ ក្រុមជំនុំមាន ក្រុមជំនុំនៃព្រះដ៏មានព្រះជន្មគង់នៅ ដែលបានត្រូវបង្កើតមកជារូបអង្គដ៏គ្រប់លក្ខណ៍របស់ទ្រង់ តាមរយៈព្រះដំរិះរបស់ព្រះគ្រីស្ទ។ ឥឡូវ ឥឡូវអ្នកត្រូវមានសេចក្តីទៀងត្រង់។

158 ខ្ញុំនិយាយទៀតថា ជារឿងទីមួយដែលអ្នកដឹង គឺថាមានអ្នកខ្លះចូលចិត្តភាពមានកេរ្តិ៍ឈ្មោះ។ គាត់មិនមែនជាមនុស្សកំណាញ់នោះទេ។ គាត់មានកេរ្តិ៍ឈ្មោះ។ មុនពេលដែលគាត់អាចបង្ហាញកេរ្តិ៍ឈ្មោះរបស់គាត់គឺថាគាត់ត្រូវតែមានវាជាមុនសិន។ មុនពេលដែលគាត់អាចឲ្យទឹកឃ្មុំបានគាត់ត្រូវតែមានទឹកឃ្មុំជាមុនសិន។ មុនពេលដែលគាត់គាត់បង្ហាញសម្រស់គឺគាត់ត្រូវតែមានវាជាមុនសិន។

159 មុនពេលដែលអ្នកអាចផ្តល់សេចក្តីទៀងត្រង់អ្នកត្រូវតែមានវាសិន។ ដូច្នេះត្រូវបន្ថែមទៅលើសេចក្តីជំនឿរបស់អ្នកនូវសេចក្តីទៀងត្រង់។។ អាម៉ែន។ យល់ឬទេ? យើងអាចនៅជាមួយនឹងការនោះបានជាយូរ ប៉ុន្តែពេលវេលារបស់យើងនឹងកន្លងផុតពីយើងទៅ។ ចូរបន្ថែមនូវសេចក្តីទៀងត្រង់ទៅ លើសេចក្តីជំនឿរបស់អ្នក។ ឥឡូវ ទីមួយគឺសេចក្តីជំនឿ រួចហើយសេចក្តីទៀងត្រង់។

160 ហើយទីបីអ្នកបន្ថែមដំរិះ។ ដំរិះ ឥឡូវនេះមិនមែនជាដំរិះរបស់លោកិយនេះទេ ពីព្រោះវាគឺជាសេចក្តីចំកួតដល់ព្រះវិញ តែគឺជាដំរិះដែលចេះវិនច្ឆ័យ(អ្វី?) ខុសមក

ត្រូវ។ រួចតើអ្នកយល់យ៉ាងណា នៅពេលដែលអ្នកមានដំរិះខាងគ្រីស្ទានជាមួយនឹងសេចក្តីទៀងត្រង់ និងសេចក្តីជំនឿរបស់អ្នក។ អ្នកនឹងកាត់សេចក្តីថាព្រះបន្ទូលត្រូវ ឬខុស។ ហើយបើយើងអាចទុកគោលជំនឿសាសនាទៅម្ខាង ហើយនឹងកាលដែលមិនជឿរបស់យើង គ្រប់ទាំងការទាំងអស់ដែលអ្នកប្រកាសថាអ្នកបានធ្វើ រួចអ្នកមានដំរិះអាចយល់ដឹងថាព្រះមិនអាចកុហកឡើយ។ "សូមឲ្យគ្រប់ទាំងពាក្យរបស់មនុស្សគឺជាការកុហក តែគ្រប់ទាំងពាក្យរបស់អញគឺជា ពាក្យពិតវិញ។" ឃើញទេ? ឥឡូវអ្នកបានទទួលដំរិះ។ គឺជាដំរិះដ៏អស្ចារ្យ។ អ្នកមិនចាំបាច់ទទួលបាន៤ឌីគ្រីពីសកលវិទ្យាល័យណាទេ ឬក៏ការអ្វីស្រដៀងនឹងនោះ ប៉ុន្តែសេចក្តីទៀងត្រង់ទាំងនេះ គឺព្រះបានប្រទានមកឲ្យអ្នកទាំងអស់គ្នា ហើយដាក់យើងនៅលើគ្រឹះ នៃសេចក្តីជំនឿរបស់អ្នក ដើម្បីឲ្យអ្នកបានក្លាយជាមនុស្សដែលរស់សំរាប់ព្រះដ៏ពិតប្រាកដ។ បាទលោក។

161 បន្ថែម បន្ថែមដំរិះ ពីព្រោះគឺជាដំរិះ នៃព្រះបន្ទូលទ្រង់។ អ្នកត្រូវតែជឿវាតាមមធ្យោបាយនេះ។ គឺថាអ្នកត្រូវតែជឿនៅថ្ងៃនេះថា...ហើយទទួលវា គឺថាថ្ងៃនៃការអស្ចារ្យមិនទាន់កន្លងផុតទេ។ ដំរិះដែល ព្រះមានបន្ទូល គឺព្រះអាចធ្វើបាន។

162 លោកអ័ប្រាហាំបានជឿការនោះ។ ហើយនៅពេលដែលគាត់មានអាយុមួយរយឆ្នាំទៅហើយ គឺគាត់មិនបានទេរ ទៅលើភាពដែលមិនជឿថាព្រះបន្ទូលសន្យារបស់ព្រះមិនអាចសម្រេចនោះទេ។ មើល ថាតើព្រះបន្ទូលនោះមានភាពមិនទំនងជាយ៉ាងណា? នេះគឺជាបុរសដែលមានអាយុមួយរយឆ្នាំទៅហើយ ហើយកំពុងតែរង់ចាំឲ្យមានកូនដែលនឹងកើតនៅក្នុងគ្រួសាររបស់គាត់ ជាមួយ និងស្ត្រីអាយុកៅសិបឆ្នាំ។ ឃើញទេ? ស្ទើរតែហាសិបឆ្នាំទៅហើយ ដែលគាត់បានរស់នៅជាមួយនាង គឺតាំងតែ—ពីនៅក្មេងមកម្ល៉េះ។ ហើយនៅពេលនេះ គាត់លែងមានចំណង់ផ្លូវភេទទៅហើយ។ ហើយផ្ទៃរបស់សារ៉ាក៏លែងដំណើរការទៅហើយដែរ។ ហើយគ្រប់ទាំងសេចក្តីសង្ឃឹមបានសាបសូន្យទៅហើយ គឺថាធ្លាប់មានសង្ឃឹមដែរ។ ប៉ុន្តែគាត់នៅតែមានសេចក្តីសង្ឃឹម គឺគាត់ជឿលើសេចក្តីសង្ឃឹម ពីព្រោះគាត់មានដំរិះថាព្រះទ្រង់រក្សាគ្រប់ទាំងបន្ទូលសន្យារបស់ទ្រង់ទាំងអស់។

163 ឥឡូវនៅពេលដែលអ្នកមានវាយ៉ាងដូច្នេះ រួចបន្ថែមទៅក្នុងសេចក្តីជំនឿរបស់អ្នក។ ពេលដែលមានសេចក្តីទៀងត្រង់ពិតត្រូវបន្ថែមវាទៅក្នុងសេចក្តីជំនឿរបស់អ្នក។ នៅពេលដែលអ្នកអាច ដើរនៅតាមផ្លូវរស់នៅ ដូចជាគ្រីស្ទានធ្វើដូចជា

គ្រីស្ទាន គឺជាឡគ្រីស្ទាន ចូរបន្ថែមការទាំងនោះទៅក្នុងសេចក្ដីចំនឿរបស់អ្នក។ នៅពេលដែលអ្នកមានដំរិះ...

164 អ្នកនិយាយថា "ខ្ញុំមិនដឹងទេថាព្រះបន្ទូល*នេះ* ត្រឹមត្រូវ ឬទេ។ ឥឡូវនេះគឺកិច្ចការ២:៣៨ ខ្ញុំមិនដឹងថាខ្ញុំគួរតែធ្វើយ៉ាងណាជាមួយនឹងព្រះគម្ពីរកិច្ចការ១៩:១៩។ ខ្ញុំមិនដឹង។" ត្រូវហើយ។ អ្នកកុំ—កុំបន្ថែមអ្វីទាំងអស់ពីព្រោះអ្នកមិនទាន់ទទួលបានវានៅឡើយ។ ឃើញទេ? តើអ្នកនឹងត្រូវធ្វើអ្វី? ពីព្រោះអ្នកមិនទាន់មានដំរិះគ្រប់គ្រាន់ដើម្បីឲ្យបានស្គាល់ព្រះ តែគឺថាព្រះគម្ពីមិនដែលប្រឆាំងនឹងខ្លួនឯងទេ។ សូមទុកវាឲ្យនៅមួយកន្លែង។ សូមកុំនិយាយអ្វីទៀតអំពីវា។ ឃើញទេ? ទុកវាឲ្យនៅមួយកន្លែង។

165 ប៉ុន្តែនៅពេលដែលអ្នកអាចមើលឃើញថា ព្រះគម្ពីរមិនដែលប្រឆាំងនឹងខ្លួនឯងទេ នោះអ្នកអាចនិយាយថា អ្នកអាចមើលឃើញដោយការបើកសំដែងរបស់ព្រះ គឺថាគ្រប់ទាំងព្រះបន្ទូលដែលតែងឡើង សុទ្ធតែជាអាថ៌កំបាំងទាំងអស់ គឺមានតែព្រះដំរិះរបស់ទ្រង់ទេដែលអាចបើកសំដែងបាន រួចហើយនៅពេលដែលអ្នកទទួលបានដោយនិយាយគ្រប់ទាំងព្រះបន្ទូលរបស់ព្រះថា "អាម៉ែន" បន្ទាប់មកបន្ថែមវាទៅក្នុងសេចក្ដីជំនឿរបស់អ្នក។

166 អូ អ្នកនឹងក្លាយទៅជាមនុស្សម្នាក់ដ៏ល្អហើយឥឡូវនេះ។ ឃើញទេ? អ្នកបានឡើងមកហើយ ឃើញទេ។ ជាមួយនឹងអ្វី? ជាមួយនឹងសេចក្ដីជំនឿ រួចជាមួយសេចក្ដីទៀងត្រង់ រួចមកជាមួយនឹងដំរិះ។ ចូរមើលថាតើវាបានបង្កើតបុរសនេះឡើងមក? យើងអាចឃើញថាគ្មាន—គ្មានផ្លូវណាដែលអាចគេចបានទេ។ នេះគឺជាផ្លូវដែលអាចក្លាយទៅជាដំណាងរូបអង្គព្រះគ្រីស្ទ។ បាទ ពិតមែនហើយ។

167 ដើម្បី វិនិច្ឆ័យឲ្យស្គាល់សេចក្ដីត្រឹមត្រូវ។ ឲ្យបានស្គាល់ការត្រូវ និងការខុស គឺដើម្បីឲ្យជឿព្រះបន្ទូលរបសប់ព្រះ។ ឲ្យបានស្គាល់ថាតើវាខុស ឬត្រូវ រឿងការបំរើគោលទិ ឬបំរើដល់ព្រះ។ វិនិច្ឆ័យឲ្យបានស្គាល់ថាតើវាខុសឬត្រូវ តើខ្ញុំត្រូវកើតជាថ្មី ឬខ្ញុំគ្រាន់តែចូលព្រះវិហារ។ រួចហើយអ្នកនឹងចាប់ផ្ដើម។ យល់ថាត្រូវនៅពេលដែលអ្នកអធិប្បាយនិយាយថា "ថ្ងៃនៃការអស្ចារ្យបានកន្លងផុតទៅហើយ។" ព្រះបន្ទូលបានសំដែងថា "ព្រះយេស៊ូវគ្រីស្ទនៅតែដដែលពីម្សិលមិញ ថ្ងៃនេះ និង ជារៀងរហូត។" ឥឡូវតើមួយណាដែលអ្នកនឹងជឿ?

168 ពេលអ្នកនិយាយថា "ខ្ញុំនឹងយកព្រះ។" ឥឡូវអ្នកមិនមែននិយាយដើម្បីតែនិយាយនោះទេ "ខ្ញុំ—ខ្ញុំយកទ្រង់" គឺវាមកអំពីចិត្តរបស់អ្នក។ ប៉ុន្តែអ្វីដែលនៅក្នុងអ្នករុញច្រានឲ្យចេញមក។ អ្នកដល់ចំនុចនោះហើយ។ សេចក្តីជំនឿរបស់អ្នកនិយាយថា "ខ្ញុំដឹងថាទ្រង់នៅតែដដែល។ អាម៉ែន ខ្ញុំធ្វើទីបន្ទាល់ថាទ្រង់នៅតែដដែល។ គ្មានអ្វីដែលអាចយកវាពីខ្ញុំបានទេ។ ខ្ញុំដឹងថាទ្រង់មានពិត។" អាម៉ែន។ រួចចូរបន្ថែមទៅក្នុងសេចក្តីជំនឿរបស់អ្នក។ ចូរដាក់វានៅលើគ្រឹះរបស់អ្នក។ ចូរឡើងមកឥឡូវ ឡើងមកឯនគរឋានសួគ៌របស់ព្រះ។ ឥឡូវមានចំនុចមួយហើយ។ ត្រូវហើយ។

169 ឥឡូវរឿងបន្ទាប់ អ្នកអធិប្បាយនឹងប្រាប់អ្នក ហើយមានមនុស្សជាច្រើននិយាយថា "គឺ...ការទាំងនេះដែរអ្នកបានអាននៅក្នុងព្រះគម្ពីរ គឺវាសំរាប់ថ្ងៃក្រោយនោះទេ។ ឥឡូវខ្ញុំនឹងប្រាប់ថាតើហេតុអ្វី។ ពីព្រោះយើងមិនត្រូវការការទាំងនោះនៅថ្ងៃនេះទេ។ យើងមិនត្រូវការវាទេ។ ឃើញទេ? យើងមិនគួរទេ។ យើងមិនគួរអនុវត្តការទាំងនោះទេគឺការព្យាបាលដែលមកពីព្រះ។ យើងមិនអនុវត្តការនិយាយភាសាដទៃនៅក្នុងក្រុមជំនុំដើម្បីឲ្យក្រុមជំនុំយើងដើរ—តាមផ្លូវត្រង់នោះទេ។ ហើយយើងមិនធ្វើយ៉ាងដូច*នេះ*ទេ។"

170 យើងនឹងទៅដល់ចំនុចនោះ។ ខ្ញុំមានបទគម្ពីរដែលនិយាយអំពីរឿងនោះនៅទីនេះ ឃើញទេ គឺថាតើយើងគួរតែធ្វើហើយ ឬនៅឥឡូវនេះ។

171 ប៉ុន្តែគាត់បាននិយាយយ៉ាងដូច្នេះថា "ខ្ញុំមិនដឹងទេ។ យើងមិនគួរធ្វើវានៅថ្ងៃនេះនោះទេ។ រឿងតែមួយដែលខ្ញុំគិតថាយើងគួរតែធ្វើនោះគឺធ្វើយ៉ាងណាយើងត្រូវនិយាយពាក្យឲ្យសមរម្យទៅដល់ពួកជំនុំ។ យើងគួរតែទៅឲ្យពេទ្យវិកលចរិតធ្វើតេសខួរក្បាលយើង ដើម្បីឲ្យយើងដឹងថាតើយើងអាចនឹងបង្ហាញខ្លួន ឬតើកំរិតចេះដឹងនៃគំនិតរបស់យើងខ្ពស់អាចធ្វើវាបាន ឬអត់ ហើយ—និងរឿងផ្សេងៗដូចការទាំងនោះ។ ខ្ញុំគិតថា...ហើយយើងមានពួកជំនុំដ៏ច្រើនបំផុត។ យើងបានបង្កើតអង្គការរបស់យើង។"

172 យើងមិនមែនបង្កើតអង្គការនោះទេ។ ខ្ញុំមិនមែននៅទីនេះនៅ ព្រឹកនេះដើម្បីបង្កើតអង្គការនោះទេ។ ព្រះមិនបានបញ្ជូនខ្ញុំមកឲ្យបង្កើតអង្គការទេ។ ព្រះគ្រីស្ទបានបញ្ជូនខ្ញុំឲ្យមក បង្កើតឲ្យធ្វើឲ្យគ្រប់គ្នាម្នាក់ៗ បានត្រលប់ដូចជារូបអង្គព្រះយេស៊ូវគ្រីស្ទ ដែលគេអាចនឹងជាទីសំណាក់ដ៏មានអំណាចចេស្តា និងជាកន្លែង

ស្នាក់របស់ព្រះវិញ្ញាណបរិសុទ្ធ ដោយសារព្រះបន្ទូលទ្រង់។ ដោយសារព្រះបន្ទូល ឃើញទេ កសាងបុគ្គលទៅកាន់កន្លែងនោះ។ មិនមែនបង្កើតអង្គការដើម្បីភាពអស្ចារ្យរបស់និកាយទេ ប៉ុន្តែគឺធ្វើឲ្យគ្រប់គ្នាបានក្លាយជាកូនប្រុសស្រីរបស់ព្រះ។ នេះគឺគំនិតរបស់យើង។ ឃើញទេ? ហើយថែមសេចក្ដីទៀងត្រង់ពីលើសេចក្ដីជំនឿរបស់យើង និងថែមដំរិះពីលើសេចក្ដីទៀងត្រង់ផងរបស់យើង។ ឥឡូវអ្នកបានមកដល់កន្លែងមួយហើយ។

173 ឥឡូវនៅពេលដែលអ្នកចាប់ផ្ដើមនិយាយ "គឺខ្ញុំមិនចាំបាច់ទទួលការនោះនៅថ្ងៃនេះទេ..." អ្នកត្រូវតែ គឺវាត្រូវតែ។

174 ព្រះគម្ពីរមិនអាចកុហកបានទេ។ "ហើយព្រះគម្ពីមិនមានការបកស្រាយឯកជនណាមួយនោះទេ"។ អ្នកគ្រាន់តែជឿទៅតាមអ្វីដែលបានចែងនៅក្នុងព្រះគម្ពីរនោះទៅបានហើយ។ ឃើញទេ? អ្នកត្រូវតែមានសេចក្ដីទាំងនេះនៅក្នុងចិត្ត។ ហើយមធ្យោបាយតែមួយដែឬអ្នកមានវា គឺត្រូវតែមានដំរិះដែលកើតពីឋានសួគ៌មក។ ហើយដំរិះដែលកើតពីឋានសួគ៌មកនឹងបង្ហាញថាគ្មានអ្វីខុសឆ្គងនៅក្នុងព្រះបន្ទូលនោះទេ។ ឃើញទេ?

175 អ្នកត្រូវតែជឿ មិនមែនធ្វើជាជឿទេ។ គ្មានអ្វីមួយនៅក្នុងនេះជារឿងដែលធ្វើជាជឿនោះទេ ឃើញទេ បើអ្នកព្យាយាមនិយាយថា "ខ្ញុំបានទទួលវាហើយ។" កុំឲ្យដូចជាបក្សីខ្មៅដែលពាក់រោមក្ងោកនោះឡើយ ឃើញទេ ពីព្រោះរោមទាំងនោះនឹងត្រូវជ្រុះទៅវិញ។ វាមិនមែនដុះមកដោយធម្មជាតិនោះទេ។ គឺវាគ្រាន់តែបិតពីលើប៉ុណ្ណោះ។

176 ខ្ញុំគិតពីអ្វីដែលស្ដេចដាវីឌបានមានបន្ទូលនៅក្នុងទំនុកដំកើងជំពូក ទី១ "គាត់នឹងបានដូចជាដើមឈើដែលដុះនៅតាមមាត់ទឹក។" អ្នកដឹងទេការដែលដាំនិងការដែលដាក់ចុះ ឬបិតគឺវាមានភាពខុសប្លែកពីគ្នា។ ដូចជាដើមសែន ដែលវាត្រូវបានគេដាំចុះ ទោះជាមានខ្យល់ជាខ្លាំងក៏ដោយក៏ដើមនោះនៅតែឈរយ៉ាងមាំ។ រីឯឈើដ៏តូចមួយដែលនៅទីនេះវិញអ្នកនឹងមិនបានដឹងថានឹងមានអ្វីកើតឡើងលើវានោះទេ។ វាគ្មានឫស្ស។ វាគ្មានគ្រឹះទេ។ ឃើញទេ?

177 ដូចជាអ្នកខ្លះបានមកពីសិក្ខាសាលា ឬអ្វីមួយ ឃើញទេ។ ឥតមាន..."លោកបណ្ឌិត*នេះ-ឬ-នោះ*បានតែងតាំងខ្ញុំឲ្យនៅក្នុងព័ន្ធកិច្ចនេះ។" កុំធ្វើឲ្យវាខុសគ្នាពីអ្វីដែលមានស្រាប់។

178 ព្រះគ្រីស្ទបានបង្កើតអ្នកឲ្យនៅក្នុងវា ឃើញទេ គឺដោយសារសេចក្តីជំនឿរបស់អ្នក។ ឃើញទេ? អ្នកត្រូវបានបង្កើតសារជាថ្មី ហើយបានកើតឡើងនៅក្នុងនោះ។ ហើយបន្ទាប់ពីអ្នកបានកើតមកក្នុងវា ហើយនេះគឺកាលដែលព្រះទ្រង់សព្វព្រះទ័យឲ្យអ្នកបន្ថែមទៅលើវា។ គឺគ្រាន់តែបន្តបន្ថែមវាទៀត។ ឥឡូវយើងនឹងចុះទៅក្រោមមួយបន្ទាត់ទៀត។

179 ឥឡូវនឹងមានអ្វីមួយទៀតពីលើដំរិះ យើងអាចនឹងនិយាយអំពីដំរិះខាងឯព្រះ។ ឃើញទេ? "តើព្រះគម្ពីរនៅសម័យនេះបានបាត់បង់នូវអត្ថន័យដើមហើយ ឬនៅ?" ឃើញទេ ពួកគេ មានមនុស្សជាច្រើនប្រាប់អ្នកថា ព្រះគម្ពីរមិនបានមានន័យយ៉ាងដូច្នេះទេ។ បើព្រះបានទតមើលខ្ញុំ ហើយបានណែនាំខ្ញុំនៅពេលដែលខ្ញុំបានធ្វើខុស ហើយបើសិនខ្ញុំគឺជាកូនរបស់ព្រះ ទ្រង់នឹងធ្វើយ៉ាងដូចនេះ។ ទ្រង់បានធ្វើដល់យើងយ៉ាងដូច្នេះ គឺជាបុត្រា និង [គ្មានសំឡេងនៅក្នុងកាសែត—Ed។] បុត្រី។ នៅពេលដែលអ្នកបានធ្វើអ្វីខុសទ្រង់បានណែនាំអ្នក។ ហើយដែលទ្រង់បានយកព្រះទ័យទុកដាក់នឹងដល់ម្ល៉េះ ដែលទ្រង់ត្រូវទតមើលយើង ហើយត្រូវណែនាំយើង ចុះតើទ្រង់នឹងថែរក្សានូវព្រះបន្ទូលរបស់ជាងអំបាលម៉ានទៅទៀត តើមួយណាជាគំរូរបស់យើង ហើយមួយណាគឺជារូបអង្គទ្រង់!

> *កាលពីដើមដំបូងឡើយមានព្រះបន្ទូល ហើយព្រះបន្ទូលគង់នៅជាមួយ ព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។*
>
> *ហើយ...បានបង្កើតសាច់ឈាមមក ហើយបាននៅជាមួយយើង...*

180 ព្រះបន្ទូលគឺជាការបើកបង្ហាញនៃព្រះយេស៊ូវគ្រីស្ទ ព្រះគម្ពីរបានសំដែងយ៉ាងដូច្នេះថា ព្រះគ្រីស្ទទ្រង់បានសំដែងរូបអង្គទ្រង់ដោយព្រះបន្ទូល។ ហើយនៅពេលដែលទ្រង់បានទតមើលយើង នៅពេលដែលអ្នកបានធ្វើខុសទៅនឹងក្រឹត្យវិន័យហើយទ្រង់បានដាក់ទោសអ្នកចំពោះរឿងនេះចុះតើទ្រង់នឹងទតមើល ហើយថែរក្សាក្រឹត្យវិន័យទ្រង់ជាងអំបាលម៉ានទៅទៀត! អាម៉ែន

181 បន្តទៀតចុះក្មេងប្រុស សូមកុំប្រាប់ខ្ញុំពីរឿងនេះ!

182 ខ្ញុំជឿទៅលើព្រះដំរិះនៃព្រះវិញ្ញាណបរិសុទ្ធ។ ព្រះដំរិះនៃព្រះវិញ្ញាណបរិសុទ្ធនឹងតែងតែបញ្ជាប់ព្រះបន្ទូលរបស់ព្រះដោយពាក្យថា "អាម៉ែន។" នៅពេលដែល

អ្នកទទួលបាននូវរឿងអ្វីមួយដែលផ្ទុយទៅនឹងព្រះគម្ពីរ ចូរអ្នកអង្គុយចុះហើយសិក្សាអំពីវា ហើយត្រូវអធិស្ឋានឲ្យបានខ្លាំងពីរឿងនេះ។ ហើយរឿងទីមួយដែលអ្នកដឹងនោះគឺថាព្រះវិញ្ញាណបរិសុទ្ធកំពុងតែយាងចូលមក។ មិនយូរប៉ុន្មានអ្នកនឹងបានឃើញថាវាចង់ជាប់គ្នា ហើយនោះអ្នកនឹងទទួលបានវា។ ឃើញទេ? នេះហើយគឺជាដំរិះ។

183 មានពួកគេខ្លះនិយាយថា "ឥឡូវព្រះបន្ទូលទ្រង់សំដែងថា ទ្រង់នៅតែដដែលតាំងពីម្សិលម៉ិញ ថ្ងៃនេះ ហើយនិងអស់កល្បជានិច្ច។"

184 ហើយក្រុមជំនុំបាននិយាយថា "នៅក្នុងរឿងមួយចំនួនទ្រង់នៅដដែល។" អូ! អូ! យើងមិនត្រូវបំបែកព្រះបន្ទូលអញ្ចឹងទេ។ ឃើញទេ? បាទ ទាំងអស់គ្នាអត់ទេ។ គឺទ្រង់នៅដដែល។ បាទ បាទ។

185 "ព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែលពីម្សិលមិញ ថ្ងៃនេះ ហើយនឹងអស់កល្បជានិច្ច។" គឺគ្មានអ្វីខុសនៅក្នុងទ្រង់ទេ។ ទ្រង់មានព្រះជន្មគង់នៅក្នុងពួកជំនុំរបស់ទ្រង់ហើយបានធ្វើការដូចដើម។ "នៅពេលបន្តិចទៀត" ដូចដែលខ្ញុំបានលើកមកបន្តិចមុននេះ "នៅពេលបន្តិចទៀត ពិភពលោកនឹងលែងបានឃើញខ្ញុំទៀត តែអ្នកនឹងបានឃើញខ្ញុំវិញ។" ដ្បិតទ្រង់បានមានបន្ទូលថា "ខ្ញុំនឹងនៅជាមួយអ្នក គឺនៅក្នុងអ្នករហូតដល់ចុងបំផុតកល្ប។" ម្តងទៀតទ្រង់មានបន្ទូលថា "ហើយកាលដែលខ្ញុំបានធ្វើអ្នករាល់គ្នាក៏នឹងធ្វើដែរ។" ម្តងទៀតទ្រង់មានបន្ទូលថា "ខ្ញុំនឹងជាគល់ ហើយអ្នកនឹងជាខ្នែង។" ដ្បិតដែលខ្នែងអាចរស់បាននោះគឺដោយសារតែគល់។ អ្វីដែលនៅក្នុងគល់បានត្រូវបានបញ្ចេញមកដោយសារខ្នែង។ សិរីរុងរឿង! រួច "ព្រះគ្រីស្ទទ្រង់នៅតែដដែលពីម្សិលម៉ិញ ថ្ងៃនេះ ហើយនឹងអស់កល្បជានិច្ច។" វាបង្កើតជីវិតនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អាម៉ែន។

186 ដំរិះ មិនមែនខាងលោកិយទេ (ហេតុផលរបស់វា)។ អ្វីទាំងអស់ដែលជាគំនិតខាងលោកិយ នោះគឺជាហេតុផលវិញ។ ឃើញទេ? ប៉ុន្តែសេចក្តីជំនឿគ្មានហេតុផលទេ។ ព្រះបានបង្ហាញឲ្យអ្នកបានឃើញអ្វីមួយ*ពិត—ពិត*ដែលនឹងកើតឡើង ដែរគ្រប់ទាំងអ្នកវិទ្យាសាស្ត្រអាចប្រាប់អ្នកត្រឹមតែថា "វាមិនទៀង វាក៏អាចនឹងមិនកើតឡើង។" ទោះអ្នកនឹងជឿវាជាយ៉ាងណាក៏ដោយ។ ឃើញទេ? បាទ អ្នកទាំងអស់គ្នា។ វាគ្មានហេតុផលទេ។ ព្រះគម្ពីរបានសំដែងថា "យើងបំបាត់មិនឲ្យមានហេតុផល។" យើងមិនត្រូវប្រើហេតុផលជាមួយនឹងសេចក្តីជំនឿនោះ

ទេ។ សេចក្ដីជំនឿគ្មានហេតុផលទេ។ សេចក្ដីជំនឿប្រព្រឹត្ត។ សេចក្ដីជំនឿប្រកាន់ខ្ជាប់។ សេចក្ដីជំនឿនៅតែបន្ត។ វាមិនអាចមានអ្នកណាយកទៅណាបានទេ។ ខ្ញុំមិនខ្វល់ថាអ្នកណានិយាយ*ពីនេះ ពីនោះ ឬអ្នកដទៃ*។ វានឹងមិនរង្គើសូម្បីតែបន្តិច។ វានឹងនៅទីនេះឯង គឺចាំ ចាំ ចាំ។ គ្មានអ្វីធ្វើឲ្យមានភាពខុសប្លែកទេ។ វានឹងនៅទីនោះ។

187 ព្រះបានប្រាប់ណូអេថា រឿងនេះនឹងត្រូវកើតឡើង។ គាត់បានជឿវា។ ឃើញទេ? ព្រះបានប្រាប់ម៉ូសេថា រឿងទាំងនេះនឹងត្រូវកើតឡើង។ គាត់បានជឿវា។ ព្រះបានប្រាប់ដល់សាវ័ករបស់ទ្រង់ថានឹង "មានរឿងមួយចំនួនកើតឡើង ចូរឲ្យទៅឯកន្លែងធ្វើបុណ្យរំលងហើយរង់ចាំ។" ពួកគេបាននៅទីនោះ។ បាទលោក។ ត្រូវហើយ។

188 ឥឡូវដំរិះ ឥឡូវមិនមែនដំរិះខាងលោកិយ៍ទេ ប៉ុន្តែគឺជាដំរិះនៃឋានសួគ៌វិញ។ ជាដំរិះនៃឋានសួគ៌ នៅពេលដែលព្រះអង្គ គឺជាប្រភពនៃគ្រប់ទាំងដំរិះទាំងអស់ ហើយព្រះអង្គគឺជាព្រះបន្ទូល រួចហើយនៅពេលដែលអ្នកមានដំរិះពីឋានសួគ៌ នោះអ្នកនឹងជឿលើព្រះបន្ទូល ហើយអ្នកនឹងមិនមានហេតុផលអ្វីទាំងអស់ ដោយព្រោះព្រះបន្ទូល។

189 ហើយករណីនេះដែលក្រុមជំនុំមាន ឬក៏ខ្ញុំបានជួប។ នៅពេលមួយមានបុរសម្នាក់បន្ទាប់បានឮហើយក៏ប្រាប់ខ្ញុំ។ និយាយថា ខ្ញុំបាននិយាយថា... "ពួកគេរកមិនឃើញថាមានអ្វីមិនត្រឹមត្រូវនោះទេ។" ហើយដូច្នេះពួកគេក៏ចាប់ផ្ដើម...

190 ខ្ញុំនិយាយថា "រួចបើគ្មានអ្វីខុសឆ្គងទេ ហេតុអ្វីក៏អ្នកមិនថយចេញពីក្រោយខ្នងខ្ញុំមក?" ឃើញទេ? ឃើញទេ? ហើយខ្ញុំក៏បានប្រាប់ពួកគេអំពីបទគម្ពីរមួយចំនួន។

191 គាត់និយាយថា មានមនុស្សធំម្នាក់ មានកាន់បារីនៅនឹងដៃ គាត់និយាយថា "លោក ប្រានហាំខ្ញុំគឺជាសិស្សសាលាព្រះគម្ពីរ។"

ខ្ញុំនិយាយថា "ខ្ញុំរីករាយណាស់ដែលឮយ៉ាងដូច្នេះ។"

192 គាត់និយាយថា "ឥឡូវខ្ញុំចង់ដឹងថាតើអ្វីទៅដែលហៅថាអបិយជំនឿ អ្នកបានយកថ្លៃសំរាប់កន្សែងដៃដែលអ្នកបានផ្ញើរទៅក្រៅ គឺជាអបិយជំនឿតូចមួយនៃការអធិស្ឋានដាក់នៅលើកន្សែងនោះ ហើយបានផ្ញើរវាទៅ 'ក្រណាត់ដែលបាន

ចាក់ប្រេងតាំង' ហើយអ្នកហៅវាថាក្រណាត់។" គាត់និយាយថា "ហើយអ្នកបានយកថ្លៃពីវា។"

ខ្ញុំនិយាយថា "អត់ទេលោក គ្មានបានយកថ្លៃអ្វីនោះទេ។"

ហើយគាត់និយាយថា "គឺថានៅលើអបិយជំនឿមួយនេះ។"

193 ខ្ញុំនិយាយថា "លោកហៅវាថាជាអបិយជំនឿ តែប៉ុន្មាននាទីមុននេះលោកប្រាប់ខ្ញុំថា លោកគឺជាសិស្សសាលាព្រះគម្ពីរ។"

គាត់និយាយថា "បាទ មែន។"

194 ខ្ញុំនិយាយថា "ចូរប្រាប់ខ្ញុំនៅក្នុងកិច្ចការ១៩:១១។" ដំរិះ! គឺគាត់បានប្តូរប្រធានបទ ពីព្រោះមិនបានចេះវាទេ។ ខ្ញុំនិយាយថា "រួចចូរប្រាប់ខ្ញុំនៅក្នុងយ៉ូហាន៥:១៤។" គាត់មិនអាចធ្វើបានទៀត ខ្ញុំនិយាយថា "ចុះយ៉ាកុប៥:១៤។" គាត់មិនអាចធ្វើបានទៀត។ ខ្ញុំនិយាយថា "តើអ្នកចេះយ៉ូហាន៣:១៦ទេ?" ឃើញទេ? ដំរិះ ជាពិភពលោកដ៏ឆ្លាត! តែនៅពេល...

195 គាត់និយាយថា "ប៉ុន្តែលោកប្រានហាំអ្នកកំពុងតែដោះស្រាយរឿងនេះដោយព្រះគម្ពីរ។ តែយើងដោះស្រាយដោយច្បាប់ផែនដីវិញ។"

196 ខ្ញុំនិយាយថា "លោកតើច្បាប់របស់ផែនដីមិនមែនអាស្រ័យដោយព្រះគម្ពីរទេឬ? រួចហើយវាយុត្តិធម៌។" អាម៉ែន! ច្បាស់ណាស់។

197 ដំរិះមិនមែនខាងលោកិយ៍ទេ។ ដំរិះខាងឯវិញ្ញាណនៃព្រះបន្ទូលគឺដឹងពីអ្វីដែលព្រះមានបន្ទូល ហើយធ្វើនូវអ្វីដែលព្រះមានបន្ទូលត្រូវហើយ។ រួចបើអ្នកមានការទាំងអស់នេះ ហើយអាចជឿគ្រប់ទាំងអស់ ដែរថាទ្រង់គឺនៅតែដដែលក្នុងគ្រប់រឿងទាំងអស់ហើយអ្វីដែលព្រះបន្ទូលបានសំដែងគឺជាការពិត ហើយអ្នកបានបញ្ចប់គ្រប់ទាំងព្រះបន្ទូលទាំងអស់ដោយពាក្យថា "អាម៉ែន។" វាគឺត្រឹមត្រូវទាំងអស់។ ចូរបន្ថែមរបស់ទាំងអស់នោះទៅក្នុងសេចក្តីជំនឿរបស់អ្នកចុះ។ ត្រូវហើយ។ បាទ។

198 បើមានអ្នកណាម្នាក់ចង់ប្រាប់អ្នកថា "ព្រះគម្ពីរបានបាត់បង់អំណាចអស់ទៅហើយ។ វាគ្មានអ្វីដែលគេហៅថា ការជ្រមុជទឹកដោយព្រះវិញ្ញាណនោះទេ។" គឺថាកុំបន្ថែមរឿងនឹង។ វានឹងមិនមានអ្វីកើតឡើងនោះទេ។ វានឹងត្រូវតែចាញ់។ វាដូចជាយកដីឥតមកដាក់នៅលើដុំថ្មវានឹងមិនឈរនោះទេ។ គឺវាពិតជានឹងដួលរលំ។

199 បន្ទាប់មកមនុស្សនឹងប្រាប់អ្នក "ព្រះគម្ពីរមិនអាចទុកចិត្តបានទេនៅថ្ងៃនេះ។ ចូរអ្នកប្រយ័ត្នខ្លួនឥឡូវ។ ចូរអ្នកកុំជឿរឿងហ្នឹងឲ្យសោះ។ វាមិនមែនអាចជារឿងពិតនោះទេ។" អ្នកធ្លាប់បានឮរឿងហ្នឹងគ្រប់ពេលទៅហើយ។ មានគេនិយាយថា "អ្នកមិនអាចទុកចិត្តព្រះគម្ពីរទេ។" បើ—បើ អ្នកមានរឿងនេះនៅក្នុងចិត្តរបស់អ្នក អ្នកកុំ—កុំ ព្យាយាមបន្ថែមវាពីព្រោះវាទៅមិនរួចនោះទេ។ អាគារទាំងមូលនឹងត្រូវរលំនៅទីនោះ។

200 នាងគួរតែបានបិតជាប់ដោយព្រះវិញ្ញាណបរិសុទ្ធ។ ខ្ញុំចង់មានន័យថាឲ្យនៅជាប់ជាមួយ គឺជាបាយអរដែលអាចបោះត្រាបាន។ ហើយការដូចគ្នាដែរបោះត្រាវា...អ្នកស្គាល់ផ្លូវ...

201 ជ័រកៅស៊ូរាងជាគូបវាតែងតែនឹងជាប់ជាងបំណាស់អ៊ុត។ បំណាស់ដែរជាប់ថេរៗនៅនឹងសំបកកង់ដោយភ្លើងអ៊ុតៗ ហើយកាលដែលអ្នកនឹងបានដឹងជាដំបូងនោះគឺ នៅពេលដែលកង់នោះក្តៅបន្តិច ហើយវិលលឿនបន្តិច នោះវានឹងរលាយអស់។ បាទ លោក។ ឃើញទេ?

202 ហើយនេះហើយគឺជាបញ្ហារបស់មនុស្សជាច្រើន នៅសព្វថ្ងៃនេះ។ ពួកគេព្យាយាមដាក់ដំរិះរបស់គេទៅលើដំរិះខាងលោកិយ៍នេះ គឺជាមួយនឹងសំរាមចាស់បុរាណ ហើយនៅពេលដែលបញ្ហាមកដល់ "ប្រហែលជាខ្ញុំបានធ្វើខុស។" ឃើញទេ? ហើយខ្យល់ក៏បក់ទៅ អ្នកនឹងបានធូរក្នុងពេលប៉ុន្មាននាទី។ ការស្រែក និងការលោត-ឡើង-ចុះរបស់អ្នកមិនអាចជួយអ្វីដល់អ្នកបានទេ។ មនុស្សទាំងឡាយបានឃើញអ្នកនៅក្នុងគ្រហ៊ុកនោះដដែល។ ឃើញទេ? ត្រូវហើយ។

203 តែបើអ្នកនៅទីនោះជាមួយនឹងកំដៅគ្រប់គ្រាន់របស់ព្រះវិញ្ញាណបរិសុទ្ធរហូតដល់ពេល ដែលទ្រង់ធ្វើឲ្យអ្នកនឹងបំពង់នោះ បានក្លាយទៅជាតែមួយ។ នោះហើយ។ អ្នកហើយនឹងបំពង់បានក្លាយទៅជាតែមួយ។ នៅពេលដែលអ្នកនៅតែបន្តរហូតដល់អ្នកនឹងព្រះបន្ទូលសន្យារបស់ទ្រង់បានក្លាយជាតែមួយ រួចចូរបន្ថែមវាទៅលើសេចក្តីជំនឿរបស់អ្នកចុះ។ បើអ្នកមិនទាន់បានក្លាយជាតែមួយទេសូមកុំបន្ថែម វាឲ្យសោះ។

អ្នកនិយាយថា "ព្រះបន្ទូលមិនអាចទុកចិត្តបានទេ។" កុំព្យាយាមបន្ថែមវា។

204 អ្នកនិយាយថា "សេចក្តីសន្យានៅទីនេះ ការជ្រមុចដោយព្រះវិញ្ញាណបរិសុទ្ធគឺមានន័យសំរាប់ តែសាវ័កទាំង១២នាក់ប៉ុណ្ណោះ" ដូចជាអ្វីដែលព្រះវិហារ

មួយចំនួននិយាយនៅថ្ងៃនេះ កុំបន្ថែមវាអី។ នេះហើយគឺជាគ្រឹះរបស់ពួកគេ គឺថាវាបាក់បែកខ្ទេចខ្ទីទាំងអស់។ ឃើញទេ? ដូចជាអ៊ូសៀស យប់មិញនៅពេលដែលគាត់បានឃើញគ្រឹះរបស់បុរសម្នាក់ដែលគាត់បានទុកចិត្ត មានសភាពខ្ទេចខ្ទីដែលត្រូវបានកំទេចដោយជម្ងឺខ្លង់ វាមិនមែនជាការល្អទេ។ ឥឡូវ "សំរាប់សាវ័កទាំង១២នាក់ គឺសាវ័កទាំង១២ប៉ុណ្ណោះ។"

205 ខ្ញុំបានចុះទៅឯប្អូនប្រុសរ៉ែក...ខ្ញុំគិតថាពួកគេបានមកវិញហើយនៅកន្លែងណាមួយ។ នៅយប់មួយមានគ្រូអធិប្បាយមកទៅនោះ ខ្ញុំកំពុងតែអធិប្បាយ ហើយគ្រូគង្វាលបួន ប្រាំនាក់នៅជុំគ្នា។ ហើយគ្រូអធិប្បាយម្នាក់ងើបឡើងហើយបាននិយាយថា "ឥឡូវខ្ញុំចង់ប្រាប់អ្នកទាំងអស់គ្នាអំពីរឿងខ្លះ អូខ្ញុំគិតថាអ្នករាល់គ្នាជាមនុស្សដែលមានសុខភាពល្អទេ។"

206 ខ្ញុំនិយាយថា ខ្ញុំបានប្រាប់មនុស្សមួយចំនួនថា "នោះ—នោះម្នាក់ដែលអង្គុយនៅទីនោះ។ ចូរមើល។"

207 ដូច្នេះប្អូនយ៉េកសាន់ ជាអ្នកអធិប្បាយថ្មីថ្មោងបានត្រលប់ពីការអធិប្បាយវិញ ហើយគាត់បាននិយាយថា...គឺបានអធិប្បាយអំពីព្រះគុណរបស់ព្រះ។ ឱ ខ្ញុំអើយ!

208 គាត់មានការធុញថប់នឹងការរង់ចាំ។ គាត់បានឡើងទៅខាងលើ ហើយគាត់បានព្យាយាមក្នុងការស្វែងយល់។ "ឥឡូវខ្ញុំចង់និយាយថា បងប្រុសប្រានហាំនៅទីនេះ ខ្ញុំចង់ប្រាប់អ្នកថាគាត់គឺជាអ្នកប្រឆាំងព្រះគ្រីស្ទ ។" ហើយគាត់តែងតែចាប់ផ្ដើមយ៉ាងដូច្នេះជារៀងរាល់យប់។

209 មានគ្រូអធិប្បាយខ្លះចាប់ផ្ដើម...ខ្ញុំនិយាយថា "សូមចាំមួយភ្លែត។ តែឥឡូវសុំកុំនិយាយអ្វីឲ្យសោះប្អូនប្រុស។ គឺមានតែគាត់ម្នាក់ឯង ហើយនឹងពួកយើងតែប៉ុណ្ណោះ។" ខ្ញុំនិយាយថា "សូមឲ្យគាត់នៅតែឯងទៅឥឡូវនេះ។ គាត់បានធ្វើមុខដាក់ខ្ញុំ។" ខ្ញុំចង់បានវាដោយខ្លួនខ្ញុំជាខ្លាំងដែរខ្ញុំមិនដឹងថានឹងត្រូវធ្វើអ្វី។ ឃើញទេ?

210 ដូច្នេះគាត់បាននិយាយថា "លោកប្រានហាំគឺជាព្រះគ្រីស្ទក្លែងក្លាយ។" ហើយគាត់បានបន្តនិយាយពីអ្វីដែលអ្នករាល់គ្នាបានដឹងទៅហើយ។ គាត់និយាយថា "លោកប្រានហាំបាននិយាយថា មានការជ្រមុជដោយ ព្រះវិញ្ញាណបរិសុទ្ធ។" និយាយថា "ព្រះគម្ពីរបានសំដែងថាគឺមានតែដប់ពីរនាក់ប៉ុណ្ណោះដែលបានជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ។" និយាយអំពីរការប្រោសពីព្រះ "គឺមានតែសាវ័កទាំងដប់ពីរប៉ុណ្ណោះដែលទទួលបានការព្យាបាល។" គាត់និយាយថា "យើងនិយាយ

នៅពេលដែលព្រះគម្ពីរមានបន្ទូល ហើយស្ងាត់នៅពេលដែលព្រះគម្ពីរស្ងាត់។" ខ្ញុំបានរង់ចាំរហូតទាល់តែគាត់បានចេញពីទីនោះប្រហែលជាកន្លះម៉ោង។

211 ខ្ញុំនិយាយថា "សុំចាំមួយភ្លែត ខ្ញុំបានកត់ទុកជាច្រើននៅទីនេះ" ខ្ញុំនិយាយថា "សូមទុកឱកាសឲ្យខ្ញុំបានឆ្លើយខ្លះ។" ហើយនៅពេលដែលខ្ញុំឡើងទៅដល់ខ្ញុំគាត់និយាយថា គាត់ 'លោកម្នាក់នេះបាននិយាយថាគាត់និយាយអ្វីដែលព្រះគម្ពីរបានសំដែង" ក្រុមជំនុំរបស់គាត់ក៏បានធ្វើយ៉ាងដូច្នេះដែរ 'ហើយបានស្ងាត់។' អ្នកទាំងអស់គ្នាគឺជាសាក្សី។ 'មែន។'" ខ្ញុំនិយាយថា "ឥឡូវគាត់បាននិយាយថា 'មានតែដប់ពីរនាក់ប៉ុណ្ណោះដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ។' ព្រះគម្ពីររបស់ខ្ញុំបានសំដែងថានៅលើកទីមួយមានគ្នាចំនួនមួយរយម្ភៃនាក់។" អាម៉ែន! ចូរបោះចោលនូវដំរិះបែបនេះចេញទៅ អ្នកបានឃើញហើយថាគាត់បាន ព្យាយាម។

212 ខ្ញុំនិយាយថា "រួចខ្ញុំ គិតថាសាវ័កប៉ុលមិនបានទទួលព្រះវិញ្ញាណបរិសុទ្ធទេ ប៉ុន្តែគាត់បាននិយាយថាគាត់បានទទួល។" ឃើញទេ?

213 ខ្ញុំនិយាយថា "នៅខាងក្នុង...នៅពេលដែលពេត្រុសបានចុះទៅអធិប្បាយដល់សាសន៍សាម៉ារី។ ពួកគេត្រូវបានជ្រមុជទឹកដោយនៅព្រះនាមព្រះយេស៊ូវគ្រីស្ទ។ គឺមានតែព្រះវិញ្ញាណបរិសុទ្ធទេ ដែលមិនបានមកឯគេ។ ហើយពួកគេត្រូវបានបញ្ជូនទៅហើយមានពេត្រុសនិងយ៉ូហានបានមកឯគេ ហើយដាក់ដៃលើគេ រួចព្រះវិញ្ញាណបរិសុទ្ធបានយាងមកសណ្ឋិតលើគេ។ ខ្ញុំគិតថាមានតែទាំងដប់ពីរទេ?"

214 ខ្ញុំបាននិយាយថា "នៅក្នុងកិច្ចការ ១០:៤៩ នៅពេលដែលពេត្រុសនៅពីលើដំបូលផ្ទះ ហើយបានឃើញនិមិត្តថា ពួកគេបានទីឯកូនីលាស។ នៅពេលដែលពេត្រុសកំពុងតែនិយាយពាក្យទាំងនេះ ព្រះវិញ្ញាណបរិសុទ្ធបានសណ្ឋិតលើពួកគេដែលបានឮព្រះបន្ទូល។" ខ្ញុំនិយាយថា "ព្រះគម្ពីរនៅតែមានបន្ទូលនៅឡើយ។ តើព្រះវិហាររបស់អ្នកនៅឯណា?" គឺថាវាបានត្រលប់មកដល់ពាក្យថា វាអាចជាម្តងទៀតហើយ។ ត្រឹមត្រូវណាស់។ ឃើញទេ?

215 ខ្ញុំនិយាយថា "ការព្យាបាលដែលមកពីព្រះ អ្នកនិយាយថា 'មានតែសាវ័កទាំងដប់ពីរប៉ុណ្ណោះដែលទទួលបាន។' ព្រះគម្ពីរបានសំដែងថា លោកស្ទេផានបានទៅឯសាសន៍សាម៉ារី ហើយបានបណ្តេញអារក្សសាតាំង ហើយបានព្យាបាលអ្នកដែលមានជម្ងឺ ហើយក៏មានសេចក្តីអំណរជាខ្លាំងដល់ទីក្រុងនោះ។ ហើយគាត់

មិនមែនជាម្នាក់នៅក្នុងចំនោមអ្នកទាំងដប់ពីរនោះទេ។ គាត់ក៏មិនមែនជាសាវ័កដែរ។ គាត់គឺជាអ្នកដឹកនាំសាសនាម្នាក់។" អាម៉ែន។ អាម៉ែន។

216 ខ្ញុំនិយាយថា "ហើយសាវ័កប៉ុលក៏មិនមែនជាម្នាក់ក្នុងចំនោមអ្នកទាំងដប់ពីរដែលបាននៅបន្ទប់ខាងលើដែរ ហើយគាត់ក៏មានអំណោយទានក្នុងការព្យាបាលដែរ។"

217 ខ្ញុំនិយាយ "គឺគ្រាន់តែមើលពីអំណោយទាននៃការព្យាបាល! ហើយប្រមើលមើលសាមសិបឆ្នាំក្រោយគឺគាត់នៅតែនៅឯទីក្រុងកូរិនថុសដដែល ហើយបានបន្តអំណោយទាននៃការព្យាបាលទៅដល់រូបកាយរបស់ព្រះគ្រីស្ទ។" ឱខ្ញុំអើយ!

218 ឥឡូវដំរិះទាំងឡាយនោះដែលអ្នកបានរៀនពីសៀវភៅមួយចំនួន អ្នកគួរតែបោះវាចោលទៅក្នុងធុងសំរាមទៅ។ ចូរមកឯដំរិះមួយនេះវិញ នៅពេលដែលព្រះមានបន្ទូលថា "ទ្រង់នៅតែដដែល ពីម្សិលមិញ ថ្ងៃនេះ និងអស់កល្បជានិច្ច" ត្រូវនិយាយថា "អាម៉ែន។" បាទ អ្នកទាំងអស់គ្នា វាមិនមែនសំរាប់អ្នកទាំងដប់ពីរទេ គឺសំរាប់ទាំងអស់គ្នាវិញ។ នៅពេលដែលអ្នកមាន—ជំនឿបែបនេះ គឺនៅពេលដែលសេចក្ដីជំនឿរបស់អ្នកបញ្ចប់ព្រះបន្ទូលទ្រង់ដោយពាក្យថា "អាម៉ែន" រួចចូរអ្នកនិយាយថា "ត្រូវហើយ" ហើយចូរបន្ថែមវាចូលទៅ។

219 ទីបួន គឺថាយើងនឹងត្រូវប្រញាប់បន្តិច ពីព្រោះខ្ញុំ...គឺវាមានអារម្មណ៍ល្អខ្លាំងណាស់ក្នុងការឈរនៅទីនេះ ហើយនិយាយអំពីវា។ អាម៉ែន។ [ប្អូនប្រុសម្នាក់និយាយថា"យើងទាំងអស់គ្នាចូលចិត្តណាស់។"—Ed។]បាទ។ ទីបួន... អរគុណ។

220 បន្ថែម "សេចក្ដីអត់សង្កត់ចិត្ត។" ឱ ខ្ញុំអើយ! យើងបានមកដល់ចំនុចអត់សង្កត់ចិត្ត។ ឥឡូវទីមួយគឺអ្នកមានសេចក្ដីជំនឿ គឺត្រូវតែមានវាសំរាប់ជាការចាប់ផ្ដើម។ រួចហើយអ្នកបន្ថែមសេចក្ដីទៀងត្រង់ពីលើសេចក្ដីជំនឿរបស់អ្នកបើវាគឺជាសេចក្ដីទៀងត្រង់ដ៏ត្រឹមត្រូវ។ បន្ទាប់មកអ្នកបន្ថែមដំរិះ បើវាគឺជាដំរិះដ៏ត្រឹមត្រូវ។ ឥឡូវអ្នកនឹងត្រូវបន្ថែមសេចក្ដីអត់សង្កត់ចិត្ត។

221 សេចក្ដីអត់សង្កត់ចិត្ត មិនមែនមានន័យថា "ឈប់ផឹកស្រា" នោះទេ។ អត់ទេ អត់ទេ។ សេចក្ដីអត់សង្កត់ចិត្តមិនមានន័យថា ការបញ្ឈប់ការផឹកស្រាទេ មិនមែនដូចនេះទេ។ នេះគឺជាការអត់សង្កត់ខាងព្រះបន្ទូលវិញ សេចក្ដីអត់សង្កត់ចិត្តខាងឯ

ព្រះវិញ្ញាណ។ នេះគឺគ្រាន់តែជាមួយនៅក្នុង ចំណង់របស់លោកិយ៍ប៉ុណ្ណោះ ប៉ុន្តែគឺយើងនិយាយអំពីសេចក្ដីអត់សង្កត់ចិត្តខាងឯព្រះវិញ្ញាណវិញ។ នោះគឺមានន័យថា តើអ្នកធ្វើយ៉ាងណាដើម្បីការពារ មិនឲ្យអណ្ដាតរបស់អ្នកនិយាយរអេចរអូចបាន តើអ្នកអាចគ្រប់គ្រងលើអារម្មណ៍របស់អ្នកបានយ៉ាងណា ដើម្បីកុំឲ្យនៅពេលដែលគេនិយាយអ្វីដល់អ្នក ការទាំងនោះនឹងត្រលប់ទៅគេវិញ។ ឱ ខ្ញុំអើយ!

222 ប្រុសៗទាំងអស់គ្នាអើយពួកយើងជាច្រើននឹងត្រូវជួលចុះមុនពេលដែលយើងនឹងចាប់ផ្ដើម តើមិនមែនទេឬអី? ឃើញទេ? រួចហើយយើងឆ្ងល់ថា តើហេតុអ្វីបានជាព្រះទ្រង់មិនគង់នៅក្នុងព្រះវិហាររបស់ទ្រង់ ហើយធ្វើការការអស្ចារ្យទាំងឡាយដែរពួកគេធ្លាប់បានធ្វើ។ បាទ អ្នកទាំងអស់គ្នា ឃើញទេ?

223 ចូរបន្ថែមការទាំងនេះ។ ចូរបន្ថែមសេចក្ដីអត់ធ្មត់សង្កត់ចិត្តទៅលើវា។ អូ សេចក្ដីអត់ធ្មត់សង្កត់ចិត្ត គឺកាលដែលឆ្លើយដោយសុភាពនៅពេលពាក្យគំរោះគំរើយបាននិយាយមកអ្នក។ មានអ្នកខ្លះនិយាយថា "អូ ពួកអ្នកបរិសុទ្ធនៅទីនោះ!" កុំលោតមកលាត់ដៃអាវ មូលជើងខោរបស់អ្នក។ ឃើញទេ? មិនមែនយ៉ាងដូច្នេះទេ។ ប៉ុន្តែត្រូវនិយាយដោយសេចក្ដីស្រឡាញ់នៃព្រះ សេចក្ដីអត់សង្កត់ និងសេចក្ដីសប្បុរស។ តើនេះជាអ្វីដែលអ្នកចង់ក្លាយ ជាមែនទេ? [ពួកជំនុំនិយាយថា "អាម៉ែន"—Ed។] នៅពេលដែលអ្នកកូរវា មិនមែនកូរមកវិញទេ។ សូមទុកឲ្យទ្រង់ធ្វើជាគំរូរបស់អ្នកវិញ។

224 នៅពេលដែលគេនិយាយថា "បើសិនជាអ្នកជាព្រះរាជបុត្រានៃព្រះមែន ចូរធ្វើឲ្យដុំថ្មនេះក្លាយទៅជានំប៉័ងទៅ" ទ្រង់អាចនឹងធ្វើវាបាន ហើយបង្ហាញឲ្យគេឃើញថាទ្រង់គឺជាព្រះ។ ប៉ុន្តែទ្រង់មានសេចក្ដីអត់សង្កត់ចិត្ត។ នៅពេលដែលគេហៅទ្រង់ថា "បិលហ្សេបាប់" ទ្រង់មានបន្ទូលថា "ខ្ញុំអត់ទោសដល់អ្នក។" តើវាត្រូវទេ? ពួកគេបានទាញពុកចង្ការរបស់ទ្រង់មួយដៃធំហើយបានស្ដោះទឹកមាត់ដាក់ទ្រង់ ដោយនិយាយថា "ចូរឯងចុះពីលើឈើឆ្កាងមក!"

225 ទ្រង់មានបន្ទូលថា "ព្រះបិតាអើយសូមទ្រង់អត់ទោសឲ្យគេ ពួកគេមិនបានដឹងថាគេធ្វើអ្វីទេ។"

226 នៅពេលដែលទ្រង់ទទួលបានអំណោយទាន ទ្រង់ ដឹងគ្រប់កិច្ចការទាំងអស់ដ្បិតនៅក្នុងទ្រង់មានពេញទៅដោយព្រះវិញ្ញាណ។ ពួកគេបានឃើញទ្រង់ធ្វើការអស្ចារ្យ ដោយបានប្រាប់មនុស្សទាំងឡាយនូវអ្វីដែលពួកគេបានធ្វើខុស នឹងរឿងអ្វី

ស្រដៀងនេះ។ ពួកគេបានដាក់កន្ទមនៅលើព្រះសិរសាទ្រង់យ៉ាងដូច្នេះ នៅជុំវិញព្រះនេត្រទ្រង់ ហើយបានវាយព្រះកេះទ្រង់នឹងដំបង ដោយពាក្យថា "ថ្លែងទំនាយថាអ្នកណាវាយឯង។ នោះយើងនឹងជឿឯង។" ឃើញទេ? ទ្រង់មានសេចក្តីអត់សង្កត់ចិត្ត។

227 ឥឡូវបើអ្នកមានអ្វីយ៉ាងដូចនេះ ចូរបន្ថែមវាទៅលើសេចក្តីជំនឿរបស់អ្នកចុះ។ បើអ្នកនៅតែមិនរឹងមាំ ហើយម្សួរម៉ៅ ហើយអន្ទះអន្ទែង និងឆេវឆាវ រួចការទាំងអស់នេះនៅតែមាន នោះអ្នកនឹងមិនអាច...អ្នកមិនអាចបន្ថែមការទាំងនោះទេ ពីព្រោះវានឹងមិនអាចចូលគ្នាបានទេ។ ឃើញទេ? វាមិនអាចស្អិតជាប់គ្នាបានទេ។ អ្នកមិនអាចយកជ័រកៅស៊ូមួយដុំមកភ្ជាប់ជាមួយនឹងដែកបាននោះទេ។ គឺវាមិនអាចទៅរួចនោះទេ។ ទេគឺវាត្រូវតែទន់ ហើយរលាស់ដូចជាកៅស៊ូដែរ។ ឃើញទេ? ហើយនៅពេលដែលសេចក្តីជំនឿ និងសេចក្តីអត់សង្កត់របស់អ្នកបានក្លាយដូចជាសេចក្តីអត់សង្កត់នៃព្រះវិញ្ញាណបរិសុទ្ធដែរ នោះវានឹងបានស្អិតជាប់ជាមួយនឹងទ្រង់។ អ្នកបានបន្ថែមទៅលើវាហើយ។

នៅពេលដែលសេចក្តីទៀងត្រង់របស់អ្នកបានដូចជាសេចក្តីទៀងត្រង់របស់ទ្រង់ នោះវានឹងបន្ថែមមកទៀត។

228 នៅពេលដែលដំរិះរបស់អ្នកបានដូចជាព្រះដំរិះរបស់ទ្រង់ "ទូលបង្គំបានមកដើម្បីធ្វើការរបស់ទ្រង់ព្រះអង្គអើយ។" ឃើញទេ? ដោយសារគ្រប់ទាំងព្រះបន្ទូលរបស់ព្រះបិតា ទ្រង់បានយកឈ្នះអស់ទាំងអារក្សសាតាំង។ ទោះទាំងផ្ទៃមេឃនិងផែនដីកន្លងបាត់ទៅ តែព្រះបន្ទូលទ្រង់នឹងមិនកន្លងបាត់ឡើយ។ ឃើញទេ? នៅពេលដែលអ្នកមានដំរិះយ៉ាងដូចនេះ វានឹងបានស្អិតជាប់ជាមួយនឹងសេចក្តីជំនឿរបស់អ្នក។

229 នៅពេលដែលអ្នកមានសេចក្តីអត់សង្កត់ដ៏ត្រឹមត្រូវ ដូចទ្រង់ វានឹងបានស្អិតជាប់គ្នា។ បើអ្នកគ្រាន់តែជាមនុស្សដែលជឿតែពាក់កណ្តាល ឬមានសេចក្តីអត់សង្កត់តែពាក់កណ្តាល "អូ ខ្ញុំគួរតែវាយវាទេ តែ—តែយកល្មមិនបាច់ទេ ពីព្រោះគេនឹងកត់ឈ្មោះខ្ញុំនៅក្នុងបញ្ជីមិនខាន។" នោះមិនមែនជាសេចក្តីអត់សង្កត់ចិត្តដែលទ្រង់បានមានបន្ទូលនោះទេ។ សូមកុំបន្ថែមវា វាមិនអាចទៅរួចទេ។ តែបើសិនអ្នកអាច អត់ទោសដល់គ្រប់មនុស្សទាំងអស់ឲ្យអស់ពីចិត្តរបស់អ្នក រក្សាសេចក្តី

សុខសាន្តរបស់អ្នកហើយឲ្យវាកន្លងបាត់ទៅ មើលវានឹងបានស្អិតជាប់។ អ្នកអាចបន្ថែមវាទៅលើសេចក្ដីជំនឿរបស់អ្នក។ រ៉េវ!

230 គ្មានអ្វីឆ្ងល់ទេក្រុមជំនុំខ្លីណាស់។ តើវាត្រឹមត្រូវទេ? គ្មានអីឆ្ងល់ទេ។ ខ្ញុំនឹងនិយាយថា "ព្រះគម្ពីរសំដែងថា ចូរលន់តួបាប ហើយជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។" ហើយពួកអ្នកដែលជឿលើព្រះទាំងបីដ៏មាំមួនមិនជឿលើការទាំងនេះទេ គេនិយាយថា "គឺជាអ្នកប្រឆាំងព្រះគ្រីស្ទពីមុន។ ទ្រង់មានព្រះនាមថា ព្រះយេស៊ូវគ្រីស្ទ។ គឺទ្រង់ជាព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណឹង។" ចូរមើលប្រុសៗទាំងអស់គ្នាអើយ ខ្ញុំមិនបានដឹងពីសេចក្ដីអត់សង្កត់របស់អ្នកនៅពេលឥឡូវនេះទេ។ ឃើញទេ? ចុះហេតុអ្វីបានជាអ្នកមិននិយាយថា "ចូរយើងឲ្យហេតុផលរឿងនេះជាមួយគ្នា បងប្រុសប្រានហាំ។ ខ្ញុំចង់ស្ដាប់ការបកស្រាយមួយនេះ"? ឃើញទេ? រួចហើយចូរចុះមកស្ដាប់វាចុះ។ រួចហើយវាត្រូវបានលាតត្រដាងនៅនឹងមុខរបស់អ្នកតែអ្នកបានដើរចេញ យើង—យើងនឹងត្រលប់មករឿងនឹងវិញនៅប៉ុន្មាននាទីទៀត ក្នុង "ភាពជាព្រះ" មើល។ ប៉ុន្ដែនៅពេលដែលអ្នក—ឆេវឆាវ ហើយចង់លោតសំរាប់គ្រប់ទាំងស្ថានការទាំងអស់ អូ-អូ នោះ—មិនមែនជាវាទេ។ ឃើញទេ? អ្នកនៅមិនទាន់មានសេចក្ដីអត់សង្កត់របស់ព្រះគម្ពីរនៅឡើយទេ នៅពេលដែលអ្នកធ្វើយ៉ាងដូច្នេះ តើអ្នកនឹងឆ្លើយបតវិញបានយ៉ាងណា។ រួចបើសិនជាអ្នកមានការទាំងអស់នេះហើយ អ្នកអាចបន្ថែមវាទៅលើសេចក្ដីជំនឿរបស់អ្នកបានហើយ។

231 រួចបន្ទាប់មក ទីបួន អ្នកអាចបន្ថែមការអត់ធ្មត់ទៅលើសេចក្ដីជំនឿរបស់អ្នក។ ព្រះបន្ទូលសំដែងថា បើអ្នកមានសេចក្ដីជំនឿ "វាបង្កើតឲ្យមានសេចក្ដីអត់ធ្មត់"។ ឃើញទេ? ដូច្នេះ*នេះ*គឺជាការអត់ធ្មត់។ ឥឡូវនេះគឺជាអ្វីដែលនឹងបង្កើតព្រះដទៃនេះមក។ អ្នកបានដឹងហើយថា ព្រះទ្រង់មានសម្ភារៈពិតសំរាប់អាគាររបស់ទ្រង់។

232 ចូរមើលបងប្អូនប្រុសស្រីអើយ តើមានអ្វីខ្លះទៀតដែលយើងមិនទាន់ដឹង? ឃើញទេ? ចូរមើលថាតើហេតុអ្វីហើយយើងនៅឯណា? បាទលោក។ ឃើញទេ? យើងមានសិរីល្អ ហើយយើងបានស្រែក ពីព្រោះយើងមានសេចក្ដីជំនឿ។ ប៉ុន្ដែនៅពេលដែលយើងបានមកខាងក្រោម*នេះ* ព្រះមិនអាចបង្កើតអ្នកឲ្យមានរាងយ៉ាងដូចនោះបានទេ។ ឃើញទេ? ទ្រង់មិនអាចទេ។ ទ្រង់មិនអាចធ្វើឲ្យយើងបានដូចជាកន្លែងនោះទេ។ យើងមានអ្វីៗផ្សេងទាំងអស់នេះ។ យើងបានដួល

ចុះដោយសារការទាំងអស់នោះ។ ឃើញទេ? ទ្រង់មិនអាចបង្កើតព្រះវិហារទ្រង់បានទេ។

233 អត់ធ្មត់ជាមួយនឹងអ្វី? តើជាសេចក្តីអត់ធ្មត់បែបណា? ទីមួយគឺត្រូវមានការអត់ធ្មត់ជាមួយនឹងព្រះ។ បើអ្នកមានសេចក្តីជំនឿដ៏ពិត អ្នកនឹងមានការអត់ធ្មត់ដ៏ពិតដែរ ពីព្រោះសេចក្តីជំនឿបង្កើតឲ្យមានការអត់ធ្មត់។ នៅពេលដែលព្រះបន្ទូល អ្នកនឹងជឿ។ ត្រឹមត្រូវហើយ។ អ្នកមានការអត់ធ្មត់។

234 និយាយ "ខ្ញុំបានសូមឲ្យទ្រង់ព្យាបាលខ្ញុំកាលពីយប់មិញ ប៉ុន្តែនៅពេលព្រឹកឡើងខ្ញុំនៅតែឈឺដូចដើម។" ឱ ខ្ញុំអើយ! តើជាការអត់ធ្មត់ប្រភេទណា?

235 ព្រះមានព្រះបន្ទូលប្រាប់អ័ប្រាហាំ ហើយម្ភៃឆ្នាំក្រោយសូម្បីតែទីសំគាល់មួយក៏គ្មាន។ តែគាត់នៅតែជឿ។ គាត់មានការអត់ធ្មត់ជាមួយនឹងព្រះ។ អូ-អូ

236 ត្រូវតែដាក់ទ្រង់ពីមុខអ្នកជានិច្ច។ សូមឲ្យទ្រង់ជាកន្លែងដែលអ្នកឆ្លងកាត់បន្ទាប់។ អ្នកមិនអាចនឹងរំលងទ្រង់បានទេ ដូច្នេះត្រូវតែដាក់ទ្រង់នៅពីមុខអ្នក។ "ទ្រង់មានព្រះបន្ទូលយ៉ាងដូច្នេះ នោះវាកើតឡើងមែន។" ឃើញទេ? ចូរដាក់ទ្រង់នៅពីមុខអ្នក។ ត្រូវហើយ។

237 ណូអេមានការអត់ធ្មត់។ មែន ណូអេមានការអត់ធ្មត់ដ៏ពិតរបស់ព្រះ។ ព្រះមានបន្ទូលថា "អញនឹងបំផ្លាញផែនដីនេះនឹងទឹកភ្លៀង" ហើយណូអេ បានប្រាប់ពីការទាំងនេះអស់រយៈពេលមួយរយម្ភៃឆ្នាំ។ មានការអត់ធ្មត់ជាច្រើនទៀត។ សូម្បីតែសន្សើមក៏គ្មានស្រក់ពីលើមេឃមកដែរ គឺគ្មានអ្វីទាំងអស់។ គឺដីនៅតែស្ងួតដូចដើម អស់រយកាលមួយរយម្ភៃឆ្នាំ ប៉ុន្តែគាត់នៅតែមានការអត់ធ្មត់។

រួចព្រះនឹងសាកល្បងការអត់ធ្មត់របស់អ្នក។ត្រូវណាស់។ ព្រះនឹងសាកល្បង។

238 បន្ទាប់ពីទ្រង់បានប្រាប់ណូអេ ឥឡូវទ្រង់មានបន្ទូលថា "ណូអេ អញចង់ឲ្យឯងបានចូលទៅក្នុងទូកធំ។ អញនឹងធ្វើឲ្យសត្វទាំងឡាយបានចូលទៅក្នុងនោះ ហើយអញ—អញចង់ឲ្យឯងបានចូលក្នុង។ ចូរឡើងទៅឯទីខ្ពស់ឥឡូវដើម្បីឲ្យបានមើលតាមបង្អួចខាងលើ។ ឥឡូវអញចង់ឲ្យឯងចូលទៅក្នុងនោះ។ អញចង់ឲ្យឯងប្រាប់ដល់មនុស្សទាំងអស់នេះថា 'ថ្ងៃស្អែកអ្វីដែលខ្ញុំបាន ប្រាប់អស់រយៈកាលមួយរយម្ភៃឆ្នាំនឹងកើតឡើង។' ដូច្នេះចូរឯងចុះទៅហើយប្រាប់ពួកគេ។"

239 តើអ្វីទៅជាទីសំគាល់ទីមួយ? ណូអេបានចូលទៅក្នុងទូកធំ។ គឺមិនទាន់មានភ្លៀងនៅឡើយទេ។ ណូអេបានរៀបខ្លួនរួចជាស្រេច ហើយបានពាក់ទាំងអាវភ្លៀងទៀត ហើយនឹងអ្វីៗផ្សេងទៀត ដើម្បីឲ្យគាត់អាចមើលមកក្រៅបានយូរៗម្ដង។ ត្រៀមរួចហើយ។ ប៉ុន្តែនៅថ្ងៃបន្ទាប់...

240 ខ្ញុំជឿថាគាត់ប្រាកដជាបានប្រាប់គ្រួសាររបស់គាត់ព្រមទាំងកូនប្រសាររបស់គាត់ ហើយនឹងអស់អ្នកផ្សេងទៀតថា "ឱ ខ្ញុំអើយ! នៅថ្ងៃស្អែកអ្នកនឹងបានឃើញអ្វីដែលអ្នកមិនដែលបានឃើញ។ ពីព្រោះនៅលើមេឃទាំងមូលនឹងត្រលប់ទៅជាខ្មៅ។ ហើយនឹងមានផ្គលាន់ និងរន្ទះ។ ដាវដ៏ធំរបស់ព្រះនឹងត្រូវហូតកាត់នៅលើផ្ទៃមេឃ។ ទ្រង់នឹងដាក់ទណ្ឌកម្មដល់មនុស្សទាំងអស់នេះ ដ្បិតគេមិនបានជឿនៅអ្វីដែលយើងបានប្រាប់អស់រយៈ កាលមួយរយម្ភៃឆ្នាំមកនេះ។ ចូរចាំមើលចុះ។" ឃើញទេ?

241 ពាក់កណ្ដាលនៃអ្នកដែលជឿ អ្នកដឹងទេ នៅក្បែរនោះសោះមិនទាំងចូលមកផង អ្នកដឹងទេ។ អ្នក—អ្នកនៅតែអាចមានវាអ្នកដឹងទេ។ ដូច្នេះពួកគេ—ពួកគេអាចនឹងមកនិយាយ "ប្រហែលជាអ្វីដែលតាចាស់នោះនិយាយអាចនឹងត្រូវ ដូច្នេះយើងគួរតែឡើងទៅហើយរង់ចាំប៉ុន្មានថ្ងៃមើល ឬក៏ចាំប៉ុន្មានម៉ោងនៅពេល ព្រឹកទៅមើល។"

242 ថ្ងៃបន្ទាប់ក្រៅពីមានពពកខ្មៅ បែរជាថ្ងៃបញ្ចេញពន្លឺដូចសព្វមួយដង។ ណូអេបានមើលទៅក្រៅហើយនិយាយថា "ហេ ឥតមានពពកទេ។"

243 មានម្នាក់ឡើងមកនិយាយថា "អូ ខ្ញុំដឹងហើយអ្នកគឺជាម្នាក់នៅក្នុងចំនោមពួកគេ។ អ្នកឃើញទេ គឺអ្នកនៅទីនេះ។"

244 "សុំអភ័យទោសលោក ប្រហែលជា ខ្ញុំ—ខ្ញុំ—ខ្ញុំគ្រាន់តែភ្ញាក់ផ្អើលតែប៉ុណ្ណោះ អ្នកដឹងទេ។ គឺវាគ្រាន់យ៉ាងនឹងឯង ហា-ហា-ហា។"

245 ប៉ុន្តែណូអេគាត់មានការអត់ធ្មត់ ដោយនិយាយថា "បើវាមិនមកនៅថ្ងៃនេះទេវានឹងមកនៅថ្ងៃស្អែក។" ហេតុអ្វី? ព្រោះព្រះមានបន្ទូលយ៉ាងដូច្នេះ។

"តើទ្រង់បានប្រាប់អ្នកនៅពេលណា ណូអេ?"

246 "មួយរយម្ភៃឆ្នាំហើយ ខ្ញុំបានរង់ចាំយ៉ាងយូរហើយ ដូច្នេះគឺខ្ញុំគ្រាន់តែរង់ចាំនៅទីនេះឥឡូវនេះ។" ឃើញទេ? បន្តិចក្រោយមក...

247 យើងបានឃើញថា ទ្រង់បានរង់ចាំយើងជាយូរណាស់ដែរ គឺរង់ចាំក្រុមជំនុំរបស់ទ្រង់ដូចគ្នា ប៉ុន្តែពេលនោះនឹងមកដល់។ តើអ្នកមិនខ្វល់ខ្វាយទេឬអី។ ទ្រង់បានសន្យាហើយ។

248 រង់ចាំអស់ពេលយ៉ាងយូរ សំរាប់ការរស់ឡើងវិញ។ នឹងមានរឿងនោះកើតឡើង។ សូមកុំភ័យឡើយ ដ្បិតព្រះទ្រង់បានសន្យាហើយ។ គឺគ្រាន់តែរង់ចាំដោយការអត់ធ្មត់។ អ្នកបានគេងលក់ទៅដែរ មិន...ប្រហែលជាអ្នកនឹងសំរាកបន្តិចមុនពេលដែលរឿងនេះកើតឡើង ប៉ុន្តែអ្នកនឹងភ្ញាក់ឡើងនៅពេលនោះ។ ទ្រង់បានសន្យា អ្នកឃើញទេ។ ការសំរាក ឃើញទេ គឺជាការសំរាកនៃសេចក្តីស្លាប់អ្នកដឹងទេ។ អ្វីដែលហៅថាការស្លាប់មួយភ្លែត គឺគ្រាន់តែជាការសំរាកបន្តិច ឬ ជាការសំរាកជាមួយនឹងព្រះគ្រីស្ទ។ នៅក្នុងព្រះគ្រីស្ទគ្មានអ្វីដែលហៅថា ជាសេចក្តីស្លាប់នោះទេ។ ជីវិតហើយនឹងសេចក្តីស្លាប់មិនអាចនៅជាមួយគ្នាបានទេ។ ឃើញទេ? យើងគ្រាន់តែសំរាកបន្តិចប៉ុណ្ណោះ គឺជាការសំរាកដែលមិត្តយើងមិនអាចហៅយើងបាន។ ទ្រង់មួយអង្គគត់ដែលអាចហៅយើងបាន។ យ៉ូបនិយាយថា "ទ្រង់នឹងហៅខ្ញុំ ហើយខ្ញុំនឹងឆ្លើយនឹងទ្រង់។" យ៉ូបបានសំរាកអស់រយៈពេលបួនពាន់ឆ្នាំហើយ។ កុំភ័យឡើយ ទ្រង់នឹងដាស់អ្នកឡើង។ កុំភ័យ។ ទ្រង់—ទ្រង់នឹងនៅតែរង់ចាំ។

249 ណូអេបានរង់ចាំ។ ថ្ងៃទីបួនបានកន្លងទៅ។ គ្មានភ្លៀងសោះ។ វាមិនថ្វីទេ។ វានឹងកើតឡើង។

250 ខ្ញុំអាចឮបានថា ប្រពន្ធរបស់ណូអេនៅក្បែរ ហើយនិយាយថា "ប៉ាវ៉ា តើអ្នកច្បាស់-...?"

"កុំនិយាយយ៉ាងដូច្នេះ។"

251 គាត់មានការអត់ធ្មត់ ពីព្រោះគាត់មានសេចក្តីជំនឿ។ បាទ លោក។ គាត់មានសេចក្តីទៀងត្រង់។ គាត់មានដំរិះដែលយល់ថា ព្រះពិតជាត្រឹមត្រូវ។ គាត់មានសេចក្តីអត់សង្កត់។ គាត់មិនបានឆេវឆាយដោយនិយាយថា "ខ្ញុំមិនបានដឹងថាទាំងអស់នោះគឺជាអ្វីទេ។ នៅទីនោះខ្ញុំបានបាត់បង់នូវប្រជាប្រិយភាពរបស់ខ្ញុំ។" អត់ទេ ទេ "មនុស្សលែងខ្វល់ខ្វាយពីខ្ញុំទៀតហើយ។ ខ្ញុំនឹងចេញទៅឯនោះ ហើយចាប់ផ្តើមជាថ្មីម្តងទៀត។" អត់ទេៗ។ គាត់មានការអត់ធ្មត់។ ព្រះបានសន្យា ព្រះនឹងធ្វើវា។ ព្រះនឹងធ្វើវាព្រោះទ្រង់មានបន្ទូលដូច្នោះ។

252 ហើយខ្ញុំអាចមើលឃើញថាកូនប្រុសរបស់គាត់ ដើរនៅក្បែរៗគាត់ដោយនិយាយថា "ពុក មានដឹងទេ..." គាត់យកដៃមកអង្អែលនៅលើក្បាលដែលមានសក់ពណ៌ប្រផេះដ៏វែងរបស់គាត់ តើអ្នកដឹងទេ។ ហើយគាត់មានអាយុដ៏ទៅមួយរយឆ្នាំហើយ ហើយបានអង្គុយនៅនទីនោះដោយនិយាយថា "ខ្ញុំដឹងថាអ្នកគឺជាមេគ្រួសារដ៏ចំណាស់ម្នាក់។ ខ្ញុំ—ខ្ញុំស្រឡាញ់ពុក តែតើវាអាចទេដែលថា ពុកបានច្រលំពីរឿងអ្វីមួយ?"

"អូ ទេ។ អត់ទេៗ"

"ហេតុអ្វី?"

"ព្រះបានមានបន្ទូលយ៉ាងដូច្នេះ!"

253 "ល្អលោកពុកអើយនេះគឺថ្ងៃទីប្រាំមួយហើយ ដែលយើងបានអង្គុយនៅលើនេះ។ គឺបានអង្គុយនៅលើទូកចាស់ ធំហើយស្ងួតមួយនេះ គឺនៅត្រង់នេះ។ ហើយនៅទីនេះគឺវាងងឹតសូន្យ ទាំងនៅខាងក្រៅ និងខាងក្នុង។ ហើយយើងបានធ្វើវាអស់រយៈពេលជាច្រើនឆ្នាំ។ ហើយអ្នកបានអធិប្បាយប្រាប់គេរហូតទាល់តែសក់បានត្រលប់ទៅជាពណ៌ប្រផេះ ហើយក្បាលទំពែកទៅហើយ។ ហើយទីនេះ អ្នកបានឡើងមកនៅទីនេះឥឡូវនេះ ព្យាយាមនិយាយថា*រឿងនេះ*-ជា-*រឿងនោះ*។ ហើយមនុស្សជាច្រើនបានសើចចំអក ហើយបានគប់ផ្លែប៉េងប៉ោះមកលើជញ្ជាំងរបស់ទូកធំ។ ចូរមកចុះនេះហើយគឺជាអ្វីដែលពុកបានធ្វើ។ ហេតុអ្វី ពុកដឹងទេ..."

"ចូរអត់ធ្មត់ឡើង កូនប្រុស។"

"តើពុកច្បាស់ទេ?"

"វានឹងមានភ្លៀង!"

កូនប្រសាររបស់គាត់និយាយថា "ពុក តើពុកមានដឹងទេ..."

"វានឹងមានភ្លៀង!"

254 "ប៉ុន្តែយើងបានរង់ចាំវាអស់រយៈពេលជាច្រើនឆ្នាំទៅហើយ។ យើងបានរៀបចំហើយអ្នកបានប្រាប់ពួកយើងថាវានឹងមានភ្លៀង កាលពីអាទិត្យមុន។ ពួកយើងនៅក្នុងនេះហើយទ្វាទាំងអស់ត្រូវបានបិត ហើយយើងដើរចុះដើរឡើងនៅទីនេះ ហើយព្រះអាទិត្យបានរះឡើង ហើយលិចទៅវិញដូចសព្វមួយដង។"

"ប៉ុន្តែវានឹងមានភ្លៀង!"

"តើពុកដឹងបានយ៉ាងម៉េច?"

"ព្រះមានបន្ទូលយ៉ាងដូច្នេះ!"

255 ឥឡូវបើយើងមានវាយ៉ាងដូចនេះ ចូរបន្ថែមវាចុះ។ តែបើយើងមិនមានវាយ៉ាងដូចនេះទេ កុំ—កុំព្យាយាមបន្ថែមវាអី។ វាមិនដំណើរការទេ។ វាក៏មិនដំណើរការសំរាប់ការព្យាបាលដែរ។ ហើយវាក៏មិនដំណើរការលើអ្វីៗទាំងអស់ផ្សេងទៀតដែរ។ ឃើញទេ?វាត្រូវតែឲ្យស៊ីគ្នាជាមួយនឹងវត្ថុដែលវានឹងស្ថិតជាមួយនោះ។ ត្រូវហើយ។ ត្រូវតែបន្ថែមវា។ មានការអត់ធ្មត់ជាមួយនឹងសេចក្ដីសន្យារបស់ព្រះ។ បាទទាំងអស់គ្នា។ ណូអេបានជឿលើការទាំងនោះ។ ហើយគាត់បានមានការអត់ធ្មត់ជាមួយនឹងព្រះអស់រយៈពេលមួយរយម្ភៃឆ្នាំ។

256 ម៉ូសេ មានការអត់ធ្មត់ជាមួយនឹងព្រះ។ បាទ អ្នកទាំងអស់គ្នា។ "ម៉ូសេ អើយ អញបានឮសំរែករបស់ប្រជារាស្ត្រអញ។ អញបានឃើញការរងទុក្ខវេទនារបស់គេ។ អញនឹងចុះមករំដោះគេ គឺអញនឹងបញ្ជូនឲ្យឯងចុះទៅ។"

257 ហើយក៏មានភាពខុសគ្នារវាងគាត់ និងព្រះ ហើយព្រះបានបង្ហាញគាត់ពីសិរីល្អរបស់ទ្រង់ដោយបន្ទូលថា "អញនឹងទៅជាមួយឯង។" នៅពេលដែលគាត់បានឃើញសិរីល្អរបស់ព្រះ នោះគាត់ក៏មានសេចក្ដីជំនឿភ្លាម។

និយាយ "តើឯងមានអ្វីនៅនឹងដៃរបស់ឯង ម៉ូសេ?"

គាត់និយាយថា "ឈើច្រត់។"

ទ្រង់មានបន្ទូលថា "ចូរបោះវាចុះ។"

ហើយវាក៏បានត្រលប់ទៅជាពស់។ គាត់និយាយថា "ឱ ខ្ញុំអើយ!" ទ្រង់បានចាប់ផ្ដើម...

258 មានបន្ទូលថា "ម៉ូសេ ចូរឯងរើសវាឡើងមក បើអញអាចធ្វើវាឲ្យទៅជាពស់ នោះអញក៏អាចធ្វើវាឲ្យទៅជារបស់ដើមវិញបានដែរ។"

259 អា! [បងប្រុសប្រានហាំបានទះដៃចំនួនបីដង—Ed។] អាម៉ែន! បើព្រះអាចឲ្យខ្ញុំមានជីវិតខាងសាច់ឈាម នោះព្រះក៏អាចឲ្យខ្ញុំមានជីវិតខាងព្រលឹងវិញ្ញាណបានដែរ! បើព្រះអាចឲ្យខ្ញុំមានកំណើតទីមួយ នោះព្រះក៏អាចឲ្យខ្ញុំមានកំណើតទីពីរដែរ! អាម៉ែន! បើព្រះអាចព្យាបាលមួយ*នេះ*បាន ដោយការព្យាបាលដ៏អស្ចារ្យ នោះទ្រង់ក៏អាចនឹងលើសិរីល្អទ្រង់នៅថ្ងៃចុះក្រោយដែរ។ ត្រូវហើយ។

260 "អញអាចទំលាក់ដំបងនេះចុះ ហើយវាត្រលប់ទៅជាពស់ ហើយអញក៏អាចត្រលប់វាឲ្យទៅជាដំបងវិញបានដែរ។ ចូរចាប់កន្ទុយរបស់វា។"

261 ម៉ូសេបានលូកដៃទៅហើយចាប់វា។ គឺវាជាដំបង។ ហើយគាត់ក៏ចាប់ផ្ដើមបន្ថែមដំរិះនោះ។ ឃើញទេ?

"តើដៃរបស់ឯងមានបញ្ហាអ្វី ឥឡូវនេះ ម៉ូសេ?"

"គ្មានអ្វីទេ។"

"ចូរដាក់វានៅលើដើមទ្រូង។"

262 "ត្រូវហើយ។ ចុះ..." ពណ៌សជាមួយជំងឺឃ្លង់ "ឱ ព្រះអង្គអើយទតមកដៃកូន!"

"ដាក់វាទៅលើទ្រូវវិញទៅ ម៉ូសេ។"

263 គាត់ក៏បានដាក់វា*ដូច្នេះ* វាក៏បានត្រលប់ទៅជា...គាត់ក៏បានបន្ថែមវាយ៉ាង*ដូចនេះ*។ មើល បាទ លោក។

264 គាត់ចុះទៅទីនោះ។ ហើយភាពខុសគ្នា...គាត់បានចុះទៅទីនោះ។ ចេញមកពីទីនោះ ហើយនិយាយថា "ព្រះដ៏ជាអម្ចាស់មានបន្ទូលថា 'ចូរឲ្យរាស្ត្រអញចេញទៅ' ផារ៉ោនខ្ញុំចង់ឲ្យអ្នកបានដឹងអំពីរឿងមួយនេះ។ ខ្ញុំមកទីនេះគឺជាតំណាងរបស់ព្រះ។ អ្នកត្រូវតែធ្វើតាមខ្ញុំ។"

265 ផារ៉ោនមានបន្ទូលថា "ធ្វើតាម? តើអ្នកដឹងទេថាតើអញគឺជាអ្នកណា? អញគឺជាផារ៉ោន។ តើឲ្យអញធ្វើតាមឯងដែលជាទាសករ?"

266 និយាយថា "បើទ្រង់មិនធ្វើតាមគឺមានតែត្រូវទទួលទោស។ ទ្រង់អាចជ្រើសធ្វើបានតែមួយគត់ នូវអ្វីដែលទ្រង់បានរើស។" ហេតុអ្វី? គាត់បានដឹងថាគាត់កំពុងតែនិយាយអ្វី។ គាត់មានព័ន្ធកិច្ចដែលត្រូវបំពេញ។ គឺគាត់បាននៅទីនោះ។ គាត់បាននិយាយជាមួយព្រះ។ គាត់មានសេចក្ដីជំនឿ។ គាត់ដឹងថាគាត់នៅត្រង់ណា។

"ឯងចង់ឲ្យអញធ្វើតាមមែនទេ? ចេញពីទីនេះទៅ!"

"ខ្ញុំនិងបង្ហាញអ្នក"

"ចូរបង្ហាញខ្ញុំនូវទីសំគាល់មួយមក។"

គាត់បានបោះដំបងចុះទៅ ហើយវាក៏ត្រលប់ទៅជាពស់។

267 "ហេតុអ្វី" ទ្រង់មានបន្ទូលថា "វាគឺជាវេទមន្តថោកទាបតែប៉ុណ្ណោះ! ចូរមកទីនេះមួយភ្លែត។ មកទីនេះ យ៉ានេស និងយ៉ាមប្រេស ចូរបោះដំបងរបស់ឯងចុះ។" ពួកគេបានបោះវាចុះហើយវាក៏បានត្រលប់ទៅជាពស់។

268 និយាយ "ឥឡូវ ឯងដែលវេទមន្តថោកទាប ហើយបានមកឯអញ ជាជនជាតិអេស៊ីប ជាស្តេចផារ៉ោននៃប្រទេសអេស៊ីប។ ហើយឯងបានមកទីនេះជាមួយវេទមន្តអន់ៗ ហើយនឹង ការឆ្លិនភ្នែក" អ្នកចេះទាយគំនិតរបស់មនុស្ស។ ឯងយល់ពីអ្វីដែលអញនិយាយទេ។ ខ្ញុំសង្ឃឹមថាអ្នកបានអានវាហើយ។ "កាលដែលដឹងពីគំនិតរបស់អ្នកណាម្នាក់ ឬក៏រឿងអ្វីផ្សេងពីនេះ ដែរឯងមាន ហើយបានចុះមកឯទីនេះ។" និយាយថា "យើងក៏អាចធ្វើនូវអ្វីដែលឯងបានធ្វើដែរ។"

269 តើម៉ូសេគឺជាអ្វី? គាត់បាននិយាយថា"អូ លោកផារ៉ោន ខ្ញុំ—ខ្ញុំសុំអភ័យទោសលោក។ ខ្ញុំនឹងធ្វើជាទាសកររបស់លោក។" អត់ទេ លោក។

270 គាត់នៅឈរបន្តទៀត។ អាម៉ែន។ គឺនៅត្រង់នោះ។ ព្រះបានមានបន្ទូលោថាមិនឲ្យមានចម្ងល់អ្វីនៅក្នុងចិត្តគាត់ឡើយ។ "ចូររក្សាសេចក្តីអំណាររបស់ឯង។ អញនឹងបង្ហាញឲ្យឯងបានឃើញរឿងខ្លះ។" នៅពេលដែលអ្នកបានធ្វើនូវអ្វីដែលទ្រង់បានប្រាប់អ្នកឲ្យធ្វើហើយ តែយល់វាដូចជារឿងដែលមិនត្រឹមត្រូវ ចូរឈរឲ្យមាំមួនហើយមានការអត់ធ្មត់។

271 ម៉ូសេបាននិយាយថា "អ្នកដឹងទេនៅពេលដែលខ្ញុំផ្អែកទៅលើគ្រឹះមួយនោះគឺមានការអត់ធ្មត់នៅទីនោះដែរ ដូច្នេះខ្ញុំគ្រាន់តែរង់ចាំមើលថា តើព្រះទ្រង់នឹងធ្វើយ៉ាងណា។"

272 នៅទីនោះ ពស់ចាស់នោះបានវាចុះឡើង ហើយជ្រលរគ្នាទៅវិញទៅមក។ ការដំបូងដែល អ្នកដឹងនោះគឺ ពស់របស់ម៉ូសេ បានវា "គើម គើម គើម" ហើយលេបពស់ទាំងពីរផ្សេងទៀតអស់ទៅ។ គាត់មានការអត់ធ្មត់។

អស់អ្នកដែលរង់ចាំដល់ព្រះព្រះអម្ចាស់ នោះនឹងបាន
កំលាំងជាថ្មី។
ពួកគេនឹងត្រូវហើរឡើងទៅដោយស្លាប ដូចជាសត្វឥន្ទ្រី។
តើវាត្រូវទេ? [ពួកជំនុំនិយាយថា "អាម៉ែន"—Ed។] ឃើញទេ? បាទ។
ពួកគេនឹងរត់តែមិនហត់ឡើយហើយដើរក៏មិនខ្សោយដែរ។

មើលគ្រាន់តែរង់ចាំទ្រង់។ មានការអត់ធ្មត់។ ឃើញទេ? បាទ លោក។

273 រួចជនជាតិអ៊ីស្រាអែលនឹងត្រូវនាំយកចេញទៅ។ ភាពផ្ទុយគ្នាបានមកដល់ ហើយម៉ូសេបានរង់ចាំ។

274 រួចហើយគាត់បានទៅដល់ទីរហោស្ថាន។ គឺវាមានចំងាយប្រហែលបីឬបួនថ្ងៃ ប៉ុណ្ណោះក្នុងការធ្វើដំណើរ។ គឺវាមានចំងាយត្រឹមតែ សែសិបម៉ាលតែប៉ុណ្ណោះ ពីកន្លែងដែលគាត់បានឆ្លងកាត់ គឺជាកន្លែងដែលគាត់នឹងត្រូវឆ្លងកាត់ម្តងទៀត។ ប៉ុន្តែម៉ូសេនៅក្នុងទីរហោស្ថាន បានរង់ចាំអស់រយៈពេលសែសិបឆ្នាំ។ អត់ធ្មត់។ ប្រុងប្រុសប្រានហាំសើច—Ed។ អាម៉ែន។ ត្រឹមត្រូវហើយ។ គាត់បានរង់ចាំអស់រយៈពេលសែសិបឆ្នាំ។ អូ! បាទ អ្នកទាំងអស់គ្នា។

275 ហើយយើងក៏គួរតែមាន ការអត់ធ្មត់ចំពោះគ្នាទៅវិញទៅមកដែរ។ ឃើញទេ? ពេលមួយ…យើងមិន—មានភាពអត់ធ្មត់ចំពោះគ្នាសោះ។ យើងគិតថាយើងគួរតែបានដូចម៉ូសេ។ ម៉ូសេមានការអត់ធ្មត់ចំពោះប្រជាជន។ មើលនេះហើយគឺជាអ្វីដែលពួកគេមិនអាចរំលងបាន។ ឃើញទេ? បើអ្នកកំពុងតែព្យាយាមក្នុងការធ្វើអ្វីមួយ…

276 ដូចជាអ្វីដែលខ្ញុំព្យាយាមយកព្រះរាជសារមកនៅលើរោងឧបោសថនេះ ដើម្បីឲ្យបានដឹងថា គ្រប់ទាំងសមាជិកនៃរោងឧបោសថបានក្លាយទៅជា*យ៉ាងនេះ*។ វាគឺជារឿងដែលមិនងាយក្នុងការធ្វើទេ។ ខ្ញុំព្យាយាមក្នុងការមានភាពអត់ធ្មត់ នេះគឺសាមសិបបីឆ្នាំហើយ។ ឃើញទេ? មានការអត់ធ្មត់។ ស្ត្រីៗនៅតែកាត់សក់ខ្លី គឺវានៅតែដដែលទេ។ ប៉ុន្តែត្រូវមានការអត់ធ្មត់។ ឃើញទេ? គ្រាន់តែមានការអត់ធ្មត់។ រង់ចាំ។ ត្រូវតែ។ បើអ្នកមិនមានការទាំងនេះទេ កុំព្យាយាមបង្កើតវានៅ*ទីនេះ*។ ត្រូវមានការអត់ធ្មត់។

277 សូម្បីតែមួយដង ពួកបះបោរមួយក្រុមដែលមិនមានភាពអត់ធ្មត់ បានធ្វើឲ្យម៉ូសេធ្វើការមួយដែលខុសឆ្គង។ ប៉ុន្តែដល់ពេលមួយព្រះទ្រង់មិនសព្វព្រះទ័យ នឹងទង្វើរបស់គេ។ ទ្រង់បានមានបន្ទូលថា "ចូរឯងញែកខ្លួនចេញទៅម៉ូសេ អញនឹងសម្លាប់ក្រុមមនុស្សទាំងអស់នោះ ហើយនឹងចាប់ផ្តើមជាថ្មី។"

278 គាត់បានក្រាបខ្លួនដល់ដីហើយនិយាយថា "សូមទ្រង់កុំធ្វើដូច្នេះអី។" ជាអ្វីទៅ? អត់ធ្មត់ជាមួយនឹងមនុស្សដែលបានបះបោរប្រឆាំងនឹងគាត់។

279 ខ្ញុំឆ្ងល់តើយើងអាចនឹងធ្វើយ៉ាងនឹងបានយ៉ាងណា? បើអ្នកមិនអាចទេសុំកុំព្យាយាមបង្កើត*ការនេះ* ពីព្រោះវា—វាមិនអាចផ្លាស់ប្តូរអ្វីបានទេ អ្នកដឹងទេ។ នេះគឺជាវិធីដែលវត្ថុទីមួយបានស្អិតជាប់ទៅលើ*ការនេះ* ហើយនេះក៏ជាវិធីដែលគ្រប់ទាំងរបស់ទាំងអស់ត្រូវស្អិតជាប់ដែរ។ បើអ្នកមិនមែនទេ អ្នកមិនចាំបាច់មកដល់ចំនុចដែលជាកន្លែងដែលព្រះគង់នៅនោះទេ បើអ្នកមិនទាន់មានការអត់ធ្មត់ ការអត់ធ្មត់ចំពោះគ្នាទៅវិញទៅមក។ ត្រូវហើយ។

280 កូនចៅហេព្រើរមានការអត់ធ្មត់។ ពួកគេមានប្រាកដមែន។ ព្រះបានសន្យានឹងគេដោយបន្ទូលថា "ចូរឯងកុំក្រាបថ្វាយបង្គំចំពោះព្រះដទៃណាឡើយ។" ប៉ុន្តែពួកគេមានការអត់ធ្មត់។ និយាយ "ព្រះរបស់យើងអាចធ្វើបាន តែទោះជាយ៉ាងណាក៏យើងមិនថ្វាយបង្គំដល់ព្រះដទៃរបស់អ្នកដែរ។" ការអត់ធ្មត់ ដោយបានដឹងថាព្រះនឹងប្រោះពួកគេនៅថ្ងៃចុងក្រោយម្តងទៀត។

281 ជាចុងក្រោយជីវិតមួយនេះមិនមានន័យប៉ុន្មានទេ។ ឃើញទេ? ព្រះនឹងប្រោសពួកគេវិញនៅថ្ងៃចុងក្រោយ។ តែបើឲ្យយើងថ្វាយបង្គំព្រះដទៃនោះយើងមិនធ្វើដាច់ខាត។ ឥឡូវយើងនឹងឲ្យអ្វីដែលជារបស់សេសាទៅសេសាវិញ តែអ្វីដែលសេសាបានជ្រៀតជ្រែកដល់ព្រះ នោះគឺព្រះជាទីមួយវិញ។

282 "ព្រះមានបន្ទូល 'ចូរឯងកុំថ្វាយបង្គំរូបសំណាកឡើយ។' ហើយយើងនឹងមិនធ្វើវាឡើយ។ ព្រះរបស់យើងអាចនឹងសង្គ្រោះយើងបាន។ ទោះជាទ្រង់មិនក៏ដោយក៏ខ្ញុំនៅតែមិនថ្វាយបង្គំព្រះដទៃដែរ។"

និយាយ "មិនថ្វីទេអញ្ចឹងមាននៅទីនោះ។"

283 "មិនអីទេ" គាត់និយាយថា "អូ ខ្ញុំទាយថា នឹងមានភ្លៀងជាខ្លាំង ហើយនឹងដាក់វាទាំងអស់ទៅក្រៅ។" ប៉ុន្តែកុំធ្វើវា ត្រូវតែបន្តការអត់ធ្មត់។

284 នៅព្រឹកស្អែក ពេលដែលគេត្រូវបានយកមកជំនុំជំរះ ដោយស្តេចនេប៊ូក្នេសា។ ទ្រង់មានបន្ទូលថា "បានហើយ តើអ្នកទាំងអស់គ្នាត្រៀមខ្លួននឹងចងចាំខ្ញុំជាស្តេចរបស់អ្នកហើយឬនៅ?"

"ពិតណាស់ សូមឲ្យព្រះអង្គមានព្រះជន្មយឺនយូរ។"

"ឥឡូវចូរថ្វាយបង្គំរូបសំណាក់របស់យើងទៅ។"

"អូ អត់ទេ។"

285 "ល្អអ្នកនឹងត្រូវគេដុត។ អ្នកទាំងអស់គ្នាគឺជាអ្នកប្រាជ្ញ។ អ្នកទាំងអស់ឆ្លាត។ អ្នកបានក្លាយទៅ ជាជំនួយដ៏ធំរបស់យើង។ អ្នកបានក្លាយទៅព្រះពរដ៏ជាតិសាសន៍របស់យើង។ តើអ្នកមិនយល់ទេឬអី យើងមិនចង់ឲ្យអ្នកទាំងអស់គ្នាធ្វើដូច្នេះទេ? តែខ្ញុំ—ខ្ញុំបានប្រកាសហើយ ហើយវាក៏នឹងត្រូវសម្រេចតាមនឹងដែរ។ យើងមិនចង់បោះអ្នកទាំងអស់គ្នាចូលទៅក្នុងនោះទេ។ ឱ អ្នកទាំងអស់គ្នាអើយ តើមានរឿងអ្វីកើតឡើងចំពោះអ្នក?"

286 "ខ្ញុំដឹងថា វាដូចជាមិនមានរឿងអ្វីនោះទេ ប៉ុន្តែព្រះរបស់យើងអាចនឹងជួយយើងបាន ប៉ុន្តែទោះជាយ៉ាងណា..." មានការអត់ធ្មត់។

287 ចាប់ផ្តើមដើរឡើងទៅតាមច្រក។ ម្នាក់មើលទៅឯម្នាក់ទៀត។ "វាមិនថ្វីទេ។ ត្រូវហើយ។" មានការអត់ធ្មត់។ នៅពេលឈានមួយជំហាន ព្រះមិនបានគង់នៅទីនោះ។ ឈានជំហានទីពីរ ព្រះមិនបានគង់នៅទីនោះ។ ជំហានទីបីជំហានទីបួន ជំហានទីប្រាំ គឺគ្រាន់តែនៅបន្តទៀត ហើយព្រះក៏នៅតែមិនបានគង់នៅទីនោះ។ ហើយគេបានឈានដើរចូលក្នុងឡភ្លើង។ ពួកគេមានការអត់ធ្មត់។ ប៉ុន្តែគឺទ្រង់គង់នៅទីនោះ។ ឃើញទេ? គឺមានភ្លើងល្មមនឹងអាចដុតឆេះច្រវាក់ដែលនៅដៃហើយនិងជើងគេប៉ុណ្ណោះ។ រួចហើយនៅពេល ដែលគាត់បានទៅដល់ខាងក្រោមនៃរណ្តៅនោះ គឺទ្រង់បានគង់នៅទីនោះ។ ឃើញទេ? ពួកគេមានការអត់ធ្មត់។

288 ដានីញ៉ែលក៏ដូចគ្នាដែរ។ គាត់មានការអត់ធ្មត់ ពិតណាស់។ គាត់បំរុងនឹងឈប់ អត់ទេលោក។ តើគាត់បានធ្វើអ្វី? គាត់បានបើកបង្អួចឡើងហើយអធិស្ឋានទោះជាមានអ្វីកើតឡើងក៏ដោយ។ នេះគឺជាអ្វីដែលព្រះសព្វព្រះហឫទ័យឲ្យគាត់ធ្វើ។ គាត់មានការអត់ធ្មត់។ គាត់បានរង់ចាំព្រះ ដោយបានដឹងថា ទ្រង់រក្សាសេចក្តីសន្យាទ្រង់។ គេបានបោះគាត់ចូលទៅក្នុងរោងតោ ដោយនិយាយថា "សូមឲ្យតោស៊ីឯងទៅចុះ។"

289 គាត់និយាយថា "វាមិនថ្វីទេ។" គាត់មានការអត់ធ្មត់។ ហេតុអ្វី? "ដ្បិតខ្ញុំបានរង់ចាំព្រះគ្រប់ពេលវេលាទៅហើយ។ ហើយបើខ្ញុំត្រូវរង់ចាំប៉ុន្មានពាន់ឆ្នាំទៀត ខ្ញុំនឹងរស់ឡើងវិញនៅថ្ងៃចុងក្រោយ។ ដូច្នេះគួរតែមានការអត់ធ្មត់ ហើយរង់ចាំ។"

290 សាវ័កប៉ុលមានការអត់ធ្មត់។ គាត់ពិតជាមានការអត់ធ្មត់មែន។ ចូរមើលពីអ្វីដែលគាត់ត្រូវធ្វើ។ និយាយពីការអត់ធ្មត់!

291 ចុះយ៉ាងម៉េចវិញចំពោះអ្នកពេនទីកុស្ត? ឲ្យតែពួកគេមានប៉េសកកម្ម "ចាំរហូត" មើល "រង់ចាំរហូតទាល់តែអ្នកបានពោពេញដោយអំណាច។" តើវាយូរប៉ុណ្ណា? ពួកគេមិនចាំបាច់សួរថា តើវានឹងមានរយៈពេលប៉ុន្មាននោះទេ? គឺពួកគេគ្រាន់តែមានចម្លើយថា "ចាំរហូត។"

292 ពួកគេបានឡើងទៅទីនោះហើយនិយាយថា "ត្រូវហើយ ក្មេងៗទាំងអស់គ្នា ប្រហែលជាដប់ប្រាំនាទីទៀត ព្រះវិញ្ញាណបរិសុទ្ធ នឹងមកសណ្ឋិតលើយើង ហើយយើងនឹងមានព័ន្ធកិច្ចរបស់យើង។" ដប់ប្រាំនាទីកន្លងផុត គ្មាននណាម្នាក់។ មួយថ្ងៃក្រោយមកក៏គ្មាន ពីរ បី បួនប្រាំ ប្រាំមួយ ប្រាំពីរ។

293 ពួកគេមួយចំនួនអាចនឹងនិយាយថា "អេ តើអ្នកមិនគិតទេថា យើងបានទទួលវារួចហើយនោះ?"

"ទេ ទេ ទេ ទេ។" នេះហើយ។ ទេ។ ត្រូវហើយ។

294 "អ្នកគួរតែចេញមកក្មេងប្រុស។" សាតាំងនិយាយថា "អ្នក—អ្នក—អ្នកទាំងអស់គ្នាបានទទួលនូវអ្វីដែលអ្នកចង់បានហើយ។ ចូរចេញទៅ ហើយចាប់ផ្តើមព័ន្ធកិច្ចរបស់អ្នកទៅ។"

295 "ទេ ទេ ទេ។" យើងមិនទាន់បានទទួលវានៅឡើយទេ។ ដ្បិតទ្រង់មានបន្ទូលថា 'នោះនឹងមានអ្វីដែលនឹងកើតឡើងនៅថ្ងៃចុងក្រោយៈ ខ្ញុំនឹងនិយាយជាមួយនឹងមនុស្សទាំងអស់នេះដោយពាក្យត្រដិត ហើយនឹងភាសាដទៃ ហើយនេះគឺអ្វីផ្សេងទៀតដែលខ្ញុំបាននិយាយ' ចូរមើលនៅក្នុងអេសាយ២៨:១៩។" ចែងថា "នេះ—នេះហើយគឺជាវា អ្នក—អ្នកនឹងបានទទួលវានៅពេលដែល...ហេតុអ្វី យើងនឹងបានដឹងនៅពេលដែលវាមក។ យើងនឹងបានដឹងនៅពេលដែលវាមក។ យើងនឹងដឹងវា 'ជាសេចក្តីសន្យារបស់ព្រះបិតា។'" នៅទីនោះគាត់បានរង់ចាំអស់រយៈពេលប្រាំបួនថ្ងៃ។ រួចហើយនៅថ្ងៃទីដប់ "ពួកយើងបាននៅទីនោះ។" ពួកគេមានការអត់ធ្មត់ក្នុងការរង់ចាំ។

296 ឥឡូវបើយើងមានការអត់ធ្មត់បែបដូចនេះ បន្ទាប់ពីព្រះបានសន្យាដល់អ្នក ហើយអ្នកបានឃើញនៅក្នុងព្រះគម្ពីរ "នេះគឺជារបស់ខ្ញុំ" រួចចូររង់ចាំចុះ។ រួចបើអ្នកមានការអត់ធ្មត់ប្រភេទនេះ ចូរបន្ថែមទៅលើសេចក្តីជំនឿរបស់អ្នកចុះ។ ហើយចាំមើលថាតើអ្នកអាចឡើងបានដល់កំរិតណាឥឡូវ? អ្នកកំពុងតែឡើង

មកដល់*ទីនេះ*ហើយឥឡូវនេះ។ ត្រូវហើយ ឯនាឡិកាដៃក៏មានរាងមូលដែរ ត្រូវទេ? ត្រូវហើយត្រូវហើយ ចូរបន្ថែមវាចូលក្នុងសេចក្ដីជំនឿរបស់អ្នក។

297 តែងតែដាក់ទ្រង់នៅខាងមុខយើងជានិច្ច ដោយចាំថា គឺជាទ្រង់ហើយដែលបានសន្យា។ មិនមែនជាខ្ញុំទេដែលបានសន្យា។ មិនមែនជាគ្រូគង្វាលបានសន្យា ឬក៏ប្អូនប្រុសនីវៀលទេ។ វាក៏មិនមែនជាអ្នកផ្សាយដំណឹងល្អខ្លះបានសន្យាដែរ។ វាក៏មិនមែនជាបូជាចារ ឬក៏ជនល្បីណាដែរ។ គឺគ្មានអ្នកណាម្នាក់នៅលើផែនដីនេះដែរ។ តែគឺជាព្រះវិញដែលបានសន្យាមក ហើយព្រះអាចនឹងសម្រេចគ្រប់ការទាំងអស់ដែលទ្រង់បានសន្យា។ ត្រូវហើយ។ បើអ្នកមានសេចក្ដីជំនឿប្រភេទនេះដែលដឹងថាព្រះទ្រង់បានសន្យា! និយាយថា "បងប្រុសប្រានហាំ ខ្ញុំឈឺ។ ខ្ញុំត្រូវការការព្យាបាលសំរាប់ការឈឺចាប់របស់ខ្ញុំ។" ទទួលវាចុះ នេះគឺជាអំណោយទានដែលបានប្រទានមកដល់អ្នក បាទ អ្នកទាំងអស់គ្នា បើអ្នកអាចជឿ។ "បាទ" អ្នកនិយាយថា "ខ្ញុំជឿ។" រួចចូរបំភ្លេចវាចុះ។ មានតែប៉ុណ្ណឹង ប៉ុណ្ណឹងចប់ហើយ។ ឃើញទេ?

298 មានការអត់ធ្មត់ បើអ្នកមានការអត់ធ្មត់។ បើអ្នកមិនមានទេ អ្នកនឹងត្រូវធ្វើឲ្យខ្មោចចេញពីអាគារនេះចេញទៅក្រៅ។ ឃើញទេ វានឹងបំផ្លាញការអ្វីដែលសេះសល់ទាំងអស់ចោល មិនសល់សូម្បីតែមួយ។ អ្នកត្រូវតែមានវា។ កុំបន្ថែមវា ពីព្រោះវានឹងអាចឲ្យអាគាររបស់អ្នករលំចុះ បើអ្នកមិនទាន់មានការអត់ធ្មត់ បើអ្នកមិនទាន់មានសេចក្ដីទៀងត្រង់ ដើម្បីបន្ថែមទៅក្នុងសេចក្ដីជំនឿរបស់អ្នក ដែលអ្នកបាននិយាយថាអ្នកមាន។ ហើយបើអ្នកមិនទាន់មានសេចក្ដីជំនឿទេ ហើយព្យាយាមបន្ថែមសេចក្ដីទៀងត្រង់ទៅលើវា នោះវានឹងបំផ្លាញសេក្ដីជំនឿរបស់អ្នក។ ឃើញទេ? អ្នកនិយាយថា "សូមចាំមួយភ្លែតនេះប្រហែលជាការយល់ច្រលំទេ។ ប្រហែលជាមិនមែនជាព្រះទេ។ ប្រហែលជានៅលើលោកនេះមិនមានព្រះទេ។" ឃើញទេ វានឹងបំបែកការទាំងនោះទៅជាពីរ។ ឃើញទេ?

299 ប៉ុន្ដែបើអ្នកមានសេចក្ដីជំនឿដ៏ពិត រួចចូរបន្ថែមសេចក្ដីទៀងត្រង់ដ៏ពិតទៅលើវារួចហើយដំរិះដ៏ពិត រួចហើយសេចក្ដីអត់សង្កត់ចិត្តដ៏ពិត រួចហើយការខ្ជាប់ខ្ជួនដ៏ពិត។ ឃើញទេ? អ្នកកំពុងតែធ្វើដំណើរឡើងតាមផ្លូវត្រឹមត្រូវ។ ត្រូវហើយ។

300 ទីប្រាំចូរបន្ថែមការចេះគោរពប្រតិបត្តិដល់ព្រះ។ អូខ្ញុំអើយ! ការចេះគោរពប្រតិបត្តិដល់ព្រះត្រូវបន្ថែម។ តើការចេះគោរពប្រតិបត្តិដល់ព្រះមានន័យដូចម្ដេច? ខ្ញុំបានឆែកមើលវចនានុក្រមបួនប្រាំហើយ តែមិនបានដឹងថាតើវា

មានន័យថាយ៉ាងណាដែរ។ ចុងក្រោយខ្ញុំបានមកជួបប្អូនប្រុសយ៉េហ្វ្រឹ នៅទីនោះ យើងបានរក— ឃើញន័យរបស់វានៅក្នុងវចនានុក្រម។ *ការចេះគោរពប្រតិបត្តិដល់ព្រះ*គឺមានន័យថា "ឲ្យបានដូចជាព្រះ។" ឱ ខ្ញុំអើយ! បន្ទាប់ពីអ្នកមានសេក្តីជំនឿហើយ សេចក្តីទៀងត្រង់ ដំរិះ សេចក្តីអត់ធ្មត់សង្កត់ចិត្ត ខ្ជាប់ខ្ជួន រួចឲ្យបានដូចព្រះ។ វើវ!

301 អ្នកនិយាយថា "ខ្ញុំមិនអាចធ្វើដូច្នេះបានទេ បងប្រុសប្រានហាំ។" អូ បាទអ្នកអាចធ្វើបាន។

302 សូមឲ្យខ្ញុំបានអានបទគម្ពីរមួយចំនួន សំរាប់អ្នកតែប៉ុន្មាននាទី ប៉ុណ្ណោះ។ ម៉ាថាយ ៥:៤៨។ យើងនឹងយកខ មួយនេះហើយចាំមើលថាវាមានន័យយ៉ាណា ម៉ាថាយ ៥:៤៨ ហើយនឹងមើលថាតើយើងគួរតែឲ្យបានដូចព្រះឬយ៉ាងណា។ អ្នកដឹងទេព្រះគម្ពីរបានសំដែងថា "អ្នកគឺដូចជាព្រះ" ព្រះយេស៊ូវមានបន្ទូលដូច្នេះ។ ហេតុអ្វី? គ្រប់ទាំងសេចក្តីទៀងត្រង់ គ្រប់ទាំងរបស់ទាំងអស់ដែលនៅក្នុងព្រះ គឺនៅក្នុងយើង។ ម៉ាថាយ ៥:៤៨ "ចូរឲ្យអ្នក..."ព្រះយេស៊ូវមានបន្ទូលប្រសិទ្ធិពរ។

> *ចូរឲ្យអ្នកទាំងអស់គ្នាបាន គ្រ-ប់-ល-ក្ខ-ណ៍* (អ្វីនឹង?) *គ្រប់លក្ខណ៍ ដូចដែលព្រះបិតារបស់អ្នក...ដែលគង់នៅស្ថានសួគ៌បានគ្រប់លក្ខណ៍។*

303 អ្នកបានមានផ្លូវឡើងមក*ទីនេះ*ហើយឥឡូវ ពីមុនអ្នកត្រូវបានប្រាប់ឲ្យធ្វើវា។ គ្រប់ទាំងការទាំងអស់នេះត្រូវតែបានបន្ថែមជាមុនសិន។ រួចហើយនៅពេលអ្នកមកដល់ទីនេះ ទ្រង់ឲ្យអ្នកបានជាគ្រប់លក្ខណ៍ឥឡូវ ការចេះគោរពប្រតិបត្តិដល់ព្រះ ជាបុត្រធីតា របស់ព្រះ។ ត្រូវហើយ ។ មានរឿងប៉ុន្មានដែលខ្ញុំអាចនិយាយអំពីវា!

304 ចូរបើកអេភេសូរ ជំពូកទី៤ ហើយស្វែងរកនៅក្នុងកាន់គម្ពីរអេភេសូរ ដែលបាននិយាយអំពីរឿងនេះដែរ គឺថាតើយើងនឹងធ្វើ—តើយើងនឹងធ្វើយ៉ាងណា។ អេភេសូជំពូកទីបួន ហើយចាប់ផ្តើមនៅខទី១២។ អេភេសូជំពូកទី៤ចាប់ពីខទី១២។ ត្រូវហើយ។ សូមចាប់ផ្តើមនៅក្នុងខទី១១។

> *ហើយទ្រង់បានប្រទានឲ្យអ្នកខ្លះធ្វើជាសាវ័ក ខ្លះជាគ្រូអធិប្បាយ ...*

305 ចាំទេកាលពីយប់មិុញ?កុំព្យាយាមយកន្លែងរបស់អ្នកផ្សេងឡើយ។ មើល?

*...ខ្លះជាគ្រូផ្សាយដំណឹងល្អខ្លះជាគ្រូគង្វាល...ហើយខ្លះជាគ្រូបង្រៀន*

306 "សំរាប់ភាពគ្រប់លក្ខណ៍របស់ព្រះ"? តើវាអានយ៉ាងនេះមែនទេ? [ពួកជំនុំនិយាយថា "អត់ទេ។"—Ed។] តើជាភាពគ្រប់លក្ខណ៍ជាអ្វី? ["ពួកបរិសុទ្ធ។"] តើពួកបរិសុទ្ធជាអ្នកណា? គឺជាពួកអ្នកដែលបានញែកចេញ។ អាម៉ែន គឺជាម្នាក់ដែលបានចាប់ផ្ដើមតាំងពីខាងក្រោម*នេះ*។

*...នាំឲ្យពួកបរិសុទ្ធរបស់ព្រះបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើ ព័ន្ធកិច្ច* (ព័ន្ធកិច្ចនៃព្រះគ្រីស្ទ) *ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង* (ស្អាងរូបកាយព្រះគ្រីស្ទឡើង ស្អាងឡើង) *ទាល់តែ...*

*ទាល់តែយើងរាល់គ្នាបានរួបរួមគ្នា ខាងឯសេចក្ដីជំនឿរួចជាស្រេចហើយ...បានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ជាអ្នកធានា* (អូខ្ញុំអើយ) *ហើយដល់ខ្នាតកំពស់នៃសេចក្ដីពោពេញផងព្រះគ្រីស្ទ:*

307 "*ភាពគ្រប់លក្ខណ៍*" ត្រូវការការចេះគោរពប្រតិបត្ដិដល់ព្រះ។ អ្នកត្រូវតែបន្ថែមការចេះគោរពប្រតិបត្ដិដល់ព្រះទៅលើសេចក្ដីជំនឿរបស់អ្នក។ ឃើញទេ គឺអ្នក ចាប់ផ្ដើម *ទីនេះ* ជាមួយភាពស្មោះត្រង់។ រួចហើយអ្នកទៅដល់ការអត់ធ្មត់សង្កត់ ចិត្ត។ រួចអ្នកទៅដល់សេចក្ដីអត់ធ្មត់។ ឥឡូវអ្នកកំពុងតែនៅក្នុងការចេះគោរព ប្រតិបត្ដិដល់ព្រះ។ ការចេះគោរពប្រតិបត្ដិដល់ព្រះ! ឱ ខ្ញុំអើយ! ពេលវេលារបស់យើងកំពុងតែដើរទៅមុខ។ ចូរមើល។ តើអ្នកដឹងទេថាការចេះគោរពប្រតិបត្ដិដល់ព្រះមានន័យថាម៉េច។ អ្នកបានច្រៀងបទចំរៀងមួយនេះ៖

ឲ្យបានដូចព្រះយេស៊ូវ ឲ្យបានដូចព្រះយេស៊ូវ
នៅលើផែនដីខ្ញុំចង់ឲ្យបានដូចទ្រង់
អស់ទាំងដំណើរជីវិតរបស់ខ្ញុំពីផែនដីទៅសិរីល្អ
ខ្ញុំសុំតែម្យ៉ាងគត់ គឺឲ្យបានដូចទ្រង់។

308 ការចេះគោរពប្រតិបត្ដិដល់ព្រះនោះ។ នៅពេលដែលគាត់ត្រូវបានគេទះនៅថ្ពាល់ម្ខាង គាត់បែរម្ខាងទៀតទៅដល់គេ។ នៅពេលដែលមានគេនិយាយពាក្យមិនល្អដល់គាត់ គាត់មិនតបត។ គាត់មិនតបតវិញ។ ឃើញទេ? ភាពដូចជាព្រះ

តែងតែស្វែងរកវត្ថុម៉្យាង "ខ្ញុំនឹងធ្វើអ្វីដែលព្រះបិតាសព្វព្រះទ័យប៉ុណ្ណោះ។" ឃើញទេ? បាទ លោក។ តែងតែមានការចេះគោរពប្រតិបត្តិដល់ព្រះ។ ឃើញទេ?

309 បន្ទាប់ពីអ្នកបានមកពី*ទីនេះ* ទៅទីនេះ ទៅទីនេះ ទៅទីនេះ ទៅទីនេះ ទៅទីនេះ ឥឡូវអ្នកមកដល់ចំនុចនៃភាពពេញលេញជាកូនរបស់ព្រះ។ ប៉ុន្តែអ្នកត្រូវតែមាន*មួយនេះ* ថែមទាំងអស់នេះ ហើយអ្នកក៏មិនអាចចាប់ផ្តើមបានដែររហូតទាល់តែមានមួយ*នេះ*។

310 ឥឡូវចូរចងចាំ អំពីចាបខ្មៅដែលពាក់រោមក្ងោក។ សុំកុំភ្លេចវា។ ឃើញទេ? សូមកុំព្យាយាមបន្ថែមវា រហូតទាល់តែអ្នកបានកើតជាថ្មី។ ពីព្រោះវាមិនអាចទៅរួចហើយ អ្នក—អ្នកក៏មិនអាចធ្វើឲ្យវាទៅរួចបានដែរ។ វានឹងមកឯ*ទី*នេះ ឬក៏ទីនេះ ហើយវានឹងខ្ទេចទៅនៅកន្លែងណា មួយ។

311 ប៉ុន្តែនៅពេលដែលអ្នកបានមកដល់ក្រោម*នេះ* ជាសត្វព្រាបដែលបានកើតជាថ្មីដ៏ពិត រួចហើយយើងមិនអាចនឹងមិនបន្ថែមអ្វីនោះទេ។ វាបន្ថែមមកអ្នក មើលវានឹងមកឯអ្នក ត្រូវហើយ មកដល់ភាពគ្រប់លក្ខណ៍ឥឡូវនេះ។ ត្រូវហើយ។

312 រួចហើយទីប្រាំមួយ ចូរបន្ថែម ព្រះបន្ទូលបានសំដែងថា ការស្រឡាញ់គ្នាជាបងប្អូន…ការរាប់អានគ្នាជាបងប្អូន។ ឥឡូវមានអ្វីដែលល្អមួយនៅទីនេះ គឺទីប្រាំមួយ ទីប្រាំពីរ។ ត្រូវហើយ។ បន្ថែមការរាប់អានគ្នាជាបងប្អូន។ ត្រូវហើយ។ នៅពេលដែលយើងបានមកដល់ទីនោះ ការរាប់អានគ្នាជាបងប្អូន សូមដាក់ខ្លួនអ្នកផ្ទាល់ទៅលើការនោះ។ ឥឡូវអ្នកនិយាយថា…

313 "បងប្អូនខ្ញុំបានធ្វើខុសនឹងខ្ញុំ" ពេត្រុសនិយាយ។ "តើខ្ញុំគួរអត់ទោសឲ្យគេទេ" គាត់និយាយថា "ប្រាំពីរដងក្នុងមួយថ្ងៃ?"

គាត់និយាយថា "ចិតសិបគុណនឹងប្រាំពីរដង។" ឃើញទេ?

314 ការរាប់អានគ្នាជាបងប្អូន។ ឥឡូវអ្នកបានដឹងហើយ បើមានបងប្អូនណាមិនស្រួល សូមកុំអស់ការអត់ធ្មត់នឹងគាត់ឡើយ។ ឃើញទេ? អត់ទេ។ ឃើញទេ? ចូរមានចិត្តសប្បុរសនឹងគាត់។ ទោះក្នុងសភាពយ៉ាងណាក៏ដោយ។

315 អ្នកខ្លះនិយាយថាមិនយូរប៉ុន្មានទេ "តើអ្នកអាចជឿរឿង អស់ទាំងនេះបានយ៉ាងម៉េច ហើយ អ្នកខ្លះទៅក្រុមជំនុំព្រះជាម្ចាស់ និង ភាពតែមួយ?" រួចចូរបន្ថែមការរាប់អានគ្នាជាបងប្អូន។ ឃើញទេ? ឃើញទេ? សង្ឃឹមថានៅថ្ងៃណាមួយអាច

អត់ធ្មត់នឹងគាត់ អត់ធ្មត់សង្កត់ចិត្តនឹងគាត់ ស៊ូទ្រាំនឹងគាត់ ឲ្យបានដំរិះពីអ្វីដែលគាត់ជឿ ចងចាំថាវាគឺនៅក្នុងចិត្តរបស់គាត់ គឺជា ទៀងត្រង់នៅក្នុងអ្នក ដើម្បីឲ្យវាហូរចេញដោយសេចក្តីសប្បុរស ដោយសុភាពដល់គាត់ មានសង្ឃឹមថានៅថ្ងៃណាមួយព្រះនឹងនាំគាត់ចូលមក។ ឃើញទេ?

316 ការរាប់អានគ្នាជាបងប្អូន គឺជាចំនុចទីប្រាំពីរ។ មួយ ពីរ បី បួន ប្រាំ ប្រាំមួយ ប្រាំពីរ។ [បងប្រុសប្រានហាំបានគោះលើក្តាខៀនចំនួនប្រាំពីរដង—Ed។] ឃើញទេ ទីប្រាំពីរ។ រួចហើយឥឡូវអ្នកកំពុងតែមក។

317 ចំនុចបន្ទាប់ រួចចូរបន្ថែមសេចក្តីសប្បុរស ដែលជាសេចក្តីស្រឡាញ់។ នេះហើយគឺជាការដែលធំជាងគេបង្អស់។ នៅថ្ងៃណាមួយ នៅក្នុងក្រុមជំនុំ...

318 ឥឡូវនេះសូមឱ្យបានឮនៅក្នុងកាសែតថតសំលេង នឹងនៅជាអង្វែងតទៅ អ្វីដែលខ្ញុំនឹងនិយាយឥឡូវនេះ ខ្ញុំមិនបានបង្រៀនការទាំងនេះឲ្យដូចជាគោលលទ្ធិនោះទេ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់បង្ហាញអ្នកថា តាមរយៈការជួយរបស់ព្រះ នូវអ្វីដែលជាការពិតនោះ គឺថាព្រះគម្ពីរទីមួយដែលព្រះបានសរសេរឡើងគឺផ្កាយក្នុងផ្ទៃមេឃ។ គឺវាចាប់ផ្តើមឡើងដោយស្ត្រីព្រហ្មចារី។ វាបានបញ្ចប់ទៅវិញជាមួយនឹងតោឈ្មោះ លីអូ។ ហើយនៅពេលដែលខ្ញុំបានមកដល់ត្រាទីប្រាំមួយ និងប្រាំពីរ អ្នកនឹងបានដឹង នៅពេលដែលត្រាផ្សេងទៀតត្រូវបានបើកឡើង នោះសញ្ញាសំគាល់របស់សូឌីកនិយម នៅទីនោះគឺជាមហារីករបស់ត្រីដែលបានឆ្លងកាត់។ ហើយនេះគឺជាពេលវេលានៃរាគមហារីកដែលយើងបាន និងកំពុងតែរស់នៅរាល់ថ្ងៃ។ ហើយការមួយទៀតដែលត្រានោះបញ្ចេញមក នោះគឺជាតោឈ្មោះថា លីអូ គឺការត្រលប់មកវិញជាលើកទីពីររបស់ព្រះគ្រីស្ទ។ ទ្រង់បានយាងមកលើកទីមួយ ដោយនាងព្រហ្មចារី ទ្រង់យាងមកលើកទីពីរគឺតោឈ្មោះលីអូ។ ខ្ញុំនឹងនាំការនេះទៅ...

319 ឥឡូវខ្ញុំមិនដឹងថាតើខ្ញុំមានពេលទេនៅព្រឹកនេះ។ ខ្ញុំនឹងធ្វើឲ្យបានល្អបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីបង្ហាញអ្នកទាំងអស់គ្នាថា ជំហាននេះគឺទៅតាមរូបពីរ៉ាមីតគឺដូចទៅនឹង ព្រះគម្ពីរទីពីរដែលព្រះបានសរសេរ។ អេណុកបានសរសេរវាហើយបានដាក់វានៅក្នុងពីរ៉ាមីត។

320 ហើយទីបី ព្រះអង្គតែងតែបានគ្រប់លក្ខណ៍ នៅទីបី រួចហើយទ្រង់បានបង្កើតព្រះបន្ទូលទ្រង់មក។

321 ទីនេះ ឥឡូវនេះ ចូរចាំ នៅក្នុងពីរ៉ាមីត...ខ្ញុំគិតថាមានទាហាន ហើយនិងរបស់ជាច្រើននៅប្រទេសអេស៊ីប។ ពីរ៉ាមីតមិនមានដំបូលនៅលើវាទេ។ មិនដែលមាន។ ដុំ—ដុំថ្មនៃការដែលមិនទទួលស្គាល់ និងអ្វីៗផ្សេងទៀតដែលគេមាន ប៉ុន្តែនៅតែ...

322 បើអ្នកមានប្រាក់ដុល្លារនៅក្នុងហោប៉ៅរបស់អ្នក ចូរអ្នកមើលក្រដាសដុល្លារសហរដ្ឋអាមេរិច នៅជ្រុងខាងស្តាំដៃ មានឥន្ទ្រីជាមួយទង់ជាតិអាមេរិច។ ហើយនិយាយថា ត្រា "នៃសហរដ្ឋអាមេរិច។" នៅផ្នែកម្ខាងទៀតវាមានរូបពីរ៉ាមីតជាមួយនឹងថ្មចំលាក់ដ៏ធំ រួមជាមួយភ្នែករបស់មនុស្ស។ នៅខាងនឹងបានសរសេរថា "ត្រាយ៉ាងអស្ចារ្យ។" ពិតណាស់ បើវាគឺជាប្រទេសដ៏អស្ចារ្យនោះ តើហេតុអ្វីបានជាត្រានេះមិនមែនជាត្រារបស់ប្រទេសនោះទៅវិញ? ព្រះធ្វើឲ្យគេមានភស្តុតាងគ្រប់ទាំងទីណាដែលគេបានទៅ។

323 ខ្ញុំបាននិយាយជាមួយនឹងគ្រូពេទ្យម្នាក់នៅពេលមួយ ហើយគាត់បានចំអកឲ្យខ្ញុំដោយព្រោះការដែលខ្ញុំមានបញ្ហាផ្តាសាយ ជាមួយនឹងការព្យាបាលដ៏អស្ចារ្យ។ គាត់បានឈរនៅតាមផ្លូវ ហើយនិយាយថា "លោកប្រានហាំ អ្នកគ្រាន់តែធ្វើឲ្យមនុស្សយល់ច្រលំប៉ុណ្ណោះ។" និយាយ "គ្មានការព្យាបាលអ្វីក្រៅពីថ្នាំពេទ្យទេ។"

324 ខ្ញុំក៏បានបែរទៅឯគាត់ ហើយបានឃើញសញ្ញាមួយនៅលើឡានរបស់គាត់ដែលមានពស់រុំជុំវិញបង្គោល។ ខ្ញុំនិយាយថា "អ្នកគួរតែយកសញ្ញានោះចេញពីឡានរបស់អ្នកទៅ ពីព្រោះសញ្ញានោះបានបញ្ជាក់ថា ព្រះជាអ្នកព្យាបាល។"

325 គ្រូពេទ្យពិតប្រាកដគឺជឿរឿងនោះ។ គេគឺជាគ្រូពេទ្យផ្តេសផ្តាស់នោះទេ។ បាទ អ្នកទាំងអស់គ្នា។ ពស់ដែលនៅលើបង្គោលឈើ! ម៉ូសេបានលើកពស់នោះឡើងនៅលើបង្គោលឈើទ្រង់មានបន្ទូលថា "អញគឺជាព្រះដែលបានព្យាបាលអស់ទាំងជំងឺរបស់ឯង។" ហើយពួកគេបានមើលមកឯសត្វពស់នោះសំរាប់ការព្យាបាលរបស់ពួកគេ។ ប៉ុន្តែគេបាននិយាយប្រឆាំងនឹងវា ផ្ទុយទៅវិញសញ្ញារបស់ពួកគេបញ្ជាក់ប្រឆាំងនឹងគេវិញ។ វ៉េរ!

326 នៅទីនេះប្រជាជាតិរបស់យើង បាននិយាយអំពីអ្វីដែលជារបស់ពួកគេ បង្កើតជារឿងកំប្លែងទៅវិញ ហើយលុយរបស់ពួកគេ រូបិយប័ណ្ណរបស់ពួកគេ បានបញ្ជាក់ថា ត្រានៃពិភពលោកទាំងមូលគឺជាព្រះ។ ឃើញទេ ភ្នែកមួយនៅខាងលើនោះទេ គឺនៅក្នុងក្រដាស់ប្រាក់ដុល្លារ? នោះហើយគឺជាត្រាដ៏អស្ចារ្យ។

327 គឺវាមិនដែលត្រូវបានដាក់នៅពីលើពីរ៉ាមីតនោះទេ។ ពួកគេក៏មិនបានដឹងថាហេតុអ្វី។ ដុំថ្មដ៏ចំបងត្រូវបានគេបដិសេធ គឺជាព្រះគ្រីស្ទដែលលើគេទាំងអស់។ ប៉ុន្តែនៅថ្ងៃណាមួយការទាំងអស់នោះនឹងកើតមានឡើង។

328 ឥឡូវក្នុងការបង្កើតឲ្យមានសេចក្ដីទៀងត្រង់...បង្កើតនូវវិមានមួយនេះ បង្កើតនូវរូបសំណាកនេះ ឃើញទេ គឺវាចាប់ផ្ដើមឡើងដោយដុំថ្មនៃគ្រឹះ សេចក្ដីជំនឿ សេចក្ដីទៀងត្រង់ ដំរិះ សេចក្ដីអត់សង្កត់ចិត្ត ការអត់ធ្មត់ ការចេះគោរពស្រឡាញ់ព្រះ ការចេះរាប់អានគ្នាជាបងប្អូន។ ឥឡូវតើវាបានធ្វើអ្វី? រួចហើយគឺពួកគេកំពុងតែរង់ចាំដុំថ្មជាមេកំពូលដែលជាសេចក្ដីស្រឡាញ់ ដ្បិតព្រះគឺជាសេចក្ដីស្រឡាញ់។ ហើយទ្រង់គឺជាអ្នកដែលគ្រប់គ្រង ហើយគឺទ្រង់ហើយដែលជាកំលាំងនៃចំណែកទាំងអស់នោះ។ ត្រូវហើយ។ បាទ លោក។

329 នៅខាងក្នុង*នេះ* គឺនៅក្នុង*នេះ* អ្នកឃើញទេខ្ញុំនៅចំកណ្ដាលនៃការដែលបានធ្វើនៅទីនេះ ហើយនេះគឺជារលកតូចមួយដែលបានមក។ តើវាគឺជាអ្វីទៅ? គឺព្រះវិញ្ញាណបរិសុទ្ធបានយាងមកតាមរយៈព្រះយេស៊ូវគ្រីស្ទឃើញទេ។ ព្រះវិញ្ញាណបរិសុទ្ធ! ព្រះវិញ្ញាណបរិសុទ្ធស្ថិតនៅពីលើទាំងអស់*នេះ* ផ្សាផ្ជាប់ការទាំងអស់នេះជាមួយគ្នា បង្កើត(អ្វី?) ក្រុមជំនុំដ៏គ្រប់លក្ខណ៍សំរាប់ថ្មដ៏ជាមេដំបូលក្នុងការគ្របពីលើការទាំងអស់នោះ។

330 តើមានអ្វីដែលបានធ្វើរួចម្ដងទៀត? គឺវាត្រូវបានបើកបង្ហាញនៅក្នុងសម័យកាលក្រុមជំនុំទាំងប្រាំពីរ ហើយនឹងព្រះរាជសាររបស់ក្រុមជំនុំទាំងប្រាំពីរ។

331 ចាប់ផ្ដើមម្ដងទៀតពីត្រង់*នេះ*។ តើក្រុមជំនុំត្រូវចាប់ផ្ដើមបង្កើតឡើងនៅត្រង់ណា? តើក្រុមជំនុំដែលត្រូវបានដឹកនាំដោយ ព្រះវិញ្ញាណបរិសុទ្ធដំបូងត្រូវបានបង្កើតឡើងនៅឯណា? ដោយសាវ័កប៉ុល នៅឯទីក្រុងអេភេសូរ ដែលជាអ្នកដែលបានបង្កើតសម័យកាលក្រុមជំនុំអេភេសូរនៅទីក្រុងអេភេសូរ។

332 សម័យកាលទីពីរនៃក្រុមជំនុំគឺស្មឺរណា។ "សេចក្ដីទៀងត្រង់។" អ៊ីរ៉ានុស គឺជាវិរៈជនដ៏អស្ចារ្យដែលបានបន្តដំណឹងល្អរបស់សាវ័កប៉ុល។

333 សម័យកាលក្រុមជំនុំបន្ទាប់គឺ ពើការម៉ុស គឺជាម៉ាទីន។ ម៉ាទីនគឺជាវិរៈជនដ៏អស្ចារ្យដែលបាននៅបន្ត។ ប៉ុល អ៊ីរ៉ានុស ម៉ាទីន។

334 រួចហើយនៅក្នុងទីយ៉ាទីរ៉ា ក្លាយមកជាកូឡុមបា។ តើអ្នកចាំដែរឬទេ? នេះគឺជាអ្វីដែលបានគូរនៅ*ទីនោះ*។ កូឡុមបា។ បន្ទាប់ពីកូឡុមបា...សម័យកាលងងឹតក៏បានចូរមកដល់។

335 រួចមកក៏មានសាឌីសដែលមានន័យថា*សេចក្តីស្លាប់*។ លូធឺ។ ហាលេលូយ៉ា! តើបន្ទាប់មកមានអ្វីទៀត? តើមានអ្វីកើតឡើងបន្ទាប់ពីសាឌីស លូធឺ?

336 រួចមកដល់ភីឡាដេភី "ភាពដូចជាព្រះ។" ភាពបរិសុទ្ធរបស់វេស្លី! លូធឺនិយាយថា "មនុស្សសុចរិតដោយ សេចក្តីជំនឿតែមួយគត់"។ ការលាងសម្អាតដោយវេស្លី។

337 រួចមកក៏មកដល់សេចក្តីរាប់អានគ្នាជាបងប្អូនតាមរយៈឡៅឌីសេ។ ហើយយើងក៏បានជឿលើព្រះរាជសារដ៏អស្ចារ្យនៃការត្រលប់មកវិញជាលើទីពីររបស់លោកអេលីយ៉ា នៅថ្ងៃចុងក្រោយ នឹងបំផ្លាញផែនដីនេះទៅ។

338 នេះហើយគឺជាសម័យកាលនៃក្រុមជំនុំទាំងប្រាំពីរ នឹងជំហានទាំងប្រាំពីរ។ ព្រះសាងសង់ក្រុមជំនុំរបស់ទ្រង់ឡើងមក ដូចជាមនុស្សម្នាក់ដោយភាពផ្ទាល់ខ្លួនសំរាប់រូបអង្គទ្រង់។ សិរីល្អ និងរិទ្ធិបារមីរបស់ព្រះ បានចុះមកតាមរយៈ*នេះ* ហើយផ្សារភ្ជាប់វាជាមួយគ្នា។ ដូច្នេះពួកអ្នកដែលថាខ្លួនដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធដែលបានធ្វើតាមរបៀបរបស់លូធឺ ធ្វើតាមរបៀបរបស់វេស្លី និងការផ្សេងៗ គេមិនបានដឹងថាពួកគេបាននិយាយអ្វីនោះទេ។ អ្នកបានឃើញទេពួកគេរស់នៅក្នុងចំនុច *មួយនេះ* នៃក្រុមជំនុំ។ នេះហើយគឺជារបៀបដែលមនុស្សអាចមកដល់ចំនុចខ្ពស់ហើយក៏បានធ្លាក់ទៅវិញ។ ប៉ុន្តែគឺជារឿងពិតរបស់វា គឺជាការដែលនៅតែបន្តឲ្យអាគារនោះសាងសង់ឡើងបន្តទៀត។ ព្រះអម្ចាស់មានបន្ទូលថា "អញនឹងសាងសង់ឡើងវិញ"។

339 តើអ្នកមានចាំទេ*ដើមឈើកូនក្រមុំ?*តើអ្នកមានចាំទេព្រះរាជសារអំពី *ដើមឈើកូនក្រមុំ?* ពួកគេបានស៊ីវា តែគាត់បានកាត់វាចេញ។ ពួកគេមានមែកធាងនៃនិកាយរបស់គេ តែគាត់បានកាត់វាចេញ។ ពួកគេបានបង្កើតក្រុមជំនុំមួយទៀតគឺមែកធាងនៃនិកាយរបស់របស់ពួកគេ គាត់បានកាត់វាចេញ។ ប៉ុន្តែទឹកចិត្តនៃដើមឈើនោះនៅតែបន្តដុះមក។ "ហើយនៅពេលល្ងាចឡើងនោះនឹងមានពន្លឺ។" ឃើញទេ?នោះគឺនៅពេលដែលព្រះវិញ្ញាណយាងមកជំនួសព្រះគ្រីស្ទ។ ព្រះយេស៊ូវបានយាងមក ហើយបានដាក់រូបអង្គទ្រង់នៅពីលើអស់ទាំងក្រុមជំនុំ

ហើយនឹងសាងសង់ក្រុមជំនុំរបស់ទ្រង់ឡើងជាថ្មី ដែលជារូបកាយរបស់ទ្រង់។ នៅក្នុង*នោះ*គឺជារូបកាយ។

340 ហើយការដែលព្រះទ្រង់ធ្វើឲ្យក្រុមជំនុំរបស់ទ្រង់ បានរីកចម្រើនជាយ៉ាងណា នោះទ្រង់សព្វព្រះទ័យឲ្យយើងបានរីកចម្រើនយ៉ាងនោះដែរ។ គ្រប់សម័យកាលនៃក្រុមជំនុំរួមគ្នាមកជាក្រុមជំនុំដ៏ធំមួយ។ ឃើញទេ?

341 *ពួកគេ*ទាំងអស់*នេះ*មិនតំរូវនូវអ្វីដែលជា*ពួកគេនោះ*ទេ។ *ការនេះ*មិនតំរូវនូវអ្វីដែលជា*ការនោះ* នោះទេ។ ឃើញទេ? ប៉ុន្តែទ្រង់បានបង្កើតក្រុមជំនុំទ្រង់ឡើងតាមរបៀបនេះដែរ។ ទ្រង់បានបង្កើត—ក្រុមជំនុំរបស់ទ្រង់ឡើងដូចដែលទ្រង់បានបង្កើតមនុស្សមកដែរ។ រួចហើយនៅទីនេះពេត្រុសបាននិយាយជាមុនដំបូងទាំងប្រាំពីរយ៉ាង សេចក្តីជំនឿ សេចក្តីទៀងត្រង់ (មើល ឡើងមកហើយ) ដំរិះ សេចក្តីអត់សង្កត់ ការអត់ធ្មត់ ការចេះគោរពប្រតិបត្តិដល់ព្រះ ការចេះរាប់អានគ្នាជាបងប្អូន សេចក្តីសប្បុរសរួច ហើយគឺជាសេចក្តីស្រឡាញ់នៃព្រះ។ ព្រះវិញ្ញាណបរិសុទ្ធ ព្រះគ្រីស្ទជាព្រះវិញ្ញាណបរិសុទ្ធយាងមកសន្ថិតលើអ្នក នៅក្នុងការជ្រមុជដ៏ពិតនៃព្រះវិញ្ញាណបរិសុទ្ធ ហើយអ្នកមានគ្រប់ទាំង សេចក្តីទៀងត្រង់ទាំងនេះដោយបានបោះត្រានៅលើអ្នក។ រួចហើយព្រះទ្រង់មានព្រះជន្មរស់នៅក្នុងអាសនាដែលត្រូវបានហៅថាក្រុមជំនុំ គឺជាពោងឧបោសថនៃព្រះដ៏មានព្រះជន្មគង់នៅ។

342 នៅពេលដែលមនុស្សទទួលបានការទាំងអស់នេះរួចហើយ នោះព្រះវិញ្ញាណបរិសុទ្ធនៃព្រះនឹងយាងមកសន្ថិតលើគេ។ មិនខ្វល់ថាអ្នកនឹងចេះនិយាយភាសាដទៃ ឬក៏អ្នកនិងមានអំណោយទានអ្វីមួយអំពីព្រះ។ អ្នកអាចនឹងធ្វើដូច្នេះបាន។ ប៉ុន្តែបើគ្មានសេចក្តីទៀងត្រង់*ទាំងនេះ* បិតនៅក្នុងអ្នក នោះអ្នកមិននៅក្នុងសេចក្តីពិតនៃព្រះគ្រីស្ទ ឬសេចក្តីជំនឿដ៏ពិតទេ។ ប៉ុន្តែនៅពេលដែលសេចក្តីទៀងត្រង់ទាំងអស់នោះនៅក្នុងអ្នក ហើយអ្នកបានដាក់វាចូលទៅក្នុងសេចក្តីទាំងនោះរួចហើយ នោះអ្នកគឺជាវិមានដ៏រស់។ អ្នកគឺជារូបសំណាកដ៏រស់ ហើយអាចផ្លាស់ទីបាន។

343 ប៉ុន្តែតើអ្នកដឹងទេ ពួក—ពួកប្រជាជាតិទាំងឡាយ គេបានក្រាបថ្វាយបង្គំដល់រូបព្រះក្លែងក្លាយហើយនឹងព្រះដែលកើតពីការស្រមើលស្រមៃរបស់ពួកគេ។ ហើយនៅក្នុងការស្រមើលស្រមៃរបស់ពួកគេ គេជឿថា ព្រះទាំងនោះអាចនិយាយមករកគេវិញ។ នេះហើយគឺការជឿប្រជាជាតិនិយម។ នេះហើយគឺជាការជឿបែបអ្នកក្រុង

រ៉ូម។ ពួកគេថ្វាយបង្គំគ្រប់ទាំងសាវ័កទាំងអស់ ហើយនឹងរបស់ផ្សេងៗទៀតផង ដែរ។ ហើយពួកគេមានសាវ័កស៊ីស៊ីលា គឺជំនាងផ្ទះ ហើយនិង អ្វីៗស្រដៀងនឹង ការទាំងអស់នោះ។ ពួកគេបានថ្វាយបង្គំចំពោះការទាំងអស់នោះ ហើយទាំងជឿ ដោយភាពស្រមើលស្រម៉ៃ។ តើនេះ—តើនេះគឺជាប្រភេទព្រះពិតរបៀបណាទៅ។

344 ប៉ុន្តែនៅពេលដែលយើងមិនមានការស្រមើស្រមៃ ប៉ុន្តែក្រាបថ្វាយបង្គំដល់ព្រះ ដ៏មានព្រះ ជនគង់នៅ ជាសេចក្តីទៀងត្រង់ដ៏រស់ ជាដំរិះដ៏រស់ ជាការអត់ធ្មត់ដ៏រស់ ជាភាពឲ្យបានដូចព្រះដ៏រស់ ជារិទ្ធិអំណាចដ៏រស់ ដែលបានមកពីព្រះដ៏មានព្រះជន្ម គង់នៅ ដែលទ្រង់បានបង្កើតមនុស្សដ៏រស់ ឲ្យដូចរូបអង្គដ៏មានព្រះជន្មគង់នៅរបស់ ទ្រង់ ដោយភាពជាព្រះរបស់ទ្រង់ មិនមែនដោយការស្រមើលស្រម៉ៃនោះឡើយ។ តើគាត់ធ្វើអ្វី? ដូចគ្នាទៅនឹងការដែលព្រះយេស៊ូវទ្រង់បានធ្វើ ដើរតាមផ្លូវដែលទ្រង់ បានដើរ ធ្វើការដែលទ្រង់បានធ្វើ។ ពីព្រោះវាមិនមែនជាការស្រមើស្រមៃនោះទេ។ គឺមានសេចក្តីពិតដែលអាចបញ្ជាក់បាន។

345 មើលថាតើខ្ញុំមានន័យថាយ៉ាងម៉េច? ចូរមើលអំពី សេចក្តីទៀងត្រង់នេះ សំភារៈសាងសង់ ទាំងនេះ គឺជាប្រភេទនៃអ្នកនាំសាររបស់ក្រុមជំនុំ ជាមួយនឹង សម័យកាលនៃក្រុមជំនុំយ៉ាងម៉ិច? ឥឡូវនៅថ្ងៃណាមួយខាងមុខ យើងនឹងយក គ្រប់ទាំងព្រះបន្ទូលទាំងអស់នេះ ហើយនឹងសិក្សាវា ហើយនឹងបង្ហាញថាវាពិតជា បានបញ្ជាក់វា។ វាគឺទៅជាមួយគ្នា។ ពិតណាស់ ឃើញទេ? អូខ្ញុំអើយ! តើវាអស្ចារ្យ យ៉ាងណាទៅ ក្នុងការដែលបានឃើញ គឺបានឃើញ—អ្វីដែលវានឹងធ្វើ។

346 ឥឡូវនេះគឺជាដំណាក់ដែលព្រះទ្រង់គង់នៅ មិនមែនជាអាគារដ៏ធំដែល មានជួងធំមួយនៅពីលើ ហើយមានកាំជណ្តើរខ្ពស់ៗ។ ឃើញទេ? "ប៉ុន្តែឯង ត្រូវរៀបចំខ្លួនឯងសំរាប់អញ" ជារូបកាយដែលព្រះអាចគង់នៅបាន ព្រះអាចដើរ នៅក្នុងបាន ព្រះអាចមើលនៅក្នុងបាន ព្រះអាចមានបន្ទូលនៅក្នុងបាន ព្រះអាច ធ្វើការនៅក្នុងបាន។ អាម៉ែន! គឺជាឧបករណ៍ដ៏រស់របស់ព្រះ ហើយព្រះនឹងយាង ដោយព្រះបាទទាំងគូររបស់ទ្រង់នៅក្នុងអ្នក។ សិរីរុងរឿង! "ស្នាមជើងនៃពួកអ្នក បរិសុទ្ធរបស់ព្រះគឺជាការសព្វព្រះទ័យដល់ទ្រង់ណាស់" ព្រះទ្រង់យាងនៅក្នុង ខ្លួនអ្នក។ "ដ្បិតឯងទាំងអស់គ្នាគឺជាទីបន្ទាល់ដ៏រស់ សំរាប់ឲ្យមនុស្សគ្រប់គ្នាបាន អាន។" ហើយបើសិនជាជីវិតដែលនៅក្នុងព្រះគ្រីស្ទនៅក្នុងអ្នកទាំងអស់គ្នា នោះ អ្នកនឹងមានជីវិតដូចព្រះដែរ។

347 ដូចអ្វីដែលខ្ញុំបានតែងតែនិយាយហើយ។ ចូរយកមែករបស់ដើមភិច(peach tree) ហើយបើសិនជាអ្នកអាចដាក់ដាំវានៅលើដើមប៉ោមបាន នោះវានឹងឲ្យផ្លែមកជាផ្លែភិចមិនខាន។ ពិតណាស់។ វាអាចទៅរួច។ បើទោះជាមែកនោះមានរាងជាយ៉ាងណាក៏ដោយ ឲ្យតែវាត្រូវបានដាំនៅលើដើមប៉ោម ឬដើមណាក៏ដោយ។ ឃើញទេ? ចូរយកជីវិតរបស់វាចេញពីដើមប៉ោម គឺយកវាចេញទាំងស្រុង រួចហើយ—បន្សាំវា រួចហើយបង្ហូរសារធាតុទាំងអស់របស់ដើមភិចដាក់ទៅលើដើមប៉ោម។ តើនឹងមានអ្វីកើតឡើង? នោះវានឹងមិនឲ្យជាផ្លែរភិចទៀតទេ។ ឃើញទេ? អត់ទេលោក។ វាមិនអាចទៅរួចទេ។ បើសិនជាជីវិតរបស់ដើមភិចត្រូវបានបង្ហូរចូលទៅក្នុងដើមប៉ោម នោះវានឹងលែងមានផ្លែរប៉ោមទៀតហើយ។ វានឹងឲ្យផ្លែរមកជាភិចវិញ ពីព្រោះមានជីវិតភិចនៅក្នុងនោះ។

348 យ៉ាងណាមិញ បើអ្នកយកយើង នោះគ្មានអ្វីទេ គឺគ្រាន់តែជាឃ្លោកព្រៃមួយតែប៉ុណ្ណោះ ហើយយើងគ្មានប្រយោជន៍អ្វីទេ ដ្បិតយើងបានស្លាប់នៅក្នុងអំពើបាប នឹងសេចក្ដីរំលងរួចទៅហើយ។ គឺយើងទាំងអស់គ្នាឋិតនៅក្នុងស្ថានភាពបែបនេះទាំងអស់គ្នា។ រួចហើយយើងខ្លួនឯង អាចថ្វាយបង្គំខ្លួនឯង ដោយថ្វាយខ្លួនឯង រហូតដល់ពេល ដែលព្រះទ្រង់យកខ្នែងរបស់ទ្រង់ គឺជាព្រះនាមព្រះយេស៊ូវគ្រីស្ទ ពីព្រោះ "គឺគ្មាននាមណានៅលើផែដីនេះ ដែលមនុស្សអាចទទួលបានសេចក្ដីសង្គ្រោះនោះឡើយ" ហើយបានបង្ហូរជីវិតរបស់ផងព្រះគ្រីស្ទមកក្នុងយើង។ រួចហើយយើងនឹងមានសេចក្ដីជំនឿប្រភេទ*នេះ*គឺជាសេចក្ដីជំនឿដែលព្រះគ្រីស្ទមាន។ ហើយសេចក្ដីជំនឿរបស់ព្រះគ្រីស្ទ មិនមែនផ្អែកទៅលើ ពួកផារ៉ាស៊ី ឬពួកសាឌូស៊ី នឹង លើការលាងចាន ឆ្នាំង និងកំសៀវរបស់គេនោះទេ។ វាផ្អែកទៅលើព្រះបន្ទូលរបស់ព្រះ អាម៉ែន ដ៏ម្ល៉េះបានជាព្រះគ្រីស្ទដ៏ជាព្រះបន្ទូល ព្រះបន្ទូលនោះឯងត្រលប់ជាសាច់ឈាម។ រួចហើយនៅពេលដែលយើងអាចទទួលបានការផ្លាស់ប្ដូរដោយព្រះចេស្ដាទ្រង់ ដែលយើងបានស្លាប់នៅក្នុងគំនិតរបស់យើង ហើយសេចក្ដីជំនឿរបស់យើងក្លាយទៅជាសេចក្ដីជំនឿដ៏ពិត ហាលេលូយ៉ា រួចហើយជីវិតរបស់ព្រះគ្រីស្ទត្រូវបានបង្ហូរមកលើជីវិតយើង។ នោះយើងនឹងក្លាយទៅជាមនុស្សដ៏មានជីវិតរបស់ព្រះ គឺជាព្រះដំណាក់ដែលព្រះវិញ្ញាណបរិសុទ្ធអាចបញ្ជូនព្រះពរដ៏ត្រចះត្រចង់របស់ទ្រង់ មកលើទីនេះហើយយើងគឺជារូបកាយរបស់ព្រះគ្រីស្ទ។

349 ព្រះយេស៊ូវមានបន្ទូលថា "តើវាមិនបានចែងទុកទេឬអី? ដែលអ្នកមកថ្កោលទោសខ្ញុំ ដែលខ្ញុំហៅខ្លួនឯងថា ជាកូនរបស់ព្រះ។ តើមិនបានចែងទេឬអីថាអ្នកទាំងអស់គ្នាគឺបុត្រធីតារបស់ព្រះ តើមិនមែនជាច្បាប់របស់អ្នកដែលបានចែងយ៉ាងដូច្នេះទេឬអី?" ដូចជាម៉ូសេ ដូចជាអេលីយ៉ា ហើយដូចជាហោរ៉ាផ្សេងទៀតដែលបានរស់នៅជិតដិតនឹងព្រះ រហូតដល់ទ្រង់បានសំដែងរូបអង្គទ្រង់ដោយសារគេ។ ហើយដែលពួកគាត់បាននិយាយនោះមិនមែនជាពួកគេទេគឺជាព្រះវិញ។ "ចូរឯងកុំគិតពីអ្វីដែលត្រូវនិយាយឡើយ ពីព្រោះមិនមែនជាឯងទេដែលនិយាយ។ គឺជាព្រះបិតាទេដែលទ្រង់បានគង់នៅក្នុងអ្នក ទ្រង់គឺជាអ្នកដែលមានបន្ទូលវិញ។" ដែលគាត់និយាយនោះមិនមែន ជាគាត់ទេ ពីព្រោះគាត់បានស្លាប់បាត់ទៅហើយ។

350 បើសិនជាអ្នកស្លាប់ ហើយអ្នកយកឈាមចេញពីមនុស្ស ហើយអ្នកអប់សពគាត់ទុក។ អ្វីដែលជាបញ្ហានោះគឺថាមានពួកគេជាច្រើនមិនត្រូវបានគេអប់ទុកទេ។ នៅពេលអ្នកយកឈាមចេញពីគេមក នោះគាត់នឹងស្លាប់បាត់ទៅ។ ហើយអ្វីដែលអ្នកគួរតែធ្វើមួយទៀតនោះគឺយកឈាមផ្សេងមកបញ្ចូលឲ្យគាត់ នោះគាត់នឹងបានរស់ឡើងវិញម្តងទៀត។ អ្នកបានយកឈាមរបស់គាត់ចេញ។

351 ហើយឥឡូវនេះយើងបានដាក់ព្រះលោហិតរបស់ព្រះយេស៊ូវចូលទៅ មើលហើយការនោះឯងបាននាំមកនូវ សេចក្តីជំនឿរបស់ព្រះយេស៊ូវគ្រីស្ទ សេចក្តីទៀងត្រង់របស់ព្រះយេស៊ូវគ្រីស្ទ ដំរិះនៃព្រះយេស៊ូវគ្រីស្ទ សេចក្តីអត់សង្កត់ចិត្តរបស់ព្រះយេស៊ូវគ្រីស្ទ ការអត់ធ្មត់របស់ព្រះយេស៊ូវគ្រីស្ទ ភាពដូចជាព្រះរបស់ព្រះយេស៊ូវគ្រីស្ទ ការចេះស្រឡាញ់គ្នា ជាបងប្អូនរបស់ព្រះយេស៊ូវគ្រីស្ទ ហើយនឹងសេចក្តីស្រឡាញ់របស់ព្រះ ដែលជារូបអង្គព្រះយេស៊ូវគ្រីស្ទ។ ទ្រង់គឺជាសិរិសារដែលគ្រប់គ្រងលើអ្នក។ ហើយជើងរបស់អ្នកបានដាក់នៅ លើគ្រឹះនៃសេចក្តីជំនឿ។ អាម៉ែន! គ្រប់គ្រងដោយក្បាល យក...?...នោះហើយគឺជាអ្នក។ នេះគឺជាមនុស្សគ្រប់លក្ខណ៍របស់ព្រះ នៅពេលដែលគាត់ទទួលបានសេចក្តីទៀងត្រង់នេះ។

352 រួចហើយព្រះទ្រង់គឺជាកូនក្រមុំដែលជាតំណាងរបស់ក្រុមជំនុំរបស់ទ្រង់ គឺជាស្រ្តី។ ព្រះអង្គគឺជាកូនក្រមុំដែលជាតំណាងរបស់ក្រុមជំនុំរបស់ទ្រង់។ ហើយរបៀបដែលទ្រង់បានទទួលយកម្នាក់ៗឲ្យបានក្លាយជាកូនរបស់ព្រះ ក្នុងការចូលទៅឯកូនក្រមុំជាយ៉ាងណា នោះទ្រង់ក៏បានយកកូនមុំនៅក្នុងសម័យនេះយ៉ាងនោះដែរ

[បងប្រុសប្រានហាំទះលើក្តាខៀនចំនួនប្រាំពីរដង—Ed។] រហូតដល់ទ្រង់បានយកក្រុមជំនុំដ៏គ្រប់លក្ខណ៍របស់ទ្រង់មួយនេះមកដល់ទី*នេះ*។

353 ជើងរបស់ខ្ញុំធ្វើចលនា។ ហេតុអ្វី? ពីព្រោះក្បាលរបស់ខ្ញុំបាននិយាយដូច្នេះ។ ឥឡូវវាមិនអាចកំរើកដូចជាដៃរបស់ខ្ញុំនោះទេ ពីព្រោះវាគឺជាជើងរបស់ខ្ញុំ។ លូធឺមិនអាចធ្វើអ្វីដែលយើងបានធ្វើនោះទេ ទាំងពួកមេតូឌីស្ទក៏ដូចគ្នា ពីព្រោះពួកគីជាអ្វីមួយផ្សេងទៀត។ ឃើញទេ? ជើងកំរើកពីព្រោះក្បាលឲ្យកំរើក។ ហើយក្បាលក៏មិនដែលនិយាយថា "ឥឡូវជើងអើយ ចូរឯងក្លាយទៅជាដៃទៅ។ ត្រចៀកអើយ ចូរឯងក្លាយទៅជាភ្នែកទៅ។" ឃើញទេ?

354 ប៉ុន្តែគ្រប់ទាំងសម័យកាលទាំងអស់ ព្រះទ្រង់បានដាក់ការមួយនេះទៅក្នុងក្រុមជំនុំរបស់ទ្រង់ ហើយបញ្ជាក់ដោយបង្ហាញថា ទាំងអស់គ្នាបានទទួលការទាំងនេះដោយស្មើរភាពគ្នា។ ហើយការ*ទាំង*នេះ**នឹងចាប់កើតឡើងនៅពេលដែលវាបញ្ចប់ គឺក្រុមជំនុំនៃព្រះនឹងត្រូវលើកឡើងទៅលើស្ថានសួគ៌។ ហើយការ** ***ទាំង*នេះ**នឹងចាប់កើតឡើងនៅពេលដែលរាស្ត្ររបស់ទ្រង់ នៅក្នុងក្រុមជំនុំរបស់ទ្រង់នឹងត្រូវបានលើកឡើងនៅលើអាកាស។ សិរីរុងរឿង! មើលថាតើខ្ញុំមានន័យជាយ៉ាងណា? គឺអ្នកនៅទីនោះ។ នោះហើយគឺជារឿងទាំងមូល។

355 *នៅទីនេះ* មានមនុស្សម្នាក់ សាវ័កប៉ុលបានចាក់គ្រឹះ។ អ៊ីរ៉ានុសចាប់ផ្តើមចាក់ការ*ទាំងនេះ* ទៅលើវា។ អ្នកបន្ទាប់មកទៀតចាក់*មួយនេះ*។ អ្នកបន្ទាប់មកទៀតចាក់*មួយនេះ*។ អ្នកបន្ទាប់ទៀត*មួយនោះ* ហើយ*មួយនោះ* ហើយ*មួយនោះ* ហើយចេះតែបន្តចុះមករហូតទាល់តែដល់សម័យកាលចុងក្រោយ។ ប៉ុន្តែតើវាគឺជាអ្វី? នោះគឺជាព្រះវិញ្ញាណតែមួយ។

356 ព្រះវិញ្ញាណតែមួយដែលគង់នៅក្នុងខ្ញុំមានបន្ទូលថា "ដៃអើយ ចូរឯងដោះស្រាយរឿងនោះចុះ។" ព្រះវិញ្ញាណដដែលនោះមានបន្ទូលថា "ជើងអើយ ចូរឯងដើរទៅ។" មើលថាតើខ្ញុំមានន័យយ៉ាងណា?

357 រួចហើយគ្រប់រូបកាយរបស់អ្នកត្រូវបានហ៊ុំបាំង និងគ្រប់គ្រងដោយការទាំងនេះ ប៉ុន្តែវាមិនអាចគ្រប់គ្រងទាំងស្រុងបាននៅឡើយទេ រហូតទាល់តែវាទទួលបានទាំងស្រុងនៃភាពស្មើរគ្នានេះ។

358 តើអ្នកធ្លាប់បានឮការទាំងអស់នេះដែរឬទេ? ឥឡូវសូមឲ្យខ្ញុំប្រាប់អ្នកអំពីរឿងនេះមួយ។ ហើយចូរបន្តក្នុងសេចក្ដីពិត...ចូរបើកត្រចៀកសំរាប់ស្ដាប់។ ឃើញទេ? ច្រវាក់ដ៏រឹងមាំបំផុត នោះក៏បានភ្ជាប់ឡើងពីការភ្ជាប់ដ៏ខ្សោយបំផុតរបស់វាដែរ។ ត្រូវហើយ វាមិនដែលខ្លាំងជាងតំណរដ៏ខ្សោយរបស់វានោះទេ។

359 មិនថាការ*នេះ*រឹងមាំប៉ុណ្ណា ត្រូវធ្វើឡើងរឹងមាំយ៉ាងណា *មួយនេះ*ត្រូវបានធ្វើឡើង បើវាមានការភ្ជាប់ដែលខ្សោយនោះ នេះហើយជាកន្លែងដែលវានឹងបាក់ទៅ។ ហើយវាមិនដែលខ្លាំងជាង តំណរដ៏ខ្សោយនោះទេ។ [បងប្រុសប្រានហាំចង់និយាយអំពីអ្វីដែលគាត់បានគូរនៅលើក្ដារខៀនមួយនេះ—Ed។] ឥឡូវបើអ្នកបានទទួល នោះអ្នកនិយាយថា អ្នកមាន*មួយនេះ មួយនេះ មួយនេះ* អ្នកមិនមាន*មួយនេះ* នេះហើយជាកន្លែងដែលវាបាក់បែក។ បើសិនជាអ្នកមាន*មួយនេះ* ហើយមិនមាន*មួយនោះ*ទេនោះវានឹងបាត់នៅត្រង់នោះ។ អ្នកមាន*មួយនេះ* ហើយមិនមាន*មួយនោះ* នោះវានឹងបាក់។ *មួយនេះ* ហើយមិនមាន*មួយនោះ* វានឹងបាក់។ *មួយនេះ* ហើយមិនមាន*មួយនោះ* វានឹងបាក់។ ឃើញទេ? បើអ្នកមិន...មិនអាចមាន*មួយនេះ* ដោយមិនមាន*មួយនេះ*ទេ។

360 ដូច្នេះនៅពេលដែលអ្នកបានចុះចូលរូបកាយរបស់អ្នកទាំងស្រុង រួចមកព្រះវិញ្ញាណបានបង្ហូរមកតាមរយៈអ្នក នូវសេចក្ដីទៀងត្រង់ទាំងអស់នេះ ហើយបន្ទាប់មកអ្នកគឺជាអាសនាដ៏រស់។ រួចហើយមនុស្សបានមើលមកដោយនិយាយថា "នេះហើយមនុស្សដែលពោពេញទៅដោយ សេចក្ដីទៀងត្រង់ ដំរិះ (គាត់ជឿទៅលើព្រះបន្ទូល) សេក្ដីអត់សង្កត់ ការអត់ធ្មត់ ការចេះគោរពកោតខ្លាចព្រះ ការចេះស្រឡាញ់គ្នាជាបងប្អូន ពោរពេញដោយសេចក្ដីស្រឡាញ់ នៃព្រះវិញ្ញាណបរិសុទ្ធ។ ឃើញទេ គាត់នៅទីនោះកំពុងតែដើរ។" តើនេះគឺជាអ្វី? គឺជារូបកាយដែរ អស់អ្នកដែលមិនជឿអាចមើលមក ដោយនិយាយថា "នេះហើយគឺជាគ្រីស្ទាន។ មានបុរសឬក៏ស្ត្រីដែលបានដឹងពីអ្វីដែលពួកគាត់និយាយ។ អ្នកមិនងាយនឹងរកមនុស្សដែលពេញដោយ សេចក្ដីសប្បុរស គួរឲ្យស្រឡាញ់ ជាមនុស្សពេញដោយព្រះដូចនេះទេ។" អ្នកត្រូវបានបោះត្រារួចហើយ។ គឺជាត្រាដែលមានទាំងសងខាង។ ទោះបីជាអ្នកទៅឬ ក៏អ្នកមកវិញក៏ដោយគង់តែអ្នកនឹងបានឃើញត្រានោះដូចគ្នា។ នោះគឺជាអ្នក។ ឃើញទេ? នៅពេលដែលមានបុរស ឬស្ត្រីណាដែលទទួលបានការ

ទាំងអស់*នេះ* នោះថ្មដ៏ជាមេដំបូលនឹងយាងចុះមក ហើយបោះត្រាឲ្យពួកគេ ទៅក្នុងនគរឋានសួគ៌ នោះគឺជាព្រះវិញ្ញាណបរិសុទ្ធ។

361 រួចហើយព្រះបន្ទូលបានមកពី*ទីនេះ* ហើយបានសំដែងខ្លួនតាមរយៈគ្រប់ទាំងរបស់មានជីវិតទាំងអស់នោះ មើល ហើយបានធ្វើឲ្យរូបកាយដ៏គ្រប់លក្ខណ៍មួយនេះក្លាយទៅជារោងឧបោសថរបស់ព្រះដ៏មានព្រះជន្មគង់នៅ ជាអ្នកដែលដើរ ហើយគឺជាទីបន្ទាល់រស់របស់ក្រុមគ្រីស្ទាន។ អ្វីដែលជាព្រះគ្រីស្ទ គឺជាពួកគេ ពីព្រោះព្រះជន្មរបស់ទ្រង់គឺនៅទីនេះ។ ពួកគេគឺនៅក្នុងព្រះគ្រីស្ទ។ ហើយជីវិតរបស់ពួកគេបានស្លាប់ហើយ ក៏ត្រូវបានបាំងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដោយសារព្រះ ហើយក៏ត្រូវបានបោះត្រានៅទីនោះដោយព្រះវិញ្ញាណបរិសុទ្ធ។ កូរិនថូស ខ្សែទី១ ជំពូកទី១២។ ត្រូវហើយ។ ឃើញទេ? អ្នកបានរាប់ខ្លួនថា ស្លាប់ រួចហើយអ្នកបានរស់ដោយខាងឯសេចក្ដីជំនឿ។ រួចហើយសេចក្ដីទៀងត្រង់ហើយនិងសេចក្ដីផ្សេងៗទៀតក៏ចេះតែបន្ថែមមកលើអ្នក រហូតទាល់តែអ្នកក្លាយទៅជារូបកាយដ៏រស់របស់ព្រះដ៏គ្រប់លក្ខណ៍។ តើវាអស្ចារ្យដែរឬទេ? [ពួកជំនុំនិយាយថា "អាម៉ែន"—Ed។]

362 រួចហើយព្រះតាមរយៈការទាំងនេះ ក៏បានបង្កើតឡើងនូវសម័យកាលនៃក្រុមជំនុំទាំងប្រាំពីរ ដើម្បីបង្ហាញនូវជំហានទាំងប្រាំពីរ ដែលទ្រង់បានយកមក ក៏បានបង្កើតបុគ្គលទាំងអស់ទៅតាមរូបអង្គទ្រង់ គឺទ្រង់បានបង្កើតក្រុមជំនុំដ៏ពេញលេញរបស់ទ្រង់ទៅតាមរូបអង្គទ្រង់។ ហើយនៅថ្ងៃដែលទ្រង់បានរស់ឡើងពីសុគតវិញនោះរូបអង្គដ៏គ្រប់លក្ខណ៍របស់ទ្រង់នឹងបានប្រោសឡើង ឲ្យរស់នៅអស់កល្បជាមួយទ្រង់ ពីព្រោះរូបកាយនោះហើយគឺជាកូនក្រមុំ។ ឃើញទេ? ដើម្បីកាត់បន្ថយគ្រប់ទាំងសម័យកាល គឺគ្រប់សម័យកាលដែលនឹងត្រូវមកដល់។

363 ហើយត្រូវចងចាំថាមានការតំរូវផ្សេងៗទៀត។ មានចាំទេនូវអ្វីដែលសាវ័កប៉ុលបាននិយាយនៅក្នុងហេព្រើរជំពូកទី១១? សូមឲ្យខ្ញុំបានអានសំរាប់អ្នកបន្តិចមុននឹងយើងបញ្ចប់ តែប៉ុន្មាននាទីប៉ុណ្ណោះ។ រួចហើយអ្នក...វាគឺជាអ្វីម្យ៉ាងដែលនិងធ្វើឲ្យអ្នកមានអារម្មណ៍ថា ចំឡែក នៅពេលដែលខ្ញុំ... រាល់ពេលដែលខ្ញុំបានអានវា។ ខ្ញុំនឹងអានហេព្រើរជំពូកទី១១ ហើយខ្ញុំនឹងចាប់ផ្ដើមនៅក្នុងខ ទី៣២។

> *មានអ្វីទៀត តើត្រូវឲ្យខ្ញុំនិយាយអ្វីទៀត? ដ្បិតគ្មានពេលវេលានឹងថ្លែងប្រាប់ពីរឿងគេឌាន...បារ៉ាក់ ហើយ...សាំសុន ហើយ...យែបថា...ដាវីឌ...ហើយសាំយូអែល...នឹងពួកហោរ៉ា*

*ដែលដោយសារសេចក្តីជំនឿ នោះគេបានឈ្នះនគរដទៃ បានសម្រេចការសុចរិត បានទទួលសេចក្តីសន្យា បានបិតម៉ាត់សឹង្ហ*

*បានពន្លត់អំណាចភ្លើង បានរួចពីមុខដាវ បានមានកំលាំងក្នុងការដែលកំពុងតែខ្សោយ ក៏ត្រលប់ជាពូកែក្នុងចំបាំង...ទាំងកំទេចពលទ័ពសាសន៍ដទៃផង*

*ពួកស្ត្រីបានទទួលមនុស្សស្លាប់របស់ខ្លួនមក ដោយរស់ពីស្លាប់ឡើងវិញ....ខ្លះត្រូវគេធ្វើទុក្ខវេទនា ឥតទទួលការប្រោះលោះឲ្យរួចឡើយ គឺដើម្បីឲ្យបានរស់ឡើងវិញបែបប្រសើរជាង។*

364 នៅខាងក្នុង*នេះ* ។ ឃើញទេ? [បងប្រុសប្រានហាំចង់និយាយអំពីគំនូរនៅលើក្ដាខៀនរបស់គាត់—Ed។]ត្រូវហើយ។

*ហើយខ្លះទៀតត្រូវសេចក្តីល្បងល...ដោយមានគេចំអក...ឲ្យទាំងវាយនឹង រំពាត់...ក៏ទ្រាំទាំងជាប់ចំណង...នឹងជាប់គុកផង*

*ត្រូវគេចោលនឹងដុំថ្ម ល្បួង ហើយអារបណ្តាច់ ក៏ត្រូវស្លាប់...នឹងដាវ : ត្រូវដើររវើររវាម ទាំងស្លៀកស្បែកចៀម នឹងស្បែកពពែ ត្រូវកំសត់ទុគ៌ត ត្រូវគេសង្កត់ សង្កិនហើយធ្វើបាប*

*(អូតើអ្នកណាដែលធ្វើឲ្យពិភពលោកនេះមិនបរិសុទ្ធ)...*

365 ចូរមើលនៅក្នុងរង្វង់ក្រចកនៅទីនោះ ហើយអានក្នុងព្រះគម្ពីររបស់អ្នក។

*...ក៏ដើរសាត់ព្រាត់នៅក្នុងទីរហោស្ថាន ហើយនៅទីភ្នំ ទាំងនៅក្នុង*

*អាងហើយនឹងរូងក្នុងដី លោកិយ៍មិនគួរនឹងពួកអ្នកទាំងអស់នោះទេ។*

*...ទាំងបើមានសេចក្តីបន្ទាល់ពីគេថា គេមានសេចក្តីជំនឿក៏ដោយ...*

366 *នៅទីនេះ*! [បងប្រុសប្រានហាំចង់និយាយអំពីគំនូរនៅលើក្ដាខៀនរបស់គាត់—Ed។]

*...សេចក្តីបន្ទាល់ពីគេថា គេមានសេចក្តីជំនឿក៏ដោយ គង់តែមិនបានទទួលសេចក្តី ដែលបានសន្យានោះទេ:* (ឃើញទេ?)

*ដ្បិតព្រះបានផ្គត់ផ្គង់សេចក្ដីប្រសើរជាងសំរាប់យើងរាល់គ្នា ដើម្បីមិនឲ្យអ្នកទាំងនោះបានគ្រប់លក្ខណ៍ក្រៅពីយើងឡើយ។*

367 អ្នកយល់វាឬទេ? មនុស្សទាំងអស់ដែលបានស្លាប់នៅ*ទីនេះ* ពួកគេពឹងផ្អែកនឹងកំពុងតែរង់ចាំយើង។ ដូច្នេះក្រុមជំនុំ*នេះ* ត្រូវតែឲ្យបានត្រលប់មកក្នុងភាពគ្រប់លក្ខណ៍របស់ខ្លួន ដើម្បីឲ្យអាចផ្តល់នូវការរស់ឡើងវិញ។ ហើយពួកគេនៅពីក្រោមព្រលឹង នៅពីក្រោមអាសនា រង់ចាំឲ្យក្រុមជំនុំនេះបានត្រលប់មកក្នុងភាពគ្រប់លក្ខណ៍គឺនៅពេលដែលព្រះគ្រីស្ទយាងមកវិញ។

368 ហើយក្រុមជំនុំនេះអ្នកបានឃើញហើយថា វាកាន់តែតូចទៅៗហើយ។ [បងប្រុសប្រានហាំចង់និយាយអំពីគំនូរនៅលើក្ដាខៀនរបស់គាត់—Ed។] នេះគឺជាអ្វីទាំងអស់ដែលមុតខ្លាំងជាង ប៉ុន្តែគ្រាន់តែចង់សរសេរកាត់នៅទីនោះ ឃើញទេ។ វាបានមករកចំនុចរួមមួយ។ រហូតទាល់តែក្រុមជំនុំដែលតូច បានក្លាយទៅជាកន្លែងដូចនេះ គឺដែលមានព័ន្ធកិច្ចដូច*មួយនេះ*គឺនៅខាងឆ្វេងនេះ ពីព្រោះនៅពេលដែលព្រះដ៏ជាមេដំបូលមកវិញ...

369 វាមានហោប៉ៅដូចនៅ *ទីនេះ* ដែលវានឹងអង្គុយនៅត្រង់នោះ គឺនៅពីលើពីរ៉ាមីត។ គឺវាគ្រាន់តែមិនមែនជាដំបូលដែលនៅពីលើប៉ុណ្ណោះ។ វាគឺជាតែមមួយហើយគឺវាត្រូវបញ្ឈរនៅទីនោះ ពីព្រោះវាស្រក់ទឹក។

ហើយនៅពេលដែលវាបានមកដល់ក្រុមជំនុំនេះនឹងត្រូវតែសម្រិតសម្រាំង។

370 ការអស់ទាំង**នេះបានធ្វើឲ្យថ្មទាំងឡាយនៅក្នុងពីរ៉ាមីតបានដាក់នៅពីលើគ្នាយ៉ាងល្អដែលអ្នកមិនអាចយកឡាមមុតមកកាត់ទៅក្នុងចន្លោះរបស់វាបាន ហើយដែលវាមានទម្ងន់រាប់សិបតោនមកដាក់ទីនោះទេ។ ពួកគេមិនបានដឹងថាគេសាងវាឡើងជាយ៉ាងណានោះទេ។ ប៉ុន្តែគឺវាត្រូវបានគេកសាងឡើង។

371 ហើយនៅខាងលើ*នេះ* នៅពេលដែលគំរប់នៃពីរ៉ាមីតបានមកដល់ គឺជាពីរ៉ាមីតខ្លួនឯង ដែលជារូបកាយរបស់ព្រះគ្រីស្ទ នឹងត្រូវសម្រាំង។ មិនមែនគ្រាន់តែសំរាប់សេចក្ដីបង្រៀនគោលិទ្ធិ ឬក៏អ្វីផ្សេងទៀតដែលយើងបានធ្លាប់ជួបប្រទះ។ គឺត្រូវតែឲ្យបានគ្រប់លក្ខណ៍ដូចជាព្រះគ្រីស្ទ រហូតដល់ពេលដែលទ្រង់យាងមក នោះទ្រង់ហើយព័ន្ធកិច្ចមួយនោះនឹងបានទាក់ភ្ជាប់គ្នាតែមួយ។ ឃើញទេ? បន្ទាប់មកការដែលនឹងត្រូវលើកឡើងទៅលើអាកាសនឹងមកដល់ គឺជាការត្រលប់ទៅផ្ទះវិញ។

372 ចូរមើលថាតើយើងកំពុងតែរស់នៅទីណា នៅក្នុងឡៅឌីសេ គឺនៅពេលដែលក្រុមជំនុំមានការអាក្រក់ជាទីបំផុតដែលមិនដែលធ្លាប់មានពីមុន។ នៅក្នុងព្រះគម្ពីរដែលយើងបានឃើញ នោះគឺជាសម័យកាលនៃក្រុមជំនុំដែលព្រះទ្រង់គង់នៅខាងក្រៅនៃក្រុមជំនុំទាំងគោះព្យាយាមដើម្បីឲ្យត្រលប់ចូលមកខាងក្នុងវិញ។ គោលជំនឿ និងនិកាយបានដាក់ឲ្យទ្រង់នៅខាងក្រៅក្រុមជំនុំរបស់ទ្រង់។ "ចូរមើលខ្ញុំឈរនៅនឹងមាត់ទ្វាទាំងគោះ ហើយបើមានអ្នកណាស្រេក ហើយបើកឱ្យខ្ញុំចូលទៅ នោះខ្ញុំនឹងបរិភោគជាមួយនឹងអ្នកនោះ។" ឃើញទេ? គឺនៅទីនេះនៅក្នុងសម័យកាលក្រុមជំនុំ*នេះ*។ ពួកគេតែងតែបណ្តេញទ្រង់ចេញទៅខាងក្រៅរហូតដល់ពេល*មួយនេះ*ដែលគេបានបណ្តេញទ្រង់ចេញទាំងស្រុង។ ពួកគេមិនចង់ឲ្យមានអ្វីនឹងត្រូវធ្វើជាមួយនឹងទ្រង់។

373 ឥឡូវអ្នកបានដឹងហើយថា តើយើងនឹងដើរទៅឯណា។ ទោះនៅពេលជិតបញ្ចប់សម័យកាលក្រុមជំនុំឡាអូឌីសេ ដែលបានក្លាយទៅជារឿងធម្មតារហូតដល់វា ហើយកាតូលិកនិយម ដែលបានបែកគ្នានៅត្រង់*នេះ* ហើយបានត្រលប់មករួបរួមគ្នា ហើយបានបង្កើតទៅជាក្រុមជំនុំដ៏អស្ចារ្យមួយ។ ជាមួយនឹងសហព័ន្ធនៃក្រុមជំនុំដទៃទៀតដែលជាកាតូលិកនិយមដូចគ្នា។

374 គឺវាមានតែការខុសប្លែកតែមួយប៉ុណ្ណោះ បើសិនជាយើងអាច នឹងស្គាល់វានោះគឺជាការប្រកបគ្នា។ នេះគឺជារឿងតែមួយនៅក្នុងតំបន់ដែលគ្រប់គ្រងដោយសម្តេចសង្ឃដែល—ដែល—ដែលអាចបញ្ឈប់ ព្រះវិហារកាតូលិក នឹងនិកាយប្រូតេស្តង់អាចបែកចេញពីគ្នា នោះគឺការប្រកបគ្នា។ ព្រះវិហារកាតូលិកនិយាយថា "នេះគឺជារូបកាយ។" ហើយក្រុមជំនុំប្រូតេស្តង់និយាយថា "វាគឺតំណាងរបស់រូបកាយ។" ពួកកាតូលិកបានធ្វើឲ្យវាក្លាយទៅជាការប្រមូលផ្តុំ។ ការប្រមូលផ្តុំនោះគឺថា ពួកគេសង្ឃឹមថាតាមរយៈការបង្រួបបង្រួមនោះគេនឹងត្រូវបានអត់ទោសឲ្យ។ តែឯខាងប្រូតេស្តង់វិញ គឺជឿថា ដោយសារសេចក្តីជំនឿ ហើយបានអរព្រះគុណដល់ព្រះក្នុងការបង្រួបបង្រួម ដែលពួកគេអាចទទួលបានការអត់ទោស។ ពួកប្រូតេស្តង់និយាយថា "យើងត្រូវបានអត់ទោសរួចហើយ។" តែខាងកាតូលិកនិយាយថា "យើងសង្ឃឹមថា យើងនឹងត្រូវបានអត់ទោសឲ្យ។" ជាការប្រមូលផ្តុំ និងការបង្រួបបង្រួម។ ពួកគេបានហៅវាថា ជាការប្រមូលផ្តុំ តែយើងបានហៅថា ជាការប្រកបគ្នា។ ការប្រមូលផ្តុំគឺសង្ឃឹមថាវានឹងបានយ៉ាងនឹងមែន។ តែ

ការបង្រួបបង្រួមបានដឹងរួចទៅ ហើយថាវាគឺពិតជាយ៉ាងនោះមែន ហើយក៏បានអរព្រះគុណសំរាប់ការទាំងនោះ។ ឃើញទេ?ហើយនេះឯងគឺជារឿងតែមួយដែលពួកគេមិនអាចចុះសំរុងនឹងគ្នាបាន។ ពួកគេនឹងធ្វើវា។

375 អូ វាពិតជាមានរូបរាងស្អាតណាស់។ វានឹងរួបរួមគ្នា ដើម្បីរត់...វានឹង—វានឹងរត់គ្រប់ទាំង...ពិតណាស់ព្រះបន្ទូលបានសំដែងយ៉ាងនេះ "ហើយសត្វតិរច្ឆានទាំងនោះក៏បានឲ្យអំណាចរបស់វាទៅដល់ស្ត្រីសំផឹង" មើល ពួកគេបានរួបរួមគ្នាឡើង។ ឃើញទេ? គឺដូចជាអ្វីដែលព្រះគម្ពីរបានសំដែងពីអ្វីដែលគេនឹងត្រូវធ្វើ គេពិតជាយ៉ាងដូចនេះមែនឥឡូវនេះ។ គឺវាមាននៅក្នុងការដើរដង្ហែរក្បួននៅក្នុងអាទិត្យនេះ។ នោះមិនមែនមានន័យថា ខ្ញុំមានគំនិតប្រឆាំងពួកអ្នកកាតូលិកទេ ហើយក៏មិនមែនពួកអ្នកប្រូតេស្តង់ដែរ។

376 អ្នកទាំងអស់គ្នាជាពួកអ្នកមេតូឌីស និងពួកអ្នកបាបទីស្ទ ហើយនឹងពួក អ្នកទាំងអស់គ្នាជាច្រើន ខាងអ្នកដែលជឿថាមានការចាក់ប្រេងតាំងដោយព្រះវិញ្ញាណ នៅពេលដែលក្រុមជំនុំរបស់អ្នកបានមកចងជាសហព័ន្ធនៃក្រុមជំនុំទាំងឡាយ គឺនៅពេលដែលកន្លែងបញ្ចុះសាកសពរបស់សហព័ន្ធនៃក្រុមជំនុំយ៉ាងធំត្រូវបានបង្កើតឡើងនៅទីក្រុងញូវយ៉ក នោះគឺវាដូចគ្នាទៅសហរដ្ឋ និងអ្វីផ្សេងទៀតដែរ។ គឺពួកគេព្យាយាមបង្រួបបង្រួមពួកអ្នកប្រូតេស្តង់ទាំងឡាយឲ្យទៅជាតែមួយ។

377 ឥឡូវនេះពួកអ្នកកាតូលិកមានភាពវាងវៃណាស់ ហើយពួកគេនឹងនាំមកនូវសម្តេចប៉ាប យូហ៉ាន ទីម្ភៃបី ឬទីម្ភៃពីរ ហើយនឹងអ្វីដែលជាគាត់។ គាត់កំពុងតែព្យាយាមដោយចិត្តសុភាពរាបសា ក្នុងការនាំសេចក្តីជំនឿរបស់ពួកអ្នកប្រូតេស្តង់ និងពួកអ្នកកាតូលិក ឲ្យក្លាយទៅជាជំនឿតែមួយ គឺដូចជាអ្វីដែលព្រះគម្ពីរបានសំដែង នោះគេនឹងធ្វើដូច្នេះមែន។ អ្នកនៅទីនេះហើយ។ ហើយពួកអ្នកប្រូតេស្តង់ក៏ធ្លាក់ចូលទៅក្នុង អន្ទាក់ និងរណ្តៅរបស់ពួកគេ។

378 ហេតុអ្វី? ហេតុអ្វី? ពីព្រោះពួកគេមិនទទួលបានការ*ទាំងអស់នេះ* នៅឡើយ។ *ដំរិះ* "ព្រះបន្ទូលគឺត្រឹមត្រូវ។" *ការអត់ធ្មត់* "គឺអស់អ្នកដែលបានរង់ចាំដល់ព្រះជាម្ចាស់។" ចូរមើលថាតើខ្ញុំមានន័យយ៉ាងណា?

379 ដូចជាអ្វីដែលសម្តេចសង្ឃនៃព្រះវិហារមេតូឌីសបាននិយាយកាលពីថ្ងៃមុន គឺនៅពេលដែលពួកគេបានឆ្លងកាត់ទីនោះ។ ហើយតើមានអ្នកណាខ្លះបានស្គាល់សេចក្តីទាំងនោះទេ តើអ្វីគឺជាកត្តាជំរុញទឹកចិត្តដល់ការនោះ ក្នុងការព្យាយាមឲ្យ

មានសេចក្ដីអធិស្ឋានណាមួយនៅក្នុងក្រុមជំនុំ ឬនៅក្នុងសាលា។ ហើយក៏ចង់... ខ្ញុំគិតថានោះគឺជាសេចក្ដីអធិស្ឋាននៅក្នុងសៀវភៅរបស់បុព្វជិតណាមួយ ឬជារឿងអ្វីផ្សេងទៀត ហើយមាតាបិតាសិស្សបានប្ដឹង—ប្ដឹង—សាលានោះ ពីព្រោះពួកគេមិនទទួលស្គាល់សេចក្ដីអធិស្ឋាននោះនៅក្នុងសាលារបស់គេទេ។ ហើយសម្ដេចសង្ឃមេតូឌីសដែលមានវ័យចំណាស់ម្នាក់នេះគឺជាមនុស្សឆ្លាត ហើយគាត់បានក្រោកឈរឡើងដោយនិយាយថា "វាពិតជាខុសហើយ។" "វាមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញនោះទេ" គាត់បានចាប់ឱកាសនេះ។ គាត់និយាយថា "ដូចជាអ្វីដែលនៅក្នុងក្រុមជំនុំមេតូឌីសរបស់យើងដែរ" គាត់និយាយថា "នៅក្នុងក្រុមជំនុំមេតូឌីសរបស់យើង" និយាយថា "មានពួកជំនុំរបស់យើងជាច្រើន តែងតែនិយាយអំពីរឿងអាស្រូវរបស់តារាហូលីវូ៉ដ តែមានប្រហែលកៅសិបប្រាំភាគរយនៃពួកគេក៏នៅតែមើលរឿងហូលីវូ៉ដដែល។"

380 តើវាមានបញ្ហាអ្វីទៅ? ពួកគេបានចាកចេញពីទី*នេះ* ។ ត្រូវណាស់ពួកគេបានចាកចេញពីទីនោះ។

381 ខ្ញុំបាននិយាយនៅក្នុងបន្ទប់នេះនៅត្រង់នេះកាលពីថ្ងៃមុន ជាមួយ—ជាមួយ—នឹងមេដឹកនាំនៃក្រុមជំនុំនិកាយមេតូឌីសដ៏ធំមួយ នៅក្នុងទីក្រុងហ្វូល គឺជាពួកជំនុំដែលពោរពេញដោយព្រះវិញ្ញាណមួយនៅក្នុងទីក្រុងនោះ។ ចូរបង្ហាញសម័យកាលមេតូឌីសដែលបានមកបន្ទាប់ពីសម័យកាលរបស់យើងនៅទីនោះ គឺពួកជំនុំពេនតេកុស្ដ។ ហើយគាត់បាននិយាយថា "នៅក្នុង អ្នកបរិសុទ្ធល្វីស ម៉ាសូរីស ពួកគេបានធ្វើការស្រាវជ្រាវមួយអស់ពេលប៉ុន្មានបីទៅបួនខែ ហើយក៏រកឃើញចម្លើយ" បុរសនោះក៏ប្រហែលកំពុង តែអង្គុយនៅទីនេះនៅថ្ងៃនេះដែល។ ពិតណាស់គាត់គឺជាជាង ដែលបានសាងសង់អាគារនេះ ហើយនឹងបានជួសជុលអាគារនេះឲ្យយើង។ ហើយក្រុមជំនុំមេតូឌីសនៅមាត់ផ្លូវខាងមុខនោះគឺជាក្រុមជំនុំរបស់គាត់ ហើយគាត់ និងប្អូនប្រុសលុំ គឺជាគ្រូគង្វាលនៅទីនោះ។ ដូច្នេះហើយពួកយើងបានរកឃើញថា នៅក្នុងនោះ ខ្ញុំជឿថាចិតសិបប៉ុន្មានភាគរយនៃពួកមេតូឌីសដែលបិននៅក្នុងការស្រាវជ្រាវនោះ។ បើយោងតាមការរកឃើញរបស់អ្នកបរិសុទ្ធល្វីសបានបង្ហាញថាមានប៉ុន្មានជាចិតសិបជាងភាគរយនៃពួកមេតូឌីសបានជក់បារី ហើយហុកសិបប្រាំបីភាគរយនៃពួកគេផឹកស្រាជាភេសជ្ជៈ។ ពួកអ្នកមេតូឌីស! ហើយអ្វីដែលចំលែកនោះគឺនៅពេលដែលប្រាប់ថា មានការ

ស្រាវជ្រាវ ឬក៏ការប្រៀបធៀបរវាងបុរស និងស្ត្រី គឺស្ត្រីតែងតែមានភាគរយជាងចិតសិបជានិច្ច នៅពេលដែលបុរសមានភាគរយត្រឹមតែជាងហាសិបប៉ុណ្ណោះ។ គឺមានស្ត្រីជក់បារី ហើយនិងផឹកស្រាច្រើនជាងបុរសទៅទៀត។ ចិតសិបភាគរយ គឺចិតសិបភាគរយជាងនៃស្ត្រីដែលមានចំនួនច្រើនជាងបុរស។

382 ឥឡូវ បើសិនជាយើងត្រលប់ទៅឯគោលលទ្ធិនៃព្រះគម្ពីរដែល ស្លៀកពាក់ខ្លី ហើយកាត់សក់ខ្លី និង រឿងអ្វីផ្សេងទៀត មើលតើស្ត្រីដែលគោរពកោតខ្លាចព្រះ ត្រូវគោរពកោតខ្លាចព្រះ ហើយនិងមានភាពបរិសុទ្ធយ៉ាងណា? ជប់លៀងលេងល្បែង ហើយនិងអ្វីផ្សេងទៀត ការនិយាយរអេចរអូច ការនិយាយបប៉ាច់បប៉ោច នឹងមិនអាចទប់អណ្តាតរបស់ពួកគេបាន។ គឺជាអណ្តាត ដែលនិយាយរអេចរអូច បប៉ាច់បប៉ោចចុះឡើងៗ។ ចុះចំពោះបុរសវិញ? ការលេងល្បែង ការជប់លៀង ការលេងកូនហ្គោល នៅខាងក្រៅ ស្លៀកពាក់មួយកំណាត់ខ្លួន ស្លៀកសំលៀកបំពាក់កខ្វក់ជាមួយនឹងស្ត្រីរបស់ពួកគេនៅខាងក្រៅនោះ។ គ្មានអីឆ្ងល់នោះទេ!

383 ឃើញគ្រោងការដ៏អាក្រក់ដែលត្រូវបានធ្លាក់ទៅលើអ្នកអធិប្បាយ គឺជាអ្នកអធិប្បាយនៅក្នុងគុកនៅពេលព្រឹកនេះទេ? បាទ អ្នកទាំងអស់គ្នា។ ខ្ញុំមិនជឿថា បុរសម្នាក់បានប្រព្រឹត្តដូចនេះទេ។ តើវាបានធ្វើអ្វីទៅ? ប្អូនប្រុសនេះ...ខ្ញុំមិនអាចគិតអំពីការនេះសោះ...[អ្នកខ្លះនិយាយថា "ខេន ហ្វីលបឺត។"—Ed។] ពិតហើយ។ ខេន ហ្វីលបឺត គឺជាអ្នកអធិប្បាយនៅក្នុងគុក។ នៅពេលដែលបុរសនោះបានចូលមកសម្លាប់ខេន កាលពីប៉ុន្មានខែមុន ហើយឥឡូវនេះប្រពន្ធរបស់គាត់ជិតនឹងឆ្លងទន្លេទៅហើយ។ ដោយព្រោះខេនបានស្លាប់ទៅហើយ នោះគេមិនអាចបង្ហូរឈាមរបស់គាត់ចូលទៅក្នុងកូនរបស់គាត់បានទេឥឡូវនេះ។ នាងបាននិយាយថា ខេនបានចាប់រំលោភនាង ហើយនេះគឺរបស់នាង..."នេះគឺជាកូនរបស់ខេន។" ដូចជា...ខ្ញុំលែងជឿរឿងនឹង ជាជាងរឿងដែលមាន់មានធ្មេញក្ងោក—នោះ—ទៅទៀត។ អត់ទេលោក ខ្ញុំជឿថារឿងនេះគឺជារឿងមិន ពិតនោះទេ។ ខ្ញុំជឿថាខេន ហ្វីលបឺត គឺជាកូនរបស់ព្រះ។ ហើយខ្ញុំជឿថា នេះគឺជាគ្រោងការអាក្រក់របស់សាតាំងទេ។

384 ដូចជាករណីដែលគេបានលើកឡើង អំពីសេចក្តីអធិស្ឋានរបស់ពួកគេដែរ។ សម្តេចសង្ឃចំណាស់ខាងមេតូឌីសមួយនោះ ឆ្លាតគ្រប់គ្រាន់អាចនឹងស្វែងយល់

បាន។ បើសិនជាគាត់បាន បើរឿងនោះបានកើតឡើង នោះវានឹងត្រូវបាន លើកទឹកចិត្តដោយអ្វីផ្សេងតែប៉ុណ្ណោះ។ ត្រូវហើយ។

385 គឺដូចគ្នាទៅនឹងបញ្ហានៃការសំយោគ នៅភាគខាងជើងដែរ វាគឺជារឿងតែមួយ។ ខ្ញុំជឿថា បុរសត្រូវតែដោះឲ្យមានសេរីភាព។ ខ្ញុំជឿថាជាតិសាសន៍មួយនេះក្រោកឈរឡើងដើម្បីសេរីភាព។ ខ្ញុំមិនបន្ទោសលោកខែននីឌី ដែលបានបញ្ជូនទាហានទៅនោះទេ ទោះបីជា ខ្ញុំ—មិនមែនជា "ឈ្មួញថ្មី" ក៏ដោយ ហើយខ្ញុំក៏មិនមែនជាអ្នកស្រឡាញ់លទ្ធិប្រជាធិបតេយ្យនោះទេ។ ខ្ញុំមិនមែនជាអ្នកសាធារណៈរដ្ឋទេ តែខ្ញុំគឺជាគ្រីស្ទាន។ ដូច្នេះខ្ញុំ...ប៉ុន្តែខ្ញុំមិនជឿទៅលើការទាំងនោះទេ។ ខ្ញុំក៏មិនជឿថាមនុស្សស្បែកខ្មៅគួរតែលក់ខ្លួនធ្វើជាទាសករដែរ។ វា—ធ្លាប់ជាបក្សរបបសាធារណៈរដ្ឋ។ ប៉ុន្តែឈាមរបស់លោកអាប្រាហាំលីងឃីនបានធ្វើឲ្យពួកគេមានសេរីភាព ដ្បិតគាត់គឺជាមនុស្សរបស់ព្រះ។ ខ្ញុំគិតថា ពួកគេគួរតែនៅឲ្យជាប់ជាមួយនឹងបក្សរបស់ពួកគេ បើពួកគេនឹងត្រូវបោះឆ្នោត។

386 ប៉ុន្តែសុំឲ្យខ្ញុំបានប្រាប់អ្នកនូវរឿងនេះមួយ ដែលក្មេងប្រុសនោះបានមកទីនេះមិនមែនដោយសារតែនេះគឺជាសាលារបស់វានេះទេ។ ក្មេងប្រុសនោះគឺជាពលរដ្ឋមួយរូប គឺគាត់ជាជនជាតិអាមេរិចកាំង។ សេរីភាពគឺមានសំរាប់គ្រប់គ្នា។ ពណ៌នៃស្បែករបស់មនុស្សមិនអាចនឹងធ្វើឲ្យគេមានភាពខុសប្លែកអ្វីនោះទេ។ យើងទាំងអស់គ្នា..."ព្រះ" មានបន្ទូលថា "ដ្បិតគឺដោយសារតែឈាមរបស់មនុស្សម្នាក់បានធ្វើឲ្យមនុស្សទាំងអស់ជាជាតិសាសន៍តែមួយ។" យើងទាំងអស់គ្នាគឺតែមួយទេ។ ប៉ុន្តែក្មេងប្រុសនោះគឺជាទាហាន។ វាគឺជាទាហានជើងចាស់។ វាបានប្រយុទ្ធសំរាប់អ្វីដែលត្រឹមត្រូវ។ វាមានសិទ្ធិទៅសាលារៀន។ ត្រូវហើយ។ ប៉ុន្តែមានសាលាច្រើនណាស់សំរាប់ឲ្យវាជ្រើសរើស។

387 នេះគឺជាវត្ថុនោះឯង។ បើសិនជាអ្នកនៅពីខាងក្រោយវា នោះនិកាយនៅសម័យនេះ ដែលនៅខាងលើនោះ ដែលបានលើកទឹកចិត្តវា។ ហេតុអ្វី? ពួកគេបានប្តូរដោយពួកស្បែកខ្មៅ ដែលបានបោះឆ្នោតផ្លាស់ប្តូរពីសាធារណៈរដ្ឋទៅជាប្រជាធិបតេយ្យ ហើយពួកគេបានលក់សិទ្ធិរបស់គេដោយសារវា។ នេះគឺជារឿងពិត។ ព្រះវិញ្ញាណបរិសុទ្ធមិនគង់នៅទីនេះទេ...

388 "ចូរឲ្យអស់អ្នក ដែលមានប្រាជ្ញា។" "ចូរឲ្យអស់អ្នក ដែលមានដំរិះ។" ពិតណាស់។ គឺដូចជាក្រុមជំនុំមួយនេះ នៅសម័យនេះ បានលក់ខ្លួនឯង។ តើអ្នកមើលមិនឃើញទេថានឹងមានរឿងអ្វីកើតឡើង?

389 ខ្ញុំមិនខ្វល់ទេ បើទោះបីនេះគឺជាខ្សែអាត់សំលេង។ វាគឺនៅទីនេះ។ អូ។ យា។ តើវាមានបញ្ហាអ្វី? អ្នកម្ដាយចាស់របស់ខ្ញុំធ្លាប់បាននិយាយថា "ចូរឲ្យបំណុលរបស់សាតាំង ទៅវាវិញទៅ។"

390 មានមនុស្សម្នាក់ដែលបានធ្វើការមួយដែលអាចដឹងបាន នោះគឺជាកាស្ត្រូ នៅទីនេះ។ បាទ អ្នកទាំងអស់គ្នា។ គាត់បានចុះទៅទីនោះ។ ហើយពួកនាយទុនមានអស់ទាំងព្រនង់ ហើយនឹងអ្វីៗដែល... វាគឺបិតនៅក្នុងស្តង់ដាមាស ដូចជាសហរដ្ឋអាមេរិកដែរ។ តើគាត់បានធ្វើអ្វី? គាត់បានទិញអស់ទាំងបណ្ណ័ភាគហ៊ុន។ គឺរកលុយតាមគ្រប់ទាំងវិធីដែលគាត់អាចធ្វើទៅបាន។ បន្ទាប់មកតើគាត់ធ្វើអ្វីទៀត? គាត់ក៏បានក្លែងបន្លំក្រដាស់ប្រាក់ ហើយបានប្តូរវា។ ហើយក៏ដាក់ទៅវិញ។ នេះហើយគឺជាអ្វីតែមួយដែលជាតិសាសន៍នេះអាចធ្វើបាន។

391 តើអ្នកមានបានឮពី*ខ្សែជីវិត* កាលពីព្រឹកមុនទេ? ហេតុអ្វី តើអ្នកមានដឹងទេថាវាដូចគ្នាទៅនឹងការដែលអ្នកលក់ប័ណ្ណភាគហ៊ុនទៅលើមាស។ បណ្ណ័ភាគហ៊ុនត្រូវបានយកទៅហើយ។ ហើយរដ្ឋាភិបាលនៅសម័យនេះកំពុងតែចាយលុយដើម្បីអ្វីសំរាប់ប្រាក់ពន្ធដារដែលគេបានប្រមូលសំរាប់សែសិបឆ្នាំទៅមុខទៀតនោះ។ វាត្រូវបានគេប្រើប្រាស់អស់ទៅហើយ។ នេះហើយគឺជា*ខ្សែជីវិត* នៅក្នុងរដ្ឋវ៉ាស៊ីនតោនឆ្លងកាត់ប្រទេសទាំងមូល។ ពន្ធដារ ទាំងអស់ត្រូវបានគេប្រើប្រាស់ ក្នុងការទិញពីបរទេស។ ពិតណាស់ពួកគេគ្រាន់តែបានឲ្យវាទៅតែប៉ុណ្ណោះ។ តើអ្នកមិនឃើញទេឬអី? នេះហើយគឺជាពួកគេ—គឺជាអ្វីដែលគេនឹងធ្វើ។ ឃើញទេ? តើនេះគឺជាអ្វី? ឥឡូវបើប្រជាជាតិនេះបានដួលរលំការតែមួយដែលវាអាចធ្វើបាននោះ គឺដួលរលំ។ ការតែមួយដែលវាអាចធ្វើទៅបាននោះ គឺការក្ស័យធន់។

392 នេះគឺជាបញ្ហាតែមួយដែលអាចដឹងទៅបាន គឺប្តូររូបិយវត្ថុ។ ប៉ុន្តែគេមិនដែលធ្វើវាទេ ទាល់តែមកដល់ការផ្គត់ផ្គង់នៅសម័យនេះ។ ព្រះវិហាររ៉ូម៉ាំងកាតូលិកគឺជាម្ចាស់នៃមាសរបស់ពិភពលោក។ ហើយអ្វីដែលពួកគេនឹងធ្វើនោះ គឺនឹងលក់វាចេញ "ពួកអ្នកមានទាំងអស់នេះ" ហើយក៏ "នៃពិភពលោក" ដូចដែលព្រះគម្ពីរបានសំដែង។ តើពួកគេនឹងធ្វើអ្វីមុនពេលដែលពួកគេត្រូវបាត់បង់ទៅ? យ៉ាងណា

មិុញក្រុមហ៊ុនបារីប្រោន និងក្រុមហ៊ុនថ្នាំជក់ វីលៀមសាន់ស្មើរតែទាំងអស់ជាកម្មសិទ្ធិរបស់ពួកកាតូលិក។ ហើយចំពោះរឿងអ្វីផ្សេងពីនេះទៀត នោះតើពួកគេនឹងត្រូវធ្វើអ្វីទៀត? ពួកគេនឹងទទួលស្គាល់វា គឺពួកគេនឹងយកលុយពីទីក្រុងរ៉ូម រួចហើយនាងនឹងលក់សិទ្ធិពីកំណើតរបស់នាង។ ហើយទីក្រុងរ៉ូមនឹងយកនាងទៅ។ ហើយឥឡូវពួកគេមាន គោលនយោបាយគ្រប់គ្រាន់ហើយ គឺមានគ្រប់គ្រាន់នៅក្នុងចំណោមគេ ក្នុងការបង្កើត គណៈរដ្ឋមន្ត្រីរបស់គាត់។ ចូរមើលពីអ្វីដែលលោកឃែនីឌីកំពុងតែសូម។

393 ហើយនៅពេលដែលអ្នកបានឃើញការនេះកាលពីថ្ងៃមុននោះគឺវាមិនត្រូវមានការបោះឆ្នោតទៀតទេ។ តើការបោះឆ្នោតវាមានប្រយោជន៍អ្វី? នៅពេលដែលគេបានដាក់វានៅលើក្រដាស ហើយមានភស្តុតាងនៅមុខសាធារណជន ហើយគេបានបដិសេដមិនព្រមធ្វើអ្វីចំពោះការទាំងនោះ។ នៅពេលដែលគេអាចបង្ហាញថា ម៉ាស៊ីនត្រូវបានបង្កើតឡើង នៅទូទាំងប្រទេស ហើយគេបានជ្រើសរើសលោកឃែនីឌីដោយការបោះឆ្នោតក្លែងក្លាយ។ តើព្រះគម្ពីរមិនបានសំដែងថា វានឹងមក ជាមួយនឹងការបោកប្រាស់ទេឬអី? ពិតណាស់ គឺជាសេចក្តីកុហក់គ្រប់យ៉ាង។ ឥឡូវខ្ញុំមិនបានប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ឬក៏សាធារណៈរដ្ឋនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែលើកយកសេចក្តីពិតដែលមាននៅក្នុងព្រះគម្ពីរមកតែប៉ុណ្ណោះ។តើការបោះឆ្នោតនឹងមានប្រយោជន៍អ្វី?ពួកគេបានដឹងហើយថា តើអ្នកណានឹងមកនៅទីនេះ។

394 តើមានប៉ុន្មាននាក់ខ្លះនៅចាំ ក្នុងការផ្សព្វផ្សាយនៅតាមទូរទស្សន៍ ដែលមានស្ត្រីពីរនាក់កំពុងតែងើបឈរឡើង? ហើយម្នាក់និយាយថា "ខ្ញុំនឹងបោះឆ្នោតឲ្យលោក...។" ឬក៏ស្ត្រីខាងប្រូតេស្តង់និយាយថា "ខ្ញុំនឹងបោះឆ្នោតឲ្យលោកឃែនីឌី។"

ពួកគេនិយាយថា "ហេតុអ្វី?"

395 និយាយថា "ពីព្រោះខ្ញុំគិតថាគាត់គឺជាមនុស្សដែលឆ្លាតជាងលោកនីកហ្សិន។ គាត់នឹងធ្វើឲ្យប្រូតេស្តង់កាន់តែប្រសើរឡើង។"

396 រួចហើយគាត់និយាយថា "នេះគឺជាស្ត្រីខាងកាតូលិក។ 'តើអ្នកនឹងបោះឆ្នោតឲ្យអ្នកណា?'"

397 នាងនិយាយថា "ខ្ញុំគឺជាអ្នកកាតូលិក ជារ៉ូម៉ាំងកាតូលិក ជាអ្នកដឹងគុណកាតូលិក។" នាងនិយាយថា "ហើយខ្ញុំនឹងបោះឆ្នោតឲ្យលោកនីកហ្សិន។"

"ហេតុអ្វី?"

398 និយាយថា "ពីព្រោះលោកនីកហ្សិននឹងក្លាយទៅជាប្រធានាធិបតីដ៏ប្រសើរ ពីព្រោះគាត់មានបទពិសោធន៍ទៅលើផ្នែកនេះច្រើនជាង។ គាត់យល់អ្វីទៅដែលហៅថា លទ្ធិកុម្មុយនីស្តនិយម។" ស្ត្រីម្នាក់នោះនិយាយពាក្យមិនពិត។

399 ខ្ញុំមាន...គឺអ្វីដែលគេបានហៅថា *សេចក្តីពិតនៃជំនឿរបស់យើង* សៀវភៅដ៏ខ្ពស់បំផុតរបស់កាតូលិកអាចនឹងរកទិញបាន។ ហើយនៅក្នុងនោះបានសរសេរថា "បើមានពាក្យថា កាតូលិកក្នុងសំបុត្រ នោះវាពិតជានឹងរត់ប្រច្រាស់នឹងប្រូតេស្តង់ហើយ បើសិនជាអ្នកខាងព្រះវិហារកាតូលិកបោះឆ្នោតឲ្យអ្នកប្រូតេស្តង់ នោះពួកគេនឹងត្រូវបណ្តេញចេញពីសមាគមន៍នៃក្រុមជំនុំកាតូលិករបស់ពួកគេ។"ត្រូវ។"ហើយបើមានអ្នកខាងព្រះវិហារកាតូលិកពីរអ្នក នៅក្នុងការិយាល័យតែមួយ នោះគេនឹងជ្រើសរើស អ្នកដែលដឹងគុណទៅដល់ក្រុមជំនុំដើមរបស់ពួកគេ។"

400 ចូរមើល តើការដែលគេបានព្យាយាមធ្វើនោះ គឺជាការបោកប្រាស់យ៉ាងណា? ឲ្យលុយទៅដើម្បីទិញ។ ហេតុអ្វី? ពួកគេកំពុងតែព្យាយាមក្នុងការបំបែកវាហើយ។ ហើយពួកគេបាននឹងកំពុងធ្វើវា នៅពេលដែលនាងត្រូវបានបែកបាក់។ ហើយតើនេះគឺជាអ្វីទៅ? វាគឺបិតនៅក្នុងស្តង់ដាមាស។ ហើយពួកអ្នកកាតូលិកដែលមានតំណែងខ្ពស់ គឺជាម្ចាស់នៃមាសរបស់ពិភពលោក។ [មានអ្នកខ្លះនិយាយថា "មួយរយហុកសិបប្រាំបី កោតដុល្លារ។"—Ed។] មួយរយហុកសិបប្រាំបី កោតដុល្លារ។ អ្នកនៅទីនោះ។ ចូរបោះវាទៅក្នុងស្តង់ដាមាសវិញទៅ ហើយអ្នកទាំងអស់គ្នាដែលជាមនុស្ស ចូរថែរក្សាផ្ទះរបស់អ្នក នឹងរបស់ផ្សេងទៀត ប៉ុន្តែអ្នកគឺជាកម្មសិទ្ធិរបស់ក្រុមជំនុំនៃពួកកាតូលិកដែរ។ ប្រជាជាតិទាំងមូលគឺជាកម្មសិទ្ធិរបស់ក្រុមជំនុំកាតូលិក។ គ្រប់ការទាំងអស់ត្រូវបានចាប់ចូលមកយ៉ាងដូច្នេះ គឺតាមរយៈរូបិយវត្ថុរបស់គេ។ តើព្រះគម្ពីរមិនបានសំដែងដូច្នេះទេឬអី? នេះហើយគឺជារូបភាពដែលព្រះគម្ពីរបានសំដែងប្រាប់យើង។

401 អ្វីដែលខ្ញុំព្យាយាមនិយាយនៅថ្ងៃនេះបងប្អូនអើយ។ ពួកគេនឹងនិយាយថា "ការនោះនឹងធ្វើឲ្យ ក្រុមជំនុំមានសភាពធម្មតា។ វានឹងបង្រួបបង្រួមនិកាយប្រូតេ

ស្គង់។″ វាគឺជារឿងល្អសំរាប់ភ្នែកពីធម្មជាតិ ប៉ុន្តែសំរាប់ចំណេះដឹងនៃលោកិយគឺការឆោតល្ងង់នៅចំពោះព្រះប៉ុណ្ណោះ។

402 ‶ហើយវាតំកើងព្រះតាមរយៈ—ការអធិប្បាយល្ងង់ខ្លៅដើម្បីសង្គ្រោះអស់អ្នកដែលបាត់បង់″ តាមរយៈតួនាទី ដែលទ្រង់បានអនុញ្ញាតិឲ្យមាននៅក្នុងក្រុមជំនុំរបស់ទ្រង់ក្នុងការបង្កើតក្រុមជំនុំនេះឡើងដោយផ្អែកលើការស្មើរភាពគ្នានៃវិញ្ញាណ ហើយមិនមែនផ្អែកលើការទាំងឡាយដែលទាក់ទងនៅលើផែនដីនេះ នោះឡើយ។

403 ពេត្រុសនិយាយថា ‶ហើយដោយព្រោះអ្នកបានរួចផុតពីសេចក្តីពុករលួយនៃផែនដី តាមរយៈការចង់បានទ្រព្យសម្បត្តិ និងការចង់បាននៃពេលវេលាដ៏ធំ និងការបំពេញចំណង់ និង ការហូប និងផឹក និងចំណង់ដែលយើងមាន។ អ្នកបានរួចផុតពីការទាំងនោះ។ ហើយឥឡូវអ្នកបានបង្កើតឲ្យមានជីវភាពនៃការរស់នៅ។ ខ្ញុំចង់និយាយការនេះជាមួយនឹងក្រុមជំនុំ។″ អ្នកនៅទីនេះ។ តើអ្នកបានអានវាដែរទេ? តើអ្នកយល់វាដែរទេ? តើអ្នកបានឮនៅពេលដែលវាត្រូវបានសរសេរម្តងទៀតនៅក្នុងពេត្រុសខ្សែរទី២ដែរទេ? គឺគ្រាន់តែស្តាប់នូវអ្វីដែលគាត់បាននិយាយនៅទីនេះ តើវាត្រូវបានសរសេរឡើងយ៉ាងល្អប៉ុណ្ណា តើ—គាត់បានលើកឡើងយ៉ាងណា។ ត្រូវហើយ។ ចូរស្តាប់ដល់គាត់ឥឡូវនៅពេលដែលគាត់និយាយ។ ត្រឹមត្រូវ។

*សំបុត្រស៊ីម៉ូន ពេត្រុស ជាបាវបំរើ ហើយជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ ខ្ញុំផ្ញើរមកពួកអ្នកដែល...ដែលបានទទួលសេចក្តីជំនឿដ៏វិសេស ត្រូវគ្នានឹងយើងខ្ញុំដែរ ដោយសេចក្តីសុចរិតនៃព្រះយេស៊ូវគ្រីស្ទដ៏ជាព្រះ ហើយជាព្រះអង្គសង្គ្រោះនៃពួកយើងទាំងអស់គ្នា:*

*...សូមឲ្យ—ព្រះគុណ នឹងសេចក្តីសុខសាន្ត បានចំរើនដល់អ្នករាល់គ្នាឲ្យបានស្គាល់ព្រះ នឹងព្រះយេស៊ូវ ជាព្រះអម្ចាស់នៃយើង*

*ដ្បិតព្រះចេស្តា—នៃព្រះបានផ្តល់ឲ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់...*

404 តើអ្នកណានឹងត្រូវទទួលបានផែនដី និងរបស់គ្រប់ទាំងអស់ជាមរតក? [មានអ្នកខ្លះនិយាយថា "ពួកបរិសុទ្ធ"—Ed។] ពិតណាស់។ "ខាងឯជីវិត..." ត្រូវណាស់។ ត្រឹមត្រូវហើយ។

> *...ខាងឯជីវិត នឹងសេចក្ដីគោរពប្រតិបត្តិដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គ ដែលទ្រង់ហៅយើងរាល់គ្នាមក ដោយសារសិរីល្អ នឹងព្រះគុណរបស់ទ្រង់:*
>
> *ដែលដោយសារសេចក្ដីទាំងនោះ ទ្រង់បានប្រទានសេចក្ដីសន្យាដ៏ធំបំផុត ហើយវិសេសផង...មកយើងរាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានចំណែកនិស្ស័យនៃព្រះ ដោយសារសេចក្ដីសន្យានោះឯង ដោយបានរួចពីសេចក្ដីពុករលួយនៅក្នុងលោកិយ៍នេះ(ស្ដាប់ការនេះ។) ដែលកើតអំពីសេចក្ដីប៉ងប្រាថ្នា។*

405 សេចក្ដីប៉ងប្រាថ្នាចំពោះប្រាក់ សេចក្ដីប៉ងប្រាថ្នាសំរាប់ការដែលធំ សេចក្ដីប៉ងប្រាថ្នាសំរាប់ការល្បីឈ្មោះ ការទាំងអស់នេះគឺជាសេចក្ដីស្លាប់សំរាប់អ្នកជឿ។ យើងមិនខ្វល់ទេ។ តង់ ឬក៏ខ្ទមតូច ហេតុអ្វីបានជាខ្ញុំត្រូវខ្វល់ រស់ឬក៏ស្លាប់ លិច ឬលង់? តែនេះគឺជារឿងដែលខ្ញុំពេញចិត្តវិញ នោះគឺជានគរនៃព្រះ។ បើទោះបីខ្ញុំរក្សាផ្ទះរបស់ខ្ញុំ បើទោះបីខ្ញុំរក្សាក្រុមគ្រួសាររបស់ខ្ញុំ បើទោះបីខ្ញុំរក្សាសេចក្ដីទាំងឡាយនោះ សូមឲ្យខ្ញុំបានរក្សាព្រះគ្រីស្ទ ដែលជាសេចក្ដីសង្ឃឹមនៃសិរីល្អ។

406 សូមព្រះអង្គបង្កើតខ្ញុំឡើងនៅក្នុងការ *នេះ*។ សូមឲ្យព្រះគ្រីស្ទគឺជាក្បាលរបស់ខ្ញុំដែលធ្វើការតាមរយៈខ្ញុំ។ លើគ្រឹះរបស់ខ្ញុំ សេចក្ដីជំនឿរបស់ខ្ញុំ គឺនៅក្នុងទ្រង់ សូមឲ្យសេចក្ដីទៀងត្រង់ ដំរិះ សេចក្ដីអត់សង្កត់ ការអត់ធ្មត់ ការចេះគោរពប្រតិបត្តិដល់ព្រះ នឹងការចេះរាប់អានគ្នាជាបងប្អូន បានធ្វើការនៅក្នុងខ្ញុំ ឱព្រះអង្គអើយ នេះគឺជាសេចក្ដីអធិស្ឋានរបស់ខ្ញុំ។ ខ្ញុំមិនខ្វល់ទោះបីជាស្លាប់ ឬរស់ ឬលិច ឬធ្លាក់ចុះ ទោះមាននិកាយ ឬគ្មាននិកាយ មានមិត្ត ឬគ្មានមិត្តក៏ដោយ។ សូមឲ្យការទាំងនោះបានធ្វើការនៅក្នុងចិត្តខ្ញុំ សូមឲ្យសេចក្ដីទៀងត្រង់របស់ព្រះគ្រីស្ទ ព្រះដំរិះរបស់ទ្រង់ បានហូរចុះមក ដែលនឹងអាចធ្វើឲ្យខ្ញុំមានសមត្ថភាពអាចនឹងបង្រៀនដល់អ្នកដ៏ទៃទៀតបាន។

407 "ដ្បិតព្រះបានចាត់ឲ្យមានក្រុមជំនុំ សាវ័ក ហោរ៉ា គ្រូបង្រៀន គ្រូគង្វាល នឹងអ្នកផ្សាយដំណឹងល្អ ទាំងអស់សំរាប់សេចក្ដីគ្រប់លក្ខណ៍ ហើយនឹងនាំយកគ្រប់

ទាំងសេចក្តីទៀងត្រង់មក សំរាប់សេចក្តីគ្រប់លក្ខណ៍នៃការយាងមកវិញនៃបុត្រា នៃព្រះ។" គ្រប់ទាំងថ្មអស់*ទាំងនេះ* គឺជាបំនែកនៃរបស់មួយ។ *នេះ*គឺជាបំនែករបស់មួយនេះ។ គ្រប់ទាំងសេចក្តីទៀងត្រង់ទាំងអស់នេះគឺជារបស់ផងទ្រង់ ហើយវាត្រូវបានច្រូចបង្ហូរចេញដោយសារទ្រង់ មកលើពួកគេ។ អាម៉ែន។

408 នេះគឺម៉ោងដប់ពីរហើយ។ តើវាទៅឯណា? អាម៉ែន។ តើអ្នកទាំងអស់គ្នាស្រឡាញ់ទ្រង់ដែរឬទេ? [ពួកជំនុំនិយាយថា "អាមែន។"—Ed។] តើអ្នកជឿរឿងនេះទេ? ["អាម៉ែន។"] កូនតូចៗអើយចូរស្តាប់។

409 បងស្រីឃីតនិយាយនៅពេលព្រឹកនេះថា "ប្អូនប្រុសប៊ីល ខ្ញុំមិនដឹងថា ខ្ញុំអាចនឹងបានជួបអ្នកម្តងទៀតឬទេ។" ការនោះដូចជាសម្លាប់ខ្ញុំដែរ ឃើញទេ? គាត់គិតថាគាត់កំពុងតែចាស់ហើយ ពិតមែនគាត់ចាស់មែន។ ខ្ញុំអធិស្ឋានសូមឲ្យព្រះបានរក្សាឲ្យនាងជាយូរទៅទៀតសំរាប់បងប្រុសឃីដ។

410 សូមឲ្យខ្ញុំបានប្រាប់អ្នក យើងមិនដឹងថាយើងនឹងអាចជួបគ្នាដល់ពេលណានោះទេ។ ខ្ញុំក៏មិនបានដឹងថា ខ្ញុំអាចនឹងនៅជាមួយអ្នកបានយូរប៉ុណ្ណាដែរ។ ព្រះអាចនឹងហៅខ្ញុំពីផែនដីនេះទៅ។ ទ្រង់ក៏អាចនឹងហៅខ្ញុំឲ្យធ្វើការងារផ្សេងទៀត។ ទ្រង់អាចនឹងត្រាស់ហៅអ្នកទៅកន្លែងណាមួយ។ អ្នកមិនដែលដឹងទេ។ តែចូរ—រង់ចាំទទួលវា។ សូមកុំឲ្យការទាំងនេះបានកន្លងផុតពីរយើងឡើយ។ ចូរចាប់យកវា។

411 នោះគឺជាអ្វីដែលមាននៅក្នុងព្រះគម្ពីរ។ នេះហើយគឺជាគំរូនៃរបស់ទាំងអស់។ ហើយបើសិនជាខ្ញុំមានពេលនឹងធ្វើវា! អ្នកមិនអាចធ្វើវានៅក្នុងរយៈពេលមួយថ្ងៃបានទេ។ អ្នកដឹងរឿងនេះហើយ។ ប៉ុន្តែមិនអាចចង ការទាំងអស់នោះឲ្យនៅជាមួយគ្នាបានទេ!

412 មើលនៅពេល ដែលយើងបានឆ្លងកាត់ព្រះរាជសារមួយនេះនៅទីនោះ អ្នកបានឃើញហើយពីអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបានធ្វើនៅត្រង់នោះគឺនៅលើជញ្ជាំង តើមិនមែនទេឬ? តើមានប៉ុន្មាននាក់បាននៅទីនោះ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] ឃើញទេ? ពិតណាស់! សូមឲ្យទេវតានៃព្រះចុះមកហើយទាញយករបស់ដដែលនោះទៅ។

413 ឃើញទេ វាគឺជារឿងពិត។ សូមកុំឲ្យវាគេចចេញពីអ្នកឡើយ។ កូនៗអើយ ចូរកាន់វាឲ្យជាប់។ កាន់វាឲ្យជាប់។ ចូរចងចាំ ត្រូវបង្កើតសេចក្តីជំនឿរបស់អ្នក សេចក្តីទៀងត្រង់ ដំរិះ ការអត់ធ្មត់!

414 ឥឡូវនៅទីនេះខ្ញុំគិតថា ខ្ញុំមានក្រដាសមួយសន្លឹកនៅទីនេះ បើខ្ញុំមិនបានធ្លាក់នៅកន្លែងណាមួយនៅពេលដែលខ្ញុំកំពុងអធិប្បាយ។ វាគឺនៅទីនេះ។ អរគុណណាស់ប្អូនប្រុស អរគុណខ្លាំងណាស់។ បើអ្នកចង់—មើលវា ហើយចាំមើលតើនៅទីនេះ ដែលអ្នកអាច...។ ប្រហែលជាវានឹងត្រូវជាគូរ ដែលល្អជាងមួយនោះដែលអ្នកអាចនឹងកត់ចំលងពីវាបាន។ ហើយខ្ញុំនឹងដាក់វានៅទីនេះ ហើយ—អ្នកនឹងអាចមើលវា រួចហើយនឹងបានសរសេរវាឡើង។

415 ហើយខ្ញុំចង់ឲ្យអ្នកយកវាទៅ ហើយសិក្សាវា ហើយប្រៀបធៀបវា រួចហើយអនុវត្តវា។ សូមកុំគ្រាន់តែសិក្សាវា ហើយប្រៀបធៀបវាឡើយ តែចូរអនុវត្តវាចុះ។ ចូរឲ្យពិតប្រាកដនឹងវាសំរាប់ខ្លួនអ្នក។ កុំនិយាយថា "ពិតណាស់ ខ្ញុំរីករាយនឹងស្តាប់វាខ្លាំងណាស់។" ខ្ញុំក៏ធ្លាប់ដែរ ប៉ុន្តែការដែលស្តាប់វា និង ការទទួលវាគឺជារឿងពីរផ្សេងគ្នា។ ឃើញទេ? ឃើញទេ? វាខុសគ្នា ឃើញទេ?

416 គឺមានលក្ខណៈសម្បត្តិប្រាំពីរយ៉ាង ក្នុងការបង្កើតនូវលក្ខណៈរបស់ព្រះ។ គឺមានសម័យកាលនៃក្រុមជំនុំទាំងប្រាំពីរ ដែលព្រះបាននាំក្រុមជំនុំឲ្យបានមកកាន់លក្ខណៈសម្បត្តិនេះ។ ហើយទ្រង់ក៏មានព្រះរាជសារប្រាំពីរក្នុងការអនុវត្តវា។ គឺមានប្រាំពីរ ប្រាំពីរ ប្រាំពីរ។ ឃើញទេ? លេខប្រាំពីរ គឺ—ជាលេខនៃការបញ្ចប់កិច្ចរបស់ព្រះហើយលេខ៣គឺជាលេខដ៏គ្រប់លក្ខណ៍របស់ព្រះ។ ដូច្នេះ គឺមានបី និង ប្រាំពីរនៃបី។ ដូច្នេះតាមគណិតសាស្ត្រ ខាងផ្នែកវិញ្ញាណ ដោយព្រះបន្ទូលរបស់ព្រះ ដោយបន្ទាល់របស់ព្រះវិញ្ញាណបរិសុទ្ធ ការទាំងអស់នេះបានបញ្ចប់វាជាមួយគ្នា។ ចូរយើងសិក្សាវា។

417 ចូរបន្ថែមឲ្យសេចក្តី ជំនឿនូវរឿងទាំងនេះ ដើម្បីឲ្យយើងអាច នឹងមកដល់លក្ខណៈពេញលេញរបស់ព្រះ ដែលនឹងត្រូវរួបរួមគ្នាឡើង ជាមួយនឹងសេចក្តីស្រឡាញ់នៃព្រះ សេចក្តីកោតខ្លាចដល់ព្រះ មានការគោរពគ្នាយ៉ាងជ្រាលជ្រៅនៅក្នុងចិត្តចំពោះគ្នាទៅវិញទៅមក សេចក្តីរាប់អានគ្នាជាបងប្អូន មិនមានភាពថោកទាប គ្មានអ្វីទាំងអស់ក្រៅពីភាពគ្រប់លក្ខណ៍របស់ព្រះវិញ្ញាណបរិសុទ្ធ។ ឃើញទេ? រស់នៅជាមួយគ្នា ចូរឲ្យក្លាយជាគ្រីស្ទាន។ ដើរដោយសេចក្តីជំនឿ។

ចូរឲ្យសេចក្ដីទៀងត្រង់របស់ព្រះបានហូរតាមរយៈអ្នក ចូរយកជំរិះនៃព្រះ នៅពេលដែលមកដល់អ្វីមួយខុស អ្វីមួយត្រូវ។ នៅពេលដែលសាតាំងបានបង្ហាញអ្វីមួយដែលមិនបានចែងនៅក្នុងព្រះគម្ពីរ ចូរដើរចេញពីវាទៅ។ ត្រូវហើយ។

418 ខ្ញុំអាចគិតបានអំពីពួកសាវ័កទាំងអស់ គឺគេមិនធ្វើដូចជាយើងទេ។ ពួកគេគឺជាមនុស្ស ដែលមិនសូវចេះនិយាយប៉ុន្មានទេ រហូតទាល់តែគេបានមកលើតុអធិប្បាយ។ ពួកគេបានដើរចូល ហើយក៏ធ្វើការអ្វីដែលគេត្រូវធ្វើ ហើយក៏ដើរចេញទៅវិញ។ បាទ អ្នកទាំងអស់គ្នា ពួកគេមានអំណាច។ ពួកគេមានសេចក្ដីទៀងត្រង់។ ពួកគេមិនដែលឈ្លោះគ្នាជាមួយមនុស្សណាឡើយ។ ពួកគេដឹងថាកន្លែងណាដែលគេគួរតែឈរ។ ទាំងអស់នេះ ពួកគេដឹងថាពួកគេជឿលើអ្នកណា។ ពួកគេនៅតែបន្តដើរនៅក្នុងវិញ្ញាណរហូត។ ធ្វើតែអ្វី...

419 ដូចជាអ្វីដែលខ្ញុំបាននិយាយកាលពីយប់មុន។ គ្រាន់តែការងក់ក្បាលតែមួយប៉ុណ្ណោះដែលព្រះត្រូវធ្វើ រួចហើយគ្មានអ្វីអាចបញ្ឈប់គេបានឡើយ។ ពួកគេមិនដែលមានសំនួរ ហើយនឹងសិក្សា នឹងបញ្ចេញសំលេងហ៊ឹមៗ នឹងខ្វល់ខ្វាយដូចជាយើង ថាតើពួកគេគួរតែធ្វើ*មួយនេះ* ឬក៏*មួយនោះ*។ ពួកគេបានសម្រេចការទាំងអស់ ទោះជាមានរឿងអ្វីក៏ដោយ។ គ្រាន់តែព្រះអង្គយល់ព្រមនោះកិច្ចការត្រូវបានបញ្ចប់កាន់តែឆាប់តាមដែលអាចធ្វើទៅបាន។ ហេតុអ្វី? តើពួកគេអាចដឹងយ៉ាងម៉េចបានថា នេះគឺជាការយល់ព្រមរបស់ព្រះនោះ? ពួកគេមានអស់ទាំងសេចក្ដីទៀងត្រង់នៅក្នុងនេះ គឺគុណសម្បត្តិទាំងអស់នេះ។ ហើយការងក់ព្រះកេះទីមួយរបស់ព្រះប្រៀបធៀបជាមួយនឹងគ្រប់ទាំងការបន្តិចបន្តួចនៃមួយនេះ ហើយជាមួយព្រះបន្ទូលរបស់ទ្រង់។ ពួកគេដឹងថា នេះគឺជាព្រះបន្ទូលរបស់ព្រះ ហើយគេក៏បានចេញទៅ។ គឺមិនដែលខ្វល់ខ្វាយអំពីអ្វីនោះទេ។ នៅពេលដែលព្រះមានព្រះបន្ទូលពួកគេនឹងចេញទៅភ្លាម។ យើងនិយាយ...

420 ព្រះមានព្រះបន្ទូលមកយើង ហើយយើងនឹងនិយាយថា "ពិតណាស់ ពិតណាស់ បញ្ចប់វាទៅ។ យើងនឹងចាំមើលថា យើងអាចរស់នៅក្នុងជីវិតនេះឬទេ។" រឿងទីមួយដែលអ្នកបានដឹងនោះគឺមានអ្នកខ្លះធ្វើឲ្យអ្នកមិនសប្បាយចិត្ត។ ពិតណាស់ ប្រាកដណាស់ នោះគឺជាវិញ្ញាណអាក្រក់។

421 អ្នកគួរតែបានឃើញវាព្យាយាមមិនឲ្យខ្ញុំមកចូលរួមនៅក្នុងការប្រជុំនៅព្រឹកនេះ។ អ្នកគួរតែមានពេលវេលាដូចនេះ។ ឱ ព្រះគុណអើយ! ខ្ញុំត្រូវតែតតាំង

នៅពេលណាដែលខ្ញុំរំលឹកអំពីការប្រជុំ។ ហើយបើសិនជាខ្ញុំនឹងត្រូវអធិស្ឋានឲ្យអ្នកជម្ងឺ ហើយ បើមានណាកំពុងតែស្លាប់ដោយមិនទាន់បានសង្គ្រោះ នោះនឹងមានអ្នកតែមកជាងសាមសិបដងក្នុងពេលដប់នាទី គឺវាចេះតែឲ្យកាន់តែបានឆាប់ដើម្បីរារាំងខ្ញុំពីការទាំងនោះ។ "អូបងប្រុសប្រានហាំអ្នកគួរតែធ្វើការមួយ*នេះ*។" ប៉ុន្តែមានព្រលឹងមួយនៅបង្គោលខាងនោះ។ ប្រាកដណាស់។ បាទ។

422 កាលពីយប់មុន ខ្ញុំត្រូវបានគេហៅទៅកន្លែងមួយ។ ខ្ញុំបាននិយាយជាមួយបុរសវ័យក្មេងម្នាក់នៅទីនេះ ជាកន្លែងដែលអ្នកហៅថា ផ្សារទំនើបកាលពីប៉ុន្មានឆ្នាំមុន។ គាត់បានក្លាយទៅជាអ្នកញៀនស្រា។ ខ្ញុំដឹងថាក្មេងប្រុសនោះ គឺជាក្មេងធម្មតាម្នាក់ ប៉ុន្តែវាគឺអ្នកមានបាប។ ហើយម្តាយរបស់វាក៏បានហៅដូច្នេះដែរ។ ខ្ញុំគិតថាគាត់ត្រូវបានគេហៅឲ្យជួប គ្រូពេទ្យប៉ុន្មានដងដែរ។ ខ្ញុំ...បានហៅ ហើយគេបានហៅថា ប៊ីលី ហើយ—រួចមកខ្ញុំក៏ទទួលបានព្រះរាជសារ។ ហើយនៅពេលដែលខ្ញុំបានទទួលព្រះរាជសាររួចមក ដោយភាពស្មោះត្រង់នឹងសេចក្តីពិត ខ្ញុំមិនសូវដែលមានជំលោះជាមួយនឹងក្មេងនោះទៀតទេ។

423 ហើយនៅពេល ដែលបានទៅដល់ទីនោះ មានអ្នកក្រម្នាក់ដែលបានស្គាល់ខ្ញុំកាលពីមុន។ ហើយគាត់ដេកនៅទីនោះទាំងបាត់បង់ស្មារតី និងការយំស្រែក។ ឪពុករបស់គាត់ព្យាយាមបបោសអង្អែលគាត់ដោយនិយាយថា "សំណព្វចិត្ត។" ហើយបុរសនោះមានអាយុហាសិប ប្រហែលជាហាសិបមួយឆ្នាំហើយ។ ហើយនិយាយថា "សំណព្វចិត្ត" *នេះ* ហើយ "នៅដេកដដែល។" ហើយគាត់ក៏ព្យាយាមក្រោកឈរឡើង។ ដៃដែលចាស់របស់គាត់ប្រហែលប៉ុន *នោះ* អោបជុំវិញគាត់។ ក្មេងប្រុសនោះមានមហារីកខ្លាំងដល់ម្ល៉េះ ដែលខ្លួនរបស់វាពេញដោយដុំរឹងៗនៃមហារីក។ គ្រប់ទាំងសរីរាង្គរបស់វាទាំងអស់ពោរពេញដោយរោគមហារីក។ សូម្បីតែឈាមរបស់វាក៏មានរោគមហារីកដែរ គឺទាំងអស់។ ហើយនៅទីនោះវាព្យាយាមក្រោកឈរឡើង ហើយត្រូវបានគេលើកឡើងយ៉ាងដូច្នេះ។

424 ខ្ញុំបានយកដៃចង្អុលប្រាប់វាដោយនិយាយថា "វ៉ូឌជ្រូ វ៉ូឌជ្រូ នេះគឺជាបងប្រុសប្រានហាំ។"

425 ឪពុករបស់គាត់និយាយថា "តើឯងស្គាល់ទេ? នេះគឺជាបងប្រុសប៊ីល។ វ៉ូឌ ជ្រូ នេះគឺជាបងប្រុសប៊ីល។"

គាត់និយាយថា "ហឺ។ ហា។ ហឺ-ហា-ហា។" ដូច*នេះ*។

426 ហើយឪពុកម្នាក់នេះបានមើលមកខ្ញុំ ហើយក៏និយាយថា "ប៊ីល អើយអ្នកមកយឺតបន្តិចហើយ។"

ខ្ញុំនិយាយថា "មិនដែលយឺតពេកនោះទេ។ ទ្រង់គង់នៅទីនេះហើយ។" ខ្ញុំមានចំបាំងទៀតហើយ។

427 ហើយនៅពេលដែលមានក្មេងប្រុសផ្សេងទៀតមកដល់ ដែលជាអ្នកមានបាបដែរនោះ ហើយអ្នកទាំងនោះគឺជាបងប្អូនជីដូនមួយនឹងវា។ ខ្ញុំនិយាយថា "ក្មេងទាំងអស់គ្នា ពួកឯងឃើញទេ ចូរប្រុងខ្លួនឲ្យហើយទៅ ពីព្រោះនៅថ្ងៃណាមួយឯងទាំងអស់គ្នានឹងដូចវាដែរ។ ឯងទាំងអស់គ្នាត្រូវតែចុះមកឯទីនេះ។ ឃើញទេ? ប្រហែលជាមិន—មែនជំងឺមហារីកនេះទេ។ អ្នកអាចនឹងកើតមានបញ្ហាអ្វីមួយនៅលើផ្លូវធំនោះ ហើយហូរឈាមស្ទើរតែនឹងស្លាប់ ឬអ្វីផ្សេងទៀត។ អ្នកនឹងបានទទួលវា។" យើងបាននិយាយទៅកាន់ពួកគេ។

428 ខ្ញុំបានរង់ចាំឲ្យព្រះវិញ្ញាណប្រាប់ខ្ញុំនូវអ្វីដែលត្រូវធ្វើបន្តទៀត។ រង់ចាំ ការទីមួយនោះអ្នកដឹងទេ ខ្ញុំមានអារម្មណ៍ថា ព្រះទ្រង់បានងក់ព្រះកេះទ្រង់ថា "ចូរដាក់ដៃឯងនៅលើវា។"

429 ខ្ញុំបានដើរជុំវិញហើយនិយាយថា "អ្នកទាំងអស់គ្នាចូរអោនក្បាលចុះ។" ពួកគេទាំងអស់គ្នាក៏បានអោនក្បាលចុះ គឺមានពីរបីអ្នកនៅក្នុងនោះ។

430 ខ្ញុំបានដាក់ដៃរបស់ខ្ញុំនៅលើគេ។ ខ្ញុំនិយាយថា "ព្រះជាព្រះអម្ចាស់អើយ សូមឲ្យក្មេងៗទាំងអស់នេះបានដឹងនូវអ្វីដែលគេគួរតែធ្វើ ដ្បិតគេនឹងត្រូវជួបការទាំងអស់នេះ។ វាកំពុងតែជិតស្លាប់ហើយ។ សាតាំងមួយនេះបានធ្វើឲ្យគេមានរបួស ហើយគេជិតស្លាប់ហើយ។ ហើយគាត់បានផឹកស្រាឲ្យស្លាប់ ហើយគាត់ក៏បានមកដល់ចំនុចនេះ។ ខ្ញុំអធិស្ឋានសូមឲ្យទ្រង់មាន សេចក្តីមេត្តាករុណាដល់គាត់"។ ហើយបន្ទាប់ពីខ្ញុំបានអធិស្ឋានឲ្យគាត់ នៅព្រឹកស្អែកឡើងគាត់ក៏ក្រោកអង្គុយឡើង ហើយនិយាយជាមួយនឹងឪពុករបស់គាត់។

431 ប៊ីស្ទី រ៉ូចី អ្នកណា...បានហៅខ្ញុំមកឯមន្ទីរពេទ្យមុនម៉ិញនេះ។ ខ្ញុំបាននៅទីនោះ បន្ទាប់ពីខ្ញុំបានអធិប្បាយនៅក្នុងទីក្រុងមីលថោនជាកន្លែងដែលក្មេងតូចចចខាតធី បានជាពីជម្ងឺ។ អ្នកទាំងអស់គ្នាបានចាំការទាំងនោះ។ ហើយនៅទីនោះ គឺនៅពេលដែលបងប្រុស ស្មីតជាអ្នកអធិប្បាយនិកាយម៉េតូឌីសនិយាយ

ថា "បើសិនជាមានអ្នកណាម្នាក់ដែលបានជ្រមុជទឹកនៅក្នុងនាមព្រះយេស៊ូវគ្រីស្ទ ចូរចាកចេញពីក្រោមតង់របស់ខ្ញុំទៅ" ដូចនេះ។ នៅឯថតទីនហ្វដមានការប្រជុំនៅទីនោះ។ ហើយចូរយកទោសខ្ញុំទៅតាមអ្វីដែលអ្នកអាចគិតដល់។ ខ្ញុំមិននិយាយអ្វីសូម្បីតែមួយមាត់ ហើយក៏ដើរចេញទៅ។ ខ្ញុំមានមហាបេសកម្មដែលត្រូវធ្វើ។ ព្រះជាព្រះអម្ចាស់បានបើកបង្ហាញឲ្យខ្ញុំឃើញនិមិ្មតមួយ។អ្នកទាំងអស់គ្នាចាំអំពីនិមិ្មតមួយនេះ គឺអ្នកទាំងអស់គ្នា។ ខ្ញុំជឿថាអ្នកចាំបាន។ តើអ្នកមានចាំវាទេ? [ពួកជំនុំក៏និយាយថា "អាម៉ែន។"—Ed។] ពិតណាស់។ ត្រូវហើយ។ ហើយខ្ញុំក៏បានដើរទៅឯទីរហោស្ថាននោះ រួចក៏បានបរបាញ់វា។

432 ខ្ញុំបានទៅឯ ថតទីនហ្វដ។ ហើយបងប្រុស ហ្វ្រេ៉ហ្គ បានដឹង។ យើងបានទៅឯទីនោះ ដោយមិនបានដឹងថានឹងត្រូវធ្វើអ្វី។ ខ្ញុំបានទិញសាប៊ូមួយកេសថ្លៃមួយកាក់។ ខ្ញុំរៀបនឹងចេញទៅទីនោះ ហើយអធិប្បាយនៅលើកាំជណ្តើរ។ គាត់បាននិយាយថា គាត់នឹងឡើងទៅឯកំពូលភ្នំ ហើយនឹងធ្វើជំនួញមួយ។ ខ្ញុំក៏បានទៅជាមួយគាត់។ នៅទីនោះមានព្រះវិហារបាបទីស្ទធំហើយចាស់មួយដែលនៅទទេ។ ព្រះបានមានបន្ទូលនឹងខ្ញុំថា "ចូរឈប់នៅទីនោះហើយ។"

433 ខ្ញុំបាននិយាយថា "សូមទុកឲ្យខ្ញុំនៅទីនេះចុះបងប្រុស ហ្វ្រេ៉ហ្គ។" ខ្ញុំបានឈប់នៅទីនោះ ហើយគាត់បានឡើងទៅដល់ខាងលើ ហើយត្រលប់មកវិញ។

434 ខ្ញុំបានទៅដល់ទីនោះ ហើយមិនអាចបើកទ្វាបាន។ ខ្ញុំនិយាយថា "ព្រះអង្គអើយបើសិនជាទ្រង់គង់នៅទីនេះ ហើយ ព្រះអង្គចង់ឲ្យខ្ញុំចូលទៅក្នុងព្រះវិហារនេះ សូមទ្រង់បានបើកទ្វាឲ្យខ្ញុំ។" ខ្ញុំក៏បានអង្គុយនៅទីនោះទាំងពិចារណា។

435 ក៏បានឮសំលេងអ្នកដើរឡើងមក ហើយគាត់និយាយថា "តើអ្នកសុខសប្បាយទេ? ខ្ញុំនឹងប្រាប់អ្នក" និយាយ "តើអ្នកចង់ចូលព្រះវិហារមែនទេ?"

ខ្ញុំនិយាយថា "បាទ លោក។"

គាត់និយាយថា "ខ្ញុំមានកូនសោនៅទីនេះ។"

436 ចាប់ផ្តើមការប្រជុំ នៅអាទិត្យទីមួយដូចជាគ្មានអ្វីសោះ។ នៅយប់ទីមួយនោះ អ្នកចូលរួមទាំងអស់គឺមានតែបងប្រុសហ្វ្រេ៉ហ្គ និងក្រុមគ្រួសារប៉ុណ្ណោះ។ ការដំបូងអ្នកដឹងទេគឺ នៅថ្ងៃចុងក្រោយនៃអាទិត្យនោះ គឺស្ទើរតែគ្មានកន្លែងឈរសោះ សូម្បីនៅទីធ្លាខាងមុខ។ ក៏នៅតែចៀមនោះមិនទាន់បានមកដល់នៅឡើយ។ ប្អូនប្រុស

ហាល ដែលឥឡូវជាគ្រូគង្វាលនៅទីនោះ ក៏បានសង្គ្រោះនៅពេលនោះដែរ។ ខ្ញុំមិនអាចរកឃើញថា តើចៀមនោះនៅទីណាទេ។ មិនយូរប៉ុន្មាននៅខាងក្រៅក្រុមជំនុំនៃព្រះគ្រីស្ទគឺនៅខាងក្រោមជើងភ្នំនោះ មានកុមារីម្នាក់អាយុប្រាំបួនឆ្នាំ និងប្រាំបីខែដេកនៅទីនោះមិនអាចកំរើកបាន។ គឺនាងនៅទីនោះ។ អ្នកទាំងអស់គ្នាដឹងរឿងនោះដែរ។ បាទ លោក។

437 នៅរសៀលនោះ គឺពេលដែលប៊ឺស្ទីរ៉ូចឺ ជានាយទាហានដែលមានមាឌធំតែសោះកក្រោះឈរនៅទីនោះ...ខ្ញុំបានដើរចេញទៅទីនោះ។ ហើយមានបងប្រុសស្មីដ និងពួកគាត់មួយក្រុមឈរនៅទីនោះចាំសើចដាក់ខ្ញុំ ធ្វើកំប្លែងពីខ្ញុំ ក្នុងកាលដែលខ្ញុំបានធ្វើបុណ្យនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ខ្ញុំបានដើរកាត់ទឹកល្អក់ៗនៃកន្លែងថតទីនហ្វដ ជាកន្លែងដែលគេបាន...[គ្មានសំលេងនៅក្នុងកាសែត—Ed។] ...នៅលើព្រៃកតូចៗទាំងនោះ ហើយស្រែកយ៉ាងខ្លាំងតាមដែលអាចធ្វើទៅបាន។ គ្រូជំនួយមួយគូរបានដើរជាមួយខ្ញុំ។

438 ខ្ញុំនិយាយថា "ខ្ញុំឈរនៅទីនេះ នៅព្រឹកនេះ ជាតំណាងនៃព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះ។" ខ្ញុំនិយាយថា "ខ្ញុំបានអាននៅក្នុងព្រះគម្ពីរត្រង់កន្លែងដែលពេត្រុសនិយាយថា 'ចូរឲ្យអ្នកទាំងអស់គ្នាលន់តួបាបចុះ ចូរឲ្យបានជ្រមុជទឹកដោយនៅព្រះនាមព្រះយេស៊ូវគ្រីស្ទ សំរាប់ការអត់ទោសបាបរបស់អ្នក'"។ ខ្ញុំបានងាកទៅហើយបានឲ្យសៀវភៅទៅគ្រូជំនួយព្រះវិហារម្នាក់។

439 ដើរចេញទៅទីនោះ ខ្ញុំនិយាយថា "អស់អ្នកណាដែលត្រូវការការផ្លាស់ប្រែពីអំពើបាប គឺជាពេលដែលត្រូវចុះចូល"។ បានដើរនៅក្នុងទឹកនោះ ខ្ញុំនិយាយថា "ខ្ញុំគិតថា មានទេវតាកំពុងតែអង្គុយនៅលើមែកឈើទាំងអស់នោះ ហើយកំពុងតែមើលមក"។ ឱ ខ្ញុំអើយ! ក្នុងខណៈពេលដែលខ្ញុំបានជ្រមុជទឹកឲ្យបានគ្នាពីរបីនាក់គ្នារបស់គាត់ទាំងនោះ មានទាំងស្រីទាំងប្រុសបានស្រែកយ៉ាងខ្លាំងអស់ពីសំលេងរបស់គេ។ ខ្ញុំបានធ្វើបុណ្យជ្រមុជទឹកឲ្យគ្នីគ្នារបស់គាត់ទាំងអស់នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ តើអ្នកមានដឹងទេ។ ខ្ញុំមានរូបថតទាំងនោះ។ គឺមួយនេះ។

440 តើវាគឺជាអ្វី? បន្ថែមទៅក្នុងសេចក្តីទៀងត្រង់របស់អ្នក។ ឃើញទេ? ចូរទុកឲ្យវានៅតែឯង។ ព្រះជ្រាបថា គួរតែត្រូវធ្វើយ៉ាងណា។ ព្រះជ្រាបថាអាចធ្វើឲ្យវាកន្លងផុតទៅបានយ៉ាងណា។ ចូរឲ្យគេនិយាយអ្វីដែលគេចង់ធ្វើ។ វាមិនអាចធ្វើឲ្យមានអ្វីប្លែកនោះទេ។ គ្រាន់តែបន្តធ្វើវាចុះ។

441 ប៊ីស្ទីរ៉ូចីបានឈរនៅទីនោះ ហើយនៅពេលដែលគាត់បានឃើញ កាត់ក៏និយាយថា "ដូច្នេះខ្ញុំនឹងជឿលើការទាំងនេះដោយអស់ពីចិត្តរបស់ខ្ញុំ"។ ហើយគាត់ក៏បានចុះមកក្នុងទឹកជាមួយនឹង សំលៀកបំពាក់ដ៏ស្អាតរបស់គាត់ ហើយក៏បានជ្រមុជទឹកនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។

442 កាលពីរបីឬបួនឆ្នាំមុនពួកគេបានហៅខ្ញុំមកឯមន្ទីពេទ្យមួយនៅទីក្រុងញូអាល់បានី។នៅទីនោះគាត់កំពុងតែរៀបនឹងស្លាប់ដោយជម្ងឺមហារីកដែលបានកាត់សាច់របស់គាត់។ គ្រូពេទ្យបាននិយាយថា គាត់អាចរស់បានត្រឹមព្រឹកស្អែកប៉ុណ្ណោះ។ និយាយថា "គាត់កំពុងតែជិតស្លាប់ហើយ ។" និយាយថា "ចូរមកឥឡូវនេះ។"

443 ខ្ញុំបានដើរទៅក្នុងបន្ទប់នោះ ហើយខ្ញុំក៏បានឈរនៅទីនោះទាំងអធិស្ឋាន។ គាត់និយាយថា "ប៊ីល មានឥន្ទនូមួយនៅជុំវិញផ្លូវខាងនាយនោះ"។

444 ហើយខ្ញុំក៏បានងាកទៅមើល។ ខ្ញុំនិយាយថា "ប៊ីស្ទី នោះគឺជាការតាំងសញ្ញា។ អ្នកនឹងមិនស្លាប់ឡើយ។ ការតាំងសញ្ញានៃព្រះលោហិតបានសង្គ្រោះអ្នក ។"

445 ខ្ញុំបានដាក់ដៃរបស់ខ្ញុំពីលើគាត់ ហើយនិយាយថា "ព្រះជាអម្ចាស់អើយ តើនិម្មិតនៃផ្លូវខាងនាយនោះអាចនឹងបញ្ជាក់ថាទ្រង់គង់នៅទីនេះបានយ៉ាងណា។ សេចក្ដីសុខសាន្តរបស់ព្រះអង្គគឺ 'ដ្បិតដោយសារស្នាមជារបស់ទ្រង់នោះយើងនឹងបានជាសះស្បើយ'"។ បានដាក់ដៃលើគាត់ ហើយគាត់ក៏បានជា រួចមកយើងក៏បានបញ្ជូនគាត់ទៅផ្ទះវិញ។

446 ហើយប៉ុន្មានជាបួនប្រាំឆ្នាំនៃការ ធ្វើនេសាទចុះឡើងៗនៅតាមមាត់ទន្លេ និងរឿងអ្វីផ្សេងទៀតដែលបានកើតឡើង។ ហើយកន្លែងដែលមហារីកមាននៅក្នុងបំពង់អាហារនោះ ក៏បានក្រិនទៅ ហើយក៏មានដុំពក់រឹងមួយ។ គ្រូពេទ្យជើងចាស់ម្នាក់នៅក្នុងពេទ្យនោះបានប្រាប់អំពីការព្យាបាលដោយកូបែត ដែលអាចពត់ឃើតវាបាន ដើម្បីឲ្យអាហារអាចធ្លាក់បានច្រើនក្នុងពេលតែមួយ។ គាត់មានការលំបាកក្នុងការញ៉ាំអាហារច្រើន គឺគាត់ត្រូវញ៉ាំអាហារឃើតៗ។ ហើយគាត់ក៏បានទៅធ្វើការវះកាត់នោះ។ ខ្ញុំមិនបានដឹងថាគាត់បាននៅទីនោះ នោះទេ។

447 រួចនៅពេលដែលគេបានវះកាត់គាត់ វាបានធ្វើឲ្យគាត់ប្រកាច់ ហើយនិងដាច់សរសៃឈាម។ ក៏បានធ្វើឲ្យស្លាប់មួយចំហៀងខ្លួនដូច្នេះទៅ។ ហើយអ្វីដែលគាត់

អាចធ្វើបាននោះគឺយំបានតែមួយចំហៀងខ្លួន។ ហើយគាត់មានខ្មៅដៃដូចមួយ *នេះ* ហើយសរសេរថា "ហូរ ហូរ ហូរ។" ហើយគាត់បានព្យាយាមសរសេរ តែវាសូម្បីតែដៃល្អរបស់គាត់ក៏ញ័រដៃ។ ផ្នែកខាងឆ្វេងនៃខ្លួនរបស់គាត់ត្រូវបានស្លាប់។ ហើយគាត់បានសរសេរ នៅលើដៃរបស់គាត់ "ព្រះយេស៊ូវសង្គ្រោះ១៩០០និងអ្វីផ្សេងទៀត។" ពួកគេមើលមិនយល់។

448 ដូច្នេះឥឡូវនៅពេលដែលប្រពន្ធរបស់គាត់និយាយ "បងប្រុសប្រានហាំ ខ្ញុំមិនដឹងទេថាគាត់ចង់មានន័យថាយ៉ាងម៉េច"។

449 ខ្ញុំនិយាយថា "លោកស្រី រ៉ូចឺ អ្វីដែលគាត់ចង់មានន័យនោះគឺមាន១៩០០ជាងនាក់ដែលបានសង្គ្រោះ និងធ្វើបុណ្យជ្រមុជទឹកដោយនៅព្រះនាមព្រះយេស៊ូវគ្រីស្ទនៅទីនោះ។ នេះហើយគឺជាថ្លៃសង គឺគាត់លែងខ្លាចសេចក្តីស្លាប់ហើយ។"

450 ខ្ញុំនិយាយថា "ព្រះអម្ចាស់អើយ សូមទ្រង់រក្សាជីវិតរបស់គាត់។ ខ្ញុំអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យទ្រង់បានរក្សាជីវិតរបស់គាត់"។ បានដាក់ដៃនៅលើគាត់។ ការដាច់សរសៃឈាមបានចាកចេញពីគាត់។ ការប្រកាច់ក៏បានឈប់។ ហើយគាត់ក៏បានក្រោកឡើងនៅលើគ្រែរបស់គាត់។ ហើយគាត់នៅខាងលើនេះធ្វើទីបន្ទាល់។

451 ចូរបន្ថែមសេចក្តីទៀងត្រង់ទៅក្នុងសេចក្តីជំនឿរបស់អ្នក បន្ថែមជំរិះទៅក្នុងសេចក្តីទៀងត្រង់ បន្ថែមការអត់សង្កត់ទៅក្នុងជំរិះ បន្ថែមការអត់ធ្មត់ទៅក្នុងការអត់សង្កត់ បន្ថែមការចេះគោរពប្រតិបត្តិដល់ព្រះទៅក្នុងការអត់ធ្មត់ បន្ថែមការចេះរាប់អានគ្នាជាបងប្អូនទៅក្នុងការចេះគោរពប្រតិបត្តិដល់ព្រះ បន្ថែមព្រះវិញ្ញាណបរិសុទ្ធទៅក្នុងការចេះរាប់អានគ្នាជាបងប្អូន រួចហើយព្រះគ្រីស្ទនឹងយាងមក។ ពីព្រោះគឺគ្រាន់តែនៅពីក្រោមព្រះអង្គប៉ុណ្ណោះ...ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះវិញ្ញាណរបស់ព្រះយេស៊ូវគ្រីស្ទដែលប្រទានមកក្រុមជំនុំ ដើម្បីសំដែងឲ្យឃើញសេចក្តីទៀងត្រង់ទាំងអស់នោះ។ ឱ ខ្ញុំអើយ!

ឥឡូវនេះម៉ោងដប់ពីរកន្លះហើយ។

ខ្ញុំស្រឡាញ់...ខ្ញុំស្រឡាញ់ទ្រង់
ពីព្រោះទ្រង់ស្រឡាញ់ខ្ញុំមុន

គឺនៅត្រង់*នេះ* មុនពេលដែលអ្នកមិនមែនជាអ្វីសោះ។

ហើយចាក់-...(តើទ្រង់បានធ្វើអ្វី?)...សេចក្ដីសង្គ្រោះ
របស់ខ្ញុំ នៅលើដើមកាល់វ៉ារី

តើខ្ញុំខ្លាចជាយ៉ាង*នោះ*បានយ៉ាងណា? ពីព្រោះទ្រង់បានស្រឡាញ់ខ្ញុំមុន។

ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំស្រឡាញ់ទ្រង់
ព្រោះទ្រង់បានស្រឡាញ់ខ្ញុំមុន...(វាមានហេតុរបស់វា។)
ទ្រង់បានទិញសេចក្ដីសង្គ្រោះរបស់ខ្ញុំ
នៅលើដើមកាល់វ៉ារី។

452 ខ្ញុំសូមសន្យានៅពេលព្រឹកនេះ ដោយអស់ពីចិត្តរបស់ខ្ញុំថា គឺដោយសារការជួយ និងសេចក្ដីមេត្តាករុណារបស់ទ្រង់ ខ្ញុំអធិស្ឋានថា ខ្ញុំនិងស្វែងរកទ្រង់រាងរាល់ថ្ងៃដោយមិនឈប់ឡើយ រហូតទាល់តែខ្ញុំយល់ គ្រប់ទាំងសេចក្ដីដែលតំរូវឲ្យមាននៅក្នុងរូបកាយដ៏តូចមួយនេះ គឺរហូតទាល់តែខ្ញុំអាចបង្ហាញអំពីព្រះគ្រីស្ទដ៏មានព្រះជន្មគង់នៅ។ ដ្បិតទ្រង់បានក្លាយទៅជាអ្នកមានបាបដូចជាខ្ញុំ ដើម្បីឲ្យខ្ញុំបានក្លាយទៅជា...មកឯភាពសុចរិតនៃព្រះ ដូចទ្រង់ដែរ។ "ទ្រង់បានជំនួសកន្លែងរបស់ខ្ញុំ ព្រះអើយសូមឲ្យខ្ញុំបានជំនួសកន្លែងរបស់ទ្រង់វិញឥឡូវ"។ ដ្បិតនេះហើយគឺជាហេតុផលដែលទ្រង់សុគត។ តើមានប៉ុន្មាននាក់ នឹងសន្យាការទាំងអស់នេះបានដោយនៅក្នុងព្រះគុណរបស់ព្រះ? [ពួកជំនុំនិយាយថា "អាម៉ែន។"—Ed។] ដោយក្បាលអោនចុះ ហើយលើកដៃឡើង។ "ខ្ញុំ..."

453 ខ្ញុំសច្ចាព្រះអង្គអើយ ក្រុមជំនុំនេះបានសច្ចា "សេចក្ដីគ្រប់លក្ខណ៍របស់ព្រះយេស៊ូវគ្រីស្ទ!"

ព្រោះទ្រង់បានស្រឡាញ់ខ្ញុំជាមុន
ហើយបានទិញសេចក្ដីសង្គ្រោះរបស់ខ្ញុំ
នៅលើដើមកាល់វ៉ារី។

# លក្ខណៈសម្បត្តិរបស់មនុស្សល្អគ្រប់លក្ខណ៍ KHM62-1014M

(The Stature Of A Perfect Man)

សារដែលធ្វើឡើងដោយ William Marrion Branham នេះ ត្រូវបានចែកចាយនៅព្រឹក ថ្ងៃអាទិត្យ ថ្ងៃទី ១៤ តុលា ១៩៦២ នៅ Branham Tabernacle in Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយ ការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និងបោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវែបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG